## ជីវប្រវត្តិ

លោក **ទូច-គឹមស្រ៊ាន** កើតនៅឆ្នាំ១៩៧៤ ក្នុងគ្រួសារកសិករ នៅក្នុងភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ

## ការសិក្សា

២០០៩ បរិញ្ញាបត្រជាន់ខ្ពស់អក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យខេមរៈ

២០០៧ បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស នៅសាកលវិទ្យាល័យបៀលប្រាយ

២០០៣ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

២០០១ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ នៅពុទ្ធិកវិទ្យាល័យសម្ដេច **ជួន-ណាត**

១៩៩៦ ពុទ្ធិកបឋមសិក្សាវត្តសុទ្ធវង្ស ឃុំក្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ

១៩៨០ សាលាបឋមសិក្សាភូមិកាប៉ូ ឃុំអូរឫស្សី ស្រុកក្រចេះ ខេត្តក្រចេះ

## មុខតំណែងនិងការងារ

សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរនៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការភាសាវិទ្យាខ្មែរនៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកគណៈកម្មការនៃការបង្កើតពាក្យនិងកម្ពីពាក្យនៃទីស្ដីការគណៈរដ្ឋមន្ត្រី

សមាជិកក្រុមជំនុំព្រះត្រៃបិដកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ប្រធានសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរនៃវត្តខ្ចណ្ណាលោម

ISBN-13 : 978-99963-705-2-6

ជំនួយស្មារតី សទ្ទានុក្រមពន្យល់ពាក្យនិងកំណាព្យ សាស្ត្រាចារ្យ ទូច-គឹមស្រ៊ាន ព.ស. ២៥៥៧ គ.ស. ២០១៣

**ជំនួយស្មារតី**

# សទ្ទានុក្រមពន្យល់ពាក្យនិងកំណាព្យ

**សាស្ត្រាចារ្យ ទូច-គឹមស្រ៊ាន**

**សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ**

ព. ស. ២៥៥៧ គ. ស. ២០១៣

ជំនួយស្មារតី

# សទ្ទានុក្រមពន្យល់ពាក្យនិងកំណាព្យ

សាស្ត្រាចារ្យ ឡូច-គីមស្រ៊ាង
សមាជិកក្រុមប្រឹក្សាជាតិភាសាខ្មែរ

ព. ស. ២៥៥៧ គ. ស. ២០១៣

# សទ្ទានុក្រមពន្យល់ពាក្យនិងកំណាព្យ


រៀបរៀង : លោក **ទូច-គីមស្រ៊ាង**

ជំនួយការ : លោក **អ៊ុន-សុភា**

ឧត្តមទីប្រឹក្សា : ព្រះតេជព្រះគុណ **យស-ហ៊ុត** ខេមចារោ

: ព្រះតេជព្រះគុណ **ឈឹម-ថេង** សោតណោ

: ឯកឧត្តម នាយឧត្តមសេនីយ៍ **តេង-សាវង្ស**

: ឯកឧត្តម ឧត្តមសេនីយ៍ឯក **ម៉ម-សំ**

: ឯកឧត្តម ឧត្តមសេនីយ៍ទោ **អឿ-សាវ៉ន**

: Mr. Christopher Lee

ពិនិត្យអក្ខរាវិរុទ្ធ : ព្រះតេជព្រះគុណ **ម៉ែន-វបុល** ឥន្ទជោតោ

: ព្រះតេជព្រះគុណ **យិន-រតនសុធាវី** អក្ខរកោវិទកោសលមុនី

: កញ្ញា **ដៃ-សារ៉ែម**

: លោក **វណ្ណា-ឡុន**

: លោក **ជោគ-ច័ន្ទវបុល**

: លោក **ឯម-ឫទ្ធី**

រចនាក្រប : កញ្ញា **នូ-ស៊ីន្លួន**



ISBN-9 789996 370526

បោះពុម្ពលើកទី១ ថ្ងៃពុធ ទី១៤ ខែសីហា ឆ្នាំ២០១៣



រក្សាសិទ្ធិគ្រប់បែបយ៉ាង ការថតចម្លងស្នាដៃរៀបរៀងនៃអ្នកនិពន្ធមកធ្វើអាជីវកម្មជាអំពើល្មើសច្បាប់



ឧបត្ថម្ភបោះពុម្ព : **មូលនិធិអៀង**

រោងពុម្ព : JSRC Printing House

អាសយដ្ឋានចែកចាយ : បណ្ណាគារសន្តិភាព បណ្ណាគារអន្តរជាតិ សាលាភ្សូធីលីដឺ...

# អារម្ភកថា

សៀវភៅ សទ្ទានុក្រមពន្យល់ពាក្យនិងកំណាព្យ នេះ ដែលលោក លោកស្រី និស្សិត អ្នកសិក្សាស្រាវជ្រាវកំពុងតែអាន បង្កើតឡើងក្នុងគោលបំណងបំពេញសំណូមពរលោកគ្រូ អ្នកគ្រូ និស្សិត អ្នកសិក្សាស្រាវជ្រាវទាំងឡាយដែលតែងតែចង់បានចំណេះដឹងអក្សរសាស្ត្រខ្មែរ ដើម្បីយល់ដឹងគំនិតល្អៗពីសទ្ទានុក្រមពន្យល់ពាក្យនិងកំណាព្យៗ

ការប្រមូលស្នាដៃរបស់អ្នកនិពន្ធទាំងឡាយ ពីអតីតកាលមករៀបរៀងជាសៀវភៅនេះឡើង គឺមានគោលបំណង គោលដៅ វិសាលភាព និយមន័យរួមចំណែកអភិរក្សនិងអភិវឌ្ឍភាសាជាតិយើងផងនិងចែករំលែកបទពិសោធ ព្រមទាំងទស្សនៈបុរាណនិងទស្សនៈថ្មីជុំវិញវិស័យភាសាខ្មែរយើងផង។

ក្នុងការសិក្សាកន្លងទៅគេបានកំណត់ថា **ភាសា អក្សរសាស្ត្រ** ជាមេកធាងសំខាន់ជាងគេនៃវប្បធម៌ ជាមេនៃប្រាជ្ញា ជាមេនៃការសិក្សា ជាមេនៃសិល្បៈនិងជាអត្តសញ្ញាណជាតិយ៉ាងសំខាន់បំផុត។

ប្រសិនបើមានកំហុសឆ្គងខ្លឹមសារដោយប្រការណាមួយ សូមអ្នកសិក្សាមេត្តាអធ្យាស្រ័យផងចុះ។ ខ្ញុំនឹងរង់ចាំទទួលយកកំហុសដោយសុច្ឆន្ទៈ មនសិការសោមនស្សនូវការកែលម្អពីសំណាក់លោកអ្នកសិក្សាស្រាវជ្រាវទាំងឡាយ។

រាជធានីភ្នំពេញ ៨កើត ខែអាសាឍ ឆ្នាំម្សាញ់ បញ្ចស័ក ព. ស. ២៥៥៧

ត្រូវនឹងថ្ងៃពុធ ទី១៤ ខែសីហា ឆ្នាំ២០១៣

សាស្ត្រាចារ្យ **ខួច-គីមស្រ៊ាង**

បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យានិងអក្សរសាស្ត្រខ្មែរ

# កតញ្ញូកតវេទិកថា

កូនសូមក្រាបថ្វាយបង្គំនិងលើកហត្ថាប្រណម្យឧទ្ទិសស្នាដៃនេះ ជូនចំពោះលោកឪពុក **ទ្វី-យ៉េន** អ្នកម្តាយ **អុី-មាស** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតជីវិតកូន។

កូនសូមសម្តែងនូវកតញ្ញូកតវេទិតាធម៌ ជាអនេកប្បការចំពោះលោកមានគុណទាំងទ្វេដែលបានផ្តល់កំណើតដល់រូបកូននិងបានចិញ្ចឹមបីបាច់ ថែរក្សា ការពារ អប់រំរូបកូនឱ្យឃ្លាតចាកឆ្ងាយពីអវិជ្ជា។ ព្រះគុណដ៏មហាប្រសើរនេះ រូបកូនចងចាំអស់មួយជីវិត ហើយមិនអាចរកអ្វីយកមកតបស្នងសងគុណឱ្យស្មើបានឡើយ។

សៀវភៅដែលកូនបានរៀបរៀងនេះគ្រាន់តែជាស្នាដៃតូចមួយប៉ុណ្ណោះ តែវាជាសក្ខីភាពមួយបញ្ជាក់ថា រូបកូនមិនបណ្តោយពេលវេលាឱ្យកន្លងផុតទៅដោយឥតប្រយោជន៍នោះទេ ហើយក៏មិនប្រើប្រាស់វាដើម្បីប្រព្រឹត្តអំពើមិនគួរគប្បីណាមួយនោះដែរ។

កូនសូមសច្ចាប្រព្រឹត្តតែកុសលកម្មនិងរស់នៅជាពលរដ្ឋល្អក្នុងសង្គមជាតិជារៀងដរាប។

រាជធានីភ្នំពេញ ៨កើត ខែអាសាឍ ឆ្នាំម្សាញ់ បញ្ចស័ក ព. ស. ២៥៥៧

ត្រូវនឹងថ្ងៃពុធ ទី១៤ ខែសីហា ឆ្នាំ២០១៣

សាស្ត្រាចារ្យ **ទូច-គីមស្រ៊ាង**

បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យានិងអក្សរសាស្ត្រខ្មែរ

**ឧទ្ទិសកថា**

សូមឧទ្ទិសស្នាដៃនេះថ្វាយ ប្រគេន ជូនចំពោះ

- បុព្វបុរសខ្មែរគ្រប់រូបដែលបានធ្វើពលិកម្មគ្រប់យ៉ាងដើម្បីការពារជាតិមាតុភូមិ

- កវី បណ្ឌិត អ្នកនិពន្ធ អ្នកប្រាជ្ញខ្មែរគ្រប់ជំនាន់ដែលបានខិតខំថែរក្សា ការពារវប្បធម៌ ភាសា អក្សរសាស្ត្រជាតិឱ្យបានរីកចម្រើនគង់វង្សរហូតមក

- សម្ដេចព្រះមហាសុមេធាធិបតី **ជួន-ណាត** ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី១ គណៈមហានិកាយ ដែលព្រះអង្គបានបន្សល់ទុកស្នាព្រះហស្ដដ៏ពិសេសសម្រាប់ខ្មែរគ្រប់ជំនាន់គឺ **វចនានុក្រមខ្មែរ**

- បុព្វការីជនរបស់ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំបាទទាំងអស់

សូមជួយទ្រទ្រង់វិស័យវប្បធម៌ អក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ចនិរន្តរ៍។

រាជធានីភ្នំពេញ ៨កើត ខែអាសាឍ ឆ្នាំម្សាញ់ បញ្ចស័ក ព. ស. ២៥៥៧

ត្រូវនឹងថ្ងៃពុធ ទី១៤ ខែសីហា ឆ្នាំ២០១៣

សាស្ត្រាចារ្យ **ទូច-គីមស្រ៊ាង**

បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យានិងអក្សរសាស្ត្រខ្មែរ

## នាមសប្បុរសជនអ្នកមានឧបការគុណក្នុងការចារធម្មនាន
## ដើម្បីដំណើរការសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ

| | |
|---|---|
| - CAM-PAINT **ថ្នាំពណ៌ជាតិ** | **សាលារៀនវ៉េស្តឡាញន៍** |
| - លោក **ប៊ិច-ប៊ូឡែន** | **សាលារៀនឈាត្សូឡាញន៍** |
| - លោក **សោម-សម្បត្តិ** | និង លោកស្រី **អ៊ុក-ចន្ថា** |
| - ឯកឧត្តម **ផាន់-ធិន** | និង ឧបាសិកា **សេង-ដួង** |
| - មហាឧបាសិកា **សុខ-អ៊ីម** | និង បុត្រ **ធូ-ឆៃគៀង** |
| - ឧបាសិកា **តិម-ស៊ីមឿន** | និង ឧបាសិកា **ឡេង-ចេងលាង** |
| - ឧបាសក **ដាំ-គុយ** | និង ឧបាសិកា **សុខ-ពៅ** |
| - លោក **ឡាយ-វណ្ណារ័ត្ន** | និង លោកស្រី **វណ្ណា-យី** |
| - លោក **ហែម-សុភខន** | និង លោកស្រី **គី-លីណា** |
| - លោក **សាម-ស៊ុនឌឿន** | និង លោកស្រី **ឈា-ផានី** |
| - លោក **យឹម-សុខហេង** | និង លោកស្រី **ប៊ូ-សុខឡេង** |
| - ឯកឧត្តម **តេង-សាវង្ស** | និង លោកជំទាវ **ស៊ាង-គីម** |
| - ឯកឧត្តម **ម៉ម-សំ** | និង លោកជំទាវ **អ៊ិត-បុប្ផាផល្គុន** |
| - ឯកឧត្តម **អឿ-សាវ៉ន** | និង លោកជំទាវ **ពៅ-សារឿន** |
| - ឯកឧត្តម **គឹម-ជាតិ** | និង លោកជំទាវ **គួង-ម៉ានឡា** |
| - ឯកឧត្តម **លី-វណ្ណានី** | និង លោកជំទាវ **ប្រាក់-ចិន្តា** |
| - ឯកឧត្តម **ង៉ុយ-ហាក់** | និង លោកជំទាវ **ង៉ូវ-សុខឡេង** |
| - លោក **ចាន់-សារ៉េត** | និង លោកស្រី **ស៊ឹម-ថារី** |
| - លោក **ហេង-ប៊ុនធី** | និង លោកស្រី **លី-អ៊ូវគីម** |
| - លោក **ហ៊ីល-សុផា** | និង លោកស្រី **ពេជ្រ-ចន្ថា** |

- ឧបាសក **អៀង-អឿន** និង ឧបាសិកា **អៀង-សាតីម**
- លោក **នុត-រ៉ានី** និង លោកស្រី **អ៊ុន-សោភា**
- លោក **សៀន-ចាន់ឡាដែត** និង លោកស្រី **ហុក-សុខា**
- ឯកឧត្តម **ព្រហ្ម-ផេង** និង លោកជំទាវ **ឃិន-ដាលីន**
- លោក **អោម-សេងបូរ៉ា** និង លោកស្រី **ស្វ-សេរីវឌ្ឍនា**
- លោក **គុយ-វ៉ាត** និង **លោកស្រី**
- លោក **ឱន-សុមេធារិទ្ធ** និង **លោកស្រី**
- លោក **រិទ្ធ-ឌីភា** និង លោកស្រី **ប្រាក់-លីណា**
- លោក **ស៊ែ-ទុន្នី** និង លោកស្រី **ព្រុំ-សុម៉ាលី**
- មហាឧបាសក **ជា-ផ្លុង** និង មហាឧបាសិកា **កេត-ត្លួង**
- លោក **ឈួរ-អាង** និង លោកស្រី **ឡ៉ូច-ស៊ុនសុខនី**
- សាស្ត្រាចារ្យ **ហ៊ុយ-ស្វវ៉ាត** និង លោកស្រី **សាត-ផាន់ណា**
- សាស្ត្រាចារ្យ **ឃាង-ច័ន្ទរិទ្ធា** និង លោកស្រី **លី-ហាក់ហៀង**
- លោក **ស្រ៊ី-ស្រេង (សំណាព្វ)** និង លោកស្រី **ឈុំ-ផាន់ណា**
- ឧបាសក **វ៉ាក់-ហ៊ាង** និង ឧបាសិកា **ម៉ឹង-សឿន**
- លោក **ប៊ូ-គីមលាង** និង លោកស្រី **ឈឹម-ស៊ីយ៉ាន**
- លោក **ឡួន-ហ៊ីន** និង លោកស្រី **ឈឹម-ចន្ទកែវ**
- លោក **ចាន់-ឌីតា** និង លោកស្រី **ជឹម-ស្រីមនោ**
- ឧបាសក **ចាយ-ផាន់** និង ឧបាសិកា **ឌី-ណារិន**
- លោក **វង់-វេង** កញ្ញា **ចាយ-គុស៊ុំ**
- លោក **ឆាង-សំពិសិដ្ឋ** និង លោកស្រី **ហៀត-ផាវីល័យ**

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណជាអតិបរមាចំពោះឧត្តមភរិយា **ម៉ែន-សេងយ៉ុង** ហៅ **ស្រីចិន** និងក្រុមគ្រួសារដែលបានយោគយល់និងចែករំលែកពេលវេលាដើម្បីឱ្យខ្ញុំ អាចមានឱកាសសិក្សាស្រាវជ្រាវប្រកបដោយជោគជ័យ។

ជាពិសេស សូមគោរពសម្តែងការដឹងគុណដ៏ជ្រាលជ្រៅបំផុតសន្តានចិត្ត ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ច័ន្ទ-សំណព្វ** ដែលបានលះបង់កម្លាំងកាយវាចាចិត្ត និងបញ្ញាស្មារតី ព្រមទាំងពេលវេលាដ៏មានតម្លៃជួយបង្ហាត់បង្រៀនខ្ញុំបាទលើមុខ ជំនាញន័យវិទ្យា វាទកម្ម វចនសព្ទ វចនវិទ្យា វេយ្យាករណ៍ប្រៀបធៀប វិភាគវេយ្យាករណ៍ វិធីសាស្ត្រស្រាវជ្រាវ។ ម្យ៉ាងទៀតសូមគោរពសម្តែងការកោតសរសើរនិងថ្លែង អំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោក **អៀង-សុធារ៉ា** ប្រធានមូលនិធិអៀង ដែលមានសន្តានចិត្តសប្បុរិសធម៌ឧបត្ថម្ភធម្មទានថវិកាជួយបោះពុម្ពសៀវភៅ សន្ទានុក្រមពន្យល់ពាក្យនិងកំណាព្យ ក្នុងគោលដៅសំខាន់ផ្សព្វផ្សាយអក្សរសាស្ត្រខ្មែរ ដើម្បីឱ្យប្រជាពលរដ្ឋទូទៅបានយល់ដឹងពីគុណតម្លៃវប្បធម៌ភាសាអក្សរសាស្ត្រជាតិ ព្រមទាំងដើម្បីឱ្យដំណើរការសមាគមទ្រទ្រង់អក្សរសាស្ត្រនិងវប្បធម៌ខ្មែរ។

សូមថ្លែងអំណរគុណឯកឧត្តម លោកជំទាវ សប្បុរសជន និងលោកអ្នកអាន ដែលបានជួយលើកស្ទួយគុណតម្លៃរៀបរៀងសៀវភៅរបស់ខ្ញុំនិងសូមមេត្តាអធ្យាស្រ័យ កំហុសឆ្គងដោយប្រការផ្សេងៗ។ ខ្ញុំនឹងរីករាយទទួលយកការកែលម្អកំហុសដើម្បីឱ្យខ្ញុំ បានបម្រើអស់លោកអ្នកអានកាន់តែប្រសើរជាងមុនថែមទៀត។ *សូមអរគុណ !*

រាជធានីភ្នំពេញ ថ្ងៃពុធ ទី១៤ ខែសីហា ឆ្នាំ២០១៣

សាស្ត្រាចារ្យ **ទូច-តីមស្រ៊ាង**

បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យានិងអក្សរសាស្ត្រខ្មែរ

## អក្សរសង្ខេប

### ប្រើក្នុងសទ្ទានុក្រមពន្យល់ពាក្យនិងកំណាព្យនេះ

| | | |
|---|---|---|
| *កិ.* | : | កិរិយាសព្ទ |
| *កិ. វិ.* | : | កិរិយាវិសេសន៍ |
| *គុ.* | : | គុណសព្ទ |
| *ចិ.* | : | ចិន (ភាសាចិន) |
| *ន.* | : | នាមសព្ទ |
| *និ.* | : | និបាតសព្ទ |
| *ប.* | : | បរិវារសព្ទ |
| *ប. សំ.* | : | បកតិសំខ្យា |
| *បា.* | : | បាលី |
| *បា. ស.* | : | បាលីសន្សត |
| *បា. សំ.* | : | បាលីនិងសំស្ក្រឹតលាយគ្នា |
| *បុ. ស.* | : | បុរិសសព្វនាម |
| *ព. កា.* | : | ពាក្យកាព្យ |
| *ព. បុ.* | : | ពាក្យបុរាណ |
| *ព. ប្រ.* | : | ពាក្យប្រៀប |
| *ព. ពុ.* | : | ពាក្យសម្រាប់ប្រើខាងពុទ្ធសាសនា |
| *ពហុ.* | : | ពហុវចនៈ |
| *សព្វ.* | : | សព្វនាម |
| *ស.* | : | សៀម (ភាសាសៀម) |

| | | |
|---|---|---|
| *សំ.* | : | សំស្រ្កឹត |
| *សំ. ក្ល.* | : | សំស្រ្កឹតក្លាយ |
| *សំខ្យា.* | : | សំខ្យាសព្ទ |
| *សំ. ឫា.* | : | សំស្រ្កឹតនិងបាលីលាយគ្នា |
| *សំ. ស.* | : | សំស្រ្កឹតសន្ធត |
| *អា. និ.* | : | អាយតនិបាត |
| *ឧ.* | : | ឧទានសព្ទ |

# សទ្ធានុក្រមពន្យល់ពាក្យនិងកំណាព្យ

## *ស្តីពីអក្សរសាស្ត្រនិងវប្បធម៌ជាតិ*

**កនិដ្ឋា** *ន.* (បា. **កនិដ្ឋ**) ប្អូន, ប្អូនតូច, ប្អូនពៅ។ ច្រើនប្រើក្នុងកាព្យហៅស្ត្រីជាគូសង្សារ, ស្ត្រីជាគូសម្លាញ់ :

**ពាក្យកាព្យ**

ឱ្យតែបានជួបកែវកនិដ្ឋា សមតាមប្រាថ្នានៅនែបនិត្យ បង់ខាតប៉ុន្មានរៀមពុំគិត ស៊ូប្តូរជីវិតឥតងាករេ។

**កាកគតិ** *ន.* (បា.) ឈ្មោះបទកាព្យពាក្យ៤ (បទដំណើរក្អែកលោត) :

**ពាក្យកាព្យ**

នេះគឺច្បាប់ក្រម ប្រសើរឧត្តម ទូន្មានអ្នកផង
ប្រើឱនលំទោន កុំបីមានឆ្គង ប្រាជ្ញាបុណ្យផង
កើតដោយប្រណិប័តន៍...។

**កុម្ភណ្ឌ** *ន.* (បា.) អមនុស្សពួកយក្ស។ បើស្ត្រីជា **កុម្ភណ្ឌី** :

**ពាក្យកាព្យ**

កុម្ភណ្ឌផ្តាំទេពី ថាហៃកែវកែវកល្យាណ បងទៅយូរប៉ុន្មាន
ទន់ទេរតិចបងយាត្រា...។

**ក្សិណនោះ** *ន.* (**ក្សិណ** + **នោះ**) ខណៈនោះ, ភ្លាមនោះ, គ្រានោះ, ដងនោះ, កាលនោះ :

**ពាក្យកាព្យ**

ក្សិណនោះព្រះយមពន្រាយ  លើសលែងសព្វសាយ  ស្ដេចបើកព្រះនេត្រយល់ជាក់ៗ

**កុំជឿងដោយខ្យល់** *កិ.* កុំជឿងព្រោះសម្ដីគេនិយាយព្យុហ៍ឱ្យភាន់គំនិត :

**ពាក្យកាព្យ**

| | | |
|---|---|---|
| កុំជឿងដោយខ្យល់ | កុំឱនពាក្យពល | កុំខ្វល់ដោយស្រី |
| កុំកាន់ពិសយង់ | គប់នូវស្ត្រី | សមណជនជី |

កុំឱ្យក្តីត្រូវ។

**ខគ្គ** *ន.* (សំ.) គ្រឿងសស្ត្រាមួយប្រភេទ ផ្ដៃមានមុខទាំងពីរខាងមានសណ្ឋានដូចផ្ដៃលំពែង ប៉ុន្ដែធំវែងជាងផ្ដៃលំពែងដងខ្លីច្រើនជាងដងលំពែងមានស្រោមសម្រាប់ស៊កសៀតចង្កេះបានដោយមានខ្សែចងស្រាក់ភ្ជាប់នឹងស្រោមនោះ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| ព្រហ្មទត្តមហាក្សត្រ | ទតឃើញព្រះខគ្គ | នៅដៃកុមារ |
| ឈ្មោះទីឃាវុ | ដូចនឹងប្រហារ | លុះទ្រង់ជ្រាបការណ៍ |

ទើបក្សាន្តព្រះទ័យ។

**ខ្ជាប់** *កុ.* បិតថេរ, មាំមួន, ជាប់លាប់។ ប្រើជា **កិរិយាវិសេសន៍** ក៏បាន :

**ពាក្យកាព្យ**

| | | |
|---|---|---|
| ត្រង់ណាហៅច្បាប់ | កាន់ខ្ជាប់កុំបីបង់ | ចំណេរទៅលង់ |

ខ្លួនបានជាធំ។

**គេហស្សាមិក** *ន.* (បា.) បុរសអ្នកម្ចាស់ផ្ទះ។ បើស្ត្រីជា **គេហស្សាមិកា** :

**ពាក្យកាព្យ**

គេហស្សាមិក ភ្ញាក់ឡើងពីព្រឹក ចាត់ចែងកិច្ចការ
ហៅកូនតូចធំ ស្រស់ស្រូបអាហារ រួចនឹងធ្វើការ
គ្រប់ទីកន្លែង។

គេហស្សាមិកា ជាអ្នកឧស្សាហ៍ មើលផ្ទះសំបែង
មិនឱ្យទាស់ឆ្គង នាទីខ្លួនឯង ជាអ្នកចាត់ចែង
ក្រែងខ្វះនេះនោះ។

**ចចើង** *កិ.* សម្ដែងអាការៈនរនាទ, ននះនរនាទ, ចើងម៉ើងដោយថ្ពើងចិត្ត :

**ពាក្យកាព្យ**

ចង់បុណ្យបានបាប ចចើងចង់លាភ វែងបាត់ធនទៅ
មាននះបាត់មិត្ត ឥតអ្នកជាផៅ ខេរខឹងឃោរឃៅ
រមែងបាត់អង្គ។

**ចាប់ហួយ** *ន.* ឬ *កុ.* (ចិ.) ការលក់ទំនិញរាយរងនេះខ្លះ នោះខ្លះប៉ប៉ះប៉ប៉ុន :

**ពាក្យកាព្យ**

លក់ដូរចាប់ហួយ របរជំនួយ នៃការទ័លក្រ
ចំណេញតិចតួច ស្ដើងស្ដួចតែល្អ រាប់ជាអម្រ
សន្សំធនធាន។

ដំបូងស្ដួចស្ដើង ប៉ើករើកប៉ើងរើង យូរទៅតែងបាន
ទ្រព្យធនក្រាស់ក្រែល ឡើងជាអ្នកមាន ការអត់ការឃ្លាន

ក៏ឃ្លាតចេញឆ្ងាយ។

**ចារថែង** *កិ.* និយាយថ្លែងសេចក្ដី, និយាយថ្លែងការណ៍ក្បោះក្បាយដោយពង្រីកសេចក្ដីឱ្យទូលំទូលាយងាយស្ដាប់ ងាយយល់ :

**ពាក្យកាព្យ**

ខ្ញុំសូមចារថែងថ្លែងពីធម៌ ដ៏បវរលើសលែងក្នុងលោកា ដែលព្រះសម្ពុទ្ធទ្រង់ទេសនា

ឱ្យជននានាប្រព្រឹត្តតាម...។

**ចៅទេស** *ន.* (ព. បុ.) ម្ចាស់ប្រទេស (ព្រះរាជា) :

**ពាក្យកាព្យ**

ចៅទេសមិនធ្វេសទ្វេ តែងរិះរករកហេតុផល ឱ្យរដ្ឋរាស្ត្របានដល់

នូវក្ដីសុខចម្រើន។

**ចេរ** *កិ.* (ព. បុ.) ដឹង, ជ្រាប, យល់ :

**ពាក្យកាព្យ**

ទោះដឹងពុតជា ពុំចេរពុតត្បុត ដឹងចិត្តបរិសុទ្ធ

ពុំចេរឥរិយា។

**ចៅវៃ** *ន.* (ព. បុ.) នាយអ្នកថែរក្សាកាន់កាប់ទៃរបស់ព្រះរាជា :

**ពាក្យកាព្យ**

ប្ដីនាងនោះវៃ បានស្គាល់ចៅវៃ ស្គាល់ព្រះស្គាល់ពញា

អ្នកផងរាប់អាន ដ្បិតបានទ្រព្យា កបនូវលក្ខណា

នាងនោះប្រពៃ។

**ឆី** ***កិ.*** ស៊ី (ព. បុ.) :

**ពាក្យភាព្យ**

ឆ្អែតជាឱ្យបាយឆី ដេកនៅដីចាំធនធាន គ្រឿងសឹកទុកទាហាន
កេរ្តិ៍គម្ពីរទុកប្រាជ្ញប្រាយ។

**ជនោត្តម** ***គុ.*** ឬ ***ន.*** (**បា. ជន** + **ឧត្តម**) ដែលឧត្តមជាងជន, ដែលខ្ពង់ខ្ពស់ជាងជន; ព្រះបរមក្សត្រ :

**ពាក្យភាព្យ**

វីព្រះជនោត្តម ទ្រង់ខិតខំបំពេញកិច្ច ការរដ្ឋពុំមានភ្លេច
ដោយកលល្បិចពិសោធន៍សព្វ។

**ជាញ** ***គុ.*** (**បា. ជញ្ញ** ***គុ.*** «ដែលគួរដឹង, ដែលគេអាចដឹងបាន; ដែលអាចដឹងហេតុទាន់ការ, ដែលស្ទាត់ជំនាញ») ជំនាញ :

**ពាក្យភាព្យ**

យោធាសុទ្ធតែជាញៗ ខ្លះចាប់អូសទាញ ពួកបច្ចាមិត្ត។
ក្លាហានមិនសូវភ័យភិត ខ្លះដេញប្រកិត តាមចាប់ពួកខ្មាំង។

**ជីវ៉ា** ***ន.*** (**បា. ជីវ**) ពាក្យសម្រាប់ហៅស្ត្រីជាគូស្នេហាដែលទុកស្មើជីវិតរបស់ខ្លួន :

**ពាក្យភាព្យ**

តាំងពីចិត្តគិតពីចងប៉ងស្នេហា លើជីវ៉ាថ្លាជីវិតរ៉មិត្តថ្លៃ
នៅមិនស្មៀមរៀមមិនស្ងាត់ឃ្លាត់អាល័យ ហាក់ស្រមៃឆ្អែស្រមោលចោលជិតប្រាណ។

**ជុលី** *ន.* (ក្លាយមកពី **សំ. បា. អញ្ជលិ ឬ អញ្ជលី**) ប្រាមដៃ, ក្រពុំប្រាមដៃ :

**ពាក្យកាព្យ**

ប្រណម្យជុលី ដាក់លើសិរសី ក្រាបក្រោមបាទា
ព្រះបាទសម្ដេច សព៌ជ្ញសាស្ដា ថ្វាយវរវន្ទា
ឆ្ពោះព្រះភូបាល ។

**ជៀស្ឋជ័យ** *គុ.* ឬ *ន.* (**សំ. ជៀស្ឋ + ជយ**) ដែលជាធំបំផុត, ដែលចម្រើនបំផុត, ដែលជាចម្បង, ដែលជាច្បងទាំងមានជ័យជម្នះផង; ការមានជ័យជម្នះលើអ្នកដែលជាចម្បង :

**ពាក្យកាព្យ**

បពិត្រព្រះបាទជៀស្ឋជ័យ សូមស្ដេចវិលវៃ កុំបីបង្អង់នៅយូរ ។

**ជំនាញជាញជ័យ** *គុ.* ជំនាញអង់អាចក្លាហានតែងតែមានជម្នះជាដរាប ។ ប្រើត្រឹម **ជាញជ័យ** ក៏បាន :

**ពាក្យកាព្យ**

សេនាចិត្តក្លាជាញជ៏យ ឥតស្លុតឥតន័យ អាស្រ័យកម្លាំងវិជ្ជា ។
ពួកពលចូលស្រគ្រប់គ្នា ពុំមានរួញរា ក្រទាក្រទឹតអង់អាចៗលៗ

**ឈម** *កិ.* ឆ្ពោះមុខរកគ្នា, ឈ្ងោកឆ្ពោះទៅរកអ្វីមួយ, សម្លឹងឆ្ពោះទៅរកអ្វីមួយ :

**ពាក្យកាព្យ**

កុំឈមកុំឈរជិត ក្រែងមិនអត់បង់កើ្តកោះ កុំល្បួងល្បែងនោះសោះ
គួរឱ្យដោះឱ្យដើរចេញៗ

**ញាំង** ***អា. និ.*** ប្រើ, បង្គាប់ :

**ពាក្យកាព្យ**

កុំនៅញាំងឈ្លោះ　　កុំស្ដាប់អសុរោះ　　កុំស្ដាប់អាស្រូវ
កុំដើរពានស្កុន　　កុំស្កាត់ច្រកផ្លូវ　　កុំធ្វើស្រែស្រូវ
នៅផ្លូវដំរី។

**ដងណោះ** ឬ **ដងនោះ** ***និ.*** ពាក្យប្រាប់កាល, គ្រាដែលកន្លងទៅហើយ (គ្រានោះ, កាលនោះ); សម្រាប់ប្រើតែក្នុងកាព្យឬពំនោលល្ខោន :

**ពាក្យកាព្យ**

ដងណោះកុម្ភណ្ឌយក្សា　ចរចេញយាត្រា　កម្សាន្តសប្បាយក្នុងព្រៃ។

**ដលោក** ***ន.*** (ព. បុ.) លោកនេះ, ឥធលោក :

**ពាក្យកាព្យ**

ធម៌នេះដំបូន្មាន　　រួមរក្សាប្រាណ　　ឱ្យបានក្ដីគាប់
ដលោកបរលោក　　ហៅរស់ពុំស្លាប់　　ធម៌នេះជាច្បាប់
ក្ដីគាប់បរិយាយ។

**ដោម** ***ន.*** (ព.បុ.) កំពូលប្រាសាទ, គ្រឹហាមានសណ្ឋានក្រឡូមច្រឡោ, ស្រដៀងនឹងរាងដោក, ខ្ពស់ត្រដែត :

**ពាក្យកាព្យ**

ក្រឡេកទៅឃើញដោមប្រាសាទ　ប្រសើរស្អាងស្អាតខ្ពស់ត្រដឹម　មើលពីចម្ងាយឃើញសន្ធឹម
លន្ធឹមស្រងាត់ក្នុងមេឃា។

**ដោម** ឬ **ដោមដុង** *គុ.* ខ្ពស់, ខ្ពស់ស្រោង, ខ្ពស់ត្រដួចត្រដឹម :

**ពាក្យភាព្យ**

លើកករប្រណម្យ ដោមដាក់សិរសា ក្រួញក្រាបវន្ទា

ឆ្ពោះព្រះត្រៃរតន៍។

ដោមដុងផុតចុងព្រឹក្សា ចុចជាប់មេឃា មើលឃើញលឹមៗ។

**ដ្បិត** *និ.* ព្រោះ, ព្រោះហេតុ, ដោយហេតុ :

**ពាក្យភាព្យ**

ទាហានថ្កើងដ្បិតសឹក ធ្វើស្រែដ្បិតទឹក ត្រឹកពលដ្បិតបាយ

សិស្សប្រាជ្ញដ្បិតគ្រូ ជេរពោលដំវាយ ពលជាដ្បិតនាយ

ហ្វឹកហ្វឺនខះខំ។

**តន់** *គុ.* ថ្លៃ, តូចថ្លៃ :

**ពាក្យភាព្យ**

ស្តេចថាហៃប្អូនតន់ នាងកុំអន់ចិត្តនឹងបង ជាតិមនុស្សតែងមោះហ្មង

ប្អូនកុំចងចិត្តប្រកាន់ៗ

**តម្លែក** *ន.* ឬ *គុ.* ដែលមានក្បាលថ្លែក, ដែលតតសក់, ដែលរលីងដុំៗ :

**ពាក្យភាព្យ**

តម្លែកទាំងបួន គាប់ជួនជួបគ្នា បានស្មុះម្ទីម្នា

ដើរទៅរៀងខ្លួន។

**តុល** *ន.* (**សំ. បា. តុលា**) ជញ្ជីង, ត្រាជូ, តម្លឹង :

### ពាក្យភាព្យ

ដឹងហាបឱ្យដឹងគុល ខ្នែកឱ្យយល់ទៀងត្រាជ្ជ គិតគ្រប់សព្វដោយផ្លូវ
ក្តីចន្លោះកុំបីមាន ។

**គោកយ៉ាក** *គុ.* (ស.) ដែលធ្លាក់ចុះជាអ្នកក្រីក្រលំបាក, ដែលទ័លក្រ
រហេមរហាមពន់ពេក :

### ពាក្យភាព្យ

គោកយ៉ាកលំបាកក្រៃក្រាស់ ពីក្មេងដល់ចាស់ នឿយណាស់ពេកពន់ ។

**គោមរ** *ន.* (សំ. បា.) លំពែងស្នែងក្របី, ផ្គាក់កកុក :

### ពាក្យភាព្យ

អហីពលករកាន់គោមរ ស្ទុះចូលឈ្មួសរ កំដររសេនាទ័ពស្រួច ។

**គោមរធរ** *ន.* (សំ. បា.) អ្នកកាន់លំពែងស្នែងក្របី, អ្នកកាន់ផ្គាក់កកុក :

### ពាក្យភាព្យ

ឯពួកពលគោមរធរ ស្រែកហោកម្ពរ គយរស្ទុះចូលគយុទ្ធ ។

**ត្រយង់** *គុ.* ល្អប៉ប្រៃ, ស្រស់បំព្រង :

### ពាក្យភាព្យ

ផ្កាឈូកដុះរហង់ រីកត្រយង់ក្នុងស្រះស្រី ហាក់ដូចនឹងចេះស្តី
មករកយើងអ្នកដើរខាង ។

**ត្រាជ្ជ** *ន.* ឈ្មោះជញ្ជីងមួយប្រភេទមានសង្រែក២មានធរណីកណ្តាល :

**ពាក្យកាព្យ**

ដឹងហាបឱ្យដឹងគុល  ទ្វែកឱ្យយល់ទៀងត្រាជូ  គិតគ្រប់សព្វដោយផ្លូវ
ក្តីចន្លោះកុំបីមានៗ

**ត្រាណត្រើយ** *ន.* ឬ *ក្រ.* ទីពំនាក់ទុកស្មើត្រើយ :

**ពាក្យកាព្យ**

ឱព្រះត្រាណត្រើយ  ប្រហែលកន្តើយ  ពុំនឹកប្អូនភ្ងា
ដែលបានព្រាត់ប្រាស  និរាសក្សត្រា  ប្អូនដឹងទៅវ៉ា
នឹងបានទៅជួប។

**ត្រីទស** *ន.* (**សំ. ត្រិទស**) អមរ, ទេវតា :

**ពាក្យកាព្យ**

យើងសូមអញ្ជើញអស់ត្រីទស មានយសសក្តិសិទ្ធិឫទ្ធិតេជះ សូមចុះមូលមកដោយរូតរះ
ដើម្បីសំពះព្រះត្រៃរតន៍ៗ

**ត្រើយត្រាណ** *ន.* ដូចគ្នានឹង **ត្រាណត្រើយ** ដែរ គ្រាន់តែប្រើត្រលប់យកមុខជាក្រោយថា **ត្រាណត្រើយ** ឬ **ត្រើយត្រាណ** សម្រួលតាមសម្ពស្សចួនរបស់កាព្យប៉ុណ្ណោះ :

**ពាក្យកាព្យ**

ឱព្រះត្រើយត្រាណ  ធ្វើម្តេចនឹងបាន  វិលមកវិញវ៉ា
ទោះផ្តាំនឹងខ្យល់  ខ្យល់ឥតប្រាប់ថា  ព្រះបាទចេស្តា
សុខឬទុក្ខឡើយ។

**ថនៈ ឬ ថនា** *ន.* (**បា. ថន**) ដោះ, កន្សោមដោះ :

**ពាក្យកាព្យ**

រៀមសូមអែបនែបនៅនិត្យជិតថនា នៃកញ្ញាថ្លាវរលក្ខណ៍ាតត្រល្អឯក

សូមក្រមុំកុំខេរខឹងប្រឹងប្រកែក សូមរំលែកចែកដាក់ទានមានផលច្រើន ។

**ថី** *ន.* (**បា.; សំ. ស្ត្រី**) ស្រី (សម្រាប់ប្រើក្នុងកាព្យជាជំនួសពាក្យ **ស្ត្រី** ជាសម្ដីខ្ពស់) :

**ពាក្យកាព្យ**

ថីនិងបុរស មូលមកទាំងអស់ ស្រស់ស្រាយរកគ្នា

រអាករពាយ រីករាយជ្រះថ្លា បានធ្វើបុណ្យផ្កា

ជួយកសាងស្ថាន ។

**ថ្វាត់** *ប.* ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ **ថ្វាយ** :

**ពាក្យកាព្យ**

លើកករប្រណម្យ ថ្វាត់ថ្វាយបង្គំ ចំពោះត្រៃរតន៍...។

**ឧខឧខ** *គុ.* ទ្រទេសទ្រទន់, ល្វាសល្វន់, ល្វតល្វៃសមរម្យ :

**ពាក្យកាព្យ**

ឱមាសមិត្តទងវង ម្ដេចមករងទុក្ខខ្លាំងក្រៃ ព្រោះហេតុកម្មស្រីថ្លៃ

ហុចផ្ដល់ឱ្យនាងទេដឹង ។

**ឧន្ន** *កិ.* (ព. បុ.) ជម្រះធ្មេញនៅពេលលុបលាងមុខមាត់ :

**ពាក្យកាព្យ**

ស្ដេចតើនចាកនិទ្រា នៅវេលាព្រហាមស្រាង មានគ្រប់គ្រឿងសម្អាង

ស្តេចទ្រង់ទន្តជម្រះតក្ក។

**ទលិទ្ទ** *គុ.* ឬ *ន.* (**បា. ទលិទ្ទ**) ដែលក្រីក្រទ្រព្យ, ដែលខ្សត់ទ្រព្យ, អ្នកកម្សត់, មនុស្សទុគ៌ត។ ស្ត្រីជា **ទលិទ្ទា** :

**ពាក្យភាព្យ**

ពួកអ្នកទលិទ្ទ គ្នាខំប្រឹងគិត រាវរកឧបាយ
ឱ្យមានទ្រព្យធន សម្រាប់ប្រើចាយ នោះខំខ្វល់ខ្វាយ
ក៏នៅតែទ័ល។

**ទស** *ប. សំ.* (បា.) ដប់ (១០) :

**ពាក្យភាព្យ**

យើងខ្ញុំបង្គំព្រះទ្រង់យស ដោយម្រាមទាំងទសផ្ទង់គោរព ព្រមដោយសក្ការៈទាំងគ្រប់
សូមឱ្យឧបទ្រពចៀសចេញឆ្ងាយ។

**ទាយី** *ន.* (បា.) ដូចគ្នានឹង **ទាយក**; ស្ត្រីថា **ទាយិនី** ដូចគ្នានឹង **ទាយិកា** ដែរ :

**ពាក្យភាព្យ**

រីពួកទាយី និងទាយិនី សំភីធ្វើទាន
ចិត្តជាកុសល លើកថ្កល់សង់ស្ពាន ព្រោះជឿថាមាន
ប្រយោជន៍ច្រើនក្រៃ។

**ទារុណ** *គុ.* (បា.) កាច, កាចអាក្រក់, អាក្រក់ :

**ពាក្យភាព្យ**

អំពើទារុណ អ្នកដែលធ្វើស៊ុន តែងនឹកមមៃ

ព្រួយហើយព្រួយទៀត ចង្អៀតចិត្តក្រៃ ដល់ពេលជិតក្ស័យ
នឹកឃើញឥតភ្លេច។

**ខាល់** ***កិ.*** ឬ ***គុ.*** មិនរហូត, ទញ់តុះ; ទើសផ្លូវ, ទើសដំណើរ; ខ្វះខាត, មិនគ្រប់គ្រាន់ :

**ពាក្យកាព្យ**

ដប់ទាល់ម្ដៃទាល់ កុំឱ្យទាល់គំនិត ដប់គិតម្ដៃគិត
កុំគិតការណ៍ឆ្វេង ដប់លេងម្ដៃលេង កុំលេងល្បែងភ្នាល់;
បើជ្រុលលេងហើយ ឃើញទោសក្រទ័ល ត្រូវកត់សម្គាល់
ស្បែស្បួចរាងចាល។

**ខាស** ***ន.*** ឈ្មោះវល្លិព្រៃមួយប្រភេទ សណ្ដានពពាយជ្រុង ប៉ុន្តែប្រើការដូចពពាយជ្រុងពុំកើតទេ :

**ពាក្យកាព្យ**

ឃើញសេះជាលា ក្ងានជាទា ពពាយជាខាស
សំណជាប្រាក់ ស្ពាន់ឆ្លាក់ជាមាស បង្គួយជាជាស
កប្បាសជា-គ។

**ខិដ្ឋមត្ត ឬ ខិដ្ឋមត្តក៍** ***ន.*** (**បា. ខិដ្ឋមត្ត, ខិដ្ឋមត្តក**) អ្នកដែលទើបច្ចូបឃើញស្គាល់រាប់រកគ្នាជាមិត្តក្នុងគ្រាដំបូងបំផុត; អ្វីៗដែលទើបបានឃើញម្ដងដំបូង :

**ពាក្យកាព្យ**

គួរតែប្រយ័ត្ន	កុំជឿទិដ្ឋមត្តក៍	ដោយឥតទំនង
ត្រូវតែពិនិត្យ	សិនសឹមទាក់ទង	ជាមិត្តភក្ដិផង
តាមហេតុហុចឱ្យ។

**ទឹកធ្លាក់** *ន.* ទឹកដែលហូរខ្លាំងពីទីខ្ពស់ចុះមកកាន់ទីទាប :

**ពាក្យកាព្យ**

ទឹកបាក់ទៅទាប	បុណ្យបាត់ដ្បិតបាប	លាភបាត់ដ្បិតឃោរ
ទឹកថ្លាដ្បិតរលក	ពុំយល់ស្រមោល	ទោសកើតដ្បិតពោល
ល្មមមាត់ឈ្មានពាន។

**ទុព្វល** *ន.* ឬ *គុ.* (បា.) កម្លាំងថយ, កម្លាំងថមថយ, ខ្សោយឬដែលមានកម្លាំងថយ, ខ្សោយ (ទុព៌ល) :

**ពាក្យកាព្យ**

វីចាស់ទុព៌ល	ច្រើនភ្លេចពុំយល់	ពុំចាំសព្វគ្រប់
កម្លាំងថមថយ	ទាំងថ្ងៃទាំងយប់	ដំណើរជ្រុលជ្រប់
ទប់ដោយឈើច្រត់។

**ទើង** *កិ.* (ព. បុ.) ចង់, ត្រូវការ :

**ពាក្យកាព្យ**

ទើងធីប្រើរក	ទើងស្វែងប្រើទៅ	ទើងស្នេហ៍ប្រើហៅ
មិត្តមកជាមិត្ត។

**នោះបីបើ** ឬ **នោះយោបី** *និ.* (ព. បុ.) ជួនក្រែង, ក្រែងលោ, ជួនក្រែងលោ; ប្រសិនបើ :

**ពាក្យកាព្យ**

នោះបីបើខ្លាំងខ្លាត់ កុំស្មៀមមាត់ត្រូវស្រដី កុំឱ្យខ្លួនអប្រិយ
នោះម្ដេចក្ដីត្រូវដោះស្រាយ។
មួយសោតនោះយោបី លោកស្រដីអតិប្រាយ អំពីការណ៍រើងឆ្ងាយ
ថានាយអាយកុំតតប។

**ទ្រព្យា** *ន.* (សំ. **ទ្រព្យ, ទ្រព្យា**) ទ្រព្យទាំងពួង, ទ្រព្យនានា :

**ពាក្យកាព្យ**

អ្នកមានទ្រព្យា បើមានចិត្តជា សម្បូរមិត្តភក្ដិ
តែងមកឈ្លូឆរ កំដរឥតអាក់ នាំឱ្យត្រជាក់
ចិត្តថ្លើមជានិច្ច។

**ទ្រមេញ** *គុ.* លំគេញ, រំគេញ, ដែលញាប់រមេញ :

**ពាក្យកាព្យ**

ហៃកែវទ្រមេញ កុំពោលទន្ទេញ តែពីទុក្ខព្រួយ
ខំធ្វើបុណ្យទៅ គង់បុណ្យនឹងជួយ ឱ្យកែវស្រាលព្រួយ
មានចិត្តរីករាយ។

**ទ្វិបថ** *ន.* (សំ. **ឆា.**) ផ្លូវបែកជាពីរ :

**ពាក្យភាព្យ**

លុះដល់ទ្វិបថ　　រីចៅកម្សត់　　មានចិត្តហ៊ឹងហ៊ាង
បើទៅខាងស្ដាំ　　ក្រែងជាផ្លូវវាង　　ផ្លូវឆ្វេងស្រួលជាង
ឬទៅខាងណា។

**ទ្វេស្សជន** *ន.* (**សំ.**) ជនដែលស្អប់, មនុស្សដែលស្អប់ :

**ពាក្យភាព្យ**

រីទ្វេស្សជន　　ពុំសូវគិតគន់　　ពីការចងមិត្ត
ច្រើនតែភ្លេចភ្លាំង　　គាំងការពិនិត្យ　　ដោយហេតុឥតមិត្ត
ព្រួយក្នុងគ្រាក្រ។

**ទ្វេហារ** *ន.* (**សំ. បា.**) អ្នកដែលនាំ, ដែលបញ្ជូនរបស់អ្វីៗទៅទាំងពីរនាក់ជាមួយគ្នា; អ្នកសែងអ្វីៗ។ សព្វនេះអ្នកប្រាជ្ញតែងកាព្យយកមកប្រើមានន័យថា **ពីរនាក់, នាំខពីរគ្រាលា** :

**ពាក្យភាព្យ**

ព្រះរាជកុមារ　　ទាំងទ្វេហារល្អពិសី　　គួរឱ្យមានមេត្រី
ក្ដីស្រលាញ់ស្មើបុត្រា។

**ធរណិន្ទ** *ន.* (**បា.**) អ្នកដែលជាធំលើផែនដី (ក្សត្រទ្រង់រាជ្យ) :

**ពាក្យភាព្យ**

ព្រះបាទធរណិន្ទ　　មានហឫទ័យជិន-　　ណាយក្នុងកិច្ចការ
ទ្រង់ត្រាស់ឱ្យហៅ　　ព្រាហ្មណ៍ព្រឹទ្ធាចារ្យ　　និងរាជបរិវារ

មកគាល់ព្រះអង្គ។

**ឆ្វេសឆ្វេ ឬ ឆ្វេឆ្វេស** *កិ.* ឆ្វេសពីរដង គឺឆ្វេសហើយឆ្វេសទៀតដល់ពីរដង ឬឆ្វេសច្រើនដង :

**ពាក្យភាព្យ**

គួរប្រុងប្រយ័ត្នកុំបីឆ្វេស បើបានជាឆ្វេសកុំឆ្វេសឆ្វេ ឆ្វេឆ្វេសប្រហែសឃើញច្រើនតែ វិនាសទ្រព្យធនពុំសូវខាន។

**នង្គ័ល** *ន.* (**បា. នង្គល**) ប្រដាប់សម្រាប់ភ្ជួរផែនដី :

**ពាក្យភាព្យ**

| | | |
|---|---|---|
| យើងជាកសិករ | បានភ្ញៀងមកអរ | រៀបចំនង្គ័ល |
| រនាស់រាល់ប្រាណ | ហើយបានខ្វាយខ្វល់ | សាបព្រោះរចល់ |

ឱ្យទាន់វេលា។

**នរៈ** *ន.* (**សំ. បា. នរ**) មនុស្ស, ជន។ បើស្ត្រីជា **នារី** :

**ពាក្យភាព្យ**

| | | |
|---|---|---|
| នរៈនារី | ត្រូវខំសំភី | រៀនសូត្ររាល់គ្នា |
| ទាន់ខ្លួននៅក្មេង | កុំលះវេលា | ដល់ចាស់ជរា |

អ្នកនឹងធូរចិត្ត។

**នរូ** *ន.* (**សំ. បា. ក្លា.** ក្លាយមកពី **នរោ; សំ. បា. នរ > នរោ**) មនុស្ស, ជន :

**ពាក្យកាព្យ**

នរអ្នកណា ទោះយកអាត្មា ចូលសាសន៍ពុទ្ធរតន៍
ចូរធ្វើឱ្យត្រង់ ដោយនូវបន្ទាត់ ហៅស្វែងសម្បត្តិ
យកផ្លូវនិព្វាន។

**នវមាលិកា** *ន.* (សំ. បា.) ម្លិះរួត៩ស្រទាប់ :

**ពាក្យកាព្យ**

នវមាលិកា បញ្ចេញបុប្ផា ក្រអូបសាយសព្វ
ពិដោរគន្ធា ដូចជាទឹកអប់ គួរជនផងគាប់-
ចិត្តដាំក្បែរផ្ទះ។

**នវាគត** *គុ.* ឬ *ន.* (**សំ. បា. នវ** «ថ្មី» + **អាគត** «មក, ដែលមក, ដែលទើបមក») ដែលទើបមកថ្មី; មនុស្សដែលទើបមកដល់ថ្មីៗ, អ្វីៗដែលទើបមកដល់ថ្មីៗ :

**ពាក្យកាព្យ**

មិត្តហ្នឹងជាជននវាគត មកមានកំណត់កាលវេលា គួរយើងទាំងអស់ស្រុះចិត្តគ្នា
នាំពាក្យសួរសមរកគេផងៗ

**នាថ** *ន.* (**សំ. បា.** ) អធិបតី, ម្ចាស់, ចៅហ្វាយ, នាយ :

**នាថ** *គុ.* (**សំ. បា.** ) ដែលជាទីពឹង, ដែលជាពំនាក់ :

**ពាក្យកាព្យ**

នាងនាថបីបុត្រ បំពេលំអុត ដោយពាក្យផ្អែមថា

ឱកូនមាសម្ដាយ ចូរដេកឆាប់វ៉ា ម្ដាយនឹងយាត្រា

ទៅរកភោជន។

**នានា** ***និ.*** (**សំ. ឍ.** ) ផ្សេងៗ, ទីទៃៗ :

**ពាក្យភាព្យ**

ស្ដេចទ្រង់យាត្រាតាមដងព្រៃ ព្រះនេត្រវិពៃទតព្រឹក្សា នូវអស់បក្សីផងនានា

ក្សត្រាត្អូកនឹកដល់ក្សត្រី។

**នាបី** ***និ.*** រីឯ, ធម្មតាឯ, ដែលហៅថា :

**ពាក្យភាព្យ**

នាបីហៅគ្រូ ដូចអ្នកនាំផ្លូវ ដើរដោយគន្លង

ទោះនឹងឆ្ពោះទៅ ស្រុកតូចធំផង សឹងដូចបំណាង

នៃចិត្តចិន្ដា។

**និត្យ** ***កិ. វិ.*** (**សំ.**) ទៀង, ពិត, មែន; រឿយៗ, មិនដែលដាច់; ច្រើនប្រើជា **និត្យនៅ** ឬ **នៅនិត្យ** គឺនៅមិនដាច់ :

**ពាក្យភាព្យ**

អនិច្ចំពុំឋិត ពុំថេរនៅនិត្យ យឺនយូរឡើយនៃ

ស្លាប់ទៅជាខ្មោច អសោចពេកក្រៃ ឆ្អឹងសាច់សរសៃ

ជាព្រះធរណី។

**នួនល្អង** ***គុ.*** ឬ ***ន.*** ដែលមានសម្បុរផ្ទូរផង់បំព្រង (ពាក្យលើកទំយើដោយសសោះអន្ទង) :

**ពាក្យភាព្យ**

ហៃប្អូនន្ទួនល្អង ខឹងអ្វីនឹងបង ពុំចេញចរចា
បងមានខុសអ្វី ត្រូវស្រីនាងថា នៃកែវកនិដ្ឋា
ម្ដេចក៏នៅស្ងៀម។

**នេត្រា** *ន.* ភ្នែកទាំងពីរ :

**ពាក្យភាព្យ**

ស្ដេចទតព្រះនេត្រា ឃើញធីតានៃសេដ្ឋី មានរូបឆោមពិសី
ព្រះចក្រីទ្រង់ត្រាស់សួរ។

**នែបនិត្យ** *កិ.* អែបជិតរឿយៗ, អែបជិតមិនដាច់ :

**ពាក្យភាព្យ**

នៃបនិត្យក្រសោប ជួញជិតអង្គឱប អង្អែលឥន្ទ្រិយ
ថើបថៃកាយា ភក្ត្រាកាកី ក្ដួចកើតមេត្រី
រាគរសតណ្ហា។

**នែបនិត្យ** *កិ.* អែបជិត, ផ្ដេកផ្ដិត, កៀកឱប, អែបជិតមិនដាច់ :

**ពាក្យភាព្យ**

ឱកែវកល្យាណ ធ្វើម្ដេចនឹងបាន ប្អូនមកនៃបនិត្យ
រួមរ័កមេត្រី ដោយក្ដីស្នេហ៍ស្និទ្ធ ឱ្យបានដូចចិត្ត
ដែលបងប៉ុនប៉ង។

**នាំពា** *កិ.* អើពើ, យកចិត្តទុកដាក់, ស្រវាស្រទេញ :

**ពាក្យភាព្យ**

ហែកែវពុំងា ម្ដេចមិននាំពា នៅស្មៀមដល់ណា

បើមិនគទេ ចូរលាន់វាចា ថាម៉េចក៏ថា

ឱ្យឮមកចុះ។

**បញ្ចង្គ** *ន.* ឬ *គុ.* (**បា. បញ្ច** «ប្រាំ» + **អង្គ** «អវយវៈ» > **បញ្ចង្គ**) ដែលមានអង្គប្រាំ; អវយវៈប្រាំ។ អង្គប្រាំនៃការគោរពនោះគឺ លុតជង្គង់ទាំង២, ដាក់ដុំដៃទាំង២លើផ្ទៃរាប, ឱនក្បាលដល់ផ្ទៃរាប (រួមជាប្រាំ) ហៅថា **គោរពដោយបញ្ចង្គ** ឬ **ដោយបញ្ចង្គប្រតិស្ឋ** :

**ពាក្យភាព្យ**

ខ្ញុំសូមគោរពដោយបញ្ចង្គ ឆ្ពោះត្រង់ព្រះពុទ្ធនិងព្រះធម៌ ព្រះសង្ឃលោកមានសីលសង្វរ ខ្ញុំមានអំណរពន់ពេកក្រៃ។

**បណ្ដិប** *ន.* សម្ដីហាមប្រាមបញ្ជាក់ហើយបញ្ជាក់ទៀត, សម្ដីហាមបញ្ជាក់ដោយដាក់កំហិតឱ្យអ្នកស្ដាប់ទទួលប្រតិបត្តិតាមដោយដាច់ខាត ជាសម្ដីដែលអ្នកស្ដាប់ច្រើនតែពុំសូវគាប់ចិត្ត :

**ពាក្យភាព្យ**

ពាក្យគ្រូរែងរឹង ស្រារែងស្រវឹង ពុំដែលពិសា

ពាក្យពិតរែងស្លែង ពុំពីរោះថា បណ្ដិបមេបា

រែងថាពុំគាប់។

**បន** *កិ.* ដ្បិត (ព. បុ.); (ព. កា.) ចង្អុលប្រាប់ពាក្យ **បន** (ដ្បិត) :

**ពាក្យកាព្យ**

ប្រពន្ធឃើញឃាត់ទៅ ប្ដីមិនត្រូវថាកុំអ្នក ឯងខឹងលោវ៉ាយធាក់
ដោយចិត្តធំបទបានស្រា។

**បារម្ភ** *ន.* (បា. ប + **អារម្ភ** > **បារម្ភ** តែមិនសូវដែលប្រទះឃើញប្រើ, ប្រែថា «សេចក្ដីផ្ដួចផ្ដើម, ការផ្ដើម, ការនាំអាទិ») ដំណើរនឹកថប់, ដំណើរនឹកព្រួយជាមុន :

**ពាក្យកាព្យ**

អាពុកបារម្ភ ក្រែងកូនមិនខំ ដូចពាក្យប្ដេជ្ញា
ហេតុនេះចូរកូន- ឯងទាំងអស់គ្នា កុំបានតែថា
ថាហើយត្រូវធ្វើ។

**បុប្ផគន្ធ** *ន.* (បា.) ក្លិនផ្កាក្រអូប, ផ្កាមានក្លិនក្រអូប :

**ពាក្យកាព្យ**

រីបុប្ផគន្ធ ប្រដូចនឹងជន អ្នកមានសីលា
ក្រអូបកេរ្ដិ៍ឈ្មោះ សាយសព្វទិសា រីជនពាលា
ផ្ទុយគ្នាស្រលះ។

**បុប្ផា** *ន.* (បា. **បុប្ផ**, ពហុ. **បុប្ផា**) ផ្កាទាំងឡាយគឺផ្កាទូទៅមិនចំពោះឈ្មោះ :

**ពាក្យកាព្យ**

សូមប្អូនខ្ចីមខ្លួនន្ទួនបុប្ផា អាណិតមេត្តាខិតមកអាយ រៀមសូមផ្ដេកផ្ដិតកិតកៀកកាយ
ព្រោះពៅឆោមឆាយបែកគ្នាយូរ។

**បុប្ផាកេសរ** *ន.* (**បា. បុប្ផ + កេសរ** «លម្អង») កេសរផ្កា (លម្អងផ្កា)។ **៧. ប្រ.** ពាក្យសម្រាប់ហៅលើកស្ត្រីដែលជាទីស្រលាញ់ថាមានលម្អដូចជា កេសរផ្កា :

**ពាក្យកាព្យ**

| | | |
|---|---|---|
| បុប្ផាកេសរ | ចូរនាងត្រេកអរ | ចំពោះសំណាង |
| គឺការកុសល | ដែលយើងបានសាង | បញ្ចេញពស្តុតាង |
| | ឱ្យឃើញទាន់ភ្នែក។ | |

**បុប្ផានារី** *ន.* (**បា. បុប្ផ + នារី**) នារីផ្កា (ស្ត្រីដូចជាផ្កា); ពាក្យសន្មតហៅស្ត្រីដោយលើកថាមានលំអដូចជាផ្កា :

**ពាក្យកាព្យ**

| | | |
|---|---|---|
| បុប្ផានារី | ចូរនាងសំភី | ខំរៀនវិទ្យា |
| ទាន់ខ្លួននៅក្មេង | កុំញុំាងវេលា | ឱ្យខាតច្រើនគ្រា |
| | នាំឱ្យស្តាយក្រោយ។ | |

**បូរណា** *គុ.* (**សំ. បា. បុរណា**) មានន័យដូចគ្នានឹង **បុរណា** ដែរ, ជាពាក្យសម្រាប់ប្រើខ្លះ ចំពោះតែក្នុងកាព្យដែលមានសម្ពស្សត្រូវថាឱ្យវែងឱ្យយឺត, ឯពាក្យរាយត្រូវសរសេរត្រូវនិយាយថា **បុរណា** ជាដរាប :

**ពាក្យកាព្យ**

វិអក្សរខ្មែរយើងសព្វថ្ងៃ អ្នកប្រាជ្ញលោកច្នៃតាមលំអាន ចាស់ព្រឹទ្ធាចារ្យពីបូរាណ
ដែលបានហាត់រៀនតៗមក។

**មួយបែបទៀតថា**

ខ្ញុំរៀនអក្សរជាតិ ពុំឃ្លៀងឃ្លាតក្លាយប៉ុន្មាន រៀនតាមបែបបូរាណ
លោកគ្រូបានពន្យល់ដែរ។

**បំណាច់នឹង** *និ.* ទោះបីនឹង, បើបានជានឹង :

**ពាក្យកាព្យ**

បំណាច់នឹងប្រាស គួរមានសម្ភាសន៍ មួយម៉ាត់ទៅវ៉ា
នេះមិនដូច្នោះ ស្រាប់តែព្រាត់គ្នា ឱ្យមានសោកា
សង្រេងរាល់ថ្ងៃ។

**បំភ្លាង** *កិ. ន.* (ព. បុ.) បណ្ដើរ :

**ពាក្យកាព្យ**

ស្ដេចទតបំភ្លាង ចរចារកនាង ដោយក្ដីស្នេហា
ទ្រង់ស្ទង់ព្រះទ័យ ស្រីថ្លៃកញ្ញា កបដោយលក្ខណា
ចរិយាឥតគ្គង។

**បរមិន្ទ** *ន.* ឬ *ន.* (**បា. បរម + ឥន្ទ > បរមិន្ទ**) ដែលជាធំក្រៃលែង; អ្នកដែលជាធំក្រៃលែងជាងពួកមនុស្ស (ក្សត្រទ្រង់រាជ្យ) :

**ពាក្យកាព្យ**

សូមព្រះបរមិន្ទ នរាធិបតិន្ទ ទ្រង់ព្រះមេត្តា
ប្រទានឱកាស ឱ្យរាស្ត្រប្រជា ចូលគាល់ក្សត្រា
នាគ្រាឥឡូវ។

**បរិជន** *ន.* (បា.) ជននៅជិតខាង; បរិពារ; អ្នកនៅភូមិផងរបងជាមួយ; បរិស័ទ, គ្នីគ្នា :

**ពាក្យកាព្យ**

សង្ឃឹមបរិជននៅជិតខាង គេសុទ្ធតែអាងថាមិនដឹង គ្នាឯងក្នុងផ្ទះក៏ធ្មឹងៗ
តើមានទីពឹងឯណាទៀតៗ

**បុត្តា** *ន.* (បា. ជាឯកសេសន័យ) កូនប្រុសនិងកូនស្រី គឺកូនទាំងអស់ ទាំងប្រុសទាំងស្រី :

**ពាក្យកាព្យ**

គ្រានោះបិតា បានឱ្យបុត្តា មកជួបជុំគ្នា
ទើបផ្ដាំប្រដៅ តាមផ្លូវធម្មា ឱ្យរួមរក្សា
បងប្អូនគ្រប់ប្រាណ។

**បេតី** *ន.* (ក្លាយមកពី **បីតិ** «សេចក្ដីត្រេកអរ, ការផ្សព្វផ្សាយ, ការព្រឺព្រួច, ការឆ្អែតចិត្តដោយអំណរ,...») សេចក្ដីស្រលាញ់, ស្នេហា, ការព្រឺព្រួច :

**ពាក្យកាព្យ**

ទើបអ្នកឱនឱប ក្រួញក្រុងក្រសោប ថ្នាក់ថ្នមធីតា
រួមរសមនោរម្យ សុខសមស្នេហា បេតីសន្ធា
មិត្តមូលមេត្រី។

**មួយបែបទៀតថា**

យល់ជាត្រូវចិត្តស្និទ្ធរួមរក្ស ស្មោះស្ម័គ្រស្រលាញ់ពេញបេតី ថែមធុំក្លិនផ្កាជាប់ក្លិនស្រី

នឹងមកធ្វើអ្វីអ្នកថ្លៃអាយៗ

**ម្ចី** *៥.* (**សំ. ធា. មន** «ម្ចាស់; ប្រុសជាម្ចាស់ផ្ទះ គឺបុរសជាគូគ្នានឹងស្ត្រីជាភរិយា») ប្រុសជាគូគ្នានឹងស្រីជាប្រពន្ធ :

## ពាក្យភាព្យ

| | | |
|---|---|---|
| កតមេហិ | បញ្ចគតី- | ហិ សាមិកា |
| ភរិយា ស- | ង្គហា ធម្មា | ប្រែតាមអត្ថា- |
| | ធិប្បាយបាលី។ | |
| ថាប្រុសឯណា | នឹងមានភរិយា | លោកឱ្យចេះក្តី |
| ទាំងប្រាំចំពោះ | សង្គ្រោះចិត្តស្រី | ប្រពន្ធប្រក្រតី |
| | ដូចធម៌សម្តែង។ | |
| បើប្តីឯណា | ពុំកាន់កិរិយា | ទាំងប្រាំនេះឯង |
| ហៅប្តីទុជ៌ន | ជួលន់ក្រៃលែង | ចេះតែកំហែង |
| | ចិត្តប្រពន្ធពិត។ | |
| បើប្តីកាន់ច្បាប់ | ទាំងប្រាំនេះខ្ជាប់ | ហៅប្តីសុចរិត |
| បម្រុងភរិយា | ដោយនាក្រមក្រឹត្យ | ប្រសើរពេកពិត |
| | ឥតអ្វីផ្ទឹមឡើយ។ | |
| អស់ប្រុសទាំងឡាយ | ចូរចាំអធិប្បាយ | ច្បាប់នេះជាត្រើយ |
| ទុកគ្រប់ប្រុសប្រាណ | កុំមានកន្តើយ | មានប្រពន្ធហើយ |
| | ជាសុខសម្រាន្ត។ | |

មួយគឺហៅប្តី ឱ្យប្រើស្រដី នឹងប្រពន្ធមាន
ពាក្យទន់ពីរោះ ស្មើស្មោះដោយក្សាន្ត សរសើររាប់អាន
តាមសព្ទវាចា។

មួយគឺប្រពន្ធ ខុសឆ្គងស្រោលធ្ងន់ កុំជេរផ្តាសា
ទាត់ធាក់ដៀលដំ ដូចខ្ញុំអាត្មា កុំស្តីដើមថា
ឱ្យឮសាយសព្ទ។

មួយគឺបានធន ប្រគល់ប្រពន្ធ ទុកដាក់រណ្តាប់
ទាំងគ្រឿងអាហារ ជាការស្រីផ្គាប់ រៀបចំសម្រាប់
ថែទាំរក្សា។

មួយគឺកុំផ្គង់ កុំខំតែប- ង្កើតកូនហើយថា
ប្រពន្ធសុខចិត្ត ឱ្យគិតប្រាថ្នា រួសរកទ្រព្យា
សម្រាប់ឱ្យផង។

មួយគឺឱ្យចាប់ ស្រលាញ់ឱ្យខ្ជាប់ កុំជិនណាយហោង
បើមានប្រពន្ធ- ទៀតកុំប៉ុនប៉ង ស្រលាញ់ស្នេហ៍ស្នង
ឱ្យស្មើមុខឡើយ។

សម្តែងសេចក្តី គ្រប់ប្រាំវិធី ថែងចប់ស្រេចហើយ
ឱ្យអស់ប្រុសផង ចាំចងជាត្រើយ ផ្គង់កុំកន្តើយ
ចោលច្បាប់បុរាណ។

បើប្រុសឯណា ពុំផ្ចង់ចិន្តា ដូចធម៌ទូន្មាន
នៅនឹងភរិយា គ្មានជាសុខសាន្ត ហិនហោចធនធាន
ទាស់ទែងលែងគ្នា។

ឯវិស័យចិត្ត អស់ស្រីផងពិត មានប្ដីប្រាថ្នា
អំពើទាំងប្រាំ នេះចាំចិន្តា គ្រប់ចិត្តភរិយា
នៅនាលោកិយ។

បើខ្វះអំពើ- ណាមួយហើយតើ ប្រពន្ធថាប្ដី
ចិត្តពុំត្រូវត្រង់ ពុំគង់មេត្រី តូចចិត្តស្វាមី
អាក់អន់ពុំស្មោះ។

លោកឱ្យប្រុសផង គន់គិតស្ងួនគ្រង ផ្ចង់ចិត្តសង្គ្រោះ-
ប្រពន្ធឱ្យពិត ដោយក្រឹត្យប្រាំនោះ ប្រពន្ធក៏ស្មោះ-
ចិត្តចូលមូលឯង។

កុំគិតតែយក- ប្រពន្ធបានមក គ្រាន់ឱបប្រលែង
បង្កើតតែកូន សោះសូន្យធនធេង លោកឱ្យគិតក្រែង
ដំណៀលនិន្ទា។

ធម្មតាជាប្ដី បានទ្រព្យធនអ្វី ឬយសសក្កា
តែងនៅសុខសឹង- ទីពឹងផងគ្នា ព្រោះដ្បិតភរិយា
កាន់ក្ដីសុចរិត។

អំពើច្នេះហោង ឱ្យអស់ប្រុសផង ចងចាំក្នុងចិត្ត
តាមធម៌ទូន្មាន គ្រប់ប្រាណប្រុសពិត ទុកជាក្រមក្រឹត្យ
ច្បាប់ច្បាស់តទៅ។

អង្គអញរចនា សេចក្ដីកាព្យ តាមច្បាប់ទុកនៅ
ក្នុងព្រះបាលី សេចក្ដីជ្រាលជ្រៅ ពុំប៉ានសៅដៅ
លើកលេងងាយដាយ។

ឧស្សាហ៍ខំប្រុង ប្រែរករើសក្នុង គម្ពីរនិកាយ
អដ្ឋកថា ដីកាបរិយាយ និបាតទាំងឡាយ
មកផ្សំស្រដី។

ជាច្បាប់ទុកត ដំណឹងតំណ ដំណើរស្ត្រី
ឱ្យជាក់ប្រាកដ ដោយបទបាលី គ្រាន់អស់ប្រុសស្រី
រើសរៀនរកផ្លូវ។

ច្បាប់នេះប្រសើរ ដំណឹងដំណើរ ទំនងនេះកូវ
ជាច្បាប់ប្រាកដ ដោយបទត្រឹមត្រូវ គួរយើងឥឡូវ
ប្រតិបត្តិរក្សា។

គួររៀនឱ្យស្ទាត់ ឱ្យចាំរត់មាត់ ដាក់ក្នុងចិន្ដា
គ្រាន់នឹងប្រិតប្រៀន បង្រៀនអាត្មា តាមដោយគាថា
នេះឯងតទៅ។

ចែងចប់អភិប្រាយ ដោយអត្ថបរិយាយ ស្ងួរេចថ្ងៃសៅរ៍
ប្រាំបីរោចឯង នាខែមាឃនៅ ឆ្នាំរកាត្រូវ
នព្វស័កស្រេចហោង។ ៙

**ប្រពន្ធ** *ន.* (**សំ. ប្រ + ពន្ធ** "ជាប់ជំពាក់, ជំពាក់ឆ្វាក់; ដែលចងរឹតរួត; ចំណងចងឆ្វាក់រឹតរួត") ស្ត្រីជាចំណងគូនឹងបុរស (ភរិយា) :

**ពាក្យភាព្យ**

មួយសោតព្រះពុទ្ធ ទេសនាចំហុត ថារីភរិយា
មានប្រាំពីរស្នេះ ប្អូននោះចិត្តជា បីនោះមោហា
ចិត្តខូចងាយដាយ :

ឯប្រពន្ធជា ឯកស្នេះមាតា- ភរិយាដូចម្ដាយ
ឈឺឆ្អាលកូនខ្លួន រែងស្ងួនមិនណាយ មិននឹករសាយ
ចិត្តចាំអាណិត។

កូនទុក្ខទោសម្ដេច ខ្សត់ក្រច្រើនតិច ខឹងខុសខូចចិត្ត
ព្រាត់ប្រាសឃ្យូរលង់ ពុំបង់បែកចិត្ត គង់ចាំចិត្តគិត
ឈឺឆ្អាលកូនស្នេះ។

ប្រពន្ធណាគាប់ ឈឺឆ្អាលប្ដីខ្ជាប់ ចិត្តចាំកាន់កោះ
ដូចម្ដាយស្រលាញ់ កូនពេញពីពោះ ហៅប្រពន្ធនោះ
ថ្លៃឥតផ្ទឹមដល់។

ប្រពន្ធជាទី ឈ្មោះហៅទាសី- ភរិយាដូចកល់
ខ្ញុំនឹងអម្ចាស់ ប្រើណាស់ខ្វាយខ្វល់ អាចអត់ទប់ទល់
ទម្ងន់បម្រើ។

មិនមានទំនេរ ទោះម្ចាស់វាយជេរ អត់ឱនសរពើ
តាមតែបង្គាប់ ប្រញាប់ចង់ធ្វើ ចិត្តពុំសើរើ
ចៀសវាងក្រោធា។

ប្រពន្ធណាអត់ ឱនអង្គអំណត់ ខ្លាចប្ដីអាត្មា
ដូចខ្ញុំនឹងម្ចាស់ ខ្លាចណាស់ធានា ប្រពន្ធនោះជា
ប្រសើរសុខសូន្យ។

ប្រពន្ធជាត្រី ឈ្មោះភគិនី- ភរិយាដូចប្អូន
ស្រលាញ់បងពិត លំអិតលំអូន ទទួលដំបូន-
មានមាត់ពាក្យបង។

ផ្ដាច់ផ្ដួលតែមួយ នឹងចងជាត្រួយ ចិត្តចាំបំណង
ពំនាក់ពំនឹង ពាក់ពឹងប៉ុនប៉ង តែនឹងអង្គបង
ឥតម៉ែទីទៃ។

ប្រពន្ធណាចូល នឹងប្ដីមួយមូល- ចិត្តជាប់អាល័យ
ដូចប្អូននឹងបង ចាំចងអាស្រ័យ ប្រពន្ធនោះថ្លៃ
មធ្យមពេកពិត។

ប្រពន្ធចត្វា ឈ្មោះហៅសខា- ភរិយាដូចមិត្ត-
សម្លាញ់ស្រលាញ់ អស់អញ្ចេកពិត ស្មើខ្លួនស្មើចិត្ត
ស្និទ្ធស្នេហ៍ចិន្តា។

បើមិត្តទៅបាត់ ស្ងប់ស្ងាត់មុខមាត់ ទុក្ខទន់ទយា
ឃើញមុខមកបាន ចិត្តក្សាន្តសោះសា ស្រស់ស្រួលភក្ត្រា
និរទុក្ខសោកសៅ។

ប្រពន្ធណាចិត្ត ស្រលាញ់ប្តីពិត គ្មានក្នុងគ្មានក្រៅ
ដូចមិត្តនិងមិត្ត ចងចិត្តជាប់នៅ ប្រពន្ធនោះហៅ
ឧត្តមក្រមាន។

សម្តែងភរិយា ទាំងបួនសឹងជា ក្រស្រីធ្វើបាន
បើស្រីណាគិត ផ្គង់ចិត្តសន្តាន ស្រលាញ់ប្តីប្រាណ
ដូចធម៌ទេសនា។

លោកថាស្រីនោះ ឮកេរ្តិ៍ពីរោះ ទូទៅនានា
បើអស់ជីវិត នៅឋិតស្ឋគ៌ា ចៀសចាកចតុរា-
បាយបាបទុក្ខភ័យ។

ប្រពន្ធពុំជា ឈ្មោះវធកា- ភរិយាដូចនៃ
សត្រូវចាំចង ទោសផងសព្វថ្ងៃ ប្រពន្ធចង្រៃ
ប្តីមានតែទុក្ខ។

បើប្តីខុសចិត្ត វាគ្មានអាណិត ខេរខឹងច្រអុក
ចាំចងទោសប្តី ស្រដីកិកកុក ឱ្យមាត់ឱ្យមុខ
វាសវាងគ្រោះគ្រើយ។

សុខទុក្ខសាំទាំ វាមើលបំណាំ នៅស្ងៀមព្រងើយ
ពុំជួយទុក្ខភ័យ ដោះដៃកន្តើយ ស្លាប់ដោយរស់ដោយ
គ្មានចិត្តមេត្រី។

ចោរីភរិយា ប្រពន្ធពុំជា លបលួចទ្រព្យប្តី
គ្មានចិត្តករុណា មេត្តាប្រណី របស់ទ្រព្យអ្វី
លក់ចាយអស់ធួន។

អយ្យាភរិយា ប្រពន្ធពុំជា តម្កើងតែខ្លួន
ចេះតែប្រើប្តី ឥតបីមានស្ងួន ធ្វើឫកណាំនួន
ទុកប្តីដូចខ្ញុំ។

ប្រពន្ធទាំងបី ធ្លាក់ទៅអវិចី រងទុក្ខដំណំ
ក្នុងខ្ទះភ្លើងក្តៅ យូរនៅក្រៀមក្រំ ព្រោះចិត្តខ្លួនធំ
ជាងប្តីអាត្មា។

ឯប្រពន្ធប្អូន- មុខនេះគួរស្ងួន យកជាភរិយា
នឹងកើតរបស់ កេរ្តិ៍យសសក្តា ថ្កើងពូជពង្សា
សោយសុខថេរឋិត។

សម្តែងបរិយាយ ភរិយាទាំងឡាយ ប្រាំពីរចរិត
ទាំងជួទាំងជា ពណ៌នាពោលពិត ចែងចប់ពិនិត្យ
តាមអត្ថគាថា។១៥

**ប្រពាស** *កិ.* ចេញឃ្លាតចាកលំនៅប្រក្រតី :

**ពាក្យភាព្យ**

ស្តេចទ្រង់យាងចេញប្រពាស អស់ទាំងពួករាស្ត្រ រទាសហែហមក្នុងព្រៃ។

**ប្រភាត** *ន.* (សំ.) អរុណោទ័យ គឺពេលព្រះអាទិត្យរះ, ព្រឹកព្រហាម :

**ប្រភាត** *គុ.* (សំ.) ដែលភ្លឺច្បាស់ហើយ, ដែលរះហើយ :

**ពាក្យភាព្យ**

នៅពេលប្រភាត សម្តេចភូវនាថ ទតសព្វទិសា
ទតឃើញព្រឹក្សព្រៃ ត្រសុំសាខា មានពួកបក្សា
បក្សីច្រើនក្រៃ។

**ប្រភាស** *កិ.* (សំ.) ពោល, ស្តី, និយាយ :

**ពាក្យភាព្យ**

ស្តេចទ្រង់ប្រភាស ឱ្យអស់ពួករាស្ត្រ បានឮរាល់គ្នា
ប្រជាពលរដ្ឋ ត្រេកអរមហិមា បានថ្វាយសច្ចា
ថាសូមស្មោះត្រង់។

**ប្រភាស** *ន.* (សំ.) ពន្លឺ, រស្មី :

**ពាក្យកាព្យ**

រីពួកនិគ្រន្ថ ច្រើនក្រៃពេកពន់ លុះឃើញប្រភាស
នៃព្រះសម្ពុទ្ធ ស្គុតរត់រទាស ខ្លះស៊ូស្លាប់ផ្តាស
ដោយលោតមុជទឹក។

**ប្រភូ** *ន.* (**សំ.**) ម្ចាស់, ចៅហ្វាយ :

**ប្រភូ** *គុ.* (**សំ.**) ដែលអង់អាច, ហៅហាន, មោះមុត :

**ពាក្យកាព្យ**

នៅក្នុងសន្និបាត នៃជនរួមជាតិ នោះមានប្រភូ
ជាអ្នកណែនាំ ទុកដូចជាគ្រូ ជាកាលញ្ញូ
ដឹងកាលដឹងការណ៍។

**ប្រមាទ** *ន.* (**សំ.**) ការភ្លេចស្មារតី, ការធ្វេសស្មារតី, សេចក្តីប្រហែស, ការធ្វេសប្រហែស :

**ពាក្យកាព្យ**

ជនណាប្រមាទ ប្រព្រឹត្តឃ្លៀងឃ្លាត ចាកធម៌សុចរិត
ជននោះទោះបី នៅមានជីវិត តាមដោយការណ៍ពិត
ថាស្លាប់ស្រេចហើយ។

**ប្រមឹក** *ន.* ឬ *គុ.* អ្នកកាន់ទម្លាប់ផឹកសុរាដល់ស្រវឹង; ដែលញៀន, ដែលជាប់សុរា :

**ពាក្យកាព្យ**

ប្រមឹកសាវ៉ា កាលបើត្រូវស្រា ស្រវឹងភ្លេចខ្លួន
ពោលពាក្យឡេះឡោះ ដដែលផ្ទួនៗ ពុំមានក្តីស្ងួន
ប្រណីគ្រួសារ។

**ប្រាការ** *ន.* (**សំ.**) កំពែង, កំផែង; បន្ទាយ, រាជវ័តិ :

**ពាក្យកាព្យ**

មានប្រាង្គប្រាសាទ ប្រាការស្អាងស្អាត ទូលំទូលាយ
មានប៉មមាំមួន និងភាគបន្ទាយ រេហ៍ពលរៀងរាយ
រាល់ថ្ងៃរាល់យប់។

**ប្រាឃាត** *ន.* (**សំ.**) សង្គ្រាម, ចម្បាំង :

**ពាក្យកាព្យ**

កើតមានវិវាទ ក្លាយជាប្រាឃាត ច្បាំងគ្នាវរវឹក
អស់រាស្ត្រប្រជា ភិតភ័យភ្លូកភ្លឹក ទ័លក្របាយទឹក
លំបាកគ្រប់ប្រាណ។

**ប្រាជ្ញ** *គុ.* ដែលមានប្រាជ្ញា, ដែលមានចំណេះ, ឈ្លាស :

**ប្រាជ្ញ** *ន.* អ្នកមានប្រាជ្ញា, អ្នកចេះ, អ្នកឈ្លាសវៃ; ការចេះដឹង, ការឈ្លាសវៃ :

**ពាក្យកាព្យ**

អសារមានបី បណ្តាំមេជី ព្រេងព្រឹទ្ធប្រដៅ
អង្គរសសុទ្ធ ចម្អិនឱ្យឆៅ ពិសីហើយខ្លៅ

ប្រាជ្ញឥតមារយាទ។

**ប្រាសព្រាត់** *កិ.* ព្រាត់ឃ្លាតចាកបុគ្គលជាទីស្រលាញ់លែងឃើញគ្នា :

**ពាក្យកាព្យ**

បំណាច់នឹងប្រាសព្រាត់ គួរហាមាត់ផ្ដាំមួយម៉ាត់ ហេតុម្ដេចក៏ទៅឬាត់
ស្ងាត់ដំណឹងឈឹងសូន្យសោះ។

**ប្រិមប្រិយ** ឬ **ប្រេមប្រិយ** *គុ.* (**សំ. ប្រេមន** *ន.* “មនុស្សឬអ្វីៗដែលជាទីស្រលាញ់” + **ប្រិយ** *គុ.* “ដែលគួរឱ្យស្រលាញ់, ដែលជាទីស្រលាញ់” ដែលស្រស់ប៉ប្រែគួរឱ្យស្រលាញ់, ដែលគួរឱ្យស្រលាញ់ក្រៃពេក :

**ពាក្យកាព្យ**

មើលមាត់ក៏ប្រិមប្រិយ ហាមាត់ស្ដីឥតទាស់ឆ្គង មើលមុខស្រស់បំព្រង
ទាំងដងខ្លួនក៏ប្រេមប្រិយ។

**ប្រិយប្រាយ** *ន.* (**សំ.**) ពាក្យ, សម្ដី :

**ប្រិយប្រាយ** *គុ.* (**សំ.**) ដែលគួរឱ្យស្រលាញ់, ដែលគួរឱ្យចង់ស្ដាប់ :

**ពាក្យកាព្យ**

សម្ដីប្រិយប្រាយ ស្ដាប់ពីចម្ងាយ ដូចសូររគាំង
ពីរោះចាប់ចិត្ត ស្អិតជាប់ភ័ន្តភាំង ពុំអាចនឹងតាំង
ចិត្តឱ្យនឹងបាន។

**ប្រីស្ន** *ន.* (**សំ.**) ខ្ទង :

**ពាក្យកាព្យ**

ព្រះប្រឹស្នរាងឋាំ ព្រះកាយសក្តិសម ជាមេទ័ពជាតិ
ទ្រង់មានសំភី ពុំដែលឃ្លៀងឃ្លាត ជាទង់ជ័យជាតិ
ឥតក្សត្រណាប្រៀប។

**ប្រុះ** ***កុ.*** ឬ ***កិ. វិ.*** ព្រោងព្រាយ, ដែលភ្លឺចម្រុះគ្នា :

**ពាក្យកាព្យ**

សេពគប់ប្រាជ្ញប្រុះ ប្រាជ្ញនាំឱ្យឆ្ពុះ ឃើញក្តីខុសត្រូវ
សេពគប់ជនពាល វែងវាលខុសផ្លូវ នាំឱ្យអាស្រូវ
បង់កេរ្តិ៍បង់ឈ្មោះ។

**ប្រើ** ***កិ.*** បង្គាប់, បង្គាប់ឱ្យធ្វើតាម; ប្រកបកិច្ចតាមត្រូវការ; ចាយវាយ; ធ្វើឱ្យជួយកម្លាំង :

**ពាក្យកាព្យ**

ប្រើថ្លឹងឱ្យស្មើ ទោះបីនឹងប្រើ ប្រើអ្នកចេះក្តី
កុំយកពាក្យស្ពោក ផ្ទឹមនឹងគម្ពីរ កុំយកពាក្យជី
ផ្ទឹមនឹងពាក្យពាល។

**ប្រើទំលែងខ្ពស់** ***កិ.*** កុំអាលប្រញាប់អង្គុយលើទីខ្ពស់ មុនគេអញ្ជើញ :

**ពាក្យកាព្យ**

កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្កម៍ កុំទុកចិត្តអភិប្រាយ
ប្រើទំលែងខ្ពស់ រំពឹងឱ្យឆ្ងាយ ស្តាប់ពាក្យបរិយាយ

បណ្ដាំមេជី។...

**ប្រះ** ***កិ.*** ផ្អៀងខ្លួនដេក, រំលំខ្លួនដេក, ផ្ដួលខ្លួនដេក :

**ពាក្យកាព្យ**

យំសោកប្រះប្រាណ ដួលដូចគេច្រាន ព្រោះក្ដីអាល័យ
ជ្រុលជ្រប់ស៊ប់ពេក សង្រេងសង្រៃ ទាំងយប់ទាំងថ្ងៃ
ភ្លេចបាយភ្លេចទឹក។

**ផល់ស្នា** ***ន.*** ស្នា :

**ពាក្យកាព្យ**

លើកដាក់តាមកម្លាំង កុំនើចខ្លាំងឈើផល់ស្នា ប្រើគេប្រើឱ្យត្រា
ប្រណីគេដោយចៅហ្វាយ។

**ផុយផាយ** ***គុ.*** ដែលកញ្ជ្រះកញ្ជ្រាយ, ចាយវាយឥតសណ្ដាប់; សើរើ :

**ពាក្យកាព្យ**

អ្នកបួសឥតក្រឹត្យ ចាស់ឥតប្រព្រឹត្ត ចាស់ឥតប្រព្រឹត្ត
ខ្សត់ច្រើនប្រមាទ
ភរិយាផុយផាយ ចាយវាយឥតខ្នាត ពលពាលសុទ្ធសាធ
ប្រដៅក្របាន។

**ផៅ** ***ន.*** ត្រកូល, ពូជ, វង្ស, អម្បូរ :

**ពាក្យកាព្យ**

ធ្វើស្រែមើលស្មៅ សន្ដានមើលផៅ បម្រើមើលពុត

ទោះដឹងពុតជា　　ពុំចេរពុតត្បុត　　ដឹងចិត្តបរិសុទ្ធ
ពុំចេរឥរិយា។

**ផ្កាត្រែង** *៩.* ឈ្មោះរលកទឹកដែលបោកបែកសស្វាចមើលទៅឃើញហាក់ដូចជាផ្កាត្រែង :

**ពាក្យភាព្យ**

ឈរក្បែរសាគរ　　រលកឈ្ងូឆរ　　បោកបែកផ្កាត្រែង
ស្រាប់តែនឹកភ្នក　　ដល់រូបប្រាណឯង　　អន្ទោលខ្វាត់ខ្វែង
កើតស្លាប់រាល់ជាតិ។

**ផ្កាប់** *១០.* ដាក់ត្រលប់មុខចុះក្រោម, ដាក់ត្រលប់បាតចុះក្រោម, ដាក់ត្រលប់ពោះចុះក្រោម :

**ពាក្យភាព្យ**

កុំស៊ុកគ្រលុក　　កុំជឿផ្កាប់មុខ　　ដោយឥតបើគិត
បំណាច់នឹងជឿ　　ជឿដោយគំនិត　　ដែលមានការណ៍ពិត
តាមធម៌តាមច្បាប់។

ស្រលាញ់ផ្កាប់មុខ　　ច្រើនតែមានទុក្ខ　　ផ្តល់ឱ្យឈឺចាប់
សង្រេងសង្រៃ　　ពេកក្រៃស្មើរស្លាប់　　ព្រោះត្រូវចំណាប់
នៃក្តីស្នេហា។

**ផ្លេកផ្លោះ** *កិ. វិ.* ដែលហោះដោយមានអាការៈលឿនភ្លែតភ្លឺផ្លេកផ្លោះរំលង ឈើខ្ពស់និងភ្នំ :

**ពាក្យកាព្យ**

ស្ដេចហោះផ្លេកផ្លោះច្រឲ្យព្រៃ ខ្ពង់ខ្ពស់ពេកក្រៃ ក្បត្រថ្លៃពុំមានផ្លឹកឡើយៗ

**ផ្សា** *អា. និ.* (ព. បុ.) ព្រោះ, ហេតុតែ, ដោយហេតុ; តាមតែ, តាមតែចង់, ព្រោះតែចំណង់ :

**ពាក្យកាព្យ**

លោកថាស្រីនោះ ចិត្តអាក្រក់ស្មោះ ស្អប់ដំបូន្មាន

ផ្សាដោយសារចិត្ត ទុច្ចរិតសន្ដាន បង្ខិនធនធាន

ចើកអាសមាយា។

**ផ្សូរផ្សូង** *កិ.* ឬ *កិ. វិ.* ឆេវង់, បង្អែបង្អង់, រ៉ែរ៉ : 

**ពាក្យកាព្យ**

ហៃប្អូនកែវពន្លក ចេញឆាប់មកកុំផ្សូរផ្សូង កុំឱ្យខុសបំណង

របស់បងមកពីនាយ។

**ផ្អុក** *កិ.* ភ្ញាក់ដល់, ភ្ញាក់គិតដល់, ភ្ញាក់នឹក :

**ពាក្យកាព្យ**

មានចិត្តផ្អុកផ្អឹះ តានតឹងទង្គឹះ រសាប់រសល់

ព្រោះតែភ្ញាក់នឹក រលឹកទៅដល់ បិតាទុព៌ល

មានគុណធ្ងន់ក្រៃ។

**ព័ចន៍** *ន.* (**សំ. បា. វចន**) ពាក្យ, សម្ដី :

**ពាក្យកាព្យ**

កុំឱ្យមានឆ្គង មោះហ្មងត្រង់ណា ទើបលោកហៅថា

អ្នកមានមារយាទ។

**ពណ្ណរាយ** *គុ.* (**បា. វណ្ណ** «ពណ៌, សម្បុរ, វ > ព និងខ្មែរ **រាយ**») ដែលធ្វើពណ៌សម្បុរឱ្យរាយគឺដែលភ្លឺត្រចះ, ដែលមានពន្លឺរស្មីរុងរឿងចាំងព្រោងព្រាយ; ភ្លឺថ្លា; ល្អប្រពៃ :

**ពាក្យកាព្យ**

កាលនោះព្រះយមពណ្ណរាយ លើសលែងសព្វសាយ ស្ដេចបើកព្រះនេត្រយល់ជាក់..ៗ

**ពនេចរ** *ន.* (**សំ. បា. វនេចរ, វនចរ**) អ្នកត្រាច់ទៅក្នុងព្រៃ (ព្រានព្រៃ) :

**ពាក្យកាព្យ**

គ្រានោះពនេចរ មានអំណរពន់ពេកក្រៃ រិះរកឧបាយឆ្មៃ

បាញ់ដំរីឱ្យបានងាយ។

**ពន្លាម** *គុ.* ឬ *កិ. វិ.* ដែលចាំងរស្មីវែងៗ ភ្លែតៗ រឿយៗ, ដែលបាញ់រស្មីវែងៗ ភ្លែតៗ រឿយៗ :

**ពាក្យកាព្យ**

ស្ទុះចូលឥតមានទីទាម ងាងាវគំរាម ពន្លាមលលាមឥតភ្លឹក។

**ពលកាយ** ឬ **ពលនិកាយ** *ន.* (**សំ. បា.**) ពួកពល, ពួករេហ៍ពល, ពួកសេនាទាហាន :

**ពាក្យភាព្យ**

ពលកាយរត់ខ្ចាយបែកខ្ញែកគ្នា ព្រោះខ្លាចឫទ្ធានុភាពខ្លាំង នៃបច្ចាមិត្តគូប្រឆាំង តតាំងច្បាំងគ្នាយូរខែហើយ ។

**ពហុកិច្ច** *ន.* (បា.) កិច្ចច្រើន, ការរវល់ច្រើន :

**ពហុកិច្ច** *គុ.* (បា.) ដែលមានកិច្ចច្រើន, ដែលមានរវល់ច្រើន; បើស្ត្រីជា **ពហុកិច្ចា** :

**ពាក្យភាព្យ**

ពហុកិច្ចខ្ញុំ វាចោមរោមរុំ ទៅណាពុំកើត
នេះហើយនុះផង រនោចដូចខ្មើត សស្លក់សស្លើត
ឥតពេលសម្រាក ។

**ពាជី** *ន.* (បា. **វាជី**) សេះ (ឈ្មោល) :

**ពាជិនី** *ន.* (សំ. បា. **វាជិនី**) សេះញី, មេសេះ :

**ពាក្យភាព្យ**

ពាជីពាជិនី សត្វទាំងទ្វីរហ័សក្រៃ លឿនឆ្លៃតហួសវិស័យ
ប្រោលមួយថ្ងៃបានច្រើនយោជន៍ ។

**ពាឌីរ** *ន.* (សំ.) កម្មករ គឺអ្នកធ្វើការឈ្នួល, កូនឈ្នួល :

**ពាក្យភាព្យ**

រីពួកពាឌីរ ធ្វើការដោយវី- រិយៈពេកពន់
ឥតមានពាឌីរ ណាមួយទម្រន់ សុទ្ធតែពួកជន

យកចិត្តទុកដាក់។

**ពានស្ពាន** *កិ.* ពានលើដំណើរស្ពានការ :

**ពាក្យកាព្យ**

កុំនៅញ៉ាំងល្ហោះ	កុំស្តាប់អសុរោះ	កុំស្តាប់អាស្រូវ
កុំដើរពានស្ពាន	កុំស្កាត់ច្រកផ្លូវ	កុំធ្វើស្រែស្រូវ
នៅផ្លូវដំរី។

**ពាន់នេត្រ** *ន.* ព្រះឥន្ទ :

**ពាក្យកាព្យ**

គ្រានោះព្រះពាន់នេត្រ	ទ្រង់ប្លែងភេទជាប្រើសមាស	ស្ទុះប្ញោលបែបទីសទាស
ងងាសងើយងាកឆ្វេងស្តាំ។

**ពិជ័យ** ឬ **វិជ័យ** *ន.* (**សំ.បា. វិជយ**) ការឈ្នះវិសេស, ដំណើរឈ្នះស្រេចបាច់ :

**ពាក្យកាព្យ**

កងទ័ពយើងមានពិជ័យ	ព្រោះមានតេជដៃ	ប្រល័យខ្មាំងឱ្យវិនាស។

**ពិជេដ្ឋ** *គុ.* (**បា. វិ + ជេដ្ឋ**) ដែលប្រសើរបំផុត, ដែលចម្រើនបំផុត, ដែលជាចម្បង :

**ពាក្យកាព្យ**

ក្សត្រក្សាន្តពិជេដ្ឋ	ទ្រង់ស្ទង់មើលហេតុ	ដំណើរក្នុងរដ្ឋ
ទ្រង់ជ្រាបថាការណ៍	នេះកើតប្រាកដ	អំពីជនក្បត់
ឧទ្ទាមព្រៃផ្សៃ។

**ពិដោរ** *គុ.* ដែលមានក្លិនក្រអូបល្អ, ដែលក្រអូបសាយ :

**ពាក្យកាព្យ**

ពិដោរផ្កាបី ពិដោរមេត្រី ស្តួស្តីសីលាចារ
ពិដោរបរិសុទ្ធ កុសលសម្ភារ ពិដោរនេះដាល
ដល់សួគ៌ពុំស្បើយ។

**ពិត** *និ.* ឬ *គុ.* មែន, ប្រាកដ, ទៀង :

**ពាក្យកាព្យ**

ពាក្យពិតការណ៍ពិត កាលបើពិនិត្យ ឃើញពិតសត្យា
គួរកាន់ប្រព្រឹត្ត តាមពិតហៅមហា- ប្រសើរថ្លៃថ្លា
មានផលតាមពិត។

**ពិទគ្ធ** *គុ.* (**សំ. វិទគ្ធ**) ឈ្លាស, វាងវៃ, ប៉ិន, ប្រសប់; ដែលមានចំណេះ :

**ពាក្យកាព្យ**

មេទ័ពពិទគ្ធ យល់កិច្ចកលជាក់ បញ្ឆោតពួកខ្មាំង
ឱ្យរុកចូលមក ប្រយុទ្ធតតាំង ទើបប្រើកម្លាំង
វាយខ្មាំងខ្ចាយខ្ចាត។

**ពិន** *ន.* ស្មៀតសក់ជុក។ កំពូល, អ្នកដែលជាកំពូល, អ្នកដែលជាឆ្នើម, អ្នកដែលចម្បងលើគេ :

**ពាក្យកាព្យ**

វីព្រះនរិន្ទ្ទ នារាយណ៍ចមពិន ទ្រង់ព្រះចិន្តា

ប្រាប់ពួលដល់ទាន    ទើបទ្រង់ត្រាស់ថា    ឱ្យអស់អមច្ចា
ចូលមកជួបជុំ។

**ពិនិស្ច័យ** *ឲ.* (សំ. **ວនិស្ចយ**) ពាក្យសម្រាប់ប្រើចំពោះតែក្នុងកាព្យផ្ទួនជាមួយនឹងពាក្យ **ពិនិត្យ** :

**ពាក្យភាព្យ**

យល់តូចកុំអាលខំ    ខោះយល់ធំកុំអាលស្រាយ    គិតក្ដីកុំគិតងាយ
មើលពិនិត្យពិនិស្ច័យៗ

**ពិមល** ឬ **វិមល** *គុ.* (សំ. បា. **វិមល**) ដែលឥតមន្ទិល, ដែលឥតសៅហ្មង; ស្អាត, ថ្លា, ស្រស់បំព្រង :

**ពាក្យភាព្យ**

ហៃប្អូនពិមល    ពីមុននាងយល់    ដូចម្ដេចបានជា
ផ្ដាំថាឱ្យបង    មករកពុំងា    នឹងបានជាគ្នា
តរៀងទៅមុខ។

**ពិលាប** *ន.* (សំ. បា. **វិលាប**) សេចក្ដីខ្សឹកខ្សួលរៀបរាប់, ដំណើរយំបូរបាច់ឮខ្លាំងៗដោយស្ដាយអាល័យឬដោយកើតទុក្ខតូចចិត្តណាស់ :

**ពាក្យភាព្យ**

បងាចារា    ពិលាបទួញថា    ប្ដីស្លាប់កូនស្លាប់
អាពុកនិងម្ដាយ    ឯនាយក៏ស្លាប់    តើឱ្យខ្ញុំស្លាប់
តាមដែរឬទេ?

**ពិលាស** ឬ **វិលាស** *ន.* (**សំ. បា. វិលាស**) លំនាំលីលា, លំនាំកែក្រាយ, លំនាំញ៉ែងញ៉ង, លំនាំល្អាយល្អង :

**ពាក្យកាព្យ**

ក្សត្រីយាងយាស ដោយនូវពិលាស កែក្រាយសមរម្យ
ដំណើរដំរី ជាញជ័យនិយម គួរចាប់អារម្មណ៍
ឆ្ពោះកាយវិការ។

**ពិសម័យ** *ន.* (**សំ. វិស្មយ; បា. វិម្ហយ**) សេចក្តីអស្ចារ្យ, ហេតុដែលគួរឱ្យលាន់មាត់ស្ងើច; សេចក្តីរីករាយ; តម្រេក; សេចក្តីស្រលាញ់, ស្នេហា :
**ពិសម័យ** *គុ.* (**សំ. វិស្មយ; បា. វិម្ហយ**) គួរឱ្យស្រលាញ់, គួរឱ្យស្ងើច, គួរឱ្យជាប់ចិត្តភ្លេចខ្លួន :

**ពាក្យកាព្យ**

ឱកែវពិស្ម័យ បងនឹកអាល័យ ប្អូនរាល់វេលា
ចុះហេតុដូចម្តេច ក៏មាសស្ងួនភ្ងា ពុំចេញវាចា
មួយមាត់មករក?

**ពិសា** ឬ **ពីសា** *កិ.* បរិភោគ (ស៊ី); ពាក្យគួរសមសម្រាប់គ្រហស្ថឬបព្វជិតនិយាយទៅរកគ្រហស្ថដែលគួរគោរព :

**ពាក្យកាព្យ**

ពិសាផ្លែប្រាំ ពិសារសធម្ម ពិសាសត្យា
ពិសាសីលទាន ទ្រើសទ្រង់ករុណា ពិសារសវា-

ចាចេញមធូរ។

**ពុតញ្ញាយ** *កិ.* ពុតខូចវៀចវេរចចេសរបិញរបុញ :

**ពាក្យកាព្យ**

ពុតញ្ញាយមានបី មួយដូចដំរី សាហាវឥតបទ
អាចផ្ទុះផ្ទាំងបាន កង្វេរកាន់កត់ ដាលដេញគោតគត់
ប្រាំមួយហត្ថហោង...។

**ពុទ្ធិព្រឹទ្ធ** *ន.* ឬ *គុ.* សេចក្ដីចម្រើនប្រាជ្ញា, សេចក្ដីចម្រើនការយល់។ អ្នកដែលចម្រើនដោយការយល់; បើស្ត្រីជា **ពុទ្ធិព្រឹទ្ធា** :

**ពាក្យកាព្យ**

អ្នកពុទ្ធិព្រឹទ្ធ ដែលមានគំនិត ប្រសើរថ្លៃថ្លា
បើជាឥត្ថី ពុទ្ធិព្រឹទ្ធា មានភាពដូចគ្នា
រក្សាក្ដីសុខ។

**ពើប** *កិ.* ប្រទះ, ចួបដោយឥតស្វែងរក, ចួបដោយឥតមានបំណង :

**ពាក្យកាព្យ**

ខំដើររលះ ស្រាប់តែពើបពះ ប្រទះពួកខ្មាំង
ដឹងថាសត្រូវ ទើបស្ទូតតាំង ប្រយុទ្ធប្រឆាំង
ខ្លាំងក្រៃឥតភ្លឹក។

**ពៀរ** *ន.* ចំណងចិត្តក្រោធដែលចងដោយព្យាបាទបម្រុងនឹងសងសឹកវិញ, ចំណងចិត្តជាសត្រូវ :

**ពាក្យភាព្យ**

ទីយាវុកុមារ មានវិចារណ៍ចៀសពៀរបាន ទើបមានសុខក្សេមក្សាន្ត
បានសោយរាជ្យគ្រងរដ្ឋពីរ។

**ពៃរី** *ន.* (**សំ. ភ្ល.**) អ្នកមានពៀរ, អ្នកចងពៀរ; បច្ចាមិត្ត, សត្រូវ :

**ពាក្យភាព្យ**

យោធាផតគរានឹងពៃរី ប្រយុទ្ធរកីរិយ៉ាងអង់អាច ធ្វើឱ្យសត្រូវបាក់ខ្លបខ្លាច
ថយរត់ប្រសាចលែងងាកក្រោយ។

**ពុំខា** *គុ.* ស្ងួនភ្ងា; ប្រសើរ, ថ្លៃថ្លា, ឆើតឆាយ :

**ពាក្យភាព្យ**

ហៃប្អូនមាសពុំងា បងសូមលាកែវពិសី ត្រលប់ទៅបុរី
សូមប្អូនស្រីនាងកុំឃាត់។

**ពុំចេរ** *និ.* (ព. បុ.) សូមឱ្យតែ, តាមតែ :

**ពាក្យភាព្យ**

ខ្ញុំសូមក្រាបលាទៅ ផ្ញើរាជ្យនៅក្សត្រថ្លៃថ្លា ពុំចេរទ្រង់មេត្តា
អត់ទោសប្រោសសត្វជាខ្ញុំ។

**ពុំចេរ** *និ.* (ព. បុ.) ថាពុំដឹង, ថាពុំចេះ, ថាពុំស្គាល់ :

**ពាក្យភាព្យ**

ប្រើដឹងតុលហាប ប្រើដឹងខ្ពស់ទាប មានភ្នែកយល់ល្អ
ទោះដឹងទឹកមាស ពុំចេរនូវថ្ម ទោះដឹងដី-ស

ពុំចេរសំបុត្រ។

ធ្វើស្រែមើលស្មៅ សន្ដានមើលផៅ បម្រើមើលពុត

ទោះដឹងពុតជា ពុំចេរពុតត្បុត ដឹងចិត្តបរិសុទ្ធ

ពុំចេរឥរិយា។

**ពំនោល** *ន.* ដំណើរដែលពោល, ពាក្យពោល; បទពោលល្ខោន។ ឈ្មោះកាព្យមួយយ៉ាង មានជើងបី គឺក្នុងមួយរបះមានឃ្លាបី, មានចួនបី, ឃ្លាទី១ និងទី៣ មាន៦ពាក្យ, ឃ្លាទី២ មាន៤ពាក្យ :

**ពាក្យភាព្យ**

យក្សក្រោធច្រឡោតខ្លាំងក្រៃ ស្ទុះហោះច្រៀវច្រៃ ពួតដៃកំញើញគួរស្ញែង។

ស្រែកហ៊ោសន្ធាប់ឥតក្រែង ថារុឺយប្រស្ដែង ម្ដេចឯងពុំកោតចេស្ដា។

**ពះ !** *ឧ.* ពាក្យស្រែកសន្ធាប់ដោយភ្ញាក់ ព្រោះបានពើបប្រទះខ្មាំងសត្រូវ, ចោរកំណាចឬមនុស្សដែលមានទោសគេចពួនឬក៏ពើបប្រទះសត្វសាហាវ; ពុំនោះស្រែកគំរាមឱ្យគេស្ទុតស្ទន់ :

**ពាក្យភាព្យ**

យមបាលក្រេវក្រោធសោះសា ទះមាត់ហើយថា ពះវាស្រីបាបអប្រិយ។

កាលដើមហាងមិនស្រដី លុះយល់អគ្គី មឹងថាចឹវរកូនឯង។

**ព្នល** *ន.* ឈ្មោះឈើមួយពួកសន្ដានញ្ចៅ មានច្រើនបែបខ្លះមានផ្លែតូចៗខ្លះមានផ្លែធំៗ :

**ពាក្យកាព្យ**

ផ្តិលផ្ចៅបង្គោលលាំងសាត  មានដើមភ្លូបាត  ដុះលាយរៀងគ្នា។

**ព្យត្តវោហារ** *ន.* (**បា.**) សម្ដីឈ្លាស; មនុស្សមានសម្ដីឈ្លាស, អ្នកឈ្លាសសម្ដី :

**ពាក្យកាព្យ**

លោកសាស្ត្រាចារ្យ  ព្យត្តវោហារ  ថ្លែងការណ៍ក្បោះក្បាយ
អស់ពួកនិស្សិត  មានចិត្តរីករាយ  រអាករពាយ
ប្រាស្រ័យរកគ្នា។

**ព្យសន៍** *ន.* (**បា. ព្យសន**) ទុក្ខ; អំពើអាក្រក់; សេចក្ដីវិនាស; ពុតត្បុត, ពុតកំណាច :

**ពាក្យកាព្យ**

ជនមានពុតព្យសន៍  តែងតែរំលស់  នូវសុខសួស្ដី
នៅក្នុងទីណា  ទីនោះអប្រិយ  នាំឱ្យមានក្ដី
ព្រួយខ្វល់ជានិច្ច។

**ព្យាក្រឹត** *ន.* (**សំ.**) ការពន្យល់, ការបំភ្លឺសេចក្ដី, ការអធិប្បាយបញ្ជាក់សេចក្ដីឱ្យភ្លឺច្បាស់, ដំណើរខែសេចក្ដីឱ្យឃើញជាក់ច្បាស់ :

**ពាក្យកាព្យ**

ការណ៍នេះជ្រៅណាស់  ខ្ញុំបានយល់ច្បាស់  ដោយសារព្យាក្រឹតិ
ដែលលោកណែនាំ  ដោយក្ដីអាណិត  ព្រោះលោកមានចិត្ត

កបដោយមេត្តា។

**ព្យាបន** *ន.* (បា.) មរណៈ :

**ពាក្យភាព្យ**

រីឯព្យាបទ តែងមានប្រាកដ ចៀសវាងមិនផុត
ទោះបីទេវតា ទោះបីព្រះពុទ្ធ ដែលទ្រង់បរិសុទ្ធ
ក៏ចៀសពុំរួច។

**ព្យោម ឬ ព្យោមា** *ន.* (សំ. **វ្យោមន**) អាកាស, មេឃ, ទឹកដែលស្ថិតនៅឯអាកាសមិនទាន់ធ្លាក់ចុះមកដល់ :

**ពាក្យភាព្យ**

មានព្យុះព្យោមា រំលើងគ្រឹហា រលំបាក់បែក
វិនាសទ្រព្យធន ពេកពន់អនេក ព្យុះព្យោមចម្លែក
ពុំធ្លាប់ឃើញឡើយ។

**ព្រលឹង** *គុ.* ឬ *ន.* ដែលមានស្រីសួស្តី, ដែលជាទីស្រលាញ់ស្មើជីវិត; អ្នកថ្លៃ, មាសថ្លៃ...:

**ពាក្យភាព្យ**

ស្តេចថាហៃព្រលឹង ចុះប្អូនខឹងអ្វីនឹងបង បើមានក្តីមោះហ្មង
ម្តេចនួនល្អងនាងមិនប្រាប់។

**ព្រហារ័ន** *ន.* (បា. **ព្រហា** «ធំ, ស្តុក, ចម្រើន, មាំមួន» + **វន** «ព្រៃ»> **ព្រហាវន**) ព្រៃធំ, ព្រៃស្តុក, ដងព្រៃធំ :

**ពាក្យកាព្យ**

ប្រើសមាសបោលចូលព្រហារនៃ ប្រាំងខ្លួនបំនាន់ព្រះនេត្រក្សត្រ ចួនកាលឱ្យឃើញចួនកាលបាត់ ពួកពលប្រឹងស្កាត់រកប្រសាច។

**ព្រេខ** ***គុ.*** បុរាណ; ដែលមានក្នុងកាលពីដើម, ដែលជាយូរអង្វែងហើយ :

**ពាក្យកាព្យ**

ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់ ទោសគេតូចសោតសល់ មើលទៅយល់ប៉ុននឹងត្នោ។

**ព្រហ្មគីត** ***ន.*** (**បា. ព្រហ្ម** «ព្រហ្ម» + **គីត** «ចម្រៀង») ឈ្មោះកាព្យមួយយ៉ាងមានជើង៤ គឺក្នុងមួយរបះមាន៤ឃ្លា, ត្រង់ឃ្លាទី១និងទី៣មាន៥ពាក្យ, ឃ្លាទី២និងទី៤មាន៦ពាក្យ :

**ពាក្យកាព្យ**

អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនិងសំប៉ាន។

**ភមរី** ***ន.*** (**បា.**) មេកន្លង់, មេឃ្មុំ គឺកន្លង់ញី, ឃ្មុំញី :

**ពាក្យកាព្យ**

ភមរភមរី ហើរពាសពេញទី សួនច្បារក្បែរឋាន
ប្រាសាទបវរ ត្រឹបកេសរស៊ាន ក្សត្រាទ្រង់មាន
ព្រះទ័យក្សេមក្សាន្ត។

**ភយន្តរាយ** *ន.* (បា. < **ភយ** + **អន្តរាយ**) អន្តរាយដែលគួរឱ្យខ្លាច, អន្តរាយយ៉ាងសម្បើម :

**ពាក្យភាព្យ**

ភយន្តរាយ អ្នកប្រាជ្ញទាំងឡាយ លោកពោលប្រាប់ថា
កើតមានព្រោះកម្ម អំពើពាលា បណ្ដាលឱ្យជា
ក្ដីទុក្ខលំបាក។

**ភយូបទ្រព** *ន.* (សំ. **ភយ** + **ឧបទ្រវ**) ឧបទ្រពដែលគួរឱ្យខ្លាច, ចង្រៃយ៉ាងសម្បើម :

**ពាក្យភាព្យ**

ភយូបទ្រព ចេញពីប្រភព នៃជនពាលា
កំពុងសុខៗ វានាំក្ដីគ្នា បង្កើតឱ្យជា
ភយន្តរាយ។

**ភយូបសគ្គ** *ន.* (បា. **ភយ** + **ឧបសគ្គ**) ឧបសគ្គដែលគួរខ្លាច, សេចក្ដីទើសទាក់យ៉ាងសម្បើម :

**ពាក្យភាព្យ**

ភយូបសគ្គ កើតមានតាមថ្នាក់ កម្មកាចចេញមុខ
ចេញផ្ដល់ឱ្យផល ជូរចត់ជាទុក្ខ អ្នកចង់បានសុខ
គួរកុំប្រមាទ។

**ភរ** *កិ.* ពោលពាក្យមិនពិត, ពោលពាក្យកុហក :

**ភរ** *គុ.* ឬ *កិ. វិ.* ដែលមិនពិត, ដែលកុហក :

**ពាក្យកាព្យ**

មនុស្សមេភរ ចេះតែកម្ភរ ភរឱ្យគេស្ដាប់
ភរទៅភរទៅ ត្រូវលង់ចំណាប់ អ្នកផងគេចាប់-
ថ្នាក់ព្រោះតែភរ។

**ភរិយា** *ន.* (បា.) ស្ត្រីដែលស្វាមីត្រូវចិញ្ចឹម (ប្រពន្ធ) :

**ពាក្យកាព្យ**

ខ្ពង់ហើរដ្បិតខ្យល់ នាយកើនដ្បិតពល រក្សាឱ្យសុខ
ទ្រព្យគង់ដ្បិតស្រី ចេះសំចៃទុក ផ្ទះធំស្រណុក
ដ្បិតភរិយាជា។

**ភរិយាជ** *ន.* (សំ. ភ្ល.; សំ. **ភាយ៌ាជ**) បុរសដែលព្រមឱ្យភរិយារបស់ខ្លួនស្វែងរកប្រយោជន៍ដោយបែបបទជាស្រីពេស្យា, មនុស្សអ្នកបណ្ដោយប្រពន្ធឱ្យធ្វើជាស្រីផ្កាមាស :

**ពាក្យកាព្យ**

នែអ្នកភរិយាជ ចូរខំខ្មីឃ្មាត បំពេញមុខការ
ចូរកុំរវាត ចាកសីលាចារ ធ្វើស្រែចម្ការ
លក់ដូរវិញទៅ !

**ភរិយាជិក** *ន.* (សំ. ភ្ល.; សំ. **ភាយ៌ាជិក**) បុរសអ្នកលុះក្នុងអំណាចភរិយា, មនុស្សអ្នកខ្លាចប្រពន្ធ គឺមនុស្សដែលប្រពន្ធត្រួតត្រាហៃហៃលើជានិច្ច :

**ពាក្យកាព្យ**

ហៃភរិយាដិក ចូរមានសំណឹក នឹកឃើញខ្លះទៅ
សមចរិយា ជាធម៌ឥតសៅ ទោះប្រាជ្ញទោះខ្លៅ
តែងកាន់រក្សា។

**ភរិយាតិក្រម** *ន.* (សំ. ភ្ល.; សំ. **ភាយ៌ាតិក្រម**) ការប្រព្រឹត្តកន្លងចិត្តភរិយា, ការក្បត់ចិត្តប្រពន្ធ :

**ពាក្យកាព្យ**

ភរិយាតិក្រម ជាកម្មច្រឡំ ច្រលូកដោយបាប
អ្នកធ្វើអំពើ អរភ័យដរាប អរព្រោះតែច្រាប
ភ័យព្រោះគេដឹង។

**ភុជង្គលីលា** *ន.* ឈ្មោះកាព្យមួយប្រភេទក្នុងមួយឃ្លាមានសង្កាត់បី, ត្រង់សង្កាត់ទី១មាន៦ពាក្យ, សង្កាត់ទី២និងទី៣មាន៤ពាក្យ ហៅថា**បទភុជង្គ-លីលា** :

**ពាក្យកាព្យ**

ព្រឹងព្រួសជន្លួសន្ធ្លូង ក្រូចព្រៃអង្រ្គង ដុះដាសលាយគ្នា។

**ភូធន** *ន.* (សំ. បា.) អ្នកដែលមានផែនដីជាទ្រព្យ, អ្នកដែលមានទ្រព្យពេញផែនដី (ព្រះរាជា) :

**ពាក្យកាព្យ**

ព្រះបាទសម្តេចព្រះភូធន ស្តេចទ្រង់និពន្ធកាព្យនានា ទូន្មានប្រដៅរាស្ត្រប្រជា

គឺអង្គក្សត្រាព្រះហរិក្សៗ

**ភូធរ** *ន.* (សំ. បា.) អ្នកទ្រទ្រង់នៅលើផែនដី (ភ្នំ)។ អ្នកទ្រទ្រង់ផែនដី (ព្រះរាជា) :

**ពាក្យកាព្យ**

| | | |
|---|---|---|
| ប្រាសាទបវរ | សង់ថ្វាយភូធរ | ព្រះភូធរគង់ |
| ជាសុខសម្រាន្ត | ក្សេមក្សាន្តអភិម- | ង្គលកបឫទ្ធិរុង |
| | រឿងតេជះជ័យ។ | |

**ភូបាល** *ន.* (សំ. បា.) អ្នកគ្រប់គ្រងរក្សាផែនដី (ព្រះរាជា) :

**ពាក្យកាព្យ**

| | | |
|---|---|---|
| សូមព្រះភូបាល | ស្ដេចទ្រង់ក្រសាល | រំហែព្រះទ័យ |
| រីដងព្រៃនេះ | ជាទីនិរភ័យ | សូមព្រះភូវន័យ |
| | ទ្រង់ព្រះកម្សាន្ត។ | |

**ភោគ្គា** *កិ.* បរិភោគហើយ, ស៊ីផឹកហើយ; ប៉ុន្តែដែលពួកកវីខ្មែរយើងធ្លាប់តែប្រើក្នុងពាក្យកាព្យរៀងមកសំដៅសេចក្ដីថា **បរិភោគហើយ** ក៏បាន, ថា **នឹងបរិភោគ** ក៏បាន :

**ពាក្យកាព្យ**

| | | |
|---|---|---|
| ភានអើយអញឃ្លាន | តើបាយនៅមាន | សល់ក្ដាំងខ្លះទេ |
| ឱ្យអញភោគ្គា | សម្រន់កាយេ | សោះពោះទទេ |
| | អញឃ្លានណាស់ភាន។ | |

**ធ្វាប្រិយ** *គុ.* ដែលគួរស្រលាញ់, ដែលគួរថ្នាក់ថ្នម, ពុំងា, ស្ងួនភ្ងា :

**ពាក្យភាព្យ**

ហៃប្អូនភ្ងាប្រិយ ម្ដេចពុំស្រដី ខឹងអ្វីនឹងបង
បើមានគ្នាន់ចិត្ត មាសមិត្តកុំចង ចូរស្រាយចំណង
កំហឹងនោះចេញ...។

**ភ្រឹតក** *ន.* (**សំ.**) អ្នកធ្វើការឈ្នួល, កូនឈ្នួល; អ្នកបម្រើ, កម្មករ :

**ពាក្យភាព្យ**

ខ្ញុំជាភ្រឹតក ពុំដែលលួចឆក់ ទ្រព្យធនជនណា
ម្ដេចក៏លោកមក ប្រកាន់ខ្ញុំថា ជាចោរពាលា
ដូច្នេះទៅវិញ?

**ភ្លាខ** *និ.* ភ្លាម; បណ្ដើរ; ជាមួយដែរ; ផង, ផងដែរ :

**ពាក្យភាព្យ**

ថាភ្លាងនាងនាថស្ទុះចេញក្រៅ ព្រះនេត្រក្រឡេកសម្លឹងដាក់ សម្ដែងអាការៈដូចមានអាក់
ថ្នឹងថ្នាក់ព្រះទ័យពុំស្នេហា។

**មករន្ទ** *ន.* (**សំ. បា.**) រសនៃផ្កា, ទឹកដមផ្កា; ទឹកឃ្មុំ :

**ពាក្យភាព្យ**

សម្ដីផ្អែមល្ហែមដូចមករន្ទ អ្នកស្ដាប់តាំងត័ន្តស្លន់គំនិត ភ្លេចខ្លួនទៅពួននៅទីជិត
ព្រោះគិតថាឆ្ងាយពុំកើត។

**មក្ខជន** *ន.* (**បា. មក្ខ + ជន**) ជនដែលលុបគុណគេ, មនុស្សរមិលគុណ :

**ពាក្យកាព្យ**

មក្ខជនខោះនៅក្នុងទីណា ច្រើនតែទេវតាបរាមុខ ឱ្យជននោះបានសេចក្ដីទុក្ខ

ពុំសុខព្រោះខ្លួនរមិលគុណា។

**មច្ឆរី** *ន.* (ឍ.) អ្នកកំណាញ់, មនុស្សកំណាញ់; បើស្ត្រីជា **មច្ឆរិនី** :

**ពាក្យកាព្យ**

រីឯសេដ្ឋី ជាមច្ឆរី ល្បីថាកំណាញ់

ថ្ងៃមួយគាត់នឹក ចង់ស៊ីនំឆ្លាញ់ ព្រោះក្ដីកំណាញ់

ពួនស៊ីក្នុងផ្ទះ។

ព្រះមោគ្គល្លាន ប្រើឫទ្ធិផ្លូវឈាន ដែលមានជ្រៅជ្រះ

ទៅបិណ្ឌបាត ឈរជិតខាងផ្ទះ ឱ្យសេដ្ឋីលះ

ក្ដីទ្រឹស្ដីស្វរបាន។

**មច្ឆានុ** *ន.* ឈ្មោះត្រីញីមួយធំ មានរូបសណ្ឋានភាគខាងលើជាមនុស្សភាគខាងក្រោមជាត្រីនៅក្នុងសមុទ្រ, ជាស្ដេចត្រី មានអាយុវែងណាស់, មានអំណាចបង្គាប់ពួកត្រីធំៗ ក្នុងសមុទ្រឱ្យពាំជញ្ជូនដុំថ្មដែលហនុមានកែនរេហ៍ពលស្វា ឱ្យជញ្ជូនដុំថ្មយកមកពីភ្នំមកបោះទម្លាក់ចងថ្នល់ក្នុងសមុទ្រទៅកាន់កោះលង្កា :

**ពាក្យកាព្យ**

ដងនោះពានរិន្ទហនុមាន ក្រេវក្រោធឥតស្រាកស្រាន្ត ក៏ចាប់នាងមច្ឆានុបាន

យកធ្វើជាប្រពន្ធគូស្នេហា។

**មជ្ជារ** *ន.* (បា.) ឆ្មាឈ្មោល (ប្រើជា **មជ្ជារៈ** ឬ **មជ្ជារោ** ក៏បាន); **មជ្ជារី** ឆ្មាញី, មេឆ្មា :

**ពាក្យភាព្យ**

មជ្ជារមជ្ជារី សត្វទាំងទ្វីមិនដេកយប់ តាំងពីពេលព្រលប់
យប់ចាំផ្ទះថ្ងៃទើបដេក។

**មធុរៈ** ឬ **មធូរ** *គុ.* (**សំ. បា. មធុរ**) ផ្អែម; ពីរោះ; ឆ្ងាញ់ :

**មធុរៈ** ឬ **មធូរ** *ន.* (**សំ. បា. មធុរ**) រសផ្អែម, រសឆ្ងាញ់; សម្តីពីរោះ :

**ពាក្យភាព្យ**

ស្តេចបើកមធូរ ប្រកបដោយសូរ- សព្ទក្រាងក្រអៅ
ឥតមានទ្រគោះ ឥតមោះហ្មងសៅ រួសរាំរចៅរៅ
ឆ្ពោះទៅរាស្ត្រផង។

**មល្លិកា** *ន.* (**បា. សំ.**) ម្លិះរួត :

**ពាក្យភាព្យ**

មល្លិកាជាផ្កាក្រអូបឆ្ងាញ់ គួរឱ្យស្រលាញ់ចង់ដាំដើម ដាំក្នុងសួនច្បារដ៏ល្អផ្អើម
ត្រូវទឹកសន្សើមផ្ការីកស្រស់។

**មហណ្ណព** *ន.* (**បា. មហណ្ណវ** < **មហន្ត** > **មហា** “ធំ”+ **អណ្ណវ** “សមុទ្រ”) សមុទ្រធំ, មហាសមុទ្រ :

## ពាក្យកាព្យ

ស្ដេចហែលកណ្ដាលមហាណ្ណព កន្លងថ្ងៃយប់ច្រើនវេលា ប្រទះហ្វូងត្រីផងនានា
រាជាហែលកាត់ឥតមានខ្លឹក។

**មហិមា** *គុ.* (**សំ. មហិមា**) ដែលមានច្រើន, ដែលច្រើនក្រៃ, ក្រៃកន្លង; ធំសម្បើម, ដែលគួរស្ញើម :

**មហិមា** *ន.* (**សំ. មហិមា**) ភាវៈធំ, ភាវៈទូលាយ :

## ពាក្យកាព្យ

កងពលច្រើនក្រៃមហិមា ឥតមានរួញរា គយាររុកចូលឥតក្រែង។
គ្រអឹតគ្រទឹតឃើញស្ដែង សន្ធាប់គ្នាឯង ឱ្យខ្លាចស្ញប់ស្ញែងរាល់ប្រាណ។
សត្រូវពុំអាចរុញច្រាន តទប់ពុំបាន ក៏រត់ប្រញាយថយក្រោយ។

**មហឹសា** *ន.* (**បា. មហិស ឬ មហឹស**, ពហុ. **មហិសា ឬ មហឹសា**) ក្របីទាំងឡាយ :

**មហឹសី** *ន.* ក្របីញី, មេក្របី :

## ពាក្យកាព្យ

គ្រានោះមហឹសា បានឃើញខ្លានាដងព្រៃ បានប្រាប់មហឹសី
ថានែវ៉ឺខ្លាធំណាស់។

**មហោឃ** *ន.* (**បា. មហា** "ធំ" + **ឱឃ** "អន្លង់; ជំនន់"> **មហោឃ** "អន្លង់ធំ") អន្លង់ធំក្នុងសំសារវដ្ដគឺការអន្ទោលកើតស្លាប់រឿយៗ ដដែលៗនៃសត្វលោក :

**ពាក្យកាព្យ**

សព្វសត្វក្នុងលោក ហែលក្នុងមហោឃ មហាសាគរ

ច្រើនរងតែទុក្ខ វិលវក់វីវរ អ្នកខ្លះសាទរ

ចង់ហែលរកត្រើយ។

**មួយបែបទៀតថា**

ហេតុនោះករី គួរមានមេត្រី រាប់អានភាសា

សម្ដីជាតិយើង តម្កើងសក្ដា ឱ្យពួកខេមរា

មិនចាញ់ប្រៀបគេ !...។

**មាគ៌ា** *ន.* (សំ. **មាគ៌**) ផ្លូវ :

**ពាក្យកាព្យ**

នាងផ្ដាំសុនខា ក្នុងឧរាអួលអន់ក្ដៅ ស្រេចនាងយាត្រាទៅ

តែឯកអង្គដោយមាគ៌ា។

**មាលា** *ន.* (សំ. **បា.**) ផ្កាកម្រង, កម្រងផ្កា, ផ្លូងផ្កា :

**ពាក្យកាព្យ**

វីយាយមាលា និងតាមាល័យ ក្រងផ្ការាល់ថ្ងៃ

ថ្វាយព្រះរាជា ទ្រង់ប្រោសប្រទាន ឱ្យមានទ្រព្យា

ចិញ្ចឹមអាត្មា កបដោយក្ដីសុខ។

**មាលី** *គុ.* ឬ *ន.* (**បា.**) ដែលមានផ្កាកម្រង; អ្នកប្រដាប់ផ្កាកម្រង, អ្នកពាក់ផ្កាកម្រង :

**មាលិនី** *ន.* ស្ត្រីប្រដាប់ផ្កាកម្រង, ស្ត្រីពាក់ផ្កាកម្រង :

**ពាក្យកាព្យ**

រីពួកមាលី និងមាលិនី រួមទីរាំវង់
សស្រោកសស្រាំ ច្រៀងរាំពេនពង់ ជនក្នុងរឿណរង្គ
រីករាយរាល់ប្រាណ។

**មាស** *គុ.* ឬ *ន.* (ព. ប្រ.) ដែលមានលម្អឬមានតម្លៃដូចមាស; អ្នកថ្លៃ; ពាក្យសម្រាប់ហៅដោយសេចក្តីថ្នាក់ថ្នម ទៅរកមនុស្សជាទីស្រលាញ់ ដែលមានអានុភាពស្មើគ្នាឬតូចជាងខ្លួន :

**ពាក្យកាព្យ**

ហៃកូនមាសឪ មាសកុំបិទផ្លូវ ចម្រុងចម្រើន
ត្រូវមាសឪពុក ក្រវើនក្រតើន កុំបាច់ឪក្រើន
រំលឹករឿយៗ។

**មាសម័យ** *គុ.* (បា. **មាស + មយ**) ដែលធ្វើហើយដោយមាស, ដែលយកមាសសុទ្ធធ្វើ :

**ពាក្យកាព្យ**

ហៃកែវមាសម័យ ហេតុម្តេចក៏ថ្លៃ ពុំចេញចរចា
ថាម៉េចថាទៅ នៅស្ងៀមដល់ណា គួរស្តីរួសរ៉ា
ឱ្យរៀមធូរចិត្ត។

**មាសស្ងួន** *ន.* ឈ្មោះចេកមួយប្រភេទ ស្រដៀងនឹងចេកនួន :

**ពាក្យកាព្យ**

ហៃកែវមាសស្ងួន ពេលនេះគាប់ជួន ឱ្យបងមកជួប

យូរឆ្នាំមកហើយ រាប់បានច្រើនខួប ទេវតាឱ្យជួប

ក្នុងថ្ងៃនេះឯង។

**មីរ** ***ន.*** ទូទឹមល្ហប់, ងងឹតល្ហប់ រកកល់ភ្លៀង (ប្រើចំពោះតែមេឃ) :

**ពាក្យកាព្យ**

មេឃមីរស្រទំ មៀងមើលទៅភ្នំ ឃើញសុទ្ធតែអព្ភ

ងងឹតបែកផ្សេង ក្រែងភ្លៀងធ្លាក់ឆាប់ ខំរត់ប្រញាប់

ស្រាប់តែភ្លៀងទាន់។

**មុខរោ** ***ន.*** ឬ ***គ.*** (**សំ. បា. មុខរ**) មាត់រឹង, ដែលមានមាត់រឹង; មនុស្ស មាត់រឹង; បើជាស្ត្រី **មុខរា** :

**ពាក្យកាព្យ**

ប្ដីមុខរោសោគម្រក់ ប្រពន្ធជ្រេងក៏មុខរា ទាំងទ្វីឥតត្រូវនឹងអ្នកណា

ថែមទាំងខ្វស្សាហ៍ឈ្លោះផងទៀត។

**ម៉ុម** ***គ.*** ឬ ***ន.*** ក្រមុំ, នាងក្រមុំ; ពាក្យថ្នមឬទំយើសម្រាប់ហៅស្ត្រីជាទីស្រលាញ់ :

**ពាក្យកាព្យ**

ស្រីម៉ុមចង់សុំអ្វីពីខ្ញុំ បើចង់សុំអ្វីក៏សុំចុះ ចូរកុំសុំតែរបស់នុះ

ព្រោះម៉ុមបានចុះសន្យាហើយ។

**មុសាវាទី** *ន.* ឬ *គុ.* (បា.) អ្នកដែលហៃនិយាយកុហក :

**មុសាវាទិនី** *ន.* ឬ *គុ.* (បា.) ស្ត្រីដែលហៃនិយាយកុហក :

**ពាក្យកាព្យ**

មុសាវាទី កុហកវក់វី ឥតក្រែងឥតល្អែង

មុវាទិនី។

(លុប **សា** ចេញរក្សាកាព្យ ហៅថា **មជ្ឈេលុប** «លុបអក្សរកណ្ដាល»)។

**មូទូ** *គុ.* ដែលមានគំនិតរាក់, ដែលមានគំនិតទាល, ដែលមិនឈ្លាស; តូវម៉ូវ, តូវមម៉ូវ, កញ្ចប់កញ្ចូវ :

**ពាក្យកាព្យ**

នាបីហៅគ្រូ កុំធ្វើមូទូ ចិត្តនោះឱ្យស្លូន

កុំធ្វើតម្កើង ចង់ធំតែខ្លួន ក្រែងបាបមកចួន

នៅនាលោកិយ។

**មួន** *គុ.* ឬ *កិ. វិ.* មាំ, ខ្ជាប់, រឹងប៉ឹង :

**ពាក្យកាព្យ**

រូបរាងមួនមាំ ទាស់តែមិនទ្រាំ ធ្វើការរបរ

បានតែខាងខ្ជិល ខិលខាងត្រាច់ចរ រីករាយត្រេកអរ

ឆ្ពោះការច្រៀងរាំ។

**ម៉ែនមាន** *និ.* ផ្សំ :

**មែនមាន** *កិ.* មានមែន, មានពិតមែន :

**ពាក្យកាព្យ**

កាលណោះមែនមានព្រានព្រៃ យោរយៅពេកក្រៃ អាស្រ័យនៅជិតជើងភ្នំៗ

**ម្នូម** *ន.* តិណជាតិមួយពួកដុះក្នុងទឹករាក់ឬនៅដីសើមតាមទំនាបឬវាលស្រែ ដោយអន្ទើៗ, មានក្លិនហាងឆ្អួលលាយក្រអូបបន្តិចៗ, ផ្កាសម្បុរស្វាយ, ប្រើជាគ្រឿងបង់សម្ពម្ផ្ទរបែបខ្លះ, ប្រើបានទាំងស្រស់ទាំងក្រៀម, ដែលនៅស្រស់ប្រើជាអន្លក់ក៏បាន :

**ពាក្យកាព្យ**

សម្ពបង់ម្នូម អ្នកដែលមិនតម គេច្រើនរាប់អាន
កាលដល់រដូវ ពុំសូវដែលខាន ដួសពីរបីចាន
ពុំខានទាវទៀត។

**យថាកាម** *កិ. វិ.* (សំ. បា.) តាមប្រាថ្នា, តាមចំណង់ :

**ពាក្យកាព្យ**

នេះគឺបម្រាម កុំឱ្យធ្វើតាម យថាកាមខ្លួន
អ្នកណាបំពាន នឹងមានទោសធ្ងន់ រាជការមិនស្ងួន
ប្រណីសោះឡើយ។

**យថាឋាន** *ន.* (បា.) ទីដដែល, កន្លែងដដែល, កន្លែងដើម :

**ពាក្យកាព្យ**

នា-យថាឋាន អណ្តើកសាមាន្យ ស្តាប់ព្រោះហើបហា

ពោលពាក្យប្រទេច ភ្លេចពុំយល់ថា បញ្ចេញវាចា

អាត្មានឹងស្លាប់។

**យស** *ន.* (បា.) អានុភាព; ឥស្សរភាព; បរិវារ; ទ្រព្យធន; កេរ្តិ៍ឈ្មោះល្អ; សេចក្ដីថ្កើងថ្កាន :

**ពាក្យកាព្យ**

សក្តិពុំស្មើយស នាអ្នកខ្ពង់ខ្ពស់ ពុំស្មើចិត្តជា

រីអ្នកមានយស សម្បូរគ្នីគ្នា សុទ្ធសឹងមិត្តភ្ជា

ជួយជាកម្លាំង។

**មួយបែបទៀតថា**

សក្តិពុំស្មើយស អ្នកមានរបស់ ពុំស្មើសក្តា

សូវបង់ធនធាន កុំខុសអាជ្ញា សូវមានរោគា

កុំឱ្យមើលងាយ។

**យាត្រា** *ន.* (សំ. បា.) ការដើរ, ការចេញចរ, ការដើរផ្លូវ; ការដើរហែ, ការដើរជាពួកជាកង; ការចិញ្ចឹមជីវិត :

**ពាក្យកាព្យ**

រីពាក្យយាត្រា ដែលមានអត្ថថា ចិញ្ចឹមជីវិត

ត្រូវអស់ជនផង គ្រប់គ្រងពិនិត្យ ទើបជីពជន្មឋិត-

នៅយូរលង់បាន។

**រពឹស** *កិ.* នៅមិនស្ងៀម ចេះតែចាប់នេះចាប់នោះរឿយៗមិនស្រាក :

## ពាក្យកាព្យ

មនុស្សរពឹសដៃ បំពេញផ្ទៃមិនដែលខ្វះ មាននេះខ្លះនុះខ្លះ
ឯអ្នកខ្វះតែងមករក។
លក់ដូរឱ្យក៏មាន អ្នកអត់ឃ្លានតែងមកជ្រក អ្នកនុះគេមិនយក
ផលប្រយោជន៍ពីអ្នកក្រ។
មានកេរ្តិ៍ឈ្មោះពីរោះ ព្រោះគេកាន់ចិត្តដ៏ល្អ សង្គ្រោះអ្នកទ័លក្រ
ចិត្តគេ-សស្អាតជានិច្ច។

**រមណី** ***៩.*** (**សំ. ធា.**) ស្ត្រី :

## ពាក្យកាព្យ

មានរមណី ចូលមកក្នុងទី ធ្វើការកុសល
ខំប្រឹងខ្នះខ្នែង ឯងៗយកផល ព្រោះការខ្វាយខ្វល់
បានផលអនេក។
នាងនេះទ័លក្រ ហេតុផលបុណ្យល្អ ផ្តល់សុខឱ្យប្លែក
គឺមានទ្រព្យធន ពេកពន់អតិរេក ឱ្យឃើញទាន់ភ្នែក
មិនរង់ចាំកាល។

**រមត់** ***ត្.*** ដែលធ្លាប់តែរត់គេចពួន, ដែលមានពុតត្បុត, ដែលមានចិត្តវៀចវេរគេចកែរឿយៗ :

**ពាក្យភាព្យ**

រីជនរមត់ គំនិតរំពត់ វៀចវេរវរវឹក

របិញរបុញ យប់ថ្ងៃល្ងាចព្រឹក គេឱ្យបាយទឹក

រមិលគុណគេ។

**រមាស់** *កិ.* នាំឱ្យចង់តែអេះឬឱ្យចង់តែចុច :

**ពាក្យកាព្យ**

មនុស្សរមាស់មាត់ ពិបាកឃាត់ឱ្យនៅស្ងៀម ហេតុចិត្តនៅជាប់ជៀម

ស្ងៀមពុំកើតព្រោះរមាស់ៗ

**រមិលគុណ** *កិ.* ឃើញគុណឬនឹកគុណដែរតែស្មើយៗ មិនសូវយកចិត្តទុកដាក់ :

**ពាក្យកាព្យ**

មនុស្សរមិលគុណាស៊ុនខាងល្មើស ចិត្តទ្រើសទ្រនង់ឆ្លេចគ្រាក្រ កាលគេផ្គត់ផ្គង់ខ្លួនឱ្យល្អ

ឥតនឹកតបតសងគុណាគេៗ

លុះដល់យូរមកនឹកស្ដាយក្រោយ នឹកឃើញក្ដីធ្លោយព្រោះធ្វេសទ្វេ មិនហ៊ានហើបមាត់មួយម៉ាត់ទេ

ចេះតែគេចខ្លួនពួនបំបាំងៗ

**រខន្ត** *ន.* (សំ.) ឈូក, ផ្កាឈូក :

**ពាក្យកាព្យ**

វរិរះឡើង វរិន្ទរីក ភមរផងត្រេក

យកកេសរ ហើរត្រឹបក្រេបរស ដ៏បវរ

ដោយនូវអំណរ របស់វា។

**រខហាឡ្ស** *ន.* (**សំ. បា. រវិហំស** «ហង្សព្រះអាទិត្យ») សត្វប្រវឹក :

**ពាក្យកាព្យ**

រំហ្វូងរវិហង្ស ហើរចុះត្រង់បឹងទឹកថ្លា ហែលទឹកបឹងត្រៀបត្រា

ខ្មែរហៅថាហ្វូងប្រវឹកៗ

**រទាំងព្រៃ** *ន.* សត្វបក្សីមួយប្រភេទ ច្រើននៅអាស្រ័យក្នុងព្រៃស្រោង :

**ពាក្យកាព្យ**

ត្រូវរាំងរវាំងព្រៃ ហើរច្រៀវព្រៃតាមពួកវា ពាសពេញក្នុងព្រឹក្សា

ព្រះរាជាទ្រង់រីករាយៗ

**រសាប់រសាយ** *កិ.* រសាប់រសល់ខ្វល់រសាយគំនិត, រសាយព្យាយាម :

**ពាក្យកាព្យ**

រសាប់រសាយ ពុំស្ដាយសីលសង្ឃ គន់គិតក្ដួចចង់-

សឹកសេពមាតុគ្រាម។

**រីនឹង** *និ.* ទោះនឹង, បើនឹង :

**ពាក្យកាព្យ**

រីនឹងចេះឯង ដូចអ្នកវង្វេង កណ្ដាលអធ្វា

ពុំនោះដូចខ្វាក់ តែម្នាក់អាត្មា ចរចេញយាត្រា

ឥតអ្នកដឹកដៃ។

**រុក** *កិ.* បុកចូល; រុល, សំរុក, ត្រសុលចូល :

**ពាក្យកាព្យ**

ទ័ពគេរុករាន ទ័ពយើងទន្ទ្រាន ស្មើរគ្មានសល់ទី
លុះយើងរុកទៅ ទ័ពគេរក់រី ដណ្ដើមបានទី
មកយើងច្រើនហើយ។

**រុក្ខា** *ន.* (**បា. ពហុ. «រុក្ខ»**) ឈើទាំងឡាយ :

**ពាក្យកាព្យ**

វិក្រុងទ្ធិពេញមានរុក្ខា នានាអនេកអមរិថី មានផ្កាគ្រប់យ៉ាងជាប្រក្រតី
ព្រឹក្សាដាំថ្មីតាមនិយម។
ជាក្រុងឯករាជ្យអព្យាក្រឹត ឆើតឆោមវិចិត្រសឹងសក្តិសម ប្លែកជាងពីដើមព្រោះសង្គម
និយមរាស្ត្ររដ្ឋស្ពាត់ព្រមព្រៀង។
នេះគឺជាផលនៃសាមគ្គី ដែលព្រះមុនីទ្រង់ប្រិតប្រៀង សម្ដេចឪនាំផ្លូវឥតឱ្យល្អៀង
រាស្ត្រអៀងរាល់ខេត្តស្រុះស្រួលតាម។
ខ្មែរមានក្តីសុខសន្តិភាព ប្រទេសរាបទាបឥតសង្គ្រាម ព្រោះខ្មែរទាំងអស់ស្អប់សឹកសាម
ជំនួញសង្គ្រាមក៏គ្មានឡើយ។

**រុចរោចន៍** *គុ.* (**សំ. បា. រោចន**) ដែលរុងរឿង; ភ្លឺផ្លេក, ពណ្ណរាយ :

**ពាក្យកាព្យ**

ព្រះចន្ទចាស់រនោច មិនរុងរោចន៍ដូចចាស់ខ្មើត ជនដែលមានកំណើត
កើតជាប្រាជ្ញអាចដឹងឬាន។

**រូបី** *គុ.* ឬ *ន.* (**បា.**) ដែលមានរូប, ដែលមានលម្អ; បុរសអ្នកមានលម្អ; បើស្ត្រីជា **រូបិនី** នាងល្អ :

**ពាក្យកាព្យ**

រូបីរូបិនី ជនទាំងទ្វីប្រាស្រ័យគ្នា កើតបានជារូបា
ឥតអ្នកណាស្គាល់ប្រភព។

**រួសរ៉ា** ***កិ. ១.*** ឆាប់រ៉ា :

**ពាក្យកាព្យ**

ប្រញាប់រួសរ៉ា បង្ហង់ដល់ណា ឱ្យខាតវេលា
ឆាប់ៗរែៗ កុំឈររេរា យើងទាំងអស់គ្នា
ជាកម្មករ។
ការមានកម្រិត លោកដាក់កំហិត ឱ្យយើងឈ្មួសរ
កាន់ការរវែង ប្រឹងប្រែងសាទរ មិនឱ្យមានឈរ
ឈប់ខុសពេលម៉ោង។

**រួសរក** ***កិ.*** រកដោយរួសរាន់, ប្រញាប់រក :

**ពាក្យកាព្យ**

អ្នកគ្រប់គ្រងផ្ទះ មិនចង់ឱ្យខ្វះ រួសរកទ្រព្យ
ឱ្យមានគ្រប់គ្រាន់ ទាន់កាលវេលា ឃើញខ្វះទ្រព្យណា
ប្រឹងរកទ្រព្យនោះ។

**រេម៉ស** ***គុ.*** ថោក; ថោកទាប, ថោកថយ, ថយថោក; កាច, កោងកាច, អាក្រក់, គម្រក់, ជួជាតិ; កំណាញ់ :

### ពាក្យកាព្យ

រីជនរេប័ស កាចឃោរឃៅណាស់ ចាស់ស្ដីមិនស្ដាប់
វាធ្វើអ្វីៗ បំពានលើច្បាប់ ខុសចាកតម្រាប់
សណ្ដាប់ភូមិស្រុក។

**រោហិត** *គុ.* (**សំ. បា.**) ក្រហម :

### ពាក្យកាព្យ

ក្រមារោហិត ច្រើនតែគាប់ចិត្ត កញ្ញានានា
ដែលនៅជំទង់ ទ្រទ្រង់ពស្ត្រា រូបស្រស់សោភា
ពានាសមប្រាណ។

**រំគាល** *កិ.* ឬ *គុ.* (**ព. បុ.**) រលស់, ថយចំនួន :

### ពាក្យកាព្យ

ស្ដេចទតព្រះនេត្រយង់យល់ រំគាលអប៉ីពល ពុំអាចតទល់ទ័ពបាន។
ទ្រង់ក្រោធច្រលោតអង្គប្រាណ ព្រះទ័យឥតក្សាន្ត បានត្រាស់បញ្ជាជាថ្មី។

**ឫក្សពារ** *ន.* (**សំ. ស.; សំ. ឫក្ស + វារ** «ថ្ងៃ» **វ > ព**) ថ្ងៃមានឫក្ស :

### ពាក្យកាព្យ

ចេញត្រូវឫក្សពារពេលបវរ កើតលាភកុះករច្រើនពេកពន់ ដែលក្បួនហោរាឱ្យគួរគន់
តាមបែបពួកជនជឿក្បួនហោរ។
ខ្លះធ្លាប់ជឿទៅត្រូវខ្លះដែរ ពិបាកបំបែរចិត្តថាតរ ជួនកាលភ្លេចគិតគំនិតវរ
ទោះតរមិនតរដឹងពុំដល់។

**លក់លន់** ឬ **លន់លក់** *កិ.* លក់ហួសប្រមាណ, លក់ជ្រៅមិនងាយភ្ញាក់ :

**ពាក្យកាព្យ**

លក់លន់លង់ជ្រៅ ទោះខ្លួនដេកនៅ ក្នុងគ្រឹះឋាន
មានចោរកំណាច អាចគាស់ទ្វារបាន លួចទ្រព្យហើយច្រាន
ទ្វារបិទដូចដើម។

**លង់លុះ** *និ.* លុះដល់, ហួសមកដល់, ដរាបមកដល់ :

**ពាក្យកាព្យ**

លង់លុះអគ្រាត្រ ស្ដេចយាងព្រះបាទ ចូលក្នុងដំណាក់
ទតឃើញអាមាត្យ រាជសេវក ឥតសល់មួយនាក់
លក់លង់ស្វាត់ស្វន្ស។

អស់កាលយូរលង់ ព្រះពោធិពង្ស ទ្រង់សាងសីលា
ពុំមានប្រមាទ ឱ្យឃ្លាតចរិយា ទើបមហាក្សត្រា
ភ្នកនឹកដល់ទាន។

**លលាម** *គុ.* ឬ *កិ. វិ.* (*សំ. គុ.* «ល្អ, ស្រស់បស់, ឆើតឆាយ, រុងរឿង»; *ន.* «ទង់») ល្អរុងរឿងដោយអំណាច; ដែលគឃ្លើនអង់អាចឥតក្រែង :

**ពាក្យកាព្យ**

វេលាពលចូលកាន់សង្គ្រាម ឥតមានទីមទាម ពញ្ហមលលាមរាល់ប្រាណ។
សេនាអង់អាចហៅហាន ចូលលុករុញច្រាន លុះត្រាតែបានជោគជ័យ។

**លាភុជិក** *ន.* (*សំ.*) អ្នកបម្រើ; បើស្ត្រីជា **លាភុជិកា** :

**ពាក្យកាព្យ**

លាកុដិក ផឹកស្រវឹង មិនដឹងខ្លួន,
តែគាប់ជួន កុដិកា ជួយដោះស្រាយ,
ឱ្យផុតទោស ដោយសន្តោស នៃចៅហ្វាយ,
ដែលលោកស្រាយ មិនប្រកាន់ បានរួចខ្លួន។

**លាកុដិកា** លុប **លា** ចេញ ទុកត្រឹមតែ **កុដិកា** ហៅថា អាទិលុប, ដូច **ឧបាសិកា** > **បាសិកា** ដែរ។

**លាយទៈ** ឬ **លាយត** *ន.* (**សំ. លាយទ**) ការស្រាល; ការប្រញាប់, ការរំហ័ស; គំនិតរហ័ស, គំនិតវាងវៃ; អនាម័យ :

**ពាក្យកាព្យ**

កូនឯងជាលាយត ពុំគួរងប់នឹងការលេង ទ្រព្យធនរលីងធេង
ព្រោះតែល្បែងបង្ហិនខ្លួន។

**អ្នកលេងលាត់សើយ** ឬ **អ្នកលេងសើយលាត់** *ន.* អ្នកលេងកោងកាចដែលរមែងតែលាត់សើយឬសើយលាត់ដើរឥតក្រែង :

**ពាក្យកាព្យ**

អ្នកលេងលាត់សើយ កាលអស់ទ្រព្យហើយ ធ្វើទុក្ខបងប្អូន
ជួនជេរប្រពន្ធ ជួនវាយធាក់កូន អស់ទាំងបងប្អូន
គេខ្ពើមរាល់គ្នា។

**លាន** *គុ.* ឬ *កិ. វិ.* ដែលទទេឥតការងារ, ដែលឥតទីពឹង, ដែលឥតពំនាក់; ណែលណោល :

**ពាក្យកាព្យ**

| | | |
|---|---|---|
| រីមនុស្សលាទា | ឥតមានគ្នីគ្នា | ណាជួយជ្រោមជ្រែង |
| កាលណាទាល់ច្រក | លបលេងតែល្បែង- | ស៊ីសងឥតក្រែង- |

ច្បាប់ដែលរដ្ឋហាម។

**លិកលាន** *កិ. វិ.* ឬ *គុ.* **(ព. បុ.)** ដែលលែនលន, ឡេះឡោះ, ដែលលូកល, ដែលលលេង, ជន្លជន្លេញ, ពាយងាយ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| នរអ្នកផង | ទោះដឹងយល់ហោង | ចិត្តនោះឱ្យបាន |
| បំពេញព្រះផ្នួស | ដោយព្រះទូន្មាន | កុំធ្វើលីកលាន |

ដោយចិត្តអន្ធពាល។

**លីលាប់** *កិ.* បាត់, សូន្យ, អស់; វិលវល់; ឡែឡប់ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| សត្វផងកើតស្លាប់ | សុទ្ធសឹងលីលាប់ | ក្នុងភពតូចធំ |
| កើតស្លាប់ស្លាប់កើត | កំណើតវង្គំ | រង្គាលឆេះងំ |

ដោយភ្លើងរាគា។

**លុទ្ធបុគ្គល** *ន.* (ធា.) បុគ្គលលោភ, មនុស្សលោភ, អ្នកល្មោភ, អ្នកដែលចង់បានតែប្រយោជន៍ផ្ទាល់ខ្លួន :

**ពាក្យកាព្យ**

លុទ្ធបុគ្គល រមែងតែយល់ ប្រយោជន៍ផ្ទាល់ខ្លួន
បើឃើញគេបាន ទ្រព្យធនផ្ទួនៗ ច្រើនតែរុកកួន
រអ៊ូរទាំ។

**លុម្បក** ឬ **វិលុម្បក** *ន.* អំពើរបស់ចោរប្លន់, អំពើប្លន់, ការប្លន់ :

**ពាក្យកាព្យ**

វីពួកលុម្បក ប៉ិនខាងការឆ្មក់ ចូលប្លន់អ្នកស្រុក
វាប៊ានចូលប្លន់ ព្រោះមានរនុក ប្រាប់ឱ្យចូលលុក
កុំបីញញើត។

**លូខវាទី** *ន.* អ្នកដែលពោលពាក្យខ្លីខ្លា, អ្នកដែលពោលពាក្យពុំគប្បី (បើស្ត្រីជា **លូខវាទិនី**) :

**ពាក្យកាព្យ**

លូខវាទី ច្រើនប្រើសម្ដី ខ្លីខ្លាឥតបទ
វាចង់ថាអ្វី ស្រេចតែនឹងមាត់ ពោលថាខុសភ្លាត់
ពុំបានការឡើយ។

លូខវាទិនី ជាស្រីញីកុំហៅស្រី ព្រោះវាប្រើសម្ដី
ជារចីពុំបានការ។

**លេញលេខ** *កិ.* លេងជន្លជន្លេញ គឺចំអែចំអន់លេងហើយលេងទៀតដដែលៗ :

**ពាក្យកាព្យ**

បាត់យសឫទ្ធិតខ្ជិល	បាត់ញាណទានសីល	ឫទ្ធិតសេពសុរា
ប្រមាទបាត់បុណ្យ	ខឹងបាត់ប្រាជ្ញា	លេញលេងដៀលថា
បាត់តរិយាគាប់។

**លេលាប់** *កិ. វិ.* ឬ *គុ.* **(ព. បុ.)** ដែលលែនលន, លើកលាន, ស្មោះងារ, ខ្ជីខ្ជា :

**ពាក្យកាព្យ**

សង្វាតសរសេរ	អស់អញកុំខ្ជិល	ទើបបានជាគាប់
សង្វាតសូត្ររៀន	ដោយគ្រូប្រញប្ត	កុំធ្វើលេលាប់
ដោយចិត្តមាក់ងាយ។

**លោណម្ពិល** *គុ.* ឬ *ន.* (**បា. លោណ** «ប្រៃ» + **អម្ពិល** «ជូរ» **លោណម្ពិល**) ប្រៃនិងជូរឬវត្ថុមានរសប្រៃជូរ :

**ពាក្យកាព្យ**

តាបសចាស់ៗ	នៅព្រៃយូរណាស់	ឆាន់ឥតអំបិល
ស្រាប់តែនឹកភ្នក	ដល់លោណម្ពិល	ក៏នាំគ្នាវិល
មករកក្រុងម្តង។

អ្នកក្រុងឈ្វេធរ	ដោយក្តីត្រេកអរ	នាំគ្នាត្រសង
មករកឥសី	យកអ្វីមកផង	បំពេញបំណង
តាបសរាល់រូប។

**លំដាប់** *ន.* របៀប, ថ្នាក់, ជាន់; សង្កាត់ :

**ពាក្យកាព្យ**

លំដាប់នោះណា នាងស្រីសុជាតា ថ្វាយមធុបាយាស
សឹងគ្រឿងទិព្វតន់ ពេញទាំងភាជន៍មាស ទើបនាងអង្គាស
ថ្វាយព្រះទសពល។

**លំពាំង** *ន.* (ស.) ទំនើង, អំណាចខ្លួន, អំពើចិត្ត :

**ពាក្យកាព្យ**

វាឃោរឃៅខ្លាំង ធ្វើតាមលំពាំង ប្រឆាំងយកឈ្នះ
ជួនកាលបាត់ខ្លួន ជួនកាលនៅផ្ទះ មានគ្នាវាខ្លះ
ខ្នះខ្នែងជ្រោមជ្រែង។

**លាំលើស** *គុ.* ប្រសើរលើស, ក្រៃលែងជាង, ល្អជាង (មានប្រើខ្លះតែក្នុងកាព្យបុរាណ) :

**ពាក្យកាព្យ**

វេហ៍ពលលាំលើស ចេញមកប្រទើស សម្តែងចេស្តា
ថ្វាយព្រះភូមិន្ទ នរិន្ទរាជា ទ្រង់ព្រះមេត្តា
ប្រទានរង្វាន់។

**ល្បាប់** *ន.* ភក់ពពុលស្អិត :

**ពាក្យកាព្យ**

រីដីមានល្បាប់ ប្រសើរចំណាប់ ចម្រើនដំណាំ
គួរអ្នកម្ចាស់ដី រក្សាថែទាំ ត្រូវដាំដំណាំ

កុំបោះបង់ចោល។

**ល្អេញល្អៅ** *កូ.* ទ្រទេសទ្រទន់, ស្រលួតស្រលះ, ស្រស់បស់ :

**ពាក្យកាព្យ**

នែនាងឆោមឆ្អៅ	រូបរាងល្អេញល្អៅ	ស្រីនៅភូមិណា
ម្ដេចដើរម្នាក់ឯង	ពុំក្រែងគេថា	មានគ្នាទៅវ៉ា
ទើបសមនឹងវ័យ។

ដើរតាមភ្លឺស្រែ	ពុំបានលាម៉ែ	ផងទេឬអី
ម្ដេចក៏មិនយក	ក្មេងតូចដឹងក្ដី	ឱ្យដើរជូនស្រី
គ្រាន់បានជាគ្នា។

**ល្អមល្អៃ** *កូ.* ល្អតល្អៃ, ទន់ភ្លន់សមរម្យ :

**ពាក្យកាព្យ**

នាងនាដនេះថ្ងៃ	រូបឆោមល្អមល្អៃ	ចេះលៃក្បាច់រាំ
ប្រើបែបសមរម្យ	ទន្ទេងទន្ទាំ	នេះហៅអ្នករាំ
ចេះរាំត្រូវបែប។

**ល្អួច** *ន.* ឬ *កូ.* អំពើលួច; ដែលរកស៊ីដោយអំពើលួច :

**ពាក្យកាព្យ**

វីមនុស្សល្អួច	គិតតែពីលួច	លួចឥតខ្លាចច្បាប់
ទោះអ្នករាជការ	ភ្នាក់ងារបានចាប់	ដាក់គុកតាមច្បាប់
រួចមកមិនចាល។

កូនខ្មែរគ្រប់គ្នា យើងកាន់សាសនា- ព្រះពុទ្ធត្រកាល
គួររៀរកម្មកាច គួរខ្លាចគួរចាល គួរត្រេកត្រអាល
ឆ្ពោះការស្លូតត្រង់។

**ល្មើស** *កិ.* ប្រព្រឹត្តរំលងលើច្បាប់, ច្រលើសបំពានលើបញ្ញត្តិ :

**ពាក្យកាព្យ**

ការល្មើសលើច្បាប់ ព្រោះហេតុមិនស្តាប់ ពាក្យប្រៀនប្រដៅ
ពុំនោះព្រោះតែ ចិត្តកាចកម្លៅ គំនិតឆោតឆៅ
ក្រៅធម៌ប្រៀនប្រាប់។

**ល្វៃ** *ឧ.* ពាក្យបរិវារសម្រាប់និយាយផ្សំនឹងពាក្យ **ល្វត** ថា : **ល្វតល្វៃ** ទន់ភ្លន់ល្វាសល្វន់ក្រៃពេក :

**ពាក្យកាព្យ**

ហៃកែវថ្កើមថ្លៃ ដំណើរល្វតល្វៃ ប្រពៃឥតឆ្គង
ទាស់តែពុំឮ សម្តីសាសង សុំឱ្យទ្រនូលល្អង
សាសងខ្លះមក។

**ល្ងក់ល្ងាច** *គុ.* ដែលសុទ្ធតែកំពុងលូតលាស់ខ្ពស់ស្រលះឬដែលសុទ្ធតែនៅក្មេងកំពុងដកកម្ពស់ :

**ពាក្យកាព្យ**

រូបរាងខ្ពស់ស្រាវ នៅក្មេងល្ងក់ល្ងាវ ពាក់អាវសមប្រាណ
កំពុងខំរៀន ដោយក្តីសុខសាន្ត មុខជានឹងបាន

ចំណោះថ្នាក់ខ្ពស់។

| | | |
|---|---|---|
| បែបអ្នកដឹងគុណ | ដឹងបាបដឹងបុណ្យ | ដឹងធម៌សប្បុរស |
| មាតាបិតា | នឹងបានក្រេបរស | គួរគាប់ទាំងអស់ |

របស់កូននេះ។

**ល្អល្អះ** *គុ.* ល្អស្រស់ល្អូតស្រលះ, ល្អឥតខ្ចោះ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| រូបឆោមល្អះល្អ | មិនខ្មៅមិនស | ល្មមតែសមរម្យ |
| មិនខ្ពស់មិនទាប | មិនតូចមិនធំ | ស្រគត់ស្រគំ |

សមជាអ្នកមុខ។

**ល្អជា** *កិ. វិ.* ឬ *គុ.* **(ព. បុ.)** ដែលល្បីល្បាញ; ជាញជ័យ, អង់អាច, ហៅហាន :

**ពាក្យកាព្យ**

| | | |
|---|---|---|
| សេនាអង់អាច | មានឫទ្ធិអំណាច | អាចហានល្អជា |
| អស់ពួកសត្រូវ | ទូទាំងទិសា | សឹងខ្លាចចេស្តា |

តេជះជាញជ័យ។

**ល្អលាន់** *កិ. វិ.* ឬ *គុ.* ដែលគ្រាន់តែល្អលាន់កងរំពងប៉ុន្តែល្អពុំប្រាកដជាសូរសព្ទអ្វីឬរឿងហេតុអ្វីឡើយ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| មានការណ៍ល្អលាន់ | តើមានអាសន្ន | អ្វីប្លែកយ៉ាងណា |
| គួរសួរបញ្ជាក់ | ឱ្យអ្នករាល់គ្នា | បានដឹងច្បាស់ថា |

ជារឿងហេតុអ្វី?។

**ព្ឋសាយ** *កិ. វិ.* ឬ *គុ.* **(ព. បុ.)** ដែលមានកេរ្តិ៍ឈ្មោះពីរោះល្បីលេចឮសាយសុសសព្វទិសានុទិស :

**ពាក្យកាព្យ**

អាពុកនិងម្តាយ នូវញាតិទាំងឡាយ សប្បាយពន់ពេក
ព្រោះឮថាកូន ឮសាយចម្លែក គេអរអនេក
ឯកឥតគណនា។

**ទន័ន** ឬ **ទនន:** *ន.* (**សំ. បា. ទនន**) ការនិយាយ; ពាក្យ; ធ្មេញ; មាត់ :

**ពាក្យកាព្យ**

ប្រយ័ត្នវទ័ន កុំពោលរួសរាន់ ដោយឥតគំនិត
មុននឹងនិយាយ ត្រូវមានការគិត ការឥតគំនិត
រមែងភ្លាំងភ្លាត់។
ដូចត្រីកំភ្លាញ មានក្តីលិចលាញ ស្លាប់ខ្លួនព្រោះមាត់
កក្អិចឥតស្រោក គេទៅជញ្ជោត់ ព្រោះតែវាមាត់
ភ្លាត់ខ្លួនចូលឆ្នាំង។

**ទនញ្ញូ** *ន.* (**បា.**) អ្នកដឹងក្នុងការនិយាយស្តី, អ្នកចេះនិយាយស្តីគួរដល់ការ; អ្នកមានចិត្តទូលាយ; មនុស្សចិត្តបុណ្យ; អ្នកដែលដឹងក្នុងការឱបអរសាទរ (ទាំងបុរសទាំងស្ត្រី) :

**ពាក្យកាព្យ**

| | | |
|---|---|---|
| អ្នកវទញ្ញូ | អាចជាគំរូ | ឱ្យគេធ្វើតាម |
| សម្ដីទៀងទាត់ | មិនភ្លាំងភ្លាត់ភ្លាម | ទើបបានមាននាម |

ថាប្រាជ្ញវោហារ។

**ខន្ធ** *ន.* (**សំ. ធា.**) ស្ត្រីមានគូស្រករ, ស្ត្រីក្រមុំដែលទើបមានស្វាមី; ស្ត្រីដែលមាតាបិតាក្មេកកំពុងសង្កេតឬកមារយាទ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| វធូជាស្រី | ខ្លួនទើបមានប្ដី | ត្រូវផ្គង់ចរិយា |
| ប្រយ័ត្នទាស់ឆ្គង | គន្លងមាត្រា | មាតាបិតា |

អរមិនតិចឡើយ។

**ខប្បរដូវ** ឬ **ខប្រូវដូវ** *ន.* រដូវសាបព្រោះ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| ហៃមាសកូនឱ | វប្បរដូវ | ចូលដល់មកហើយ |
| ចូរខំខ្នះខ្នែង | កុំធ្វើកន្ដើយ | រដូវហ្នឹងហើយ |

បង្កើតធនធាន។...

**ខម្មិត** ឬ **ខរ្មិត** *ន.* ទាហានពាក់ក្រោះ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| វេហ៍ពលវម្មិត | លើកចូលទៅជិត | កងទ័ពខាងខ្មាំង |
| រុកចូលគឃ្លើន | ផ្ដើនដោយកម្លាំង | ចូលលុកប្រឆាំង |

តតាំងយកជ័យ។

**វយ** ឬ **វ័យ** *ន.* (**បា. វយ**) អាយុ, ដំណើរស្ទូន្យទៅខាងក្រោយលឿនកើនទៅខាងមុខ (នៃអាយុ) :

**ពាក្យកាព្យ**

ក្នុងវ័យទាំងបី គួរធ្វើអ្វីៗ កុំឱ្យឃ្លាតក្លាយ
ខុសចាកវយ: នៃវ័យទាំងឡាយ ទាស់ខុសនាយអាយ
គួរស្តាយពន់ពេក។

**វយវឌ្ឍនាការ** *ន.* (**បា. វយ + វឌ្ឍន + អាការ**) អាការៈចម្រើនតាមលំដាប់វ័យគឺតាំងពីប្រសូតមករហូតដល់ចម្រើនធំខ្លួនរៀងទៅដល់ចាស់ :

**ពាក្យកាព្យ**

បុត្រមានវ័យវឌ្ឍនាការ គ្រូបាអាចារ្យគួរពោលក្រើន មាតាបិតាឱ្យក្រវើន
រកក្តីចម្រើនឱ្យកូនខ្លួនៗ

**វល័យ** *ន.* (**បា. សំ. វលយ**) កង; កងដៃ, កងជើង :

**ពាក្យកាព្យ**

នាងនាដពាក់វល័យ មុខប៉ប្រែចេញកែក្រាយ អ្នកដែលរាំទាំងឡាយ
សឹងសប្បាយរីករាយក្រៃៗ

**វលី** *ន.* (**បា. សំ. វលិ ឬ វលី**) ស្បែកដែលជ្រិតជ្រីវ; ផ្នត់; ផ្នត់ពោះ; ផ្នត់ថ្ងាស :

**ពាក្យកាព្យ**

យាយតាទាំងទ្វី មុខមានវលី ជរាណាស់ហើយ

ពុំសមបីបើ ធ្វើឫកតោះតើយ ខ្លួនចាស់ម្ដឹងហើយ

គួរមានសង្វេគ។

**វលីមុខ** *ន.* (បា. សំ. **វលិមុខ** ឬ **វលីមុខ**) ស្វា :

**ពាក្យកាព្យ**

វីសត្វវលីមុខ ស៊ីកគ្រលុកបែបសម្បើម ចេះតែញាក់ចិញ្ចើម

មុខពព្រើមដូចឥតទុក្ខ។

**វាទានុវាទ** *ន.* (បា. «**វាទ + អនុវាទ**») ការពោលបណ្ដោយតាមគ្នា, ពាក្យចាក់បណ្ដោយ; ពាក្យប្រកាន់និងពាក្យដោះ :

**ពាក្យកាព្យ**

វាទានុវាទ ច្រើនតែឃ្លៀងឃ្លាត ពុំសូវទៀងទាត់

ពាក្យខ្លះក៏ត្រូវ ពាក្យខ្លះក៏ភ្លាត់ ព្រោះមាត់និងមាត់

ប្រឆាំងតគ្នា។

**មហាវាបី** *ន.* បឹងធំ :

**ពាក្យកាព្យ**

កម្ពុជរដ្ឋ មាននគរវត្ត ប្រាសាទសិលា

មានទន្លេសាប ធំធេងមហិមា ដែលជាមហាវាបីនៃរដ្ឋ។

ចុល្លវាបី ប្លែកៗច្រើនក្រៃ ជាទីវិវឌ្ឍន៍

ដោយជាតិមច្ឆា នានាច្រើនក្កាត់ ជាទ្រព្យសម្បត្តិ

នៃកម្ពុជា។

**វិកត្ថនៈ** ឬ **វិកត្ថា** *ន.* (**បា. សំ. វិកត្ថន** ឬ **វិកត្ថា**) ការពោលអួត; អំនួត; សម្ដីអួតអាង; ការនិយាយលើកកម្ពស់; ការនិយាយបញ្ចោរ; សម្ដីលើកជើង :

**ពាក្យកាព្យ**

វិកត្ថាជាវាចាពុំគួរស្ដាប់ បើឮប្រញាប់ដើរចេញឆ្ងាម បង្អង់ស្ដាប់យូរទាក់ទាម
ឮឆ្ងាមត្រូវចៀសឆ្ងៃតឱ្យឆ្ងាយ ៗ

**វិឃាសាទ** *ន.* អ្នកបរិភោគភោជនដែលសេសសល់ពីគេ, អ្នកស៊ីបាយដែល :

**ពាក្យកាព្យ**

ពួកវិឃាសាទ អាស្រ័យបាយបាត្រ ប្រមាថព្រះសង្ឃ
ធម៌អាថ៌នៅជិត ពុំគិតផ្ចិតផ្ចង់ រៀនសូត្រត្រង់
អាត្មាសោះឡើយ ។

**វិចារណ៍** *ន.* (**បា. សំ. វិចារណា**) ការពិចារណា, ការរិះរេ, ការរំពឹងរកហេតុ, ការរំពឹងរកទំនង :

**ពាក្យកាព្យ**

អ្នកប្រាជ្ញលោកថា ត្រូវមានវិចារណ៍ ក្នុងការផ្ចូផ្ចង
គិតហើយសឹមធ្វើ ការសរពើផង ទើបសមបំណង
ពុំដែលខុសខូច ។

**វិចិន្តា** *ន.* (**បា. សំ.**) ការនឹកឃើញផ្សេងៗ, ការនឹកផ្ដេសផ្ដាស; សេចក្ដីរវើរវាយចិត្ត; សេចក្ដីអផ្សុក :

**ពាក្យកាព្យ**

| | | |
|---|---|---|
| វីរិចិន្តា | នាំការសិក្សា | ឱ្យកើតរាយមាយ |
| ត្រូវបោះបង់ចេញ | បណ្តេញឱ្យឆ្ងាយ | កុំឱ្យរសាយ |
| | ចាកការរៀនសូត្រ។ | |

**ខជ្ជមាន** *គុ.* (បា.) ដែលកំពុងមាននៅឡើយ, ធរមាន :

**ពាក្យកាព្យ**

| | | |
|---|---|---|
| វាហ៊ានបំពាន | លើច្បាប់វិជ្ជមាន | ឥតខ្លាចឥតក្រែង |
| ធ្វើតាមទំនើង | ទើងមើងជាក់ស្តែង | បងប្អូនវាឯង |
| | ក៏ខឹងក្តៅដែរ។ | |

**ខជ្ជា** ឬ **ខឡា** *ន.* (បា. ឬ សំ.) សេចក្តីដឹងច្បាស់; ការចេះដឹង, ចំណេះ; វេទមន្ត, មន្តអាគម :

**ពាក្យកាព្យ**

| | | |
|---|---|---|
| អ្នករៀនទាំងឡាយ | ប្រយ័ត្នរាយមាយ | ព្រោះក្តីសល់រ៉ល់ |
| ត្រូវខំមាត់រៀន | ចំណេះសកល | ឱ្យត្រាតែដល់ |
| | ត្រើយត្រាណវិទ្យា។ | |
| វិទ្យាជាទ្រព្យ | ប្រើបានគ្រប់សព្វ | លើសទ្រព្យនានា |
| អ្នកមានទ្រព្យស្រាប់ | អាប់ឥតវិជ្ជា | មិត្តភក្តិផងគ្នា |
| | គេច្រើនមើលងាយ។ | |

**ខរាព** *ន.* (បា. សំ. ***វិរាវ, វិរវ***) សម្រែក, សូរសព្ទស្រែកខ្លាំង :

**ពាក្យកាព្យ**

ទីឥតវិភាព ដែលមានសភាព គួរតែញុំាងចិត្ត
ឱ្យបានស្ងប់ស្ងាត់ បំបាត់ទុច្ចរិត កុំឱ្យមានឋិត
នៅក្នុងត្រៃទ្វារ។

**ទីង** *និ.* វិញ, វិញទៀត; ភ្លាម :

**ពាក្យកាព្យ**

ខ្ញុំឥតទីពឹង សូមបងវិលវឹង ឱ្យរួសរាន់រ៉ា
ទោះបានអ្វីក្តី ពុំបានក្តីណា សូមបងយាត្រា
វិលឆាប់កុំខាន។

ឱគាត់បានប្រាប់ ថាឱ្យប្រញាប់ វិលវិញឱ្យបាន
ត្រូវកុំបង្អង់ ឱ្យខកឱ្យខាន ត្រូវតែឱ្យបាន
ត្រលប់វឹងស្នង។

**សកុណាណ្ឌ** *ន.* (**បា. សកុណ** «បក្សី» + **អណ្ឌ** «ស៊ុត») ពងសត្វស្លាប, ពងស៊ុតបក្សី :

**ពាក្យកាព្យ**

ព្រះពុទ្ធត្រាស់ថា រាជបុត្រា ព្រះនាមពោធិ
ពុំមានបុត្រសោះ ព្រោះកម្មអំពី ជាតិមុនដែលស៊ី
សកុណាណ្ឌនាកោះ។

**សក្ការសម្មាន** *ន.* (**បា.**) សក្ការៈនិងសេចក្តីរាប់អាន, សក្ការៈនិងសេចក្តីគួរសម :

### ពាក្យកាព្យ

សក្ការសម្មាន នាំឱ្យបានគ្នាជាមិត្ត នរណាបានប្រព្រឹត្ត
ពិតជានឹងមានមិត្តច្រើន។
ចងមិត្តដោយការឱ្យ ឱ្យញយៗមិត្តក៏កើន ក្ដីសុខក្ដីចម្រើន
តែងមានច្រើនព្រោះការឱ្យ។

**សក្តា** *គុ.* ដែលអាច, ដែលអង់អាច, ដែលមានអំណាច, ក្លាហាន; ដែលមានកម្លាំង; ដែលមានព្យាយាមរឹងប៉ឹង; ពូកែ, ខ្លាំងពូកែ; ជំនាញ; ដែលប៉ិនធន់ទ្រាំ :

### ពាក្យកាព្យ

សក្តាខ្ពង់ខ្ពស់ ប៉ុន្តែគ្មានយស ពុំស្មើប្រជា
ដែលគេគ្មានសក្តិ គេមានមេត្តា សទ្ធាជ្រះថ្លា
ទេវតាស្រលាញ់។

**សក្យសីហៈ** ឬ **សាក្យសិង្ហ** *ន.* **(ព. ប្រ.)** សីហៈឬសិង្ហរបស់ពួកសាក្យៈ (ព្រះសក្យមុនី) :

### ពាក្យកាព្យ

ព្រះសក្យមុនី ទ្រង់ចេញពីសក្យវង្ស ទ្រង់បួសតាមបែបបទ
ជាបន្ទាត់នៃពុទ្ធា។
ដែលបានត្រាស់មុនៗ មានបុណ្យគុណដូចៗគ្នា ទ្រង់កាន់ធម៌ចរិយា
ត្រាតែបានជាព្រះពុទ្ធ។

**សចសីក** *៣.* ធ្វើអាក្រក់តបទៅរកវិញ, បំផ្លាញតបទៅវិញ, ចងពៀរតប :

**ពាក្យភាព្យ**

| | | |
|---|---|---|
| ទីឃាវុកុមារ | មុនមានការគិតសងសឹក | ក្រោយមកបានឆ្លកនឹក |
| | ដល់បណ្ដាំនៃបិតា។ | |
| ព្រះបាទព្រហ្មទត្ត | ក៏ពុំភ្លាត់បង់ជន្មា | ព្រោះការស្រាយវេរា |
| | នៃទីឃាវុបណ្ឌិត។ | |

**សង្គមរាស្ត្រនិយម** *៩.* សង្គមនិយមរាស្ត្រប្រជាពលរដ្ឋទូទៅទាំងប្រទេស ប្រកបដោយលក្ខណការណ៍មានសាមគ្គីជាមូល ជាប្រភពរួបរួមគ្នាដោយលទ្ធិតែមួយដូចគេវេញខ្សែបញ្ចូលផ្គុំគ្នា មិនឱ្យមានការប្រេះឆាបែកកន្លែកញែកចេញពីគ្នាឡើយ :

**ពាក្យភាព្យ**

| | | |
|---|---|---|
| រាជការសង្គម | រដ្ឋរាស្ត្រនិយម | នៃកម្ពុជា |
| ដើរលឿនគគុក | ទៅមុខឥតរា | រាស្ត្រទាំងអស់គ្នា |
| | បានសុខចម្រើន ! | |
| សមិទ្ធិភាព | ទាំងខ្ពស់ទាំងទាប | ចេះតែកើតកើន |
| ប្រៀបដូចជាផ្សិត | ត្រូវភ្លៀងដុះច្រើន | ខ្មែរប្រឹងក្រវើន |
| | តាមបែបសង្គម ! | |
| ខ្មែរក្មេងខ្មែរចាស់ | រីករីករាយណាស់ | ផ្ដោះរាស្ត្រនិយម |

បើដូចសព្វថ្ងៃ　　រដ្ឋមិនរលំ-　　ទេព្រោះមានភ្នំ
បាំងខ្យល់ព្យុះហើយ !
រដ្ឋខ្មែរមាឌតូច　　ប៉ុន្តែប្រដូច　　នឹងកោះរំហើយ
ហៅកោះសន្តិភាព　　ដីរាបដូចត្រើយ　　ពលរដ្ឋសុខដើយ
ក្នុងអាស៊ីទ្វីប !

**សង្ឃឹម** *កិ.* នឹកផ្គងគំនិតទុកថាមុខជានឹងបានសម្រេចដូចបំណង, មានសេចក្ដីកក់ក្ដៅក្នុងចិត្តទុកជាមុន :

**ពាក្យកាព្យ**

ម្ដាយសង្ឃឹមកូន　　បងនិងប្អូនទាំងពីរប្រាណ　　ថាមុខជានឹងបាន
ថែរក្សាមាតាចាស់ៗ
ឥឡូវខុសបំណង　　បែរជារងឯកម្មក្រាស់　　លំបាកពន់ពេកណាស់
ព្រោះកម្មចាស់របស់ខ្លួនៗ

**សង្ឃដ្ឋសព្ទ** *ន.* (**បា. សង្ឃដ្ឋ + សទ្ទ**) សូរគឹកកង, សូរកងរំពង, សូរទ្រហឹងអឹងកង :

**ពាក្យកាព្យ**

សង្ឃដ្ឋសព្ទ　　ទ្រហឹងអឹងអាប់　　តើសូរសព្ទអ្វី
ចូររត់ទៅសួរ　　ឱ្យដឹងសេចក្ដី　　ទោះការណ៍អ្វីៗ
ចូរវិលវិញឆាប់។

**សង្ខាត** *កិ.* ខំប្រឹងខ្លាំង, ខ្មីឃ្មាត, ស្រវាស្រទេញ :

**ពាក្យកាព្យ**

កុំធ្វើរាយមាយ នឹងគ្រូបាធ្យាយ ទុកស្មើអម្ចាស់
សង្វាតសរសេរ សូត្ររៀនឱ្យណាស់ ប្រាជ្ញាយល់ច្បាស់
នាំញាតិទាំងឡាយ។

**សត្តលោក** ឬ **សត្វលោក** *ន.* លោកគឺពពួកសត្វ, ដែលរាប់ថាជាលោកមួយ :

**ពាក្យកាព្យ**

រីសត្វលោក តែងមានការស្មោក ព្រោះលោកធម៌
ឥតលាភអាក់អន់ មានលាភត្រេកអរ ចិត្តវែងត្រាច់ចរ
រវើកឥតស្រាក។

**សន្ធិប្រកាស** *ន.* ឬ *គុ.* (សំ.) ពេលព្រះអាទិត្យអស្តង្គត, ពេលថ្ងៃលិច (សន្ធ្យាកាល) :

**ពាក្យកាព្យ**

លុះដល់ពេលសន្ធិប្រកាស ឃើញមនុស្សដើរពាសពេញទាំងផ្លូវ ខ្ញុំសួរគេប្រាប់ថាឥឡូវ
ស្អែកត្រូវធ្វើការហាត្ថកម្ម។

**សន្និស័ន** *កិ.* (បា. **សន្និសទ**) អង្គុយស៊ប់; អង្គុយនៅស្ងៀម; អង្គុយប្រជុំគ្នា។ ប្រើជា *ន.* ក៏បាន «ការអង្គុយនៅស្ងៀម; ដំណើរស្ងាត់ច្រៀប» :

**ពាក្យកាព្យ**

ពួកជនច្រើនក្តាត់ មកសន្និស័ទ នៅក្នុងសាលា
នៃវត្តព្រះសង្ឃ ផ្គង់ចិត្តជ្រះថ្លា តាមដោយសទ្ធា

ព្រមគ្នាធ្វើទាន។

**សមគ្គជន** *ន.* (បា.) ជនជាសត្រូវ, បច្ចាមិត្ត :

**ពាក្យភាព្យ**

នៅក្នុងភូមិស្វាត់ ត្រូវតែប្រយ័ត្ន សបត្តជន
ក្រែងវាលៃលក លបចូលមកប្លន់ កម្លាំងយើងអន់
ពុំអាចធន់បាន។

**សមន្ធការ** *ន.* (បា. សំ.) សភាពដែលធ្វើឱ្យងងឹតសូន្យដូចជាខ្វាក់, ដំណើរងងឹតសូន្យឈឹង :

**ពាក្យភាព្យ**

សមន្ធការ ជាអន្ធពាល ប្រដូចនឹងខ្វាក់
ងងឹតសូន្យសុង រិងស៊ីងទើសទាក់ លុះតែមានអ្នក-
នាំផ្លូវទើបកើត។

**សមរ** *ន.* ការរឭក, ការចងចាំ, ដំណើរនឹកឃើញមិនចេះភ្លេច; សេចក្ដីស្រលាញ់អស់ពីចិត្ត។ *គុ.* ជាទីស្រលាញ់ជាប់ចិត្ត; ដែលស្ម័គ្រស្លាប់ស្ម័គ្ររស់ជាមួយ :

**ពាក្យភាព្យ**

ហៃកែវសមរមិត្ត ចូរកុំគិតពីក្តីក្រ ព្រោះយើងប្រព្រឹត្តល្អ
តំណាសុខមុខតែមាន។

**សមិទ្ធិ** *ន.* (បា.) សេចក្ដីសម្រេច; សេចក្ដីកើតការ, ការសម្រេចប្រយោជន៍ដ៏ស្ដុកស្ដម្ភ, សំរឹទ្ធិ, លទ្ធផលដែលសម្រេចបានពិតៗ ដូចជាការកសាងសាលារៀន, ការលើកថ្នល់ឬលើកទំនប់ទឹកជាប្រយោជន៍សាធារណៈជាដើម :

**សមិទ្ធុបាយ** ឬ **សមិទ្ធោបាយ** *ន.* (បា. «**សមិទ្ធិ + ឧបាយ**» ) ឧបាយនៃសេចក្ដីសម្រេច...:

**ពាក្យកាព្យ**

| | | |
|---|---|---|
| កម្ពុជរដ្ឋ | ឯករាជ្យ | ទៀងទាត់ |
| អព្យាក្រឹតា | រដ្ឋរាស្ត្រនិយម | សង្គមសត្យា |
| កាន់ពុទ្ធសាសនា | មានក្ដីសុខស្ងប់។ | |
| សមិទ្ធិកើត | សុទ្ធតែឆើតៗ | ពីមួយទៅដប់ |
| ពីដប់ទៅរយ | រាប់រយក្រចប់ | ចម្រើនគ្រប់សព្វ |
| | ដូចផ្សិតត្រូវភ្លៀង។ | |

**សមិទ្ធន៍** *ន.* ឬ *គុ.* គ្រឿងឆេះ; ដែលសម្រាប់ដុត, ដែលសម្រាប់ឆេះ; ឧស :

**ពាក្យកាព្យ**

| | | |
|---|---|---|
| ភ្លើងឆេះព្រោះសមិទ្ធន៍ | សត្វទាក់ទិន | ព្រោះតណ្ហា |
| ជាគ្រឿងដុតអាត្មា | ឱ្យក្ដៅផ្សា | ឥតស្រាកស្រាន្ត។ |

**សម្ភាយ** *គុ.* សាមញ្ញ, ដែលជាធម្មតា, រាយរង, បន្ទាប់បន្សំ; ដែលរាប់រយរាប់ពាន់ :

**ពាក្យកាព្យ**

ការក្រគិតងាយ    ការសម្ទាយជាកំរោល    សន្សឹមកុំបំបោល

ក្រែងពុំដល់ដូចប្រាថ្នា។

**សម្ពន្ធី** *ត្.* (បា.) ដែលជាប់តគ្នា, ដែលចងភ្ជាប់គ្នា, ដែលទាក់ទងរកគ្នា; បើស្ត្រីជា **សម្ពន្ធិនី** :

**ពាក្យកាព្យ**

រីសម្ពន្ធី    សម្ពន្ធិនី    ពេញទាំងភូមិស្រុក

រាប់គ្នាជិតដិត    ស្នាលស្និទ្ធពេញមុខ    ពុំដែលមានទុក្ខ-

ព្រួយព្រោះឈ្លោះឡើយ។

**សម្ពរ** *ន.* (បា. សំ. **សំវរ** ឬ ប្រើជា **សម្ពរ** ក៏មានខ្លះ) ការសង្រួម, ការស្ងៀមស្ងប់, ស្រគត់ស្រគំ, រម្យទម :

**ពាក្យកាព្យ**

រីអ្នកត្រេកអរ    ចំពោះសីលធម៌    ត្រូវមានសម្ពរ

ឥន្ទ្រិយប្រាំមួយ    ជាត្រួយសំវរ    ទើបមានអំណរ

ទាំងខ្លួនទាំងគេ។

**សម្ពល** *ន.* (បា. សំ. ឬប្រើជា **សំវល** ក៏មានខ្លះ) ស្បៀងសម្រាប់ដើរផ្លូវ, ស្បៀងលៀងជីវិតតាមផ្លូវឆ្ងាយ :

**ពាក្យកាព្យ**

ដូចកងងល់    លុះបានសម្ពល    ដែលភរិយាក្មេង

ចាត់ចែងឱ្យស្រេច សម្រេចចិត្តឯង ប្រចុយចេញស្វែង

រកខ្ញុំប្រុសស្រី។

ឱ្យមកបម្រើ ភរិយាសើរើ ជួជាតិអប្រិយ

ឱ្យតែគាប់ចិត្ត អាណិតមកប្ដី ខុសត្រូវអ្វីៗ

តាចាស់ឥតគិត។

**សម្ភាពន៍** ឬ **សម្ភាវនៈ** *ន* (បា. សំ. **សម្ភាវន** ឬ សំ. **សំភាវន**) សេចក្ដីសរសើរ, ការស្ងើចសរសើរ។ ខ្មែរប្រើជា *គុ.* ក៏មាន :

**ពាក្យភាព្យ**

នាអ្នកកាន់ល្អ ទោះបីខ្សត់ក្រ ចំណេះទន់ទាប

តែងបានទទួល នូវពាក្យសម្ភាពន៍ កើតទ្រព្យកើតលាភ

រៀងរាបមិនដាច់។

**សម្ភិត** ឬ **សម្ភីត** *កិ.* ឬ *គុ.* (បា. សំ.) ភ័យខ្លាំង, ភ័យចំប្រប់; ដែលខ្លាចខ្លាំង :

**ពាក្យភាព្យ**

ព្រឹកមិញចូលព្រៃ ស្រាប់តែមានភ័យ ពុំបានជាគិត

ប្រទះដំរី- មួយគួរសម្ភិត ឃើញភ្លាមខ្ញុំមឹត

ឥតងាកមើលក្រោយ។

**សម្មុជ្ជនី** *ន.* (បា.) អំបោស :

**ពាក្យភាព្យ**

នាងទេពធីតាឈ្មោះលាជា ម្ដីម្នាចុះមកក្នុងរាត្រី ដៃកាន់សម្មជ្ជនី

**សាកិយានី** *ន.* (បា.) ស្ត្រីជាតិសក្យៈ :

**ពាក្យកាព្យ**

កាលព្រះសិទ្ធត្ថ ស្ដេចទ្រង់និវត្ត ពីរាជោទ្យាន
មកដល់រាជវាំង ពេលនោះមែនមាន កញ្ញាស្អាតស្អាន
សាកិយានី។

នាងជាស្រីស្នំ រូបឆោមឧត្តម នាមគោតមី
បានពោលសរសើរ សិរីសួស្ដី នៃព្រះនរបតី
ជាព្រះមហាសត្ត។

**សាណិ** ឬ **សាណី** *ន.* (បា. **សាណិ**) វាំងនន, រនាំង; ឆាក; ឡប់ឡែ :

**ពាក្យកាព្យ**

ពួកក្មេងស្រីៗ នៅក្នុងសាណី ស្វរសើចកក្អឹក
ខ្លះចរចាគ្នា ថាស្អែកពីព្រឹក ត្រូវរៀបបាយទឹក
ទទួលភ្ញៀវយើង។

**សាទិន** *ន.*(សំ.) អ្នកជិះសេះ; ទាហានសេះ; សារថី; ទម័កសត្វពាហនៈ :

**ពាក្យកាព្យ**

ទាហានសាទិន មានចិត្តមិនជិន ក្លាហានសង្វាត
បំផាយសេះចូល ពុះពារគគាត ដេញខ្មាំងឱ្យឃ្លាត
រវាតដៃថយ។

**សាទុភោជន** *ន.* (ឆា.) ភោជនឆ្ងាញ់, អាហារឆ្ងាញ់ពិសា ៖

**ពាក្យកាព្យ**

| | | |
|---|---|---|
| សេចក្ដីស្និទ្ធស្នាល | មានរសត្រកាល | ពិសាពេកពន់ |
| ពិសាជាងរស | សាទុភោជន | ទោះទីនៅអន់ |
| | ចង្អៀតក៏ដោយ។ | |

**សាប** *កិ.* បាចគ្រាប់ស្រូវពូជដែលត្រាំហើយទៅក្នុងទីថ្នាលដើម្បីឱ្យដុះជាសំណាប ៖

**ពាក្យកាព្យ**

| | | |
|---|---|---|
| កុំសាបពូជពាល | ក្រែងនាំឱ្យរាល | ពេញទាំងភូមិស្រុក |
| ត្រូវសាបពូជប្រាជ្ញ | អាចនាំឱ្យសុខ | គ្មានការណ៍អុកឡុក |
| | ស្រណុកនិត្យនៅ។ | |

**សាមគ្គីភេទ** *ន.* ការបែកសាមគ្គី; សាមគ្គីភេទកើតពីមានះ គឺការប្រកាន់រៀងរាល់ខ្លួន ជាប្រភពមានត្រឹមតែសេចក្ដីវិនាសជាលទ្ធផលផ្ដល់សេចក្ដីទុក្ខឱ្យជាដរាប ៖

**ពាក្យកាព្យ**

| | | |
|---|---|---|
| សាមគ្គីភេទ | ជាមូលហេតុ | បើកឱ្យសត្រូវ |
| ចូលលុករុករាន | អស់ឥតមានផ្លូវ | ទោះធ្វើម្ដេចក្ដូវ |
| | ក៏កែពុំបាន។ | |
| ដូចរដ្ឋរដ្ឋី | មានសាមគ្គី | តាំងពីបុរាណ |

វស្សការៈ មន្ត្រីឈ្លានពាន ប្រើល្បិចចូលបាន
ញុះញង់ខ្មៅខ្ចី។
យកបានប្រទេស ដែលគេប្រហែស ឱ្យបែកសាមគ្គី
ប្រើខ្សឹបងាយៗ ឥតចាយរូបិយ ថែមទាំងមានល្បី
ថាឈ្លាសផងទៀត។
ហេតុនេះគួរខ្លាច ប្រយ័ត្នកំណាច លបចូលជ្រៀតបៀត
ធ្វើសាមគ្គី ឱ្យខូចបង់សៀត បែកហើយផ្សារទៀត
ពុំងាយជិតឡើយ។

**សាមាន្យ** *គុ.* (សំ.) សាធារណៈ; ដែលជាធម្មតា; ដែលស្មើៗតែគ្នា; ដែលរាប់រយរាប់ពាន់ :

**ពាក្យកាព្យ**

វីចោរសាមាន្យ វាលួចគេបាន គ្រាន់តែស៊ីផឹក
ពុំគិតអត់ឃ្លាន បានល្ងាចស៊ីព្រឹក វាល់ល្ងាចវវឹក
ធ្វើទុក្ខប្រពន្ធ។

**សាមិក** *ន.* (បា.) ម្ចាស់, ម្ចាស់របស់; ប្ដី; ចៅហ្វាយ, នាយ :

**ពាក្យកាព្យ**

អាចោរសាមាន្យ យប់លួចគេបាន ធ្វើហាក់ងូតទឹក
លាក់ទ្រព្យផ្ដេសផ្ដាស ច្រឡាសទាល់ព្រឹក ត្រាតែសាមិក

នៃទ្រព្យគេឃើញ។

**សាយធាត** ឬ **សាយម្បាត** *ន.* វេលាល្ងាចនិងវេលាព្រឹក :

**ពាក្យកាព្យ**

រាល់សាយម្បាត ត្រូវខំសង្វាត រៀនសូត្រកុំធ្វេស
ធ្វេសម្ដងមិនអី កុំឱ្យទ្វេធ្វេស ទ្វេធ្វេសប្រហែស
ប្រហែសបង់ទ្រព្យ។

**សារព័ន** *ខ. ស.* ឬ *គុ.* សព្វ, សរពើ :

**ពាក្យកាព្យ**

សព្វសារព័ន ត្រូវមានគ្រប់គ្រាន់ កុំឱ្យមានខ្វះ
អ្វីៗក៏ដោយ នេះខ្វះនោះខ្វះ ណាដែលកន្លះ
ត្រូវដាក់បន្ថែម។

**សុរិយង្គ** *ន.* (បា.) អង្គព្រះអាទិត្យ គឺតួព្រះអាទិត្យ, ដួងព្រះអាទិត្យ :

**ពាក្យកាព្យ**

វីព្រះសុរិយង្គ ព្រះបាទឯកអង្គ ទ្រង់ធម៌សត្យា
ណែនាំពលរដ្ឋ ឱ្យកាន់សីលា សឹងបានសុខា
ក្ដីស្ងប់ជានិច្ច។

**សុខជ្ជា** *ន.* (បា.) វិជ្ជាល្អ, ចំណេះឃោងអាត្មាឱ្យបានទ្រព្យធនបុណ្យសក្តិ
សុខចម្រើន :

**ពាក្យកាព្យ**

វីសុវិជ្ជា ចូរកូនរាល់គ្នា ប្រឹងរៀនកុំធ្លោយ
ព្រោះជាចំណេះ កម្លាត់កម្សោយ រៀនចេះតែងឱ្យ
សម្រេចផលល្អ។

**សុស្និន ឬ សុស្និ៍** *គុ.* (សំ.) ដែលមានកម្ដៅ; មានពន្លឺ; មានតេជះ, មាន អំណាច, ក្លាហាន; ហ៊ឺកហ៊ាក់ :

**ពាក្យកាព្យ**

កងទ័ពសុស្និន លើកចូលសង្គ្រាម ប៉ុនកលមាយា
ពុះពារពួកខ្មាំង ខ្លាំងក្រៃមហិមា ពេញជាយោធា
ជំនាញអាចហាន។

**ស៊ូ** *កិ.* ប្រថុយ, ហ៊ាន; ខំប្រឹងមិនលែង, តាំងព្យាយាមមាំ :

**តស៊ូ** *កិ.* តមិនលែង, តដោយប្រថុយ :

**ពាក្យកាព្យ**

ស៊ូខំតស៊ូ ធ្វើតាមគំរូ អ្នកប្រាជ្ញព្រេងនាយ
ស៊ូដាច់ស៊ូបង់ ព្រោះចង់ពណ្ណរាយ ស៊ូកុំឱ្យក្លាយ
ទៅជាទុជ៌ន។

**សួគ៌ា** *ន.* ទេវលោក :

**ពាក្យកាព្យ**

អ្នកធ្វើបុណ្យទាន គេតែងតែបាន ផលានិសង្ស

ជិតអស់ជីវិត ចិត្តគិតឆ្ពោះត្រង់ បុណ្យដែលផ្ចិតផ្ចង់
ផ្តល់សួគ៌ាឱ្យ។
ឃើញក្នុងមនោ បុណ្យលេចចេញឆ្ពោ ព្រោះផលអំណោយ
បុណ្យទានដែលធ្វើ ជូនឮដង្ហោយ ស្រែកហៅថា
លះលោកនេះទៅ។
ទៅនៅភពថ្មី ដែលជាបុរី សួគ៌សុខមាននៅ
ជានិច្ចនិរន្តរ៍ ឥតមានក្តីក្តៅ អ្នកកុំទ្រាំនៅ
ឋានមនុស្សឃ្យូរពេក។

**សេចគ្រេច** *ន.* សេចក្តីរាក់ជ្រៅ, ការខុសត្រូវ, ការហ្មត់ចត់; អាថ៌សេចក្តី :

**ពាក្យកាព្យ**

ស្រដីឱ្យស្រួលស្រេច គិតសេចគ្រេចកុំគិតងាយ រំពឹងឱ្យវែងឆ្ងាយ
យល់លង្វែកពាក្យលោកថាៗ

**សេដ្ឋា, សេដ្ឋោ, សេដ្ឋំ** *គុ.* ប្រសើរបំផុត :

**ពាក្យកាព្យ**

បុរសសេដ្ឋោ ស្ត្រីសេដ្ឋា នៅក្នុងរដ្ឋណា
រដ្ឋនោះសេដ្ឋំ អាចជួយសព្វគ្រប់ ទប់រដ្ឋឱ្យខ្លាំង
ពុំសូវមានខ្មាំង ហ៊ានមើលងាយឡើយ។

**សេណី** *ន.* (**បា.** សេណិ) ពួក, កង, ក្រុម; ពួកមនុស្សមានជាតិស្មើគ្នាមានសិល្បៈប្រហែលៗគ្នា។ ខ្មែរសំដៅសេចក្តីថា «អ្នកមានជាតិត្រកូលស្មើគ្នា

មានចំណេះវិជ្ជាប្រហែលៗគ្នា មានយសសក្តិស្មើៗគ្នា»។

**ពាក្យភាព្យ**

| | | |
|---|---|---|
| នៅក្នុងបុរី | ដែលមានសេណី | ជំនាញច្រើនក្រៃ |
| មានសាមគ្គី | ជាហេតុបច្ច័យ | ញុំាងរដ្ឋឱ្យថ្លៃ |

ចម្រើនសុខស្ងប់។

**សេតម្ពរ** *ន.* (**ឆា.**) សំពត់ស្លៀកដណ្ដប់មានពណ៌ស។ អ្នកដែលប្រកាន់ស្លៀកដណ្ដប់ចំពោះតែសំពត់មានពណ៌ស តមមិនប្រើប្រាស់សំពត់ពណ៌ឯទៀត; អ្នកស្លៀកដណ្ដប់សកាន់សីល :

**ពាក្យភាព្យ**

| | | |
|---|---|---|
| ពួកសេតម្ពរ | កាន់សីលសង្វរ | និងធម៌សុចរិត |
| លះបង់អំពើ | ដែលទាញនាំចិត្ត | ឱ្យលង់គំនិត |

ប្រព្រឹត្តធម៌ខ្មៅ។

**សេវនៈ** ឬ **សេវនា** *ន.* (**សេវន** ឬ **សេវនា**; **សំ. សេវន**) ការសេពគប់, ការគប់រក, ការរាប់រក, ការរាប់រកយកជាគ្នា; ការជិតដិតស្និទ្ធស្នាល : ពាក្យកាព្យប្រើជា **សេវ័ន** ក៏បាន :

**ពាក្យភាព្យ**

| | | |
|---|---|---|
| ពាលសេវ័ន | រមែងតែភ័ន្ត | គំនិតតាមពាល |
| ប្រព្រឹត្តទុច្ចរិត | មានចិត្តរង្គាល | រង្គំរោលរាល |

ដោយទុក្ខរង្កើ។

បណ្ឌិតសេវ៉ន រមែងគ្រប់គ្រាន់ ដោយក្ដីអើពើ
ស្អប់ខ្ពើមទុច្ចរិត មិនស្បិតចង់ធ្វើ ទោះប៉ះពាល់លើ
ក៏ផាត់ចេញបាន។

**សេវាល** *ន.* (បា.; ប្រើជា **សេវាលិកា** ក៏មាន) សារាយ; ចក :

**ពាក្យកាព្យ**

ខ្លួនប្អូនដូចសេវ៉ាល ព្រះឱ្យបាលដូចកល់វ៉ាត អាចបក់ប្អូនឱ្យឃ្លាត
ចេញទៅឆ្ងាយក៏សឹងបាន។

**សោកី** *គុ.* ឬ *ន.* (បា.) ដែលមានសោកឬអ្នកដែលមានសោក; បើស្ត្រីជា **សោកិនី** :

**ពាក្យកាព្យ**

បុរសសោកី និងសោកិនី ស្ត្រីក្នុងលោកា
តែងគេចពុំផុត ពីកាមតណ្ហា ក្នុងជាតិណាៗ
ក៏មានសោកស្ដាយ។

**សោធនី** *ន.* (បា.) អំបោស, ច្រាស; ប្រែង :

**ពាក្យកាព្យ**

គ្រានោះដូនជី កាន់សោធនី បោសទីក្បែរតូប
ទីនោះមានផ្កា ធុំក្លិនក្រអូប ច្រមុះស្រងស្រូប
ភ្លេចធម៌កម្មដ្ឋាន។

**សោបាន** *ន.* (បា. សំ.) ជណ្ដើរ; បង្អោង (បា.ប្រើជា **សោបានា** ក៏មាន):

**ពាក្យភាញ**

ស្ដេចស្ដែងទ្រង់បាន ឡើងតាមសោបាន ចូលថ្កានប្រាសាទ
រាជកញ្ញា ប្រសើរស្អាងស្អាត សម្រាលព្រះបាទ
ពុំឱ្យឮសូរ។

**នាគសោបាន** *ន.* ជណ្ដើរមានរូបនាគ (ជណ្ដើរនាគ) :

**ពាក្យភាញ**

លុះហែសពរាជា មកដល់នាមេរុដ្ឋាន មាននាគសោបាន
គេបានយោងព្រះសពឡើង។
តម្កល់លើបញ្ចា ដ៏ថ្លៃថ្លារុងរឿងថ្កើង មន្ត្រីសឹងកាន់គ្រឿង
សក្ការៈថ្វាយព្រះសព។

**សោភ័ណ** ឬ **សោភ័ន** *គុ.* (**បា. សោភន** ឬ **សោភណ**) ល្អ; ហ្មត់ចត់ :

**ពាក្យភាញ**

ផ្ទះថ្មច្រើនជាន់ រាប់បានច្រើនពាន់ សោភ័ណពិសី
នៅក្រុងភ្នំពេញ ដែលរៀបចំថ្មី នៅនាលោកិយ
ជាក្រុងមួយដែរ។
ភ្នំពេញយូរទៅ រឹងរឹតត្រឹមត្រូវ ដោយស្នាដៃខ្មែរ
សម័យជាន់ក្រោយ ខិតខំបង្វែរ ពង្រីកបំបែរ
ឱ្យធំឡើងទៀត។

**សៅដៅ** *កិ. ១.* ឬ *គុ.* (**ព. បុ.**) ពាយងាយ, ខ្ជីខ្ជា, ផ្ដេសផ្ដាស :

**ពាក្យកាព្យ**

ចាស់ទុំតែងថា ជនទ្រើសពាលា ទ្រនង់យង់ឃ្នង
ច្រើនធ្វើសៅដៅ ឃោរឃៅកន្លង អស់ញាតិផៅផង
គេស្អប់គេខ្ពើម។

**ស្ពាល** *ក.* ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ **ស្និទ្ធ** ថា : **ស្និទ្ធស្នាល** ស្និទ្ធជិតដិតនឹងគ្នា, ស្និទ្ធឥតរង្កៀស :

**ពាក្យកាព្យ**

សេចក្តីស្និទ្ធស្នាល មានរសត្រកាល ប្រសើរថ្លៃថ្លា
ជាងអស់រសផង ដែលឆ្ងាញ់ពីសា ឥតមានភោជនណា
ប្រដូចស្មើបាន។

ដ្បិតរសភោជន ទោះឆ្ងាញ់ពេកពន់ ចិញ្ចឹមរូបប្រាណ
ឆ្ងាញ់តែមួយពេល ពុំយូរប៉ុន្មាន ស្និទ្ធស្នាលឆ្ងាញ់បាន
អស់កាលយូរលង់។

**ស្នេហ៍ស្នង** *ន.* សេចក្តីជាប់ចិត្តស្អិតក្រៃពេកដោយអាចនឹងចេញខ្លួនស្នងគេបាន :

**ពាក្យកាព្យ**

ឱមាសស្នេហ៍ស្នង ម្តេចក៏ឱ្យបង ទទួលរងទុក្ខ
ចំណង់បើដល់ ទៅពេលខាងមុខ សមនឹងផ្តល់ទុក្ខ
ជាងនេះទេដឹង?...។

**ស្នេហា** *ន.* ឬ *គុ.* សេចក្ដីស្រលាញ់ស្និទ្ធ, សេចក្ដីស្រលាញ់ជាប់ចិត្ត, ស្និត ដូចជ័រ :

**ពាក្យកាព្យ**

ហៃមាសស្នេហា ក្រែងបានផ្ដាំថា ឱ្យខ្ញុំចូលមក
ពុំមែនទេឬ កែវថ្លៃពន្លក ខ្ញុំបានជាមក-
ហើយឱ្យទៅណា?...។

**ស្នេហ៍ហឹត** *កិ.* ឬ *ន.* ស្រលាញ់ជាប់ចិត្តស្អិតល្អួត កាលបើភ្ជួកនឹកដល់ក៏ ខ្វល់ចិត្តនាំដកដង្ហើមធំវែងៗញយៗ ដូចមនុស្ស ហឹត :

**ពាក្យកាព្យ**

ស្នេហាស្នេហ៍ហឹត នាំឱ្យផ្ដាក់ផ្ដឹត ភ្លេចការរបរ
ទោះនៅក្នុងផ្ទះ ទោះបីចេញចរ គ្មានចិត្តត្រេកអរ
ចំពោះការងារ។

**ស្នេហ៍ហៃ** *កិ.* ឬ *ន.* ស្នេហាស៊ប់ងងុលងប់ហួសហេតុថែមទាំងហៃហៃ ដោយម៉ឺងម៉ាត់ប្រុងប្រយ័ត្នជានិច្ចមិនឱ្យគូស្នេហាងាកចិត្តពីខ្លួនផងទៀត :

**ពាក្យកាព្យ**

ស្នេហាស្នេហ៍ហៃ ជាតួចង្រៃ បំផ្លាញទ្រព្យ
ងប់ចិត្តជោកជាក់ ធ្លាក់ការសិក្សា នាំឱ្យអាត្មា
ខូចកេរ្តិ៍ខូចឈ្មោះ។

**ស្បែ** ៥. ពាក្យសម្រាប់និយាយផ្សំនឹងពាក្យ **ស្បថ** ថា : **ស្បថស្បែ** ឬ **ស្បែស្បថ** ស្បថយ៉ាងស្រាល (ឥតមានសូត្រសច្ចាប្រណិធាន) :

**ពាក្យកាព្យ**

កូនចៅកុំប៊ាន ស្បែស្បថបំពាន ខុសច្បាប់បញ្ញត្ត
ចាស់ទុំហាមប្រាម ថាត្រូវប្រយ័ត្ន ស្បថខុសតែងបាត់
ប្រយោជន៍ឬខ្លួន។
គួរខ្លាចគួរស្ដាយ ក្រែងក្ដីអន្តរាយ កើតតាមគាប់ជួន
នៅនាលោកិយ ឥតអ្វីជួយសួន- គ្រងរក្សាខ្លួន
រងសុទ្ធតែបាប។

**ស្នា** ៨. ប៉ែកអវយវៈត្រង់ខាងលើគល់ដៃមនុស្សឬត្រង់ខាងលើគល់ជើងមុខសត្វតិរច្ឆាន :

**ពាក្យកាព្យ**

ចាស់ទុំលោកថា អម្រែកនិងស្នា ត្រូវស្រែកសួរគ្នា
ថាអញនិងឯង ពុំក្រែងចេស្ដា ឯងធ្ងន់ប៉ុនណា
អញខ្លាំងប៉ុននោះ។
បើឯងធ្ងន់ជាង សង្កត់អញភ្លាង អញចាញ់ឯងស្មោះ
បើអញខ្លាំងជាង អញរែករត់ផ្លោះ លឿនស្មៅឥតខ្ចោះ
ហៅថាអញឈ្នះ។

**ស្មាក្តី** *ន.* អ្នកកាន់ក្តី :

**ពាក្យកាព្យ**

រីអ្នកស្មាក្តី ប្រយ័ត្នកុំបី កាន់ក្តីខុសច្បាប់
ដ្បិតធ្លាប់មានរឿង ពីព្រេងមកស្រាប់ កាន់ក្តីខុសច្បាប់
បានបាបក្រាស់ក្រៃ។

ច្បាប់ដ៏បវរ ប្រាប់យុត្តិធម៌ ត្រឹមត្រូវប្រពៃ
អ្នកកាន់ក្តីគេ កុំកែបំភ្លៃ ឱ្យហួសវិស័យ
នៃមាត្រាច្បាប់។

**ស្ទូស្រករ** *ន.* គូស្វាមីភរិយាដែលមានអាយុស្រករគ្នា :

**ពាក្យកាព្យ**

រីគូស្រករ ប្រសើរបវរ ពុំសូវដែលមាន
ច្រើនតែលើសខ្វះ ខែឆ្នាំធនធាន បើបានជាមាន
ហៅពេញមានភ័ព្វ។

**ស្រី** *ន.* ពាក្យសម្រាប់ប្រើជាសាធារណៈ ឃ្លាតមកពីពាក្យសំស្រ្កឹតថា ស្ត្រី គឺមនុស្សជាតិដែលមានភេទទីទៃពីប្រុស :

**ពាក្យកាព្យ**

ស្រីប្រុសទាំងទ្វី ជាគូមានពី- បុរាណព្រេងនាយ
ស្រីជាប្រពន្ធ ប្រុសទោះសម្មាយ បណ្ឌិតទាំងឡាយ
ឱ្យឈ្មោះថាប្តី។

ស្ត្រីនិងបុរស ក្នុងលោកទាំងអស់ ភរិយាស្វាមី
គឺប្ដីប្រពន្ធ ហ្នឹងឯងលោកស្ដី ជនក្នុងលោកិយ
ហៅបានតាមថ្នាក់។

ប្ដីជាអ្នករក ទ្រព្យធនបានមក ប្រពន្ធទុកដាក់
ចាស់ទុំបុរាណ បានពោលបញ្ជាក់ ឱ្យនាងឱ្យអ្នក
ចងចាំគ្រប់ប្រាណ។

សំណាបយោងដី រីឯស្រីៗ យោងប្រុសសាមន្យ
ទោះមារយាទខ្សោយ- ក៏ដោយបើបាន ស្រីមានសន្ដាន
ខ្ជាប់ខ្ជួនមួនមាំ។

តែងបានចម្រើន ទ្រព្យាកើតកើន ព្រោះស្រីថែទាំ
ចាត់ចែងទុកដាក់ ចេះលាក់សន្សំ សង្វាតខិតខំ
រក្សាឱ្យគង់។

នេះនឹងសម្ដែង បរិយាយចារចែង ដើមបទអដ្ឋា-
ហិ ឋានេហិ សុចរិតា ឥត្ថីលក្ខណា
មង្គលច្នេះពិត។

ប្រែថាស្រីជា កើតកបលក្ខណា ដោយនូវសុចរិត
មង្គលប្រាំបី ឱ្យស្រីពិនិត្យ ចាំយកជាក្រឹត្យ
គ្រប់រូបស្រីៗ។

ដើមបទពណ៌នា លោកថាស្រីជា សុចរិតភក្តី
ឫករាបស្រគត់ ផ្គង់ផ្គត់សម្ដី ការកេរខ្មាសស្រី
បរិសុទ្ធមែនមួន។

លោកថាស្រីត្រង់ កាន់សុចរិតផ្គង់ គំនិតចេះស្ងួន
អស់ទ្រព្យសម្បត្តិ ប្រយ័ត្នថៃធួន ទុកដាក់ខ្ជាប់ខ្ជួន
មិនមានប្រមាទ។

លោកថាស្រីគាប់ កាន់សុចរិតខ្ជាប់ ឧស្សាហ៍សង្វាត
ធ្វើការសន្សំ តឿនខ្ញុំឱ្យឃ្លាត ឱ្យខ្ពីសង្វាត
មិនមានស្មៀមដៃ។

លោកថាស្រីប្រាជ្ញ សុចរិតអង់អាច ចេះអធ្យាស្រ័យ
ញាតិព្រៀងទៅមក រាប់រករួសរៃ ទោះជនដទៃ
ក៏រាប់តាមពិត។

លោកថាស្រីស្អាត សុចរិតគ្មានឃ្លាត មែនមានគំនិត
ចេះរៀបអាហារ ភ្នាក់ងារស្រីពិត រណ្ដាប់ផ្គាប់ចិត្ត
ប្ដីគ្រប់វេលា។

លោកថាស្រីស្មោះ កាន់សុចរិតឆ្ពោះ ចាំចិត្តស្នេហា
តែនឹងអង្គប្ដី ឥតបីរេរា ស្ម័គ្រស្មោះស្មើជា
និត្យនៅរៀបរៀង។

លោកថាស្រីស្លូត សុចរិតរហូត អបអត់ឥតល្អៀង
តាមពាក្យប្ដីផ្ដាំ ចងចាំទុកទៀង ពោលពាក្យមិនឃ្លៀង
មិនឃ្លាតសត្យា។

លោកថាស្រីស្មើ សុចរិតសរពើ អាចរងធានា
ទម្ងន់ចិត្តប្ដី ទោះបីទុក្ខា ខ្សត់ក្រម្ដេចម្ដា
អាចទទួលប្រាណ។

សុចរិតប្រាំបី ជាមង្គលស្រី ប្រសើរក្រមាន
អ្វីមកផ្ទឹមផ្ទាល់ ឱ្យដល់នេះបាន ស្រីណាអាចធ្យាន
ចិត្តចាំរៀនយក។

ទាំងប្រាំបីច្បាប់ ហៅស្រីមហាគាប់ លោកិយកម្រ
ស្រីកាន់សុចរិត ប្រព្រឹត្តល្អិតល្អ ស្រីណាថាក្រ
ធ្វើតាមពុំបាន។

លោកថាស្រីនោះ ចិត្តអាក្រក់ស្មោះ ស្អប់ដំបូន្មាន
ផ្សាដោយសារចិត្ត ទុច្ចរិតសន្ដាន បង្ហិនធនធាន
ចើកអាសមាយា។

ក្ដីជួច្រើនកល ក្រដឹងចេះដល់ លែបខាយពុតវា
បើចិត្តចង់ស្រាប់ ចង់ស្ដាប់ហាក់ជា ងាយដាយសោះសា
ចេះឯងដឹងឯង។

ឯត្រង់ច្បាប់ល្អ តិចទេយល់ក្រ កម្រក្រៃលែង
ក្រព្រោះមិនចង់ ប្រុងអង្គឱ្យស្ដែង ក្រដោយចិត្តល្បែង
ចំណង់តណ្ហា។

អំពើសុចរិត អធ្យាស្រ័យចិត្ត សម្អាតឧស្សាហ៍
ស្មើស្មោះស្លូតត្រង់ ផ្គត់ផ្គង់ក្រឹត្យា ប្រាំបីនេះណា
សុចរិតប្រាកដ។

ឯសុចរិតស្រី ផ្គត់ផ្គង់ស្វាមី លោកឱ្យអបអត់
ឱនអៀនចិត្តទន់ ចេះគន់បែបបទ តាមតែចិត្តពត់
ម្ដេចៗតាមបាន។

មិនមានប្រកែក មិនមានជជែក ថាធ្វើមិនបាន
ទោះអៀនអន់អត់ សង្កត់ចិត្តប្រាណ តាមចិត្តប្ដីធ្យាន
ម្ដេចៗមិនថា។

ច្បាប់នេះគួរស្រី នៅនាលោកិយ ផ្ចង់ចិត្តឧស្សាហ៍
កាន់ក្ដីសុចរិត ជាក្រឹត្យថ្លៃថ្លា ឱ្យខ្ជាប់ជាក់ជា
ចរិតសព្វថ្ងៃ។

កាន់បានដូច្នោះ នឹងឮកេរ្ដិ៍ឈ្មោះ ប្រសើរពេកក្រៃ
នឹងបានសាន្តសុខ ចៀសទុក្ខចង្រៃ ដល់បរលោកថ្លៃ
សោយសុខសួគ៌សិទ្ធ។

សម្ដែងសេចក្ដី ពីមង្គលស្រី ប្រសើរពេកពិត
គ្រប់ទាំងប្រាំបី ក្រឹត្យស្រីសុចរិត ថែងចប់ភាសិត
តាមព្រះបាលី។

**ស្លាក** *ន.* (**ឆា. សលាកា**) សំបុត្រជាកំណត់តូចៗ ជាគ្រឿងសម្គាល់ឈ្មោះជាដើម; ឆ្នោត; ទីវ; ខ្នាច់ :

**ពាក្យកាព្យ**

រីការបោះឆ្នោត ត្រូវកុំបញ្ឆោត បន្ទំស្លាកគ្នា
ត្រូវបោះត្រង់ៗ ផ្ទង់រាល់អាត្មា ទើបលោកហៅថា
ស្លាកត្រូវតាមច្បាប់។

**ស្វាង្គ** *គុ.* ដែលមានរូបឆោមល្អ, សមរម្យ; បើស្ត្រីជា **ស្វាង្គា** :

**ពាក្យកាព្យ**

ស្វាង្គស្វាង្គា ស្វាមីភរិយា មានភ័ព្វបវរ
តាំងពីចាប់ដៃ ជាគូស្រករ មានចិត្តត្រេកអរ
ចំពោះបុណ្យទាន។

**ស្វាង្គនា** *ន.* ស្ត្រីមានរូបល្អ, នាងឆើតឆោម :

**ពាក្យកាព្យ**

រីស្វាង្គនា បើមានវិទ្យា គ្រប់គ្រាន់ប្រពៃ
រមែងមានយស ខ្ពង់ខ្ពស់ពេកក្រៃ សឹងមានតម្លៃ
កម្រមានប្រៀប។

**ស្វាន** *ន.* (**សំ.**) សុនខ។ ខ្មែរហៅសំដៅតែ «ឆ្កែព្រៃ» :

**ពាក្យកាព្យ**

សម័យបុរាណ ក្នុងព្រៃស្មសាន មានពួកស្វាននៅ
ចាំស៊ីសាកសព ស្រស់ៗឆៅៗ សម័យឥឡូវ
មិនដូចព្រេងនាយ។

**ស្អប់** *កិ.* មិនស្រលាញ់, ទាស់ចិត្តមិនចង់ឱ្យប៉ះអារម្មណ៍ :

**ពាក្យកាព្យ**

ខ្ញៅរែងស្អប់ចេះ ខ្សត់ឥតចំណេះ ស្អប់អ្នកមានទ្រព្យ
ស្រីស្រាលប្រចណ្ឌ រែងស្អប់ខ្ញុំគាប់ ពាលពិតឥតច្បាប់
រែងស្អប់ប្រដៅ។

**ស្អាងស្អាត** *កិ.* តាក់តែងគ្រឿងប្រដាប់ឱ្យស្អាតល្អ :

**ស្អាងស្អាត** *គុ.* ដែលតាក់តែងគ្រឿងប្រដាប់ស្អាតល្អឥតឆ្គង :

**ពាក្យកាព្យ**

ប្រាសាទស្អាងស្អាត សម្រាប់ព្រះបាទ បរមបពិត្រ
ស្ដេចគង់ប្រក្រតី ក្សត្រថ្លៃទ្រង់ឫទ្ធិ ទ្រង់កាន់ទសពិធ
ប្រព្រឹត្តទៀងទាត់។

**ស្អាន** *ឞ.* ពាក្យបរិវារសម្រាប់និយាយផ្សំជាមួយនឹងពាក្យ **ស្អាត** ថា :

**ស្អាតស្អាន** គឺស្អាតប្រពៃ, ស្អាតបាត :

**ពាក្យភាព្យ**

| | | |
|---|---|---|
| ស្រីស្រស់កល្យាណ | រូបឆោមស្អាតស្អាន | គួរចាប់ស្នេហ៍ស្និទ្ធ |
| ទាំងមានវិទ្យា | ប្រាជ្ញាថ្លាពិត | ទាំងមានគំនិត |
| | ជ្រៅជ្រះផងទៀត។ | |

**ហង្ស** *៩.* (**ធា. សំ. ហំស**) ក្ងានព្រៃ :

**ពាក្យភាព្យ**

| | | |
|---|---|---|
| ល្អនេះពេញល្អ | គន់មើលទៅក | មូលដូចកហង្ស |
| គន់មើលទៅមុខ | មុខមូលក្រឡង់ | គួរឱ្យតែចង់ |
| | មើលហើយមើលទៀត។ | |

**ហដ្ឋចោរក** *៩.* ចោរអ្នកលួចឆក់យកអីវ៉ាន់គេក្នុងផ្សារឬទីតាំងរបស់សម្ងាចឱ្យមហាជនមើល :

**ពាក្យភាព្យ**

| | | |
|---|---|---|
| ហដ្ឋចោរក | វារែងលបឆក់ | ទ្រព្យគេឥតក្រែង |
| ច្រើនតែគេចាប់ | បានខ្លួនពុំលែង | ទ្រព្យឆក់ជាក់ស្ដែង |
| | ជាពស្ដុនៅដៃ។ | |
| រួចពីជាប់គុក | នៅតែលុយលុក | ឆក់ទៀតទាំងថ្ងៃ |
| ត្រូវកូនប្រុសស្រី | ចៀសកុំប្រាស្រ័យ | នឹងជនចង្រៃ |
| | នេះដោយដាច់ខាត។ | |

**ហ័តហោង** ឬ **ហាត់ហោង** *គុ.* (**បា. សំ. ហត** «បៀតបៀន; ដែលត្រូវគេបៀតបៀន») ដែលស្ទាត់គួរខ្លាច ព្រោះតែមានសត្រូវចាំបៀតបៀន :

**ពាក្យកាព្យ**

នាព្រៃហ័តហោង សឹងមានគោតខ្លោង សាហាវយង់ឃ្នង
កុំទៅម្នាក់ឯង កណ្ដោងកន្លង ចរចូលម្ដងៗ
ត្រូវឱ្យមានគ្នា។
បើមានគ្រោះកាច ដែលគួរតែខ្លាច ព្រោះការពាធា
នៃសត្វសាហាវ ឬជនពាលា ចរចូលឥតគ្នា
វែងភិតភ័យខ្លាំង។

**ហសិកា** (**សំ.**) *ន.* សំណើច, សំណើចក្អាកក្អាយសប្បាយភ្លេចខ្លួន :

**ពាក្យកាព្យ**

ហៃនាងកញ្ញា ធ្វើហសិកា ត្រូវគិតមុខក្រោយ
គិតការណ៍រាក់ជ្រៅ ពុំត្រូវបណ្ដោយ ឱ្យចិត្តទន់ខ្សោយ
ត្រអាលភ្លេចខ្លួន។

**ហាហៅ** *កិ.* ស្រែកហៅ :

**ពាក្យកាព្យ**

អ្នកមានពូជផៅ ឃើញភ្ញៀវហាហៅ ថៅរៅរាក់ទាក់
ចរចាស្មោះស្មើ អើពើដោយស្ម័គ្រ ហៅលោកហៅអ្នក
តាមការប្រាស្រ័យ។

**ហារអឺៗ** *ន.* ពាក្យបន្ទរក្នុងបទចម្រៀងពួកខ្លះ មានបទអុំទូកពាក្យបួនជាដើម :

**ពាក្យកាព្យ**

បងអុំទូកទៅ បោចស្មៅឃាប្លង យកស្រីទៅផង
ហារអឺៗ បានជាពីរនាក់ ។

**ហាត់ព្យាម** *កិ.* ព្យាយាមហាត់, ហាត់ដោយយកចិត្តទុកដាក់ :

**ពាក្យកាព្យ**

ឧស្សាហ៍ហាត់ព្យាម រមែងមាននាម ថាអ្នកសម្ដី
ពុំសូវមានអន់ ច្រើនចេះខ្មេចខ្ចី ឡើងជាមុនី
ក៏សឹងតែមាន ។

**ហិចហោះ** *កិ.* ហោះភ្លែតចុះភ្លែតឡើង, ហោះផ្សៀលឆ្វាត់សន្ធឹមលន្ធឹម :

**ពាក្យកាព្យ**

ពួកយក្សកំលោះ ស្ទុះឡើងហិចហោះ ផ្ដោះលើជួរភ្នំ
បញ្ចេញឫទ្ធី ជាភ្លើងយ៉ាងធំ ឆេះឆាបរង្គំ
រង្គាលពេញព្រៃ ។

**ហ៊ីង** *ន.* សត្វមួយប្រភេទសន្ដានកង្កែបតែសណ្ឋានមាឌត្រមុលបំប៉ោងខ្លួនបាន, បង្កប់ខ្លួននៅក្នុងដីសើមឬគំនរស្លឹកឈើសើម កាលណាមានភ្លៀងចេញមកខាងក្រៅតែងស្រែកយំឮសូរខ្លាំងហួសមាឌ :

**ពាក្យកាព្យ**

ហ៊ីងខែដើមឆ្នាំ ភ្លៀងធ្លាក់សស្រាំ ចេញយំអឺងអាប់

យំពុំដឹងខ្លួន ថាគេនឹងចាប់ យកទៅសម្លាប់
ងាប់ព្រោះតែមាត់។

ជនពាលឆ្មោះដែរ ពោលពាក្យបៀតបែរ ឥតការទៀងទាត់
និយាយព្រត១ ដោយក្ដីភ្លាំងភ្លាត់ ស្លាប់ដោយសារមាត់
រឥលឥតគ្រឿងទប់។

**ហិមវ័ត ៧.** ដែលមានទឹកសន្សើម :

**ហិមវ័ត ៨.** ភ្នំហិមពាន្ត :

**ពាក្យកាព្យ**

ហិមវ័ត-ហិមវន្ត-និងហេមវា មានន័យដូចគ្នាតែមួយបែប ជាវេវចនៈសម្រាប់អែប
អែបនែបលែបខាយជាជើងកាព្យ។

ជូនប្រើជាពាក្យហេមពាន្ត ឱ្យមានសម្មូស្សស្រស់មិនសាប កវីប្រើតាមលំអានកាព្យ
កំណាព្យសម្បូរណ៍សម្ដីប្រើ។

**ហីនលក្ខណ៍ ៨.** លក្ខណ៍ថោកទាប; ដែលមានលក្ខណ៍ថោក, ថោកឬក, ខាតលក្ខណ៍ :

**ពាក្យកាព្យ**

រីឯហីនលក្ខណ៍ នោះមានបីថ្នាក់ មួយគេឥតហៅ
ខ្លួនដើរជម្រក- មមកចូលទៅ នេះប្រាជ្ញលោកហៅ
ថាហីនលក្ខណា។

ពីរឥតគេសួរ ការណ៍គួរពុំគួរ ខ្លួនចេះតែថា

ប៉ោចៗម្នាក់ឯង ឥតក្រែងនរណា អ្នកប្រាជ្ញលោកថា

កិរិយាហីនលក្ខណ៍។

បីពោលអួតខ្លួន អួតពេកផ្ទួនៗ អួតហួសវោតវគ្គ

អ្នកឮគេទ្រាន់ ស្មើរផ្ទាន់ឱ្យអាក់ រាប់ថាហីនលក្ខណ៍

មានបីប្រការ។

**ហួតថ្នាក់** *ន.* ដែលនៅថ្មោងឥតទាន់សៅហ្មង, បរិសុទ្ធស្អាត, ថ្មីថែស; ដែលនៅកំលោះឬនៅក្រមុំសុទ្ធសាធ :

**ពាក្យកាព្យ**

កំលោះហួតថ្នាក់ ត្រូវយល់ឱ្យជាក់ នូវមាត្រាច្បាប់

កូនគេក្រមុំ កុំហ៊ានពាល់ចាប់ ពុំបានទេស្លាប់

ប្រយោជន៍លោកិយ។

ក្រមុំហួតថ្នាក់ ត្រូវរក្សាលក្ខណ៍ ប្រយ័ត្នអប្រិយ

ត្រូវប្រើឬកពា ចរិយាកូនស្រី ទោះនឹងស្រដី

ឱ្យត្រូវបែបបទ។

**ហួល** *ន.* ឈ្មោះសំពត់សូត្ររបស់ខ្មែរ ត្បាញដោយសូត្រចងគាធលើកជាគោមជាក្រឡាក្បាច់រចនាវិចិត្រផ្សេងៗ តាមចំណេះនិងសេចក្ដីពេញចិត្តនៃអ្នកត្បាញ, ជាការយ៉ាងល្អិតធ្វើដោយផ្ចិតផ្ចង់មមឹះមមៀវរបស់ស្ត្រីខ្មែរ :

**ពាក្យកាព្យ**

មេប្បាស្លៀកហួលជរ សម្ដីខ្នរប្រកាន់ច្បាប់ ឱ្យត្រូវតាមទម្លាប់

សណ្ដាប់ធ្នាប់ទម្រង់ការៗ

ពីបូរាណព្រេងព្រឹទ្ធ ត្រូវតែគិតតាមវោហារ ចាស់ទុំជាអាចារ្យ

ទើបកិច្ចការបានចម្រើនៗ

**ហៀវហោះ** *កិ.* ហោះលឿនប្លៀវ, ហោះផ្ដេកផ្ដោះច្រៀវច្រែ :

**ពាក្យកាព្យ**

យន្តមេឃហៀវហោះ រំលងចន្លោះ ដងភ្នំនានា

ត្រដែតត្រដឹម សន្ធឹមនេត្រា ពួដ៏វេហាស៍

ដូចក្រៀលបក្សី។

អ្នកជិះក្នុងយន្ត ក្រឡេកគយគន់ មើលមកផែនដី

ឃើញឆ្ងាយលន្លឹម គួរព្រឺមហឫទ័យ បែរជាឥតភ័យ

ព្រោះអាងគ្រឿងចក្រ។

**ហេតុវិជ្ជា, ហេតុវិទ្យា** ឬ **ហេតុសាស្ត្រ** *ន.* វិជ្ជាដែលត្រិះរិះរកឱ្យឃើញតាមហេតុ (**តក្កវិជ្ជា**) :

**ពាក្យកាព្យ**

ហេតុវិជ្ជា អ្នកប្រាជ្ញនានា ក្នុងលោកទាំងមូល

រមែងស្រាវជ្រាវ រាវដោយអនុកូល រកឃើញប្រមូល

ប្រមុំតាមពិត។

ហេតុនិងបច្ច័យ មានការប្រាស្រ័យ ជាគូការគិត

រាវរកខុសត្រូវ តាមផ្លូវពិនិត្យ បើទាល់ការគិត

ពុំអាចរកឃើញ។

**ហេរិក** *ន.* (**សំ.**) អ្នកស៊ើប, ចារបុរស; អ្នកសម្ដែងសេចក្ដីស្និទ្ធស្នាល ដើម្បីស៊ើបការណ៍ពិត (បើស្ត្រីជា **ហេរិកា**) :

**ពាក្យកាព្យ**

| | | |
|---|---|---|
| រីពួកហេរិក | មានយោបល់ញឹក | សង្កេតហេតុការណ៍ |
| គេប្រើការស៊ើប | ដោយនូវវិចារណ៍ | ច្រើនតែបានការ- |
| | ពិតពុំសូវឃ្លាង។ | |

**ហៃរិក** *ន.* (**សំ.**) ចោរ, ចោរលបលួច (បើស្ត្រីជា **ហៃរិកា**) :

**ពាក្យកាព្យ**

| | | |
|---|---|---|
| រីគ្រឿងចាប់ចង | គ្រឿងឃុំឃាំងផង | គឺពួកហៃរិក |
| វាផ្ដើមបង្កើត | ជាគ្រឿងគួរភ្ញឹក | បើគ្មានហៃរិក |
| | គុកក៏មិនមាន។ | |
| មូលបង្កើតមុង | ហៃរិកព្រយុង | ព្រឃើតឈ្លានពាន |
| នាំឱ្យរាជការ | នៅស្ងៀមពុំបាន | បាបហៃរិកច្រាន |
| | ឱ្យសង់គុកចាំ។ | |

**ហោរ** *ន.* (ពាក្យឃ្លាតក្លាយមកពី **សំ. ហោរា**) អ្នកចេះហោរាសាស្ត្រ ឬអ្នកចេះតារាសាស្ត្រ, ហិណ្ឌិក :

**ពាក្យកាព្យ**

| | | |
|---|---|---|
| ពួកហោរព្យាករ | ថាបុត្របវរ | កបដោយលក្ខណា |

នៅជាគ្រហស្ថ នឹងបានឡើងជា ចក្រពត្រា-
ធិរាជអង្គឯក។
បើទ្រង់ព្រះផ្នួស នឹងបានឡើងហួស ដល់ធម៌ដ៏ប្លែក
គឺជាព្រះពុទ្ធ វិសុទ្ធក្រៃពេក ជាសាស្ដាឯក
តែមួយក្នុងលោក។

**ឃាំ** *គុ.* មាំ, មាំមួន, មាំសាច់ហាប់; សំណាំ :

**ពាក្យភាព្យ**

អ្នកប្រុសមាឌឃាំ ទាស់តែមិនខំ រកស៊ីធ្វើការ
ដល់ពេលប្រពន្ធ ចម្អិនអាហារ ទើបចូលមកស្ដារ
ពមញាត់ពមញាត់។
កូនប្រុសទាំងឡាយ អ្នកកុំវាយមាយ ឥតប្រឹងនឿយហត់
កើតជាកូនប្រុស ត្រូវខំខាំមាត់ កាន់ការឱ្យស្ទាត់
កុំធ្វើលែនលន។

**មោះហ្មង** *គុ.* មោះមៃ :

**ពាក្យភាព្យ**

តាំងពីយូរហើយ ជាសុខកន្ដើយ ពុំដែលមោះហ្មង
ទើបតែគ្រានេះ ទៅជាហ្មងឆ្គង មកពីរំលង
សុជីវធម៌។

**ឡប់ ៩.** ដែលផ្សាយក្លិនធុំអាក្រក់ខ្លាំង :

**ពាក្យកាព្យ**

កេរ្តិ៍ឈ្មោះស្អុយឡប់ ទោះលាបទឹកអប់ ក៏កែមិនឡើង
ទោះបីមានបុណ្យ យសសក្តិធ្លាប់ថ្កើង ប្រើឫកចើងម៉ើង
ក៏ឡើងមិនរួច។

**ឡិន ៨.** ចៅទួត។ ខ្មែរប្រើស្ទើរជាបរិវារសព្ទសម្រាប់និយាយបានតែផ្សំជាមួយនឹងពាក្យ **ចៅ** ថា : **ចៅឡិន** ចៅទួតឬចៅដែលជាប់ក្រសែញាតិឆ្ងាយទៅហើយ :

**ពាក្យកាព្យ**

ត្រកូលញាតិផៅ ពីកូនដល់ចៅ រៀងដល់ចៅឡិន
គួរប្រុងប្រយ័ត្ន កុំឱ្យហោចហិន គំនិតឱ្យឆ្អិន
កុំឱ្យឃ្លៀងឃ្លាត។

ពូជពង្សធ្លាប់ខ្ពស់ ធ្លាប់មានសក្តិយស ត្រូវរក្សាជាតិ
កុំធ្វើលែនលន ឱ្យបង់មារយាទ ត្រូវយោងវង្សញាតិ
ដោយក្តីឃ្នាតខ្មី។

ខ្លួនបានធំថ្កើង កុំឱ្យចើងម៉ើង ឱ្យញាតិប្រុសស្រី
គេធុញគេទ្រាន់ គេស្អប់មិនស្តី ស្ងួរបង់អ្វីៗ
កុំឱ្យបង់ឈ្មោះ។

**ឡើមឡ្មុំ** *ទុ.* ឬ *ភិ.* *១.* ដែលចាប់ចុងព្រយុងដើមស្រមូលប្រឡិមប្រឡុំ :

**ពាក្យភាច្យ**

ត្រូវហាត់និយាយ កុំធ្វើរាយមាយ ឡិបឡុបឡិមឡុំ
កុំប្រើឬកពា ចច្រិមចច្រុម កណ្តាលជំនុំ
ឱ្យគេធុញទ្រាន់។

ការចេះព្រោះហាត់ សម្តីព្រោះមាត់ ធ្លាប់ថ្មីកគ្រប់គ្រាន់
បើឥតបានហាត់ រែងនឹកពុំទាន់ និយាយច្រើនភ័ន្ត
នែះៗញយៗ។

សម្តីជាឯក ត្រូវការជជែក ពាក្យពេចន៍មិនខ្សោយ
បើអន់សម្តី និយាយច្រើនធ្លោយ បាត់មុខបាត់ក្រោយ
នែះៗច្រំដែល។

**ឡើម** *ភិ.* លួចកិបបន្តំលាក់ទុកខ្លះ, កិបបំបាត់យកខ្លះ :

**ពាក្យភាច្យ**

កុំប្រើកលឡើប លៃលកកាញ់កិប បំបាត់បំបែរ
យើងកើតជាមនុស្ស ស្រីប្រុសជាតិខ្មែរ ដឹងខុសត្រូវដែរ
ត្រូវកាន់ទៀងត្រង់។

ព្រះពុទ្ធត្រាស់ថា សត្វក្នុងលោកា រាល់រូបរាល់អង្គ
បើចង់បានសុខ ត្រូវខំផ្ចិតផ្ចង់ កាន់ធម៌ត្រង់ៗ

សុខកើតមានឯង។

**ឡឹត** *កិ.* ដែលតម្លើងឫកឬលេងឫកហួសសភាពខ្លួន, ដែលសម្ដែងឫកពាខ្ពស់ហួសប្រមាណខ្លួន :

**ពាក្យភាព្យ**

កុំធ្វើឫកឡឹត ក្រឱងក្រអឺត ឱ្យគេមើលងាយ
ទោះជនធំតូច ទោះជនសម្មាយ អ្នកផងទាំងឡាយ
គេស្អប់ឫកឡឹត។

**ឡុងចុង** *កិ.* ឬ *កិ. វិ.* ទាំងអស់ដែលខាតបង់ឬខូចខាតទាំងអស់ :

**ពាក្យភាព្យ**

ខាតបង់ឡុងចុង បាត់ដើមទាំងស្រុង លង់ព្រោះយល់ឃ្លាង
តទៅខាងមុខ ត្រូវគិតត្រូវវាង កុំគិតឱ្យឃ្លាង
ដូចកាលមុនទៀត។

**ឡុងសុង** *ន.* ឈ្មោះបែបទម្រង់សក់មួយប្រភេទនៃបុរសកាត់ចៀរជើងសក់មូលសណ្ឋានស្រដៀងនឹងផ្កាសម្បូរទេស ឬផ្កាក្ទម្ពប៉ែកខាងលើទុកឱ្យមានភាពវែងក្រពុំ :

**ពាក្យភាព្យ**

សម័យព្រេងនាយ ប្រុសខ្មែរទាំងឡាយ កាត់សក់ឡុងសុង
គេរាប់អានថា សមរូបសមទ្រង់ បែបនោះពុំគង់
នៅយូរប៉ុន្មាន។

មនុស្សប្រុសនិងស្រី នៅនាលោកិយ តាក់តែងខ្លួនប្រាណ
តាមកាលសម័យ និយមរាប់អាន តាំងពីបូរាណ
រៀងដល់ឥឡូវ។
បណ្ឌិតឃើញថា ការតែងកាយា តាមលោកតម្រូវ
ទោះសមទោះឆ្គង ទោះត្រូវពុំត្រូវ ពីដើមឥឡូវ
សន្មតថាល្អ។

**ឡុងសុង** *ន.* ឈ្មោះបទភ្លេងពិណពាទ្យមួយមេសម្រាប់លេងថ្វាយក្នុងវេលាដែលព្រះរាជាទ្រង់ស្នាន (ទ្រង់ស្រង់); ឬលេងក្នុងវេលានិមន្តភិក្ខុសង្ឃស្រង់ទឹកក្នុងថ្ងៃសង្ក្រាន្តជាដើមក៏ប្រើខ្លះដែរ :

**ពាក្យកាព្យ**

មហាក្សត្របួសង្ឃ នៅពេលត្រូវស្រង់- ទឹកដោយកម្សាន្ត
ក្នុងកាលចូលឆ្នាំ ជាថ្ងៃសង្ក្រាន្ត ហៅថាពេលស្នាន
មានភ្លេងឡុងសុង។
សម័យសព្វថ្ងៃ បើចង់កែខៃ គួរហៅភ្លេងស្រង់
ចម្រើនសិរី មង្គលអស់អង្គ ទោះក្សត្រទោះសង្ឃ
ប្រុសស្រីទូស្សស្តី។

**ឡើយណា** *និ.* ទេណា, សោះណា :

**ឡើយនៃ** *និ.* ទេនៃ :

**ឡើយហោង** *និ.* សោះហោង :

**ពាក្យកាព្យ**

| | | |
|---|---|---|
| រីពាក្យកាព្យថា | ឡើយនែ, ឡើយណា | និងពាក្យឡើយហោង |
| កវីប្រើផ្សំ | កុំឱ្យចួនឆ្គង | បើឱ្យហ្មត់ហ្មង |
| | គួរកុំសូវប្រើ។ | |

**ឡែបឡប** *កិ.* អែបអប, ប្រចុបប្រចែងអែបអបឱ្យតែបានស៊ីបានចាយ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| រីមនុស្សឡែបឡប | ច្រើនតែអែបអប | ពោលចាក់បណ្ដោយ |
| ប្រើពាក្យប្រចុប | ត្រលប់មុខក្រោយ | កាលបើគេឱ្យ |
| | នេះនោះដើរចេញ។ | |

**ឡោម** *កិ.* ព័ទ្ធជុំវិញ, ចោមជុំវិញ, ចោមព័ទ្ធជុំវិញ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| មេទ័ពឈ្លាសស្ទាត់ | សត្រូវឡោមព័ទ្ធ | ក៏ឥតភ្លាំងភ្លឹក |
| មិនស្លុតមិនស្លន់ | មិនភ័ន្តវរវឹក | ពួកខ្មាំងសន្ធឹក |
| | ក៏វាយតបាន។ | |
| ជាមេជំនាញ | ឈរបង់ជំទាញ | នាំពលឱ្យប៉ាន |
| ទប់ទ័ពសត្រូវ | អស់ផ្លូវរុករាន | ពុំអាចទន្ទ្រាន |
| | រុកចូលមកទៀត។ | |

**អក ៩.** អដ្ឋុបាតកសត្តមួយប្រភេទ សម្បុរខ្លួនខ្មៅស្រអាប់ មាឌធំកន្តុល បន្តិចជាងកុកខ្មៅ, ឆាបចាប់មច្ឆជាតិជាចំណី; កាលណាព្រាត់គូឬព្រាត់កូនស្រែកយំគ្រលួចសង្រេងសង្រៃហើរឆ្វៀលឆ្វាត់ខ្ពស់ៗ ទាបៗ ប្រះប្រាណគួរឱ្យស្រងេះស្រងោចអាណោចអាធម្ម :

**ពាក្យកាព្យ**

សត្វអកជាសត្វមានចិត្តស្មោះ អាឡោះអាល័យហួសទំនង នៅពេលដែលព្រាត់ប្រាត់គូគ្រង
ទោះព្រាត់រំលងកាលយូរថ្ងៃៗ

ស្រែកយំរង្គំមិនសូវស្រាក ក្រៀមក្រំលំបាកពន់ពេកក្រៃ ជូនកាលហ្មោកខ្លួនឱ្យក្សិណក្ស័យ
សង្រេងសង្រៃដល់ស្លាំងស្លម ៗ

មនុស្សខ្លះកើតទុក្ខដូចជាអក ច្រើនខកខូចចិត្តដល់ខ្លួនទ្រម ទោះគេពន្យល់ក៏ពុំព្រម
រញ្ជមត្រាតែមានជំងឺៗ

**អកតញ្ញូ ៩. (ឃ.)** អ្នកមិនដឹងឧបការគុណដែលគេបានធ្វើហើយ (ចំពោះខ្លួន) :

**ពាក្យកាព្យ**

អកតញ្ញូ ព្រះពុទ្ធជាគ្រូ ទ្រង់ត្រាស់ប្រាប់ថា
ទោះលើកផែនដី ទាំងមូលឱ្យវា ពុំស្កប់ចិន្តា
នៅតែរករឿងៗ

**មួយបែបទៀតថា**

អកតញ្ញូ បំភ្លេចគុណូ- បការៈចោល
ទោះអ្នកផ្គត់ផ្គង់ មានគុណជាគោល វាតែងតែថ្កោល

ទោសជានិរន្តរ៍។

ព្រះពុទ្ធត្រាស់ថា ទោះលើកពសុធា ឱ្យវាគ្រប់គ្រាន់
វាឥតត្រេកអរ នៅតែបំភ័ន្ត បង្អាប់បង្អន់
បំភ្លេចគុណគាប់។

**អកអំបុក** *ន.* ឈ្មោះពិធីមួយប្រភេទ មានការសម្រក់ទៀនលើស្លឹកចេក ស្រស់ផ្សងមើលទឹកភ្លៀងក្នុងឆ្នាំភ្នែកបន្ទាប់ឆ្នាំនោះ, បន្ទាប់ពីសម្រក់ទៀន មកនាំគ្នាអកអំបុក, ធ្វើក្នុងវេលាយប់នៃថ្ងៃ១៥កើតខែកត្តិក (ហៅ **ពិធី-សំពះព្រះខែ** ក៏បាន)។ ចំណែកខាងព្រះរាជពិធី ធ្វើក្នុងវេលាយប់នោះដែរ, រួមជាមួយគ្នានឹង **ព្រះរាជពិធីចុះផែ**, ក្នុងវេលារសៀលដល់ល្ងាចមាន ប្រណាំងទូក, វេលាយប់មានបណ្ដែតប្រទីបផ្កាលា, អុជពន្លឺរំសេវផ្សេងៗ មានកាំជ្រួចជាដើម...។ ហៅដោយរួបរួមថា **ព្រះរាជពិធីចុះផែ** កំណត់ ៣ថ្ងៃ គឺថ្ងៃ១៤, ១៥កើតនិងថ្ងៃ១រោចខែកត្តិក :

**ពាក្យកាព្យ**

ថ្ងៃអកអំបុក ពួកខ្មែរអ្នកស្រុក តែងធ្វើពិធី
ហៅអកអំបុក សូមសុខសួស្ដី តាមប្រពៃណី
បុរាណព្រេងព្រឹទ្ធ។

**អកាល** *ន.* (បា. សំ.) កាលមិនគួរ, កាលខុសប្រក្រតី; ដែលខុសកាល, ដែលពុំជួកាល :

**ពាក្យកាព្យ**

ជនទាំងអម្បាល គួរស្គាល់អកាល និងកាលវេលា
ដែលគួរប្រព្រឹត្ត ឱ្យបានសមជា អ្នកមានប្រាជ្ញា
ស្មារតីរឹងប៉ឹង។

**អកុសល** *ន.* (**បា.**) សេចក្តីអាក្រក់, បាប, អពមង្គល :

**អកុសល** *គុ.* (**បា.**) អាក្រក់, ដែលជាបាប; ដែលមិនឈ្លាស :

**ពាក្យកាព្យ**

រីអកុសល ជាកម្មតែងផ្តល់ ក្តីទុក្ខលំបាក
ឱ្យដល់អ្នកធ្វើ មិនឈប់មិនស្រាក កម្មនេះស្រកាក
គួរជនផងខ្លាច។

ផ្ទុយពីកុសល ដែលតែងតែផ្តល់ ក្តីសុខមិនកាច
កម្មនេះល្អលន់ ជាបុណ្យអង់អាច បានជាអ្នកប្រាជ្ញ
ពេញចិត្តចង់ធ្វើ។

ជនជឿផលកម្ម មានស្មារតីចាំ ប្រព្រឹត្តអំពើ
កុសលកល្យាណ ក្សេមក្សាន្តឥតបើ មានមោះហ្មងលើ
មនោទ្វារឡើយ។

**អក្ខធុត** *ន.* (**បា. អក្ខធុត្ត**) អក្ខទេវី ឬ ជូតការី (បើស្ត្រីជា **អក្ខធុតី** ឬ **អក្ខធុត្តី**) :

**ពាក្យកាព្យ**

ព្រះពុទ្ធត្រាស់ថា អក្ខធុតា ទោះប្រុសទោះស្រី

រែងតែលង់ខ្លួន ផ្ទួនដោយទុក្ខភ័យ វិនាសហិនហែ
ចង្រៃរូបរឹត។

គួរសាធុជន តាំងចិត្តឱ្យធ្ងន់ ក្រាស់ដោយការគិត
ឱ្យស្គាល់រាក់ជ្រៅ ក្នុងមួយជីវិត ជនស្លាប់គំនិត
រមែងរងទុក្ខ។

**មួយបែបទៀតថា**

រីធូតមានបី មួយអ្នកលេងស្រី មួយអ្នកលេងស្រា
មួយអ្នកប្រព្រឹត្ត អំពើពាលា លេងស៊ីសងគ្នា
ហៅអក្ខធូត។

**អក្ខរកោវិទ** *ន.* ឬ *គុ.* (បា.) អ្នកឈ្លាសក្នុងអក្សរសាស្ត្រ :

**ពាក្យកាព្យ**

អក្ខរកោវិទ រែងតែរិះគិត ឆ្ពោះត្រង់អក្សរ
របស់ជាតិខ្លួន ឱ្យបានបវរ មានចិត្តត្រេកអរ
ស្មោះឆ្ពោះត្រង់ជាតិ។

**អគតិប្បហាន** ឬ **អគតិប្រហាន** *ន.* ការលះអគតិ; ការមិនលុះក្នុងអគតិ :

**ពាក្យកាព្យ**

រីជនសោសិ លុះក្នុងអគតិ ណាមួយឥតដឹង
លុះកម្មឱ្យផល ទើបធ្វើភ្នែកស្លឹង គន់គិតរំពឹង
ដឹងខ្លួនថាខុស។

គួរអស់ជនផង កុំធ្វើកន្លង ទោះស្រីទោះប្រុស
ទោះធំទោះតូច គួរខ្លាចកំហុស អំពើឆ្គងខុស
គួរចៀសវាងឆ្ងាយ។

**អគន្ធកបុស្ស** *ន.* ផ្កាឥតក្លិន :

**ពាក្យកាព្យ**

អគន្ធកបុស្ស មានពណ៌ត្រសុស ប៉ុន្តែឥតក្លិន
ដូចអ្នកចេះច្រើន មារយាទហោចហិន បានខាងតែប៉ិន
និយាយព្រោកប្រាជ្ញ។
ខាងធម៌និងសីល រោយរាយរេចរិល អាប់ឥតអំណាច
មានត្រឹមតែឈ្មោះ ថាជាអ្នកប្រាជ្ញ អ្នកខ្លៅកោតខ្លាច
បំពេញលាភឱ្យ។

**អគុណ** *ន.* (បា. សំ.) សភាពមិនមែនជាគុណ (ទោស) :

**ពាក្យកាព្យ**

រីជនពាលស៊ិន ពុំស្គាល់អគុណ ថាគួរចៀសវាង
ចេះតែប្រព្រឹត្ត តាមចិត្តពុំរាង ជីកគាស់រំលាង
រំលើងឫសគល់។
ទោះប្រាជ្ញប្រាយប្រាប់ នៅតែពុំស្ដាប់ ងងឹតងងល់
ងងើលចចើង ឡើងចាងឥតយល់ ធម៌ព្រះទសពល

ស្រោចស្រង់ពុំរួច។

**អគោចរដ្ឋាន** ឬ **អគោចរភូមិ** *ន.*ឋានឬភូមិជាអគោចរ; ដោយបរិយាយ តាមតែទីណាៗក៏ដោយដែលយល់ថា ពុំគួរគប្បីតែត្រាច់ចរទៅក៏សុទ្ធតែជា **អគោចរដ្ឋាន** ទាំងអស់ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| អគោចរដ្ឋាន | គួរតែខានកុំត្រាច់ចរ | ព្រោះក្រែងកើតវឹកវរ |
| | ដល់ថ្នាក់មរណ៍ក៏សឹងមាន។ | |

**អគ្គិសាស្ត្រ** (**សំ. អគ្និ** «ភ្លើង» + **អស្ត្រ** «ដងទៃ» + **ឝាស្ត្រ** «អាវុធ») *ន.* កាំភ្លើង :

**ពាក្យកាព្យ**

| | | |
|---|---|---|
| វីអគ្គិស្ត្រ | ជាគ្រឿងប្រើប្រាស់ | សម្រាប់ការពារ |
| ស្រុកទេសខ្លួនប្រាណ | កើតមានដោយសារ | ពួកជនបរិវារ |
| | រដ្ឋរាជ្យផ្ដួចផ្ដើម។ | |
| ប្រសិនបើមនុស្ស | ទាំងស្រីទាំងប្រុស | មានចិត្តជោកសើម |
| ដោយទឹកមេត្តា | រាល់តែដង្ហើម | អ្នកណានឹងផ្ដើម |
| | បង្កើតធ្វើអ្វី។ | |
| អគ្គិស្ត្រមាន | ព្រោះក្ដីឈ្នានពាន | នៃជនប្រុសស្រី |
| ដែលដាច់មេត្តា | ករុណាពិសី | នៅនាលោកិយ |
| | ទើបមានគ្រឿងនេះ។ | |

**អគ្គិនុប្បាត** (**សំ. អគ្និ** «ភ្លើង» + **អនុ** «ដទៃ» + **ឧប្បាត** «ការធ្លាក់ចុះ») *ន.* ភ្លើងដែលធ្លាក់ចុះពីអាកាស; ថ្មអាចម៍ផ្កាយ, ឧក្កាបាត, កេតុធ្លាក់ :

**ពាក្យកាព្យ**

អគ្គិនុប្បាត យូរៗឃ្លាតៗ កើតមានម្តងៗ
ចាស់ទុំប្រាប់ថា គួរអស់ជនផង កុំភ័យកុំផ្សង
ព្រោះធម្មតាទេ។

**អង់អាច** *គុ.* ដែលអាចហាន, ក្លាហាន, ដែលឥតញញើត, ដែលឥតក្រែង, ដែលឥតភ្លឹក :

**ពាក្យកាព្យ**

ធម្មតាអ្នកប្រាជ្ញ មានចិត្តអង់អាច កាន់ធម៌សុចរិត
ទោះគេបង្ខំ បំភ័ន្តគំនិត ឱ្យកាន់ទុច្ចរិត
សូវស្លាប់មិនកាន់។

**អង្កត់** *ន.* កន្ទុយឧសឬកំណាត់ឈើតូចខ្លី :

**ពាក្យកាព្យ**

រូបប្រាណស្រស់ៗ ស្រាប់តែលោះអស់ ជីវិតសូន្យឈឹង
ជារូបស្គីងស្គក ឥតផ្អកឥតដឹង ដេកផ្ងារសន្ធឹង
ដូចជាអង្កត់។

អង្កត់ឧសឈើ គេអាចយកធ្វើ- ការកើតតាមបទ
ប្រើជានេះនោះ តាមពេលក្រខ្សត់ ឯរូបរលត់

ឥតខ្លឹមសារឡើយ។

**ចាក់អន្ទារយកអន្ទាម** *កិ.* បោះបង់ប្រយោជន៍ធំ បែរទៅយកឯប្រយោជន៍តូចវិញឬបោះបង់មនុស្សល្អ បែរទៅរាប់រកយកមនុស្សអាក្រក់ជាគ្នាវិញ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| អសារក្តីបី | បណ្តាំមេជី | ព្រេងព្រឹទ្ធប្រដៅ |
| អង្ករសសុទ្ធ | ចម្អិនឱ្យឆៅ | ពិសីហើយខ្លៅ |
| | ប្រាជ្ញឥតមារយាទ។ | |

**ស្រុះគ្នាដូចអន្ទូង** *កិ.* ស្រុះគ្នាជាឯកច្ឆន្ទ (មិនមើលបំណាំមិនប្រចាំគ្នា) :

**ពាក្យកាព្យ**

| | | |
|---|---|---|
| គួរជនប្រុសស្រី | នៅនាលោកិយ | មានសាមគ្គី |
| ដូចជាអន្ទ្រូង | រ៉ាប់រងនាទី | ឱ្យមានវុឌ្ឍី |
| | សុខសាន្តបវរ។ | |
| សាមគ្គីភេទ | បង្កើតជាហេតុ- | ការណ៍លម្អក់ពណ៌ |
| ខូចខាតប្រយោជន៍ | ហោចទាំងអំណរ | គុណាគាប់បវរ |
| | វិនាសសូន្យបង់។ | |

**អង្គនា** *ន.* (**សំ. បា.**) ស្ត្រី, នាង :

**ពាក្យកាព្យ**

| | | |
|---|---|---|
| ពួកនាងកញ្ញា | ជាអង្គនា | កំពុងពេញរៀន |
| ខំប្រឹងសង្វាត | មិនខ្ជិលអៀនប្រៀន | មានចិត្តជាប់ញៀន |

ផ្ដោះការសិក្សា។

គំនិតមារយាទ ពុំដែលឃ្លៀងឃ្លាត ខុសចាកក្រឹត្យា

ជាស្រីចុះបែប សណ្ដាប់ចរិយា ពេញជាកញ្ញា

ត្រឹមត្រូវគួររាប់។

**អន្ទុកអន្ទុល** *កិ. ១.* ដែលខ្សឹកខ្សួលប៉ផ្អែបជ្រប់មុខ, ដែលកើតទុក្ខជ្រប់ :

**ពាក្យកាព្យ**

ការកើតទុក្ខជ្រុល អង្គុកអង្គុល មមុលមិងមាំង

អ្នកមានប្រាជ្ញា គួរតែប្រឆាំង កុំឱ្យចិត្តគាំង

ក្នុងក្ដីសោកសៅ។

ព្រះពុទ្ធប្រាប់ថា ត្រូវប្រើប្រាជ្ញា ដេញទុក្ខចេញក្រៅ

ត្រូវកុំប្រមូល- ទុក្ខឱ្យក្ដួលក្ដៅ ដេញយូរៗទៅ

គង់ទុក្ខឃ្លាតបាន។

ព្រោះក្ដីកើតទុក្ខ តែងដេញក្ដីសុខ ឱ្យឃ្លាតចាកប្រាណ

សុខនៅពុំកើត ដ្បិតទុក្ខរុញច្រាន កម្ចាត់ទុក្ខបាន

ហៅថាមានសុខ។

**អន្ទុយចាំតែ** ឬ **អន្ទុយតែ** *និ.* (ព. ប្រ.) រង់ចាំតែ, ចេះតែ (ហាក់ដូចជាអង្គុយរង់ចាំតែ) :

**ពាក្យកាព្យ**

ខ្លួនឥតធ្វើអ្វី អង្គុយតែស្ដី ត្រួតត្រាលើគេ
បន្ទោសញយៗ ថែមៗទ្វេទ្វេ ត្រង់ខ្លួនទទេ
ឥតរៀនឥតខ្នាស។

**អង្គុល** *កិ. វិ.* ឬ *គុ.* ដែលសំយុងមុខងងុលចុះក្រោម :

**ពាក្យកាព្យ**

ស្រវឹងអង្គុល យារមុខងងុល ជជ្រុលជជ្រក
តេងតាងពេញផ្លូវ ស្ទើរទៅស្ទើរមក ជួនស្រែកគំហក
ដាក់កូនប្រពន្ធ។
សើយលាត់ឥតខ្នាស ស្ដីអាសអាភាស ឥតក្រែងចិត្តជន
ដែលគេឈរមើល រចល់ច្រើនលន់ កម្លាំងថយអន់
ទ្រេតទ្រោតទ្រើបទ្រាប។
អ្នកប្រាជ្ញពោលថា អ្នកស្រវឹងស្រា វែងមានសភាព
អាប់ឱនថយថោក ជ្រោកជ្រាកទន់ទាប ថែមទាំងញ៉ាំងលាភ
ឱ្យថយផងដែរ។

**អង្គ្បើល** *កិ. វិ.* ឬ *គុ.* ដែលចេញអាការៈងងើលលើកដាក់ៗ, ទើលងើល :

**ពាក្យកាព្យ**

ជនពាលងងើល ចេះតែអង្គ្បើល ឥតគិតខុសត្រូវ
ប្រទូស្តប្រទាំង ប្រឆាំងរាំងផ្លូវ ក្លាយជាសត្រូវ

ជាតិសាសន៍ក៏មាន។

| | | |
|---|---|---|
| កើតជាមនុស្ស | គួរស្គាល់ត្រូវខុស | កុំដើរបំពាន |
| បំពារលើច្បាប់ | សម្រាប់ទូន្មាន | ផ្លូវចិត្តឱ្យបាន |

សាន្តសុខស្ងប់ឡើយ។

**អង្រែ** *ន.* ប្រដាប់សម្រាប់បុកទង្គិចទៅក្នុងត្បាល់ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| អង្រែនិងត្បាល់ | ប្រតាប់ប្រញាប់ | ទង្គិចឥតស្លួន |
| ប្រៀបដូចពួកសត្វ | រងទុក្ខផ្ទួនៗ | រាល់រូបរាល់ខ្លួន |

ចៀសវាងមិនផុត។

**អចលា** *ន.* (**សំ. បា.**) ប្រឹថពី, ពសុធា, ផែនដី :

**ពាក្យកាព្យ**

| | | |
|---|---|---|
| សព្វសត្វធម្មតា | នៅលើអចលា | មហាប្រឹថពី |
| សឹងមានបំណង | ប៉ងឱ្យមានក្ដី- | សុខរាល់រាត្រី |

មិនឱ្យអាប់អន់។

| | | |
|---|---|---|
| ខ្លះបែរជាឃ្លាង | ធ្វើខុសច្រងាង | ស្ញើតស្លក់ស្លោស្លន់ |
| យល់ខុសជាត្រូវ | ដើរតាមផ្លូវភ័ន្ត | ពុទ្ធារហន្ត |

ប្រដៅពុំកើត។

**អចិត្តិភាព** *ន.* (សំ. **អចិត្តិភាវ**) ភាវៈភ្លេចស្មារតី, ដំណើរភ្លេចស្មារតី, ការភ័ន្តស្មារតី; ដំណើរស្រឡាំងកាំង :

**ពាក្យកាព្យ**

អចិត្តិភាព តែងមានដរាប ព្រោះក្ដីប្រមាទ
ទ្វេធ្វេសស្មារតី មិនខំសង្វាត បណ្ដោយឱ្យឃ្លាត
រវាតការចាំ។

**អចេស្ដា** *ន.* ដំណើរឥតចេស្ដាគឺដំណើរទន់ខ្សោយ, អស់កម្លាំង, អស់ការប្រឹងប្រែង; ដំណើរកម្រើកអវយវៈមិនកើត :

**ពាក្យកាព្យ**

បណ្ឌិតលោកថា រីអចេស្ដា នាំចិត្តនិងកាយ
ឱ្យអន់ទន់ខ្សោយ វាយមាយរសាយ កិច្ចការទាំងឡាយ
រមែងកើលគាំង។

**អច្ឆិទ្រព្រឹត្តិ** *ន.* (សំ. **អច្ឆិទ្រវ្ឫត្តិ**; បា. **អច្ឆិទ្ទវុត្តិ**) ការប្រព្រឹត្តមិនដាច់, ដំណើរធ្វើការងារជាប់ជានិច្ច (ច្រើននិយាយតែពីការល្អ) :

**ពាក្យកាព្យ**

អច្ឆិទ្រព្រឹត្តិ ជនជាបណ្ឌិត ពេញចិត្តរាល់ប្រាណ
រមែងកាន់យក ពុំឱ្យខាតខាន ព្រោះនាំឱ្យបាន
ប្រយោជន៍ខ្ពង់ខ្ពស់។

**អញ្ញត្រសព្ទ** *ន.* សព្ទទីទៃ, សព្ទផ្សេងពីគេ, សព្ទដោយឡែក, សព្ទផ្សេង, សព្ទផ្សេងដោយឡែក :

**ពាក្យកាព្យ**

| | | |
|---|---|---|
| អញ្ញត្រសព្ទ | ប្រើតាមទម្លាប់ | ចាស់ព្រឹទ្ធព្រេងនាយ |
| សរសេរយ៉ាងនេះ | គេស្ដីឱ្យក្លាយ | សូរសព្ទឃ្លាតឆ្ងាយ |
| | ពីការសរសេរ។ | |
| ដូចអញថាអាញ់ | ពួកប្រាជ្ញមិនក្នាញ់ | មិនបានបំបែរ |
| មិនលុបលាងចោល | មិនថ្កោលទោសដែរ | បែបនេះពាក្យខ្មែរ |
| | សឹងមានក្រាស់ក្រែល។ | |
| ទោះជនជាតិណា | នៅក្នុងលោកា | ក៏គេពុំដែល |
| បានលុបលាងចោល | ព្រោះថ្កោលថាក្អែល | ថាជាដំណែល |
| | ខុសគួរលុបឡើយ។ | |

**អដ្ឋប្រតិភូ** *ន.* (សំ. បា.) អ្នកធានារឿងក្ដី, អ្នកកាន់ក្ដី, ស្នាក្ដី :

**ពាក្យកាព្យ**

| | | |
|---|---|---|
| អដ្ឋប្រតិភូ | ត្រូវជាវិញ្ញូ | ដឹងការណ៍ខុសគាប់ |
| កុំល្មោភតែលាភ | ក្រសាវប្រញាប់ | កាន់ក្ដីខុសច្បាប់ |
| | ស្ដាប់ប្រយោជន៍ខ្លួន។ | |

**អត់ឱន** *កិ.* បន្ទន់ចិត្តអត់ទ្រាំ; ខំទ្រាំអត់មិនប្រកាន់ទោស :

**ពាក្យកាព្យ**

អត់ឱនឥតទោស ធ្វើចិត្តសន្តោស បង្កើតជាទ្រព្យ
មេត្រីជាញាតិ រក្សាដល់ស្លាប់ ចៀសក្តីពុំគាប់
ជាគន្ធពិដោរ។

**អត់ឱ្យ** *កិ.* ទ្រាំឱ្យ, បណ្ដោយឱ្យ :

**ពាក្យកាព្យ**

អត់ឱ្យបណ្ដោយឱ្យឡើងចាង តែក្នុងរវាងកាលដ៏ខ្លី អត់ឱ្យឃ្លូរពេកច្រើនអប្រិយ
ស្ដីថាហួសពេកច្រើនបានទោស។
អត់ឱ្យយ៉ាងច្រើនត្រឹមបីដង កុំឱ្យកន្លងព្រោះសន្តោស ក្រែងនឹងប្រែក្លាយជារឿងថ្លោស
នាំឱ្យរខិស្ហកែលែងកើត។

**អត្ថិភាព** *ន.* (**បា. អត្ថិភាវ**) ភាវៈមាន, ភាពនៃអ្វីៗដែលមាន, ការមាន (ពាក្យផ្ទុយ **នត្ថិភាព**) :

**ពាក្យកាព្យ**

វីនត្ថិភាព បានសាបរលាប រលាយបាត់ទៅ
ទើបអត្ថិភាព បានជ្រាបចូលជ្រៅ ពីថ្ងៃនេះទៅ
នឹងរីកមុខមាត់។
អត្ថិភាពកើត ចាកដើមកំណើត គឺការនឿយហត់
ព្យាយាមរឹងប៉ឹង ខំប្រឹងខំអត់ ធ្វើអ្វីប្រាកដ-
ជាធ្វើនោះមែន។

**អនារុណកម្ម** *ន.* (បា.) អំពើស្លូត; អំពើល្អ :

**ពាក្យកាព្យ**

អនារុណកម្មជាអំពើ សុភាពស្មោះស្មើគួរពេញចិត្ត អស់ជនប្រុសស្រីគួរផ្ដេកផ្ដិត
ដ្បិតនឹងផ្ដល់ផលប្រសើរឱ្យ។

ផ្ទុយគ្នានឹងទារុណកម្ម ដែលនាំឱ្យបានក្ដីទន់ខ្សោយ បើបានជាជ្រុលកុំបណ្ដោយ
ក្រោយៗត្រូវរាំងចាលរអា។

**អទិស្សមាន** *គុ.* (បា.) ដែលមើលពុំឃើញ; ដែលពុំប្រាកដ :

**ពាក្យកាព្យ**

អទិស្សមាន សឹងមានរូបប្រាណ ប៉ុន្តែកំបាំង
ខ្លះមានភាពខ្សោយ ខ្លះមានភាពខ្លាំង ខ្លះកាន់សច្ចំ
ខ្លះដាច់មេត្តា។

ខ្លះរាប់អានមនុស្ស វៀរចាកក្ដីខុស អំពើពាលា
ព្រះពុទ្ធទតឃើញ នៅសព្វទិសា ទ្រង់ទូន្មានថា
ឱ្យវៀរទុច្ចរិត។

**អទ្ធាន** *ន.* (បា.) ផ្លូវ, ផ្លូវឆ្ងាយ :

**ពាក្យកាព្យ**

ទៅកាន់អទ្ធាន ត្រូវតែឱ្យមាន ជនផងជាគ្នា
ជាមិត្តតាមផ្លូវ កុំទៅឯកា ក្រែងជាពុំជា
គ្រាន់បានគ្នាជួយ។

**អធម្មវាទី** *ន.* (បា.) អ្នកនិយាយខុសធម៌, អ្នកនិយាយខុសច្បាប់ (បើស្ត្រីជា **អធម្មវាទិនី**) :

**ពាក្យកាព្យ**

| | | |
|---|---|---|
| អធម្មវាទី | និយាយញាំញី | ព្រះពុទ្ធសាសនា |
| ព្រោះលោភជិះជាន់ | ភ័ន្តភ្លេចសិក្ខា | លែងកាន់រក្សា |
| | ថាឥតអៀនខ្មាស។ | |
| ពោលតាមទំនើង | ដែលចិត្តខ្លួនទើង | ពាយងាយផ្ដេសផ្ដាស |
| ខុសខ្លះត្រូវខ្លះ | ច្រឡេសច្រឡាស | ព្រោះឥតក្ដីខ្មាស |
| | ហៅអលជ្ជី។ | |

**អធិកអធម** *ន.* (**សំ. បា. អធិក** «ក្រៃលែង, លើសលែង, លើសលន់, រុងរឿង, ហ៊ឹកហ៊ាក់» + **អធម** «ថយថោក, ថោកទាប; មិនរុងរឿង, រម៉េះរម៉ោះ, របុិចរប៉ី, រាយរង, បន្ទាប់បន្ទំ; ...») ខ្មែរប្រើពាក្យនេះចំពោះតែពិធីបុណ្យឬពិធីអ្វីមួយដែលរុងរឿងផង រម៉េះរម៉ោះឬរបុិចរប៉ីរាយរងខ្លះផង :

**ពាក្យកាព្យ**

| | | |
|---|---|---|
| គេធ្វើបុណ្យសព | មានអ្វីទាំងគ្រប់ | អធិកអធម |
| ទាំងថ្លៃទាំងថោក | តាមគេនិយម | អ្នកតូចអ្នកធំ |
| | ឈូឆរតាមពេល។ | |

**អធិជោតិស** *ន.* ពន្លឺខ្លាំងក្រៃ; ពន្លឺដែលភ្លឺខ្លាំងចាំងភ្នែក; ពន្លឺព្រះអាទិត្យ :

**ពាក្យកាព្យ**

ភ្លើងហ្វារថយន្ត ភ្លឺចាំងពេកពន់ មើលយូរពុំបាន
អធិជ្យោតិស ហាក់ដូចជាច្រាន សម្លឹងពុំបាន
ព្រោះចាំងភ្នែកខ្លាំង។

**អធិភូ** *ន.* (**សំ. បា.**) អធិបតី :

**ពាក្យកាព្យ**

លោកអធិភូ ធំជាងអស់គ្រូ ក្នុងការសិក្សា
ឯគ្រូទាំងអស់ ត្រូវស្ដាប់បញ្ជា បង្គាប់យ៉ាងណា
ត្រូវធ្វើយ៉ាងនោះ។

**អធិមត្ត** *គុ.* (**បា.**) ដែលពុំអាចរាប់បាន, ដែលរាប់ពុំអស់, លើសលន់, ហួសប្រមាណ :

**ពាក្យកាព្យ**

កងទ័ពអធិមត្ត មានការប្រតិបត្តិ តាមច្បាប់យោធា
បើនាយជាធំ បង្គាប់បញ្ជា ឱ្យធ្វើយ៉ាងណា
ត្រូវធ្វើយ៉ាងនោះ។

**អឌ្ឍរាត្រ** *ន.* ពាក់កណ្ដាលយប់ :

**ពាក្យកាព្យ**

លង់លុះអឌ្ឍរាត្រ ហៅឆន្នអាមាត្យ មកគិតនៃបាន
ព្រះស្ដែងយកសេះ កម្លាំងហៅហាន ចងគ្រឿងនូវអាន

នាំមកថ្វាយថ្វាត់។

**អនគ្ឃ** *គុ.* (**បា.** **អន** «មិន, មិនមែន, ពុំ, ឥត» + **អគ្ឃ** «ថ្លៃ») ដែលកាត់ថ្លៃពុំបាន, ដែលមានតម្លៃឥតបើគណនា :

**ពាក្យកាព្យ**

ត្បូងពេជ្រសោភគ្គ ជាទ្រព្យអនគ្ឃ ពុំអាចកាត់ថ្លៃ
ចាស់ថាចម្រើន រាល់យប់រាល់ថ្ងៃ រំងាប់ចង្រៃ
ក្នុងផ្ទះលំនៅ។
កើតលាភកើតយស កើតទ្រព្យរបស់ ប្រសើរឥតសៅ
បើអ្នកណាមាន អ្នកនោះនឹងទៅ ជាមនុស្សសន្ធៅ
សន្ធោថ្កើងថ្កាន។

**អនង្គ** *ន.* (**សំ.** **អន** «ឥត» + **អង្គ** «រូបអង្គ» = អ្នកដែលឥតរូបអង្គ) អទិស្សមានកាយមួយពួកហៅថា **កាមទេព** ជាអ្នកនាំបណ្តាលឱ្យកើតសេចក្តីត្រេកត្រអាល។ ខ្មែរប្រើជាពាក្យប្រៀបសំដៅសេចក្តីថា «ស្ត្រីមានរូបល្អ, នាងមានលម្អ, នាងឆើតឆោម» :

**ពាក្យកាព្យ**

អនង្គមាសថ្លៃ ចុះនាងសព្វថ្ងៃ ធ្វើការងារអ្វី
នៅជាកញ្ញា ឬមានប្តីសី ចូរនាងស្រដី
ប្រាប់តាមពិតមក។

**អនង្គណ** *គុ.* ឬ *ន.* (**បា. អន** «មិនមាន, ពុំ, ឥត» + **អង្គណ** «ធូលី; កិលេស») ដែលឥតកិលេស; អ្នកដែលឥតកិលេស (អរហន្ត); ដែលឥតសៅហ្មង; អ្នកបរិសុទ្ធ :

**ពាក្យកាព្យ**

ព្រះពុទ្ធអរហន្ត ជាអនង្គណ លើសលន់កន្លង
ទាំងជាស្រែបុណ្យ នៃអស់ជនផង ព្រោះក្ដីសៅហ្មង
ប្រាសចេញអស់ហើយ។
នរណាបានទាន់ ពុទ្ធារហន្ត តែងបានសុខស្បើយ
ជួនបានសម្រេច មគ្គផលកន្ដើយ អាចឆ្លងដល់ត្រើយ
គឺនិព្វានហោង។

**អនត្ថការី** *ន.* (**បា.**) អ្នកដែលធ្វើអំពើឥតប្រយោជន៍ (បើស្ត្រីជា **អនត្ថការិនី**) :

**ពាក្យកាព្យ**

អនត្ថការី រែងមានសម្ដី ចាក់ចុចនាយអាយ
តែងញុំាងការណ៍ពិត ឱ្យឃ្លាតឆ្ងាយ អ្នកស្ដាប់ជិនណាយ
លែងចង់ឮទៀត។

**អនត្ថវាទី** *ន.* (**បា.**) អ្នកដែលច្រើនតែនិយាយសម្ដីឥតប្រយោជន៍យកជាការពុំបាន (បើស្ត្រី **អនត្ថវាទិនី**) :

**ពាក្យកាព្យ**

អនត្ថវាទី ច្រើនប្រើសម្ដី ឥតគិតមុខក្រោយ

ស្ដីផ្ដោៗទៅ ខុសឆ្គងក៏ដោយ ស្ដីគ្រាន់តែឱ្យ
ធ្លាយចេញពីមាត់។

**អនស្ចារ្យ** *គុ.* ដែលមិនមែនជាអស្ចារ្យ, ដែលមិនគួរទះដៃស្ញើច, ដែលមិនគួរស្ញើច :

**ពាក្យកាព្យ**

ហៃភិក្ខុទាំងឡាយ ភ្លៀងអុរធ្លាក់ខ្លាយ ជាបោក្ខរពស្ស
គ្រាន់តែឱ្យញាតិ- អញមានអំណរ គេថាបវរ
ប៉ុន្តែអនស្ចារ្យ។

**អនាកុល** ឬ **អនាកូល** *គុ.* (**សំ. បា. អនាកុល «អន + អាកុល»**) ដែលមិនច្រលូកច្រឡំ, មិនច្របូកច្របល់, មិនសៅហ្មង, មិនមានទោស :

**ពាក្យកាព្យ**

អនាកូលជាគោលនៃក្ដីសុខ មិនសុកមម៉ុកដោយក្ដីព្រួយ មិនញាំងចិត្តជនឱ្យរព្រួយ
រង្គើរង្គំរង្គាលឡើយៗ

**អនាគម** *ន.* (**សំ. បា. អន** «មិន, ពុំ» **+ អាគម** «ការមក») ការមិនមក; ដំណើរមិនទាន់មកដល់។

**អនាគម** *គុ.* ដែលមិនឋិតនៅក្នុងសណ្ដាប់ធ្នាប់ឬក្នុងទម្លាប់, ក្នុងទំនៀមទម្លាប់; ដែលមិនកាន់ទម្លាប់ :

**ពាក្យកាព្យ**

អនាគម ច្រើននិយម តាមទំនើង,

តាមចិត្តទើង លះបង់នូវ ទម្លាប់ល្អ,
បែរជាកាន់ ទម្លាប់ដែល នាំឱ្យក្រ,
សឱ្យឃើញ ថាជាមនុស្ស ទ្រុស្តប្រយោជន៍។
ព្រោះទម្លាប់ សឹងមានខុស- សឹងមានត្រូវ,
ខ្លួនតម្រូវ ពារលើខុស តែងតែហោច,
ពុំសមប៉ង ឃ្វាងបំណង វែងផ្សាខ្លោច,
ខាតប្រយោជន៍ ដែលគួរបាន ឱ្យខូចបង់។

**អនាថជន** *ន.* (បា.) អ្នកដែលឥតទីពឹង :

**ពាក្យកាព្យ**

អនាថជន គួរកុំទម្រន់ ក្នុងក្ដីក្រទ័ល
កុំធ្វើលែនលន ត្រូវខំខ្វាយខ្វល់ ឱ្យគ្រាតែដល់
ទីផុតទ័លក្រ។

**អនិមន្តន៍** *ន.* (បា. **អនិមន្តន**) ការមិននិមន្ត, ការមិនអញ្ជើញ, ការឥតអញ្ជើញ :

**ពាក្យកាព្យ**

ដំណើរហិនលក្ខណ៍ ប្រាជ្ញលោកបញ្ជាក់ អស់អាថ៌សេចក្ដី
ឱ្យអស់ជនផង យល់ការណ៍វែងខ្លី កន្លងវិធី
ទៅជាសៅដៅ។

ហិនលក្ខណ៍មានបី មួយឥតមានក្ដី ហៅរកឱ្យទៅ
ខ្លួនចូលទទ្រុប ទៅកាន់លំនៅ នៃជនអ្នកក្រៅ
តាមដោយទំនើង។

ពីរឥតគេសួរ ខ្លួនស្ដីយកគួរ ពុំយល់ថាយើង
និយាយច្រើនពេក ស្មើរតែអស់ជើង គេយល់ថាយើង
ឆ្កោៗឥតបទ។

បីឥតគេអួត ខ្លួនថ្លែងអំនួត អួតខ្លួនស្មើរហត់
ទាល់តែគេធុញ គេទ្រាំខំអត់ អួតហួសកំណត់
ឱ្យគេអផ្សុក។

**អនិស្សយមុត្តក** ឬ **អនិស្សយមុត្តក៍** *ន.* (បា. **អនិស្សយមុត្តក**) អ្នកដែលមិនទាន់រួចផុតអំពីនិស្ស័យ គឺអ្នកដែលនៅក្នុងបន្ទុកឬក្នុងអំណាចគេទូន្មានប្រៀនប្រដៅស្ដីថា :

**ពាក្យកាព្យ**

អនិស្សយមុត្តក៍ កាលបើចេញផុត ចាកអ្នកគ្រប់គ្រង
ត្រូវសុំនិស្ស័យ អ្នកដែលខ្លួនផ្គង នឹងជ្រកនៅផង
ទើបអាចនៅបាន។

អនិស្សយមុត្តិកា មានន័យដូចគ្នា កុំបីឈ្លានពាន
ត្រូវសុំនិស្ស័យ ទើបខ្លួននឹងមាន ក្ដីសុខសម្រាន្ត

តរៀងទៅមុខ។

អ្នកបួសគ្រហស្ថ ដូចគ្នាទាំងអស់ ត្រូវចងចាំទុក

បើគ្មាននិស្ស័យ ខុសផ្លូវច្បាប់ស្រុក ក្រមច្បាប់ចាត់ទុក

ថាតាមទំនើង។

**អនិស្សរ** ឬ **អនិស្សរៈ** *ន.* ឬ *គ.* (**បា. អន** «មិន, មិនមែន; ពុំ, ពុំមែន, ឥត» + **ឥស្សរ** «ជាធំ») ដែលមិនមែនជាធំ; អ្នកដែលមិនមែនជាធំលើគេ, ចិត្តដែលមិនមែនជាធំលើរូបកាយ (ប្រើជា **អនិស្សរោ, អនិស្សរា, អនិស្សរំ**) :

**ពាក្យកាព្យ**

កាលខ្លួននៅក្មេង កុំយកការលេង មកធ្វើជាមុខ

ត្រូវខំរៀនសូត្រ កុំស៊ុកគ្រលុក សន្សំទ្រព្យទុក

តាមវ័យកុំធ្លោយ។

ដល់ចាស់ជរា អនិស្សរា កម្លាំងថយខ្សោយ

ធ្វើអ្វីពុំកើត ភ្លេចមុខភ្លេចក្រោយ គួរកុំបណ្តោយ

ឱ្យខាតវេលា។

អាយុជីវិត ភ្លេចពុំបានគិត អាទិត្យចន្ទ្រា

ថ្ងៃស៊ីយប់ស៊ី ខ្ទេចខ្ទីអាត្មា ដល់ពេលអនិច្ចា

ទើបភ្ញាក់ខ្លួនព្រើត។

**មួយបែបទៀតថា**

ខ្លួនប្រាណជនចាស់ ទ្រមតាមចំណាស់ អនិស្សរា
ធ្វើអ្វីលែងកើត រស់តែមាត់ថា អ្នកមានប្រាជ្ញា
គួរកាន់សុចរិត។
តាំងពីខ្លួនក្មេង កុំគិតតែលេង ភ្លាំងភ្លេចការណ៍ពិត
លុះដល់ខ្លួនចាស់ ទើបកាន់សុចរិត រូបកាយមិនស្និត
ស្ដាប់ចិត្តចង់ឡើយ។

**អនុនាយក** *ន.* (**បា.**) នាយកបន្ទាប់; នាយករង (បើស្ត្រីជា**អនុនាយិកា**) :

**ពាក្យកាព្យ**

អនុសព្ទនេះ អស់លោកអ្នកចេះ តន្ត្រីភាសា
អាចផ្សំជាមួយ- នឹងសព្ទនានា ឱ្យច្រើនមហិមា
ជាងនេះទៀតបាន។
ជាបុព្វបទ អ្នកប្រាជ្ញកំណត់ តាមដោយលំអាន
ពាក្យដែលគួរផ្សំ ច្រើនទៀតនៅមាន អ្នករៀនចូរប៉ាន
ផ្សំចុះតាមគួរ។

**អនុបទ្រព** *ន.* (**សំ. អន** «មិន, ពុំ, ឥត» + **ឧបទ្រវ** «ឧបទ្រព») ដែលឥតឧបទ្រព :

**ពាក្យកាព្យ**

អនុបទ្រព កើតមានព្រោះឈប់ លែងកាន់ទុច្ចរិត
ផ្លូវកាយវាចា និងខាងផ្លូវចិត្ត ថែមទាំងអាណិត

សព្វសត្វផងទៀត។

ឧបទ្រពចង្រៃ	វែងមានច្រើនក្រៃ	ព្រោះចិត្តចង្អៀត
ប្រព្រឹត្តអាក្រក់	នេះហើយនោះទៀត	គ្រោះកាចតែងបៀត
	អែបចូលមិនស្រាក។

**អន្តសយ្យា** ឬ **អន្តសេយ្យា** *ន.* ការដេកក្នុងកាលជាទីបំផុត (ការដេកស្លាប់, ការដេកស្លាប់លើផែនដី); ទីដីបញ្ចុះសព, ដីកប់ខ្មោច :

**ពាក្យកាព្យ**

អន្តសេយ្យា	ឥតមានសត្វណា	គេចចៀសវាងបាន
ដល់កាលកំណត់	មច្ចុរុញច្រាន	ឱ្យសត្វផងបាន
	ដូចៗជាគ្នា។

វិកម្មនិងផល	ពុំដែលខានផ្តល់	ទុក្ខសុខកាចជា
ឱ្យឃើញជាក់ស្តែង	ជិតពេលមរណា	ព្រះពុទ្ធប្រាប់ថា
	ឃើញតាមផ្លូវចិត្ត។

ឃើញតែម្នាក់ឯង	ពុំអាចនឹងថ្លែង	ប្រាប់អ្នកនៅជិត
បន្ទាប់ពីនោះ	ទើបអស់ជីវិត	កម្មណានៅជិត
	ទៅតាមកម្មនោះ។

**អន្តិមសាសន៍** *ន.* ពាក្យផ្ដាំឬសំបុត្រជាទីបំផុត (បច្ឆិមសាសន៍) :

**ពាក្យកាព្យ**

អន្តិមសាសន៍នៃម៉ែឪ	ដែលត្រូវកូនកាន់កុំបំភ្លេច	ព្រោះជាបណ្តាំត្រឹមនោះស្រេច

កូនណានឹងគេចកែពុំបានៗ

កុំឱ្យជាធូមកាលិក ត្រូវនឹកកុំឆ្លេចរាល់រូបប្រាណ ត្រូវកាន់ប្រព្រឹត្តតាមលំអាន បុរាណគឺរឿងទីឃាវុៗ

**អន្ទុ, អន្ទុក; អន្ទូ, អន្ទូក** *ន.* (**សំ.; បា. អន្ទុ, អន្ទុក**) កជើង; ទន្លីង; ច្រវាក់; ច្រវ៉ល; ខ្នោះ, គ្រឿងឃុំខាំង :

**ពាក្យកាព្យ**

ជនជាប់អន្ទុក រមែងមានមុខ ស្រពោនស្រពាប់
កើតទុក្ខព្រួយប្រាណ ឥតមានក្តីស្ងប់ ព្រោះតែទម្លាប់
ខុសចាកផ្លូវច្បាប់ៗ

គឺខ្លួនប្រព្រឹត្ត អំពើទុច្ចរិត ប្រាជ្ញប្រាប់មិនស្តាប់
ធ្វើតាមទំនើង ពុំស្គាល់រស់ស្លាប់ នរណាបង្គាប់
ខ្លួនធ្វើខ្លួនឯងៗ

**អន្ទោល** *កិ.* (**សំ. អន្ទោល ឬ អាន្ទោល** «គ្រវី; គ្រវែង; ស្ទុះ; លឿន; លឿនដោយកម្លាំងខ្យល់») ត្រាច់រង្គាត់កើតស្លាប់ក្នុងវាលវដ្តសង្សារ, វិល កើតវិលស្លាប់ :

**ពាក្យកាព្យ**

សព្វសត្វក្នុងលោក សុទ្ធតែវិយោគ ព្រោះការអន្ទោល
មានក្តីនិរាស ព្រាត់ប្រាសជាគោល ទោះចង់រត់ចោល
ក៏គ្រាន់តែចង់ៗ

រីព្រះសម្ពុទ្ធ　មានញាណមោះមុត　បំពេញចំណង់
ដោយទ្រង់យាត្រា　តាមមាគ៌ាត្រង់　ពីព្រោះព្រះអង្គ
ជ្រាបការអន្ទោល។

**អន្ទ** *គុ.* (សំ. បា.) ខ្វាក់ (ទាំងពីរខាង); ព. កា., បើបុរសប្រើជា **អន្ធោ;** ស្ត្រីជា **អន្ធា** ក៏បាន :

**ពាក្យកាព្យ**

អន្ធោអន្ធា　នៅជាមួយគ្នា　សុទ្ធតែពពើម
រាវរកនេះនោះ　ទទឹមទទើម　ពពឹមពពើម
ជួនរកមិនឃើញ។

**អន្ធិកា** *ន.* (សំ.) រាត្រី (យប់) :

**ពាក្យកាព្យ**

ពេលអន្ធិកា　ពន្លឺចន្ទ្រា　នាខាងដើមខ្នើត
ភ្លឺខ្សោយស្ទើរមើល-　អ្វីៗពុំកើត　ប្រៀបដូចអ្នកឆើត
ឆាប់ឈប់លែងរៀន។

ត្រូវរៀនឱ្យដល់　ថ្នាក់ខ្ពស់និម្មល　កុំគេចវេះរៀន
មិនដល់កម្រិត　កុំខ្ជិលអៀនប្រៀន　ត្រូវខំប្រឹងរៀន
ប្រណាំងសែងចន្ទ។

ចន្ទដប់ប្រាំកើត　ដូចអ្នករៀនឆើត　មានចិត្តក្លួចកាន់

រៀនទាល់ដល់ថ្នាក់- ខ្ពស់ដ៏សំខាន់ កុំឱ្យចាញ់ចន្ទ
ដប់ប្រាំកើតឡើយ។
អ្នករៀនរូបណា យល់ក្តីឧបមា នេះពុំកន្តើយ
អ្នករៀនរូបនោះ ឆ្លងឆ្ពោះដល់ត្រើយ- វិទ្យាស្រេចហើយ
រមែងក្សេមក្សាន្ត។

**អន្យតិរ្ថិយ** *ន.* (សំ.) តិរ្ថិយដទៃ គឺដទៃក្រៅពីពុទ្ធសាសនិកជន :

**ពាក្យកាព្យ**

ជនអន្យតិរ្ថិយ ចិត្តជួអប្រិយ ឥតមានមេត្តា
ទោះឃើញអ្នកក្រ ទុគ៌តម្តេចម្តា ឥតមានករុណា
អាណិតគ្នាសោះ។
កើតមកជាមនុស្ស ទោះស្រីទោះប្រុស ក្រមុំកំលោះ
គួរមានមេត្តា ករុណាដៅឆ្ពោះ អ្នកដែលមានគ្រោះ
ឱ្យបានសុខផង។

**អបរូប** *គុ.* (សំ.) ដែលមានរូបប្រែប្លែកខុសពីប្រក្រតីដើម; ដែលប្រែរូបប្រែទ្រង់; ដែលបង់រូបបង់ឆោម :

**ពាក្យកាព្យ**

នែនាងកញ្ញា អបរូបា តើទាស់ពីអ្វី?
កាលពីឆ្នាំមុន នាងមានសិរី បណ្តាកូនស្រី

នាងធាត់ជាងគេ។

ដែលទៅឱ្យពេទ្យ ពិនិត្យរកហេតុ ជំងឺឬទេ?
បើពុំដែលទៅ ទៅៗមាសមេ កុំបាច់រិះរេ
ឱ្យយឺតយូរឡើយ។

**អបហាស** *ន.* (**សំ. ឆា.**) ការសើចឥតទំនង, ការសើចឥតមូលហេតុគឺការគ្មានទំនងឱ្យចង់សើចសោះទៅជាសើច, ការសើចស្គូត :

**ពាក្យកាព្យ**

កុំធ្វើអបហាស សើចស្គូតផ្ដេសផ្ដាស ឱ្យគេរង្កៀស
សុជីវធម៌ ថាត្រូវឱ្យចៀស បើគេរង្កៀស
ជាហេតុហិនលក្ខណ៍។

**អបាយមុខ** *ន.* (**ឆា.**) ហេតុឬអំពើជាប្រធានឬក៏ជាផ្លូវនៃសេចក្ដីវិនាស :

**ពាក្យកាព្យ**

អបាយមុខបួន បើរាប់ផ្ទួនមានប្រាំបី មួយគឺការលេងស្រី
ពីរគឺក្ដីសេពសុរាៗ
បីគឺការចាយវាយ- ទ្រព្យខ្ជះខ្ជាយលើសមាត្រា បួនគឺល្បែងពាលា
លេងភ្នាល់គ្នាបង្ហិនធនៗ
ប្រាំគឺការសេពគប់ ជនខូបទ្រព ជាមិត្តពន្ធ
ប្រាំមួយគឺជាតិជន ខ្ជិលច្រអូសហួសប្រមាណៗ
ប្រាំពីរដើរលេងយប់ ត្រាតែងប់ពុំសូវខាន ប្រាំបីគឺរាប់អាន

មើលមហោស្រពត្រាតែញៀនៗ
ប្រាំបីនេះអ្នកឈ្លាស ខ្លាចវិនាសរឹងអៀនប្រៀន ជួនកាលគេចវេះវៀន
ព្រោះក្រែងញៀនឈប់ពុំបានៗ
**អបុត្តក** ឬ **អបុត្តកៈ** *គុ.* ឬ *ន.* (**បា. អបុត្តក**) ដែលគ្មានកូន; អ្នកដែលឥតកូន :
**ពាក្យកាព្យ**
អបុត្តកោ អបុត្តិកា ព្រះពុទ្ធត្រាស់ថា
ស្ងោរស៊ុតសត្វស៊ី កាលពីបុព្វជាតិ ឱ្យឃ្លាតឥន្ទ្រិយ
បានជាទាំងទ្វី អាឥតមានកូន។
**អបោគណ្ឌ** *គុ.* (**សំ.**) ដែលវិកលឬពិការរាងកាយ; ដែលជាអ្នកខ្លាចច្រើន (កម្លាច) :
**ពាក្យកាព្យ**
មនុស្សអបោគណ្ឌ ច្រើនតែភ័ន្តវល់គំនិត ព្រោះគ្មានចរិត
មិនដិតដល់ខ្វល់ម្តងៗ។
**អប្រិយ** *គុ.* (**សំ.**) ដែលមិនជាទីស្រលាញ់, ដែលពុំគួរស្រលាញ់ : **អប្រិយ** *ន.* (**សំ.**) បុគ្គលដែលមិនជាទីស្រលាញ់, អ្វីៗដែលមិនជាទីស្រលាញ់ :
**ពាក្យកាព្យ**
រីជនអប្រិយ ទោះប្រុសទោះស្រី អាប់ឥតលក្ខណា
គេច្រើនចៀសវាង ពុំចង់សន្ទនា ព្រោះគេយល់ថា
អាប់កេរ្តិ៍អាប់យស។

**អផាសុក** *ន.* (**បា.**) សេចក្ដីមិនសប្បាយ; សេចក្ដីអផ្សុក; សេចក្ដីព្រួយចិត្ត; ដំណើរមិនស្រួលចិត្ត; ដំណើរមិនសូវបានសុខ, ការប្រដាក់ប្រទុក្ខ (ដោយហេតុមានជំងឺតម្កាត់ជាដើម) :

**ពាក្យកាព្យ**

សព្វថ្ងៃខ្ញុំមានអផាសុក ក្ដីទុក្ខកង្វល់ផ្ដល់ឥតស្រាក ខ្ញុំខំទ្រាំនៅទាំងលំបាក
ណាទុក្ខព្រោះចាកចោលញាតិផៅ។

**អផ្សុក** *កិ.* ឬ *គុ.* (**បា. អផាសុក** *ន.* «សេចក្ដីមិនសប្បាយ; សេចក្ដីព្រួយចិត្ត») មិនសប្បាយចិត្ត, ព្រួយចិត្ត, ខ្វល់ចិត្ត; ធុញទ្រាន់នៅមិនសុខ :

**ពាក្យកាព្យ**

អផ្សុកអប្សាន្ត ស៊ីដេកពុំបាន មានតែកង្វល់
រងទុក្ខលំបាក ព្រោះអកុសល ផលកម្មមកផ្ដល់
ឱ្យមានទុក្ខព្រួយ។
ទុក្ខព្រោះកម្មកាច ឥតនរណាអាច នឹងចូលមកជួយ
រំលែកទុក្ខធ្ងន់ ឱ្យអន់រញ្ជួយ មានតែខ្លួនមួយ
ទើបជួយខ្លួនបាន។
ដោយការកុសល ដែលខ្លួនខ្វាយខ្វល់ កាន់សីលធ្វើទាន
ចម្រើនភាវនា សទ្ធាជាយាន លុះបាននិព្វាន
ទើបមានសុខពិត។

**អពល** *គុ.* (សំ. បា.) ដែលឥតកម្លាំង, ខ្សោយ; ដែលឥតរេហ៍ពល; **ឥត្ថីលិង្គ** **អពលា** ប្រែថា **ស្ត្រី** ក៏បាន ព្រោះជាមនុស្សរមែងតែខ្សោយជាងបុរស :

**ពាក្យកាព្យ**

ខ្លួនវាជាស្រីអពលា  កុំជេរវាយគ្នាឥតប្រណី  ខ្លួនឯងជាប្រុសគ្នាជាស្រី
ឯងធ្វើជាប្ដីត្រូវទ្រាំអត់ៗ

ខុសម្ដងឆ្គងម៉្វៃកុំប្រកាន់  ក្នាញ់គ្នាន់ដោយចិត្តឥតអំណត់  ទោះបីម្ដេចម្ដាត្រូវខំមាត់
ទប់ចិត្តកាន់កត់ទើបបានសុខៗ

**អព្យាបាទ** *ន.* (បា.) ការមិនព្យាបាទ គឺការមិនចងគំនុំ, មិនគុំកួន :

**ពាក្យកាព្យ**

វីអព្យាបាទ  ជាកម្មដ៏ស្អាត  កើតក្នុងមនោ
ក្នុងពួកសុចរិត  វិសិដ្ឋសេដ្ឋោ  ព្រះសម្ពុទ្ធោ
ទ្រង់ត្រាស់សរសើរ។

**អភិជ្ឈា** *ន.* (បា.) គំនិតសម្លឹងរំពៃរកទំនងឱ្យបានទ្រព្យអ្នកដទៃមកជារបស់ខ្លួន; ការចង់បានហួសហេតុហួសទំនង; តណ្ហា; អភិលាស :

**ពាក្យកាព្យ**

វីជនចិត្តស្លូត  អភិជ្ឈាភិភូត  បែរជាកាចល្មោភ
ឥតអៀនឥតខ្មាស  ព្រោះតែក្ដីលោភ  នាំឱ្យក្រសោប
ប្រយោជន៍ផ្ទាល់ខ្លួន។

ទោះគេហិនហោច  ឈឺចិត្តផ្សាខ្លោច  ក៏ដោយឥតស្ងួន

កៀរយកប្រយោជន៍ ឱ្យតែបានខ្លួន កាចល្មោភផ្ទួនៗ

ឥតក្ដីអៀនខ្មាស។

**អភិនេស្រ្កម៍** *ន.* អ្នកដែលលះទ្រព្យសម្បត្តិហើយចេញទៅប្រព្រឹត្តព្រហ្ម-ចរិយធម៌ឬអ្នកចេញបួស, បព្វជិត :

**ពាក្យកាព្យ**

កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្រ្កម៍ កុំទុកចិត្តអភិប្រាយ

ប្រើទំលែងខ្ពស់ រំពឹងឱ្យឆ្ងាយ ស្ដាប់ពាក្យបរិយាយ

បណ្ដាំមេជី។

**អភិមង្គល** *ន.* (សំ. បា.) មង្គលដ៏ឧត្ដម, ហេតុដែលនាំឱ្យមានសេចក្ដីចម្រើនក្រៃលែង, អភិវុឌ្ឍករណ៍ :

**ពាក្យកាព្យ**

ព្រះពុទ្ធស្ដេចទ្រង់ ប្រទានអភិមង្គល៍ ដោយព្រះឱវាទ

ឱ្យសត្វលោក តាំងចិត្តឱ្យស្អាត កុំឱ្យគ្រោតគ្រាត

ច្របូកច្របល់។

ប្រព្រឹត្តប្រតិបត្តិ កម្ចាយកម្ចាត់ ធម៌ជាអកុសល

ជម្រះសន្ដាន ឱ្យបានលុះដល់ អរិយមគ្គផល

ដល់និព្វានហោង។

**មួយបែបទៀតថា**

អ្នកកាន់សីលគង់ កបដោយអភិមង្គល៍ សព្វទិនរាត្រី

ប្រាសចាកឧបទ្រព    កបដោយសិរី    ចម្រើនសួស្តី
ឥតបីមោះហ្មង។

**អភិវន្ទ** ឬ **អភិវាទ** *កិ.* (**សំ. បា.**) ថ្វាយបង្គំ, គំនាប់, សំពះ, ក្រាបសំពះដោយគោរព :

**ពាក្យកាព្យ**

សូមក្រាបអភិវាទ    ឆ្ពោះព្រះលោកនាថ    បរមសាស្តា
ជាគ្រូនៃមនុស្ស    និងទេវតា    ទ្រង់ត្រាស់ទេសនា
ប្រទានឱវាទ។
សូមក្រាបអភិវន្ទ    ឆ្ពោះធម៌សោភ័ណ    តំណាងលោកនាថ
សូមធ្វើអភិវន្ទន៍    ឆ្ពោះសង្ឃសីលស្អាត    ស្តាប់ព្រះឱវាទ
ប្រព្រឹត្តត្រឹមត្រូវ។

**អភ្យាគម** *ន.* (**សំ.**) សង្គ្រាម :

**ពាក្យកាព្យ**

រដ្ឋតូចរដ្ឋធំ    មានអភ្យាគម    កើតជាកង្វល់
ប្រជាពលរដ្ឋ    រដើបរចល់    រមែងតែដល់
នូវក្តីទុក្ខព្រួយ។
អភ្យាគមកើត    ចេញពីកំណើត    នៃហេតុតែមួយ
គឺក្តីរំលោភ    នាំឱ្យរញ្ជួយ    បង្កក្តីព្រួយ

ដល់រដ្ឋសុខសាន្ត។

រដ្ឋដែលបានសុខ កើតការអុកឡុក ព្រោះទ្រាំពុំបាន
ត្រូវតែតទប់ ខំប្រឹងរុញច្រាន ទោះបានពុំបាន
ខានទប់ពុំកើត។

**អមគម** *កិ.* (ស.) អបស្អបឱ្យមាំ, ទល់ទប់ឱ្យមាំ, ជ្រោមជ្រែងឱ្យមាំ, ជ្រោមជ្រែងឱ្យនឹង :

**ពាក្យភាព្យ**

ជនចាស់ទ្រែមទ្រម ឈើច្រត់អមគម បង្ការក្រែងដួល
ចាស់ដួលម្ដងៗ ច្រើនតែពុំស្រួល ជួនស្លាប់ព្រោះដួល
ក៏សឹងតែមាន។

គួរចាស់ព្រឹទ្ធា កាលបើជរា ចូលមកទន្ទ្រាន
ត្រូវប្រើឈើច្រត់ អមគមគ្រាន់បាន ទទ្លួទប់រូបប្រាណ
កុំឱ្យជ្រុលដួល។

**អមាវសី** ឬ **អមាវាសី** *ន.* (បា.) រាត្រីដែលមានពន្លឺព្រះអាទិត្យនិងពន្លឺព្រះចន្ទនៅរួមជាមួយគ្នា ឬរាត្រីដែលមានពន្លឺព្រះអាទិត្យគ្របបាំងពន្លឺព្រះចន្ទ គឺយប់ខែដាច់ (យប់១៤រោចឬ១៥រោចនៃខែខាងចន្ទគតិ) :

**ពាក្យភាព្យ**

អមាវាសី ពុំមានរស្មី នៃព្រះចន្ទ្រា

ងងឹតសូន្យសុង | ឃើញតែតារា | ពាសពេញមេឃា
មើលគ្នាពុំយល់។
ហៅយប់ខែដាច់ | អ្នកប្រាជ្ញសម្រេច | ថាទុកដូចកល់
ជនឥតបើគិត | គំនិតសល់វល់ | ពុំដឹងពុំយល់
គុណទោសត្រូវខុស។

**អម្បាយ** ឬ **អំបាយ** *និ.* ប្រើជា *គុ.* (ព. បុ.) មាល្បាយ :

**ពាក្យកាព្យ**

ឆ្ងាយអ្វីអម្បាយ | នេះពេញហៅឆ្ងាយ | ឆ្ងាយដាច់សង្វែង
សង្សារវដ្ត | ឆ្ងាយយ៉ាងហ្នឹងឯង | សព្វសត្វផងតែង
វិលកើតវិលស្លាប់។

**អម្រាម** *ព. បុ.* (ដូចគ្នានឹង **ម្រាម**) :

**ពាក្យកាព្យ**

អម្រាមដៃដប់ | លើកឡើងគោរព | ឆ្ពោះគុណត្រ័យរត្ន
សូមតេជជោគជ័យ | និងសួស្តីភទ្រ | កើតមានអភិវឌ្ឍន៍
ជានិច្ចនិរន្តរ៍ !

**អលសភាព** *ន.* (**បា. សំ.** «**អលស + ភាវ**») ភាពនៃបុគ្គលខ្ជិលច្រអូស, អំពើច្រអូស, ការទម្រន់ឬកៀចមិនចង់អើពើនឹងកិច្ចការទាំងពួង :

**ពាក្យកាព្យ**

អលសភាព | ជាភារៈទាប | នាំឱ្យខុសខាត

ជិះជាន់ផ្លូវចិត្ត ខូចក្ដីឱហាត ព្យាយាមសង្វាត
ក៏ឃ្លាតចេញឆ្ងាយ។
ប្រយោជន៍ផ្លូវលោក ផ្លូវធម៌ក៏ស្មោក ខូចអន្តរាយ
ហេតុនេះគួរជន ប្រុសស្រីទាំងឡាយ កុំបីរាយមាយ
គួរមានព្យាយាម។

**មួយបែបទៀតថា**

អលសភាព ជាលក្ខណ៍ទន់ទាប ឱ្យទ្រព្យធនខ្សោយ
ពុំគួរកូនចៅ បណ្ដែតបណ្ដោយ បើកឱកាសឱ្យ
ភាពនេះជាន់ឡើយ។

**អល់អែក** *កិ.* ឬ *កិ. វិ.* ស្ទាក់ស្ទើរ :

**ពាក្យកាព្យ**

បើពេលទំនេរកុំអល់អែក ថ្ងៃនេះជាស្អែកឱ្យខកខាន ស្អែកជាខានស្អែករឹងពុំបាន
ខានៗច្រើនដងយែតទទេៗ
គេអាទិយើងអាទិកុំទ្រមក់ ដូចជនដេកលក់ព្រោះធ្វេសទ្វេ គេម៉េចយើងម៉េចត្រូវមើលគេ
គេដើរយើងដើររត់យើងរត់ៗ
ធ្វើការរកស៊ីកុំចំអៀក ជ្រលៀកឱ្យស្មារតីរលត់ មនុស្សខ្ជិលកុំសេពសមព្រមត់
ត្រូវពត់គំនិតជានិរន្តរ៍ៗ

**អវរុទ្ធ** *គុ.* (សំ. បា.) ដែលគេបណ្ដេញឬបំបរបង់; ដែលគេលុបឈ្មោះចោលលែងរាប់រក; ដែលគេលុបឈ្មោះចេញពីរាជការ។ (បើស្ត្រីជា **អវរុទ្ធា**) :

**ពាក្យកាព្យ**

| | | |
|---|---|---|
| មនុស្សមានពុត | ជាអវរុទ្ធ | គេលុបឈ្មោះចេញ |
| មិនតែប៉ុណ្ណោះ | ថែមគេបណ្ដេញ | ឱ្យខ្លួនឃ្លាតចេញ |
| | ចាកផ្ទះផងទៀត។ | |
| ចំណែកភរិយា | ជាអវរុទ្ធា | ខូចចោលបង់សៀត |
| ទោះបីម្ដីងហើយ | ក៏នៅតែឆ្កៀត | បំបែរបំបៀត |
| | រកវៀងវ៉ាវគេ។ | |

**អហិង្សា, អហឹសា** ឬ **អហេសា** *ន.* (សំ. បា. **អហឹសា** ឬ **អហេសា**) ការមិនបៀតបៀនគេ, ការមិនធ្វើទុក្ខគេឱ្យបានសេចក្ដីលំបាក, ការមិនធ្វើទុក្ខបុកម្នេញគេ :

**ពាក្យកាព្យ**

| | |
|---|---|
| អហិង្សាជាធម៌ដ៏សំខាន់ | ប្រសិនបើកាន់បានគ្រប់គ្នា សមលោកទាំងមូលនឹងសះជា |
| | ការឈ្លោះទាស់គ្នាក៏នឹងគ្មាន។ |
| ព្រោះអហិង្សាជាធម៌ស្ងប់ | ឱ្យរាប់ឱ្យរកគ្នារាល់ប្រាណ អាចនាំឱ្យមានសុខសម្រាន្ត |
| | ធ្វើម្ដេចនឹងបានដូចថាអ្វើយ។ |
| ប្រសិនបើអាចប្រជុំគ្នា | ទូទាំងលោកាពុំកន្ដើយ ជជែកប្រឹក្សារកកោះត្រើយ |
| | បើបានឃើញហើយព្រមកាន់តាម។ |
| ឱ្យអហិង្សាមានរាល់ទ្វីប | ភ្លឺដូចប្រទីបនៃលោកគ្លាម នោះលោកទាំងមូលនឹងមាននាម |
| | ថាបានរួចផុតចាកហិង្សា។ |

**អហោ** *និ.* ជា *ឧ.* (សំ. បា.) ឱ :

**ពាក្យកាព្យ**

អហោឱរូបអនិច្ចំ ទុក្ខំមានទាំងអនត្តា បីនេះជាត្រៃលក្ខណា

សត្វក្នុងលោកាគេចពុំផុត !

បើគ្រាន់តែដឹងចោលទទេ ចេះតែធ្វេសធ្វេឃ្លាតបរិសុទ្ធ ធ្វើម្ដេចនឹងបានដល់វិមុត្ត

និរោធនិរុទ្ធក្ដីទុក្ខបាន !

**អហោរត្ត** ឬ **អហោរាត្រ** *ន.* (បា. ឬ សំ.) ថ្ងៃនិងយប់, ថ្ងៃមួយនិងយប់មួយ :

**ពាក្យកាព្យ**

កើតទុក្ខជួរមុខឥតមានឃ្លាត អហោរាត្រណាក៏សញ្ជប់ គិតទៅគិតមកឃើញសព្វគ្រប់

គួរឈប់លះលែងល្បែងហ្នឹងទៅៗ

ព្រោះបើខំប្រឹងតទៅមុខ ក្ដីទុក្ខនឹងចេះតែងំនៅ គួរគិតឱ្យឃើញការណ៍រាក់ជ្រៅ

ញើក្ដាយត្រូវលែងទៅកុំអាល័យ !

**អាក្រីឌស្ថាន** ឬ **អាក្រីឌភូមិ** *ន.* ទីសម្រាប់លេង, ទីលេងកម្សាន្ត, កីឡាឋាន, កីឡាភូមិ :

**ពាក្យកាព្យ**

អាក្រីឌស្ថានសម្រាន្តរម្យ គេតែងនិយមទៅកម្សាន្ត ជាទីជិតមិនឆ្ងាយប៉ុន្មាន

គេទៅមកបានដោយងាយស្រួលៗ

**អាខ្យា** *ន.* (សំ. បា.) នាម, អធិវចនៈ; ការស្រែកហៅ; ការហៅឈ្មោះ, ការហៅតាមឈ្មោះដែលរៀងក្នុងបញ្ជី :

**ពាក្យកាព្យ**

អ្នកទាំងអស់គ្នា ប្រុងស្ដាប់អាខ្យា ឮហើយមូលមក
កុំបាច់ឱ្យគេ ពិបាកដើររក ជជ្រកមមក
នាំឱ្យខាតការ។

**អាចម** *ន.* (**សំ. ឆា.**) ការលាងជម្រះឱ្យស្អាត, ការលាងជម្រះឱ្យជ្រះមន្ទិលកខ្វក់ :

**ពាក្យកាព្យ**

អាចមជាពាក្យសមជាងអាចម៍ ចាស់ទុំសម្រេចថាត្រូវស្ដី ចំពោះបុគ្គលដែលគប្បី
គោរពកោតក្រែងរអែងចិត្ត។

**អាចម៍កន្លង់** *ន.* **(ព. ប្រ.)** កម្ទេចដែលកើតអំពីខ្លួង, ស្វាន, ខៃ, ក្ដារ (ដោយដែកកណ្ដារ) ជាដើមស្រដៀងឬដូចកម្ទេចដែលកន្លង់ចោះ (ពាក្យក្រាបទូលក្សត្រថា **មូលកន្លង់** ឬ **កម្ទេចដែកខួង** ជាដើម)។ ស្លឹកចេកទុំជាដើម ដែលញាត់បុកក្នុងប្រហោងកាំភ្លើងធំឱ្យណែនរំសេវ :

**ពាក្យកាព្យ**

រីពាក្យណាៗ ខាងដើមមានថា អាចម៍ៗនេះផ្សំ
ត្រូវស្ដីថាមូល ខាងដើមទើបសម- នឹងក្សត្រឧត្ដម
ដែលត្រូវកោតក្រែង។

ពាក្យមូលកន្លង់ ជាវាចាផ្គង់ ដោយក្ដីរអែង
គោរពមហាក្សត្រ ជាព្រះគម្ដែង ចាស់បូរាណតែង-

តែស្ដីយ៉ាងហ្នឹង។

**អាឍ្យចរ** *គុ.* (សំ.) ដែលធ្លាប់មានទ្រព្យស្ដុកស្ដម្ភពីដើមមក គឺដែលធ្លាប់តែមានទ្រព្យស្ដុកស្ដម្ភមាំមួនច្រើនតំណមកហើយ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| ពូជអាឍ្យចរ | ជាផៅបវរ | តាំងពីដូនតា |
| ជួនតាំងពីទួត | ពីលួតពីលា | សឹងមានចរិយា |
| | ប្រព្រឹត្តត្រឹមត្រូវ។ | |
| ពូជខ្ពង់ខ្ពស់ថ្កើង | ទោះបីបានឡើង | យសសក្តិម្ដេចក្ដូវ |
| ពុំដែលចើងម៉ើង | ពព្រើតខុសផ្លូវ | ច្រើនកាន់ត្រឹមត្រូវ |
| | គួរយកតម្រាប់។ | |

**អាណិកជន** *ន.* (បា. «**អាណា + ណិក + ជន**») ជនដែលនៅក្នុងអំណាចគេ, ជនអ្នកនៅក្រោមអំណាចនៃបុគ្គលដទៃ; ជនជាតិនានាដែលនៅអាស្រ័យប្រកបមុខរបរក្នុងប្រទេសដទៃ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| អាណិកជន | ទោះបីមានធន- | ទ្រព្យច្រើនត្រឹមណា |
| មកនៅក្នុងរដ្ឋ | ដទៃនានា | ត្រូវស្ដាប់បញ្ជា |
| | តាមច្បាប់រដ្ឋនោះ។ | |

**អាណិត** *កិ.* នឹកអាសូរ, មានករុណា, នឹកស្រណោចលន្លោចចិត្តទៅរក, នឹកប្រណី :

**ពាក្យកាព្យ**

វីក្ដីអាណិត បណ្ដាលពីចិត្ត សង្វេគលន្លោច
នៅស្ងៀមពុំសុខ ដូចគេបោចរោច ចេះតែអាណោច
ចង់ជួយសង្គ្រោះ។

**អាណិតអនាថ** *កិ.* អាណិតអ្នកដែលឥតទីពឹង, អាណិតអ្នកដែលឥតទីពំនាក់; អាណិតអាសូរពន់ពេក :

**ពាក្យកាព្យ**

អាណិតអនាថ ឆ្ពោះមនុស្សឥតញាតិ ណាមួយជួយគ្នា
ឃើញគ្នាទ័លក្រ កំព្រើកំព្រា គួរសង្គ្រោះគ្នា
ឱ្យបានសុខផង។
គ្នាក៏ដូចយើង ចង់សុខចង់ថ្កើង ចង់ឱ្យហួត់ហួង
ប៉ុន្តែកម្មផល ផ្ដល់ខុសបំណង សូម្បីប៉ុនល្អង
ក៏កែពុំកើត។

**អាណិតអាណោច** *កិ.* អាណិតស្រណោចលន្លោចចិត្ត :

**ពាក្យកាព្យ**

អាណិតអាណោច ហាក់ដូចជាខ្លោច- ចិត្តឆ្ពោះទៅរក
ជនដែលរងទុក្ខ ជជ្រុលជជ្រក មានអ្វីក៏យក
ទៅជួយសង្គ្រោះ។

**អាណិតអាសូរ** *កិ.* អាណិតខ្លោចចិត្ត, អាណិតស្រណោចខ្លោចចិត្ត :

**ពាក្យកាព្យ**

អាណិតអាសូរ កាលឮគេថ្ងូរ នៅស្មៀមពុំសុខ
ចង់តែទៅជួយ ឱ្យគេស្រាលទុក្ខ ចិត្តធ្ងន់កណ្ដុក
ប៉ផ្អុករឿយៗ។

**អាណោច** *កិ.* ស្រងោចលន្លោចចិត្ត; នឹកអាណិតខ្លោចចិត្ត :

**ពាក្យកាព្យ**

នឹកឃើញចេះតែអាណោចចិត្ត ព្រោះដ្បិតធ្លាប់រាប់អានគ្នាមក ឥឡូវពុំដឹងជាទៅជ្រក
សំណាក់អាស្រ័យនៅទីណា?
ឃ្លាតបាត់ទៅហើយតើធ្វើម្ដេច បើលេចដំណឹងខ្លះទៅវ៉ា នឹងបានលៃលកតាមរកគ្នា
ឥឡូវទៅជាទាល់គំនិត។

**អាត្ម័ន** *ន.* (**សំ. អាត្មន**) អាត្មា (ខ្លួន; ចិត្ត)។ តាមលទ្ធិខ្លះប្រែថា «**ព្រលឹង**» ក៏មាន :

**ពាក្យកាព្យ**

អាត្ម័នអាត្មា ទោះប្រើពាក្យណា ក៏បានដូចគ្នា
ទាំងពាក្យអត្តា នេះឯងក៏ជា ពាក្យមានន័យថា
ចិត្តឬខ្លួនប្រាណ។
តាមពិតសម្ដី ទាំងពីរទាំងបី នេះមានសន្ដាន
ប្រភពកំណើត កើតពីដើមធាន **អទ**-ធាតុដែលមាន
ន័យប្រែថា **ស៊ី**។
ស៊ីសុខស៊ីទុក្ខ ស៊ីអ្វីគ្រប់មុខ ស៊ីឥតរើសទី

អត្តាហ្នឹងឯង ចេញទែងខាងស៊ី ដែលហៅថាស៊ី
គឺរងអារម្មណ៍។
អារម្មណ៍គ្រប់មុខ ទោះសុខទោះទុក្ខ ចេះតែសន្សំ
ទោះអរទោះខឹង ទោះខ្ពិលទោះខំ ត្រជាក់ក្តៅធំ
ចេះតែទទួល។

**អាត្មោបជីវិន** *ន.* (**សំ. អាត្មន** «ខ្លួន; ចិត្ត» + **ឧបជីវិន** «អ្នកចិញ្ចឹមជីវិត») អ្នកចិញ្ចឹមជីវិតដោយអាស្រ័យកម្លាំងខ្លួន :

**ពាក្យកាព្យ**

អាត្មោបជីវិន ជាអ្នកប៉ិនខាងរកស៊ី ទោះបីនឿយរ៉ាំរ៉ៃ
ក៏ពុំដែលត្អូញមួយម៉ាត់ៗ
ជាជនចេះខំប្រឹង មិនតម្អឹងខ្លាចវិបត្តិ ធ្លាក់ត្រូវហើយកម្ចាត់
នូវទ្រព្យធនឱ្យហិនហោចៗ

**អាទ្យូន** *គុ.* (**សំ.**) ដែលមានពោះធំកំប៉ោង, ដែលដុះពោះកំប៉ោង; ដែលបរិភោគបានច្រើនហួសប្រមាណ (ស៊ីច្រើន) :

**ពាក្យកាព្យ**

មនុស្សអាទ្យូន ដុះពោះធំពូន កំប៉ោងដូចហ៊ីង
អាហារមួយថាស ស៊ីអស់រលីង ពោះធំត្រពីង
នៅតែដដែល។

**មួយបែបទៀតថា**

រូបរាងអាឡូន ប៉ុន្តែមានកូន សុទ្ធតែស្រស់បស់
គាត់មានកេរ្តិ៍ឈ្មោះ ថាជាសប្បុរស កូនគាត់ទាំងអស់
សុទ្ធតែបានការ។

**អានាហារោគ** *ន.* (**សំ. បា. អានាហ** «ដំណើរទល់ឧច្ចារៈឬបស្សាវៈ» + **រោគ** «ជំងឺ») រោគទល់ គឺជំងឺទល់ឧច្ចារៈឬបស្សាវៈ, ជំងឺទល់ខ្យល់, ជំងឺទល់ពោះច្រអរ :

**ពាក្យកាព្យ**

អានាហរោគមានម្ដងៗ ពុំគួរផ្សរផ្សងត្រូវរកថ្នាំ មន្ទីរព្យាបាលមានប្រចាំ
ប្រយ័ត្នកុំប្រើថ្នាំព្រៃផ្សៃៗ

**អាប់ចុន** *គុ.* (**ស.**) ដែលទាល់គំនិត, ដែលទាល់ផ្លូវទាល់ដំណើរ; តោកយ៉ាក, ដុនដាប; ទន់ថយ, ខ្សោយអានុភាព :

**ពាក្យកាព្យ**

កាលខ្លួនមានបុណ្យ ពុំស្គាល់អាប់ចុន ស្រវឹងថ្កើងថ្កាន
លុះដល់ធ្លាក់ខ្លួន អស់យសធនធាន ទើបភ្ញាក់វិញ្ញាណ
ស្គាល់ភាពអាប់ចុន។
ឥតគេរាប់អាន ព្រោះកម្មរុញច្រាន ឱ្យអស់សក្តិបុណ្យ
ខំប្រឹងរិះរក ប៉ប៉ះប៉ប៉ុន តាមភាពអាប់ចុន
ផ្សងបុណ្យព្រេងចាស់។

**អាប័ន** ឬ **អាបទា** *ន.* (**សំ. អាបទ** ឬ **សំ. បា. អាបទា**) គ្រោះកាច; អន្តរាយ; វិបត្តិ :

**ពាក្យកាព្យ**

នៅស្ងៀមស្ងាត់ៗ ស្រាប់តែអាប័ទ កើតឡើងភ្លាមៗ
នាំឱ្យវាក់វិន ទាក់ទិនទីមទាម គ្រោះកាចគំរាម
ឱ្យបង់ធនធាន។
គឺអាបទា ទោះខ្លួនមានគ្នា ក៏ជួយពុំបាន
ព្រោះកម្មអាក្រក់ មកផ្ទក់រុញច្រាន ភិតភ័យឥតស្រាន្ត
រហាមរងទុក្ខ។

**អាប់ប៉ត្រាប់** *គុ.* ដែលអួអាប់; ប្រឡាក់ប្រឡូស, ព្រលូស, កខ្វក់ :

**ពាក្យកាព្យ**

ស្លៀកពាក់អាប់ប៉ត្រាប់ ខុសទម្លាប់គេនិយម នាំឱ្យអ្នកតូចធំ
ជាតិជាមួយអាប់ឱនផង។

**អាបឡាប** *គុ.* ព្រវីព្រវារ, តតេបតតាប; កខ្វេសកខ្វាស :

**ពាក្យកាព្យ**

ដូចខ្វាក់បាំងស្បែក ដូចកល់តម្ដែក ចង់សូមប្រេងលាប
ដូចថ្លង់ស្ដាប់ច្រៀង ទះដៃទាបៗ ដូចខ្វិនអាបឡាប
ចង់ចងក្បិនរត់។

**អាប៉ោង** *ន.* (ស. ឈ.) ឈ្មោះជូតកម្មមួយយ៉ាង លេងស៊ីសងដោយមាន មេបង្វិលឱ្យវិលឈរ ហើយគ្របបំបាត់មិនឱ្យឃើញ, លុះបើកគម្របឡើង ទើបដឹងថាត្រូវស៊ីត្រូវសងតាមលក្ខណៈដែលកំណត់ :

## ពាក្យកាព្យ

អាប៉ោងជាជូតកម្មមួយ  អ្នកចាក់វង្វេយព័ទ្ធជុំវិញ  ច្រើនតែខាងមេមានចំណេញ
អ្នកចាក់ឈ្លក់ចេញប្រាក់ចាក់លេងៗ

អ្នកចាក់អស់ប្រាក់ពីហោប៉ៅ ជួននៅខ្ចីគ្នាចាក់មិនលែង  ចាក់ៗអស់ប្រាក់រលីងធេង
ចំបែងមកផ្ទះដេកព្រួយចិត្តៗ

**អាពាធិក** *គុ.* (**សំ. បា.**) ដែលមានជំងឺ :

## ពាក្យកាព្យ

ជនអាពាធិក  ពុំបានបាយទឹក  គួរអ្នករក្សា
ប្រញាប់ទៅសួរ  គ្រូពេទ្យរួសរាំ  បង្គឹបង្គា
ច្រើនតែពុំស្រួល។

**អាពាហ៍ពិពាហ៍** *ន.* (**សំ. បា. អាវាហ + វិវាហ**; ខ្មែរប្រើផ្លាស់ **វ** ជា **ព**) មង្គលការគូបុរសស្ត្រីដែលបាននាំមកហើយនាំត្រលប់ទៅវិញ (ពីរលើក) :

## ពាក្យកាព្យ

អាពាហ៍ប្រែថាការនាំមក  នូវប្រុសពន្លកជាគូគ្នា  មកផ្ទះខាងស្រីតាមវេលា
ពិពាហ៍ថានាំស្រីទៅវិញៗ

**អាភរណៈ** ឬ **អាភរណ៍** *ន.* (**សំ. បា. អាភរណ**) គ្រឿងប្រដាប់កាយ, អលង្ករណ៍, អលង្ការ :

## ពាក្យកាព្យ

អម្ពរស្អាតស្អំ  មានអាភរណ៍ផ្សំ  ថែមផងរូបប្រាណ

សមនឹងយសសក្តិ អនគ្ឃថ្កើងថ្កាន អ្នកផងរាប់អាន
បានពេញមុខមាត់។

**អាភា ៩.** (**ឃ.**) រស្មី, ពន្លឺរស្មី :

**ពាក្យកាព្យ**

ពន្លឺប្រាជ្ញា ព្រះពុទ្ធហៅថា ពន្លឺឧត្តម
ហៅបញ្ញាភា មិនដែលច្រឡំ ពន្លឺតូចធំ
ប្រៀបផ្ទឹមពុំបាន។
ពន្លឺអាទិត្យ ផ្សាយធំពេកពិត ពុំអាចរុញច្រាន
នូវទោសនិងទុក្ខ ឱ្យឃ្លាតចាកប្រាណ ឱ្យសត្វផងបាន
ក្តីសុខស្ងប់ឡើយ។
ពន្លឺប្រាជ្ញា មានមុខមុតថ្លា កាត់ទុក្ខឱ្យស្បើយ
បង្កើតក្តីសុខ ស្រណុកកន្តើយ នាំសត្វដល់ត្រើយ
គឺក្តីសុខស្ងប់។

**អាម ៥.** ពាក្យសម្រាប់និយាយផ្សំជាមួយនឹងពាក្យ **ឧម** ថា **ឧមអាម** អាគម ដែលមានពាក្យ **ឧម** ផ្តើមជាមុន :

**ពាក្យកាព្យ**

អាគមឧមអាម ព្រះពុទ្ធទ្រង់ហាម មិនឱ្យអ្នកបួស
រៀនសូត្រក្បួចកាន់ ក្រណាន់ជ្រុលជ្រួស ភ្លេចគិតសីលផ្នួស

ដើរស្តោះព្រួសគេ។

**អាមយ** ឬ **អាម័យ** *ន.* (**សំ. បា. អាមយ**) រោគ, អាពាធ, ព្យាធិ, ជំងឺ :

**ពាក្យកាព្យ**

ខ្លួនអ្នកសព្វថ្ងៃ ពុំមានអាម័យ ទេឬយ៉ាងណា?

ប្រសិនបើមាន គួរថែរក្សា ឆាប់ៗរួសរាំ

ទើបបានស្រួលខ្លួន។

**អាមវាត** (**សំ. បា. អាម** «ឆៅ» + **វាត** «ខ្យល់») ខ្យល់ដែលបណ្តាលឱ្យហើមពោះ, ខ្យល់ហើមពោះ; រោគហើមពោះ (បណ្តាលអំពីការបរិភោគអាហារឆៅឬព្រោះអាហារមិនរលួយ) :

**ពាក្យកាព្យ**

រីអាមវាត ជារោគាពាធ ហើមពោះច្រអឹង

កើតពីបរិភោគ អាហាររឹងៗ ដែលពុំអាចនឹង

រលាយឆាប់បាន។

ពុំនោះកើតព្រោះ អាហារស្រស់ៗ ឆៅទាំងប៉ុន្មាន

ដែលក្រ-រលាយ ក៏សឹងតែមាន អ្នកថែទាំប្រាណ

ត្រូវស្តាបស្ទង់មើល។

**អាមសូល** *ន.* (**បា. អាម** «ឆៅ» + **សូល** «ការចាក់ដោត») ជំងឺចុកសៀតពោះ, ជំងឺចុកពោះ (បណ្តាលអំពីការបរិភោគអាហារឆៅជាដើម) :

**ពាក្យកាព្យ**

អាមស្អូលជាអាគចុកសៀតពោះ    កើតព្រោះអាហារស្រស់ឆៅៗ    គួរស្ទាបស្ទង់មើលកុំសៅដៅ
ជួនមេរោគនៅនោះក៏មានៗ

ចាស់ថាថ្នមខ្លួនស្ងួនចំណី    ថ្នមស្រីកុំប្រើការឈ្លានពាន    អាម័យត្រូវចៀសកុំឱ្យមាន
ទោះឃ្លានត្រូវមើលសិនសឹមស៊ីៗ

ត្រូវតែឱ្យមានអនាម័យ    រាល់យប់រាល់ថ្ងៃត្រូវសំគី    រក្សាខ្លួនប្រាណជន្មជីវី
ដ្បិតស្លាប់ព្រោះស៊ីក៏សឹងមានៗ

**អាមោទ** ឬ **អាមោទៈ** *ន.* (**សំ. បា. អាមោទ**) សេចក្ដីរីករាយច្រើន; គ្រឿងឬក្លិនក្រអូបខ្លាំងឬក៏ក្រអូបសាយ, ក្រអូបឈ្ងប់។ ប្រើជា *គុ.* ផង ក៏បាន «ដែលរីករាយច្រើន, ដែលមានអំណរខ្លាំង; ក្រអូបខ្លាំង, ក្រអូបសាយ» :

**ពាក្យកាព្យ**

អាមោទវាទញាតិរីករាយ    ស្រស់ស្រាយសប្បាយទាំងអស់គ្នា    ជាគាពឱ្យមានសមគ្គា
ដែលជាប្រទពសាមគ្គីៗ

**អាយ** *សព្វ.* ដែលទីទៃពីពាក្យថា **នាយ** ឬ **ខាងនាយ** គឺខាងនេះ, ខាងឯណោះ :

**ពាក្យកាព្យ**

ហៃកូនមាសម្ដាយ    មកអាយឆាប់វ៉ា    ម្ដាយនឹងប្រាប់បា
ឱ្យដឹងរឿងហេតុ។

**អាយតនិបាត** *ន.* (**សំ. បា. អាយត** «ដែលញែកឬវាតចេញឱ្យទូលាយ» + **និបាត** «និបាតសព្ទ») ទីបំផុតនៃនាមសព្ទដែលសម្រេចដោយវិភត្តិនាមស្រេចហើយ, ពាក្យប្រែរបស់វិភត្តិនាម :

### ពាក្យកាព្យ

និបាតពួកនេះទាំងប៉ុន្មាន អ្នកប្រើស្មានៗច្រើនតែឆ្លាត់ នៃ-នូវ-ដល់-ដោយគួរប្រយ័ត្ន
កុំឱ្យវិបត្តិខូចសេចក្ដីៗ
គួរអ្នកស្រលាញ់អក្សរជាតិ កុំប្រើឱ្យឃ្លាតចាកវិធី គួរធ្វើសម្ពន្ធឱ្យខ្ចេចខ្ចី
ឈ្លេចឈ្លីជាមុនសិនសឹមប្រើៗ
ពាក្យដល់និងនៃសេចក្ដីផ្សេង ជួនតែន្តរង្វេងប្រើសើៗ បែរមានសេចក្ដីប៉ះទៅលើ
ក្ដីច្នេះសោះតើជាច្នោះវិញៗ

**អាយោធន ឬ អាយោធន៍** *ន.* (**សំ. បា. អាយោធន**) សង្គ្រាម, ចម្បាំង :

### ពាក្យកាព្យ

ប្រទេសសុខសោត បើមានអាយោធន៍ រដ្ឋរាស្ត្រច្របល់
កិច្ចការប្រយោជន៍ ហិនហោចឥតសល់ ព្រោះតែកង្វល់
ផ្ដល់ឱ្យតាមកាល។

### មួយបែបទៀតថា

កំណើតអាយោធន៍ មានការក្រេវក្រោធ ជាដើមប្រធាន
ទោះម្ខាងខំទប់ ម្ខាងទៀតរុករាន ដោយក្ដីឈ្នានពាន
ទន្ទ្រានញាំញី។
ជួនម្ខាងរំលោភ ព្រោះតែក្ដីល្មោភ ចង់បានទឹកដី
របស់គេលាំងៗ ឥតអៀនខ្មាសអ្វី ម៉្លោះម្ចាស់ទឹកដី
គេអត់ពុំបាន។

**អារាធនា** *ន.* (**សំ. បា. អារាធន**) សេចក្ដីពេញចិត្ត; ការរាប់រក; ការឱបអរ; ការយកចិត្តយកថ្លើម; ការប្រោសប្រាណ; ការបូជា; សេចក្ដីសម្រេច; ការនិមន្ត, ការអញ្ជើញ។ ខ្មែរប្រើជា *កិ.* សំដៅសេចក្ដីថា «និមន្តឬអញ្ជើញដោយគោរពសូមឱ្យសូត្រឬឱ្យសម្ដែង, ឱ្យនិយាយអធិប្បាយ» ជាដើម (ប្រើចំពោះតែទៅរកបព្វជិត) :

**ពាក្យកាព្យ**

អ្នកមានវិជ្ជា ឥតអារាធនា កុំពោលអួតខ្លួន
ព្រោះនាំឱ្យសាប បង់ភាពខ្ជាប់ខ្ជួន ចំណេះមាំមួន
ប្រែរជាទន់ខ្សោយ។

**អារាមាធិការ** *ន.* (**បា.**) ចៅអធិការវត្ត (ហៅ **អាវាសាធិការ** ក៏បាន) :

**ពាក្យកាព្យ**

អារាមាធិការ ចេះធម៌អាចីអ្នកគ្រប់គ្រង ទើបត្រូវតាមទំនង
នាយកធម៌ប្រាំមួយៗ
បើខ្វះធម៌ទាំងនោះ ច្រើនមានមោះហ្មងឱ្យព្រួយ ឥតមានអ្នកណាជួយ
ត្រូវតែខ្លួនជួយខ្លួនឯងៗ

**អាលាបកថា** *ន.* សម្ដីរួសរាយរកគ្នា :

**អាលាបសល្លាប** *ន.* ការនិយាយចរចារាក់ទាក់ទៅវិញទៅមករកគ្នា :

**ពាក្យកាព្យ**

អាលាបកថា បង្កើតជាការប្រាស្រ័យ កើតឫានជាបច្ច័យ

នៃសេចក្ដីព្រមព្រៀងគ្នា។

អាលាបសល្លាប ជាសតាពសមគ្គា ព្រះពុទ្ធទ្រង់ប្រាប់ថា

ជាបក្ខពួកសាមគ្គី។

**អាលុលិកវាចា, អាលុលិកវាទ** ឬ **អាលុលិកពាក្យ** *ន.* សម្ដីផ្ដេសផ្ដាស, សម្ដីឡេះឡោះ; សម្ដីដែលរឹកវរ :

**ពាក្យកាព្យ**

អាលុលិកវាទ តែងតែឃ្លាតចាកការណ៍ពិត មនុស្សមានគំនិត

គេពុំចង់ឮសោះឡើយ។

**អាវ៉ាសែ** ឬ **អាវ៉ាសៃ** *កិ. វិ.* ឬ *គុ.* ណែលណោល, តែលតោល, ដែលឥតទីពឹងពំនាក់, ដែលសាត់អណ្ដែតទៅមកតាមតែបាន :

**ពាក្យកាព្យ**

ជនអាវ៉ាសែ ធ្លាប់ឃើញច្រើនតែ លុបលាងគុណគេ

បើគេសង្គ្រោះ ហ៊ានឈ្លោះនឹងគេ ជួនឱ្យទោសទ្វេ

ក៏សឹងតែមាន។

**អាវុធ** *ន.* (បា.) គ្រឿងប្រហារផ្សេងៗដែលទីទៃពីសស្ត្រា, គ្រឿងចម្បាំងផ្សេងៗដែលទីទៃពីសស្ត្រា :

**ពាក្យកាព្យ**

ទាហានមោះមុត ដែលមានអាវុធ ជាប់នៅក្នុងដៃ

កាលបើបានជួប ចោរកាចចង្រៃ មិនសូវសំចៃ

ច្រើនតែគំរាម។

ព្រោះមានអាវុធ សម្រាប់ប្រយុទ្ធ ពុំដែលទីមទាម
ប្រទះសត្រូវ ច្រើនតទប់ភ្លាម ស៊ូប្ដូរសាច់ឈាម
ពុំដែលរួញរា។

ការពារប្រទេស ពុំដែលមានធ្វេស គួររាស្ត្រប្រជា
ជួយឧបត្ថម្ភ គាំទ្រយោធា ដោយក្ដីស្នេហា
ស្រលាញ់ទាហាន។

**អាសគ្រាម** *គុ.* (**សំ. អាសា** «បំណង» + **គ្រាម** «ស្រុក, អ្នកស្រុក») ដែលគួរឱ្យអៀនខ្មាស, ដែលគួរឱ្យរឹងខ្លួន, ពុំគួរនឹងនិយាយ, ពុំគួរនឹងថា មានថាដល់កេរខ្មាសឬចំអាសចំអូងជាដើម (ប្រើចំពោះតែវាចា) :

**ពាក្យកាព្យ**

សម្ដីអាសគ្រាម ចាស់ទុំហាមយ៉ាងម៉ឺងម៉ាត់ ថាត្រូវតែប្រយ័ត្ន
កុំឆ្លាត់មាត់និយាយស្ដី។

ទោះបីពាក្យគន្លាស់ ជាទំនាស់ពុំគប្បី ត្រូវតមកុំស្រដី
ជនប្រុសស្រីគេជ្រេញចិត្ត។

**អាសង្កា** *ន.* (**ធា.**) សេចក្ដីសង្ស័យខ្លាំង; ការនឹកពិភាល់ខ្លាំង; សេចក្ដីរង្កៀសខ្លាំង; ដំណើរដិតចិត្តឬចាប់មន្ទិលទៅរក :

**ពាក្យកាព្យ**

បើមានអាសង្កា កុំអាលថាឱ្យគេដឹង ត្រូវរិះរេរំពឹង

ស្ទង់មើលហេតុឱ្យជាក់សិន។

**អាសនៈ** ឬ **អាសន៍** *ន.* (**សំ. បា. អាសន**) ទីអង្គុយ, កន្លែងអង្គុយ, កម្រាល សម្រាប់អង្គុយ, ប្រដាប់សម្រាប់អង្គុយ :

**ពាក្យកាព្យ**

កុំអាលច្រឡាស  អង្គុយដើមអាសន៍  រួចបែរជាថយ
ចុះមកចុងអាសន៍  ឱ្យខ្មាសស្ដាយក្រោយ  ប្រយ័ត្នកុំធ្លោយ
ឱ្យខ្សោយភាពខ្លួន។

**អាសន្ន** *គុ.* (**សំ. បា.**) ជិត។ ខ្មែរប្រើជា *ន.* ផងក៏មាន «ទីជិត; ហេតុឬដំណើរ, ការធុរៈដែលមានទីជិត, ប្រចុចប្រចំ, បន្ទាន់, ប្រញឹកខ្លាំង, មមាញឹក, ទាន់ហន់» :

**ពាក្យកាព្យ**

បើមានអាសន្ន  កុំអាលភ័យស្លន់  ត្រូវប្រុងស្មារតី
រំពឹងដង្ហិន  ឱ្យដឹងសេចក្ដី  រាក់ជ្រៅវែងខ្លី
រួចលៃលកភ្លាម។

**ឥត្ថី** *ន.* (**បា.**«មនុស្សដែលបុរសគួរចង់បាន, មនុស្សដែលជាគូនឹងបុរស») ស្ត្រី, ស្រី :

**ពាក្យកាព្យ**

ឥត្ថីបុរស  ជាតិខ្មែរទាំងអស់  ធ្វើការជួយរដ្ឋ
ស្មុះស្មា-រទែង  ខ្នះខ្នែងតាមបទ  ធ្វើការប្រាកដ
ជាធ្វើមែនៗ។

ស្ម័គ្រចិត្តខ្លួនឯង ពុំមែនខ្លាចក្រែង អំពីកំណែន
សមិទ្ធិច្រើន កើតកើនក្នុងដែន រដ្ឋខ្មែរមែនទែន
ដូចផ្សិតខែភ្លៀង។

សម័យអង្គរ ប្រទេសខ្មែរឈរ នឹងថ្កល់ឥតល្អៀង
សម័យសង្គម និយមធម៌ទៀង កម្ពុជាឥតជ្រៀង-
ជ្រេទ្រេតទ្រោតឡើយ។

**ឥទ្ធិបាទ** *ន.* (បា.) គុណធម៌ប្រៀបដូចជាជំហាននៃសេចក្តីសម្រេច, គុណធម៌ប្រៀបដូចជាជំហាននៃសេចក្តីចម្រើន :

**ពាក្យកាព្យ**

យើងគួរសង្វាត បំពេញឥទ្ធិបាទ ឱ្យបានគ្រប់គ្រាន់
គង់នឹងសម្រេច ប្រយោជន៍ឃើញទាន់-ភ្នែកនាបច្ចុប្បន្ន
ពុំដែលឃ្លាងឡើយ។

**ឥន្ទ្រិយ** *ន.* (សំ. បា.) ភាវៈជាធំ, ឥស្សរភាព; អានុភាព, អំណាច; គុណានុភាពឬគុណសម្បត្តិរបស់ព្រះឥន្ទឬដែលជាប់ទាក់ទង អំពីព្រះឥន្ទមក; រូបកាយ; កម្លាំង, កម្លាំងកាយ; សេចក្តីដឹង, ប្រាជ្ញា; អារម្មណ៍; មុខការ, នាទី; អាយតនៈខាងក្នុង, ប្រសាទ, ប្រសាទរូប :

**ពាក្យកាព្យ**

សង្រួមឥន្ទ្រិយ ពាក្យចាស់អំពី បុរាណហៅថា

ស្រគត់ឥន្ទ្រិយ ជាទីជ្រះថ្លា ទោះបីជនណា
ក៏តែងពេញចិត្ត។
សង្រួមឥន្ទ្រិយ តាជីដូនជី និងបព្វជិត
ស្រគត់ស្រគំ សមរម្យមែនពិត ចេញចរឆ្ងាយជិត
គេរែងគោរព។

**ឥរិយាបថ** *ន.* (បា.) គន្លងនៃឥរិយា គឺការដើរ, ឈរ, អង្គុយ, ដេក :

**ពាក្យកាព្យ**

ឥរិយាបថបួន គួរជនប្រុងខ្លួន តាមសុជីវធម៌
ត្រឹមត្រូវទៀងទាត់ បែបបទបវរ នឹងមានអំណរ
មិននឹកស្ដាយក្រោយ។

**ឥសុការ** ឬ **ឧសុការ** *ន.* (សំ.) អ្នកធ្វើព្រួញ; អ្នកធ្វើគ្រឿងបាញ់គ្រប់យ៉ាង (មានធ្នូ, ស្នាជាដើមព្រមទាំងសរ គឺព្រួញនិងគ្រាប់សម្រាប់បាញ់ផង) :

**ពាក្យកាព្យ**

ឧសុការពត់ព្រួញវៀចឱ្យត្រង់ ជនមានរូបអង្គគួរពត់ចិត្ត ដែលវៀចឱ្យត្រង់យល់ការណ៍ពិត
បណ្ឌិតគួរត្រាប់ឧសុការ។

**ឥស្វរ** ឬ **ឦស្វរ** *គុ.* (សំ. **ឦឝ្វរ**; ខ្មែរប្រើ **វ** > ្វ) ដែលជាធំ, ជាចម្បង, ជាទីកំពូលលើគេ, ជាម្ចាស់លើគេ :

**ពាក្យកាព្យ**

ឥស្វរនារាយណ៍និងព្រះព្រហ្ម អ្នកជឿនិយមថាសក្តិសិទ្ធិ ឯព្រះសម្ពុទ្ធទ្រង់ពិនិត្យ

ឃើញថាការណ៍ពិតផ្សេងទៅវិញ។

ទ្រង់ឃើញអដ្ឋង្គិកមគ្គ ជាផ្លូវជៀងជាក់ត្រង់រលេញ ទើបលះចោលផ្លូវអមខាងចេញ

ចំណោញបានត្រាស់ពោធិញ្ញាណ។

**ឥស្សា** *ន.* (**បា.**) សេចក្ដីច្រណែន; សេចក្ដីឈ្នានីស (ឫស្យា) :

**ពាក្យកាព្យ**

ឥស្សាឫស្យាដូចជាគ្នា និន្នាឈ្នានីសអ្នកដទៃ ជាតួអកុសលពុំប្រពៃ

ជាធម៌ព្រៃផ្សៃកុំសន្សំ។

ផ្ដល់ផលអាក្រក់ឱ្យញាតិមិត្ត បែកគ្នាពិតៗពិបាកផ្សំ ព្រោះយល់ខុសជ្រុលតន្ត្រច្រឡំ

ពុំសមមនុស្សកាន់ឫស្យាឡើយ។

**នរេស** *ន.* (**បា.**) អ្នកដែលជាម្ចាស់នៃនរជន (ព្រះរាជា) :

**ពាក្យកាព្យ**

ព្រះបាទសម្ដេចព្រះនរេស ជ័យជេស្ឋគ្រប់គ្រងរាជរដ្ឋ មានព្រះតម្រាស់ឱ្យសេនា

ចូលមកគ្រប់គ្នាក្នុងវាំងជ័យ។

**អឹមអៀម** *គុ.* ឬ *កិ. វិ.* ដែលចេះតែស្ងៀមក្រអឹមអៀនប្រៀន, មិនសូវស្ដី និយាយឬដែលច្រើនតែនិយាយរហ៊ឹមៗ ស្ទើរមិនហើបមាត់ (ដោយមានសេចក្ដីអៀនច្រើន) :

**ពាក្យកាព្យ**

បើមិនប៉ិនស្ដី អឹមអៀមវាហី ជាការស្រួលជាង

និយាយខុសៗ ប្រុសគួរចៀសវាង ទោះបីនាងៗ

ក៏គួរធ្លោះដែរ។

សម្ដីជាឯក ទោះចេះដឹងប្លែក ប៉ុន្ដែនៅក្បែរ
អ្នកប្រាជ្ញជ្រៅជ្រះ កុំស្ដីបង្វែរ ការណ៍ពិតឱ្យបែរ
ជាឆ្គងទៅវិញ។

**ឧកាស** ! ឬ **ឧកាសះ** ! *និ.* (**បា. សំ.**; **បា. ឱកាស**) ពាក្យគោរពសម្រាប់ផ្ដើមមុនបង្អស់ក្នុងវេលារៀបនឹងសូមអ្វីៗ ប្រកាសសេចក្ដីណាមួយ, ដោយសេចក្ដីថា «សូមគោរព !, សូមទានគោរព !; សូមមេត្តា !, សូមមេត្តាប្រោស !, សូមទានប្រោស !» (សម្រាប់ប្រើតែខាងសាសនាតាមសេចក្ដីពេញចិត្តឬធ្លាប់ប្រើ) :

**ពាក្យភាព្យ**

ឧកាសៈ ! យើងខ្ញុំ សូមបង្គំឆ្ពោះត្រ័យរត្ន សូមយើងមានវិវឌ្ឍន៍
និងក្ដីសុខស្ងប់សព្វកាល។
សូមឱ្យមានទ្រព្យធន ច្រើនលើសលន់ពន់វិសាល សូមគុណអនិប្បាល
ប្រជាជាតិឱ្យឃ្លាតទុក្ខ។

**មួយបែបទៀតថា**

ឱកាសៈ ! យើងខ្ញុំ មកជួបជុំព្រមព្រៀងគ្នា សូមពោលពាក្យប្ដេជ្ញា
ថានឹងកាន់ចិត្តសច្ចំ។
ចំពោះប្រទេសជាតិ មាតុភូមិរាជបល្លង្ក ពុទ្ធសាសនំ
យើងសូមកាន់ដោយគោរព។

**ឧក្កដ្ឋិសព្ទ** *ន.* (**បា. ឧក្កដ្ឋិសទ្ទ**) សូរហ៊ោ :

**ពាក្យកាព្យ**

ឧក្កដ្ឋិសព្ទ លាន់ឮអឺងអាប់ តើមានការណ៍អ្វី
សួរសព្ទចម្លែក ជ្រែកសោតិន្ទ្រិយ គួរគ្នាយើងម្នី-
ម្នារត់ទៅមើល។
ចាស់ព្រឹទ្ធាចារ្យ ប្រាប់ថាឥតការណ៍ ប្លែកទេកុំផ្អើល
ពួកក្មេងលេងឈ្មូង ទេតើកុំព្រើល ឱ្យរត់ទៅមើល
វាលេងត្រង់ណា?

**ឧក្រិដ្ឋ** ឬ **ឧក្រឹដ្ឋ** *គុ.* (បា. ឬ សំ. ក្ល.; បា. **ឧក្កដ្ឋ**) ធ្ងន់, យ៉ាងធ្ងន់; យ៉ាងតឹង, យ៉ាងតឹងតែង, យ៉ាងម៉ឺងម៉ាត់ :

**ពាក្យកាព្យ**

រីពាក្យឧក្រិដ្ឋ ប្រើបានតាមចិត្ត ផ្សំនឹងគុណទោស
ឆ្ពោះភាពធ្ងន់តឹង ប្រឹងឬសន្តោស ដែលហួសកំណោស
ហៅឧក្រិដ្ឋបាន។

**អុជអាល** *កិ.* **(ព. ប្រ.)** ញុះញង់ចាក់រុកនាយអាយឱ្យក្ដៅចិត្តខ្លាំង (ដូចគេអុជផងអាលផង) :

**ពាក្យកាព្យ**

សម្ដីអុជអាល រែងនាំបណ្ដាល ឱ្យកើតវិវាទ
ឬបើពុំនោះ ក៏ត្រឹមបែកឃ្លាត ទោះញាតិនិងញាតិ
ក៏អាចបែកគ្នា។

ខូចការប្រាស្រ័យ    លុះយូរខែថ្ងៃ    រីករាលទៅជា
បែកសាមគ្គី    ដែលព្រះភគវា    ទ្រង់ត្រាស់ប្រាប់ថា
នឹងមានវិនាស។

សម្ដីអុជអាល    ចង្រៃត្រកាល    ទោះបីអ្នកឈ្លាស
អាចក្លាយជាខ្មៅ    មួម៉ៅផ្ដេសផ្ដាស    មន្ត្រីឬរាស្ត្រ
ដើរទាសខុសផ្លូវ។

**ឧជ្ឈាន** *ន.* (បា.) ការសម្លឹងរំពៃទោសដើម្បីរិះគន់គេ, ការនិយាយអាក្រក់ពីគេ, ការពោលទោសគេ, ការនិយាយដើមគេ; សេចក្ដីរិះគន់គេ :

**ពាក្យកាព្យ**

កុំប្រើឧជ្ឈាន    ព្រោះនាំឱ្យមាន    កំហុសលើខ្លួន
បើបានជាជ្រុល    ម្ដងហើយកុំផ្ទួន    ក្រែងលោគាប់ជួន
ដល់បង់កេរ្ដិ៍ឈ្មោះ។

**ឧដ្ឋាន** ឬ **ឧដ្ឋានៈ** *ន.* (បា. **ឧដ្ឋាន**) ការក្រោក; ការក្រោកពីដេក; សេចក្ដីព្យាយាមក្លៀវក្លា, សេចក្ដីខំប្រឹងពេញកម្លាំង, សេចក្ដីក្រវើនឬក្រវើនក្រតើនធ្វើការដោយមិនខ្ជិលច្រអូស :

**ពាក្យកាព្យ**

ឧដ្ឋានគឺព្យាយាម    មិនទីមទាមដោយក្ដីខ្ជិល    មិនក្រាញឱ្យអេចរិល
អាចរំកិលបង្វិលការ។

ជាគុណធម៌ថ្លៃ    អ្នកឈ្លាសវៃ    មានវិចារណ៍

ពុំដែលមានថ្នោះការ ព្រោះដោយសារមានឧដ្ឋាន។

**ឧដ្ឋានសម័យ** *ន.* (**បា.** **ឧដ្ឋាន** + **សមយ**) សម័យដែលត្រូវក្រោក; សម័យដែលត្រូវខំប្រឹងប្រែងធ្វើកិច្ចការដោយពេញកម្លាំង :

**ពាក្យកាព្យ**

ប្រុទះឧដ្ឋានសម័យ ត្រូវប្រឹងកែខៃឱ្យទាន់គេ កុំនៅទម្រន់ដោយធ្វេសធ្វេ
គេធ្លាក់ពីដេកយើងត្រូវធ្លាក់។

គេផ្ដើមកិច្ចការយើងត្រូវផ្ដើម កុំអើតអើមត្រាតែខ្លួនធ្លាក់ ព្រយុងចំហុងផុងខូចលក្ខណ៍
រអាក់រអួលដួលសន្លប់។

**ឧត** *ន.* ឈ្មោះរោគមួយពួក :

**ពាក្យកាព្យ**

អុតជាជំងឺគួរតែខ្លាច ព្រោះរោគនេះកាចរុករានឆ្លង ពេលណាឮថាមានម្ដងៗ
ជនផងត្រូវស្ដាប់បញ្ជាពេទ្យ។

ប្រញាប់ចាក់ថ្នាំបង្ការឆ្លាម ធ្វើតាមបម្រាមកុំបណ្ដែត- បណ្ដោយឱ្យកើតទៅជាហេតុ
នាំឱ្យរោគអុតឆ្លងពេញពាស។

**ឧត្តម** *គុ.* (**សំ. បា.**) ខ្ពស់, ខ្ពង់ខ្ពស់; កន្លង; ល្អ; ប្រសើរ; ថ្លៃថ្លា; បរិបូណ៌; សម្បូណ៌។ **ព. កា.** ប្រើជា **ឧត្តមះ, ឧត្តមា, ឧត្តមោ, ឧត្តមំ** ក៏បាន :

**ពាក្យកាព្យ**

ព្រះសម្ពុទ្ធោ ព្រះអង្គឧត្តមោ មានធម៌ឧត្តមំ
ទោះបីមានជន និគ្រន្ថប្រឆាំង ប្រទើសប្រទាំង

ក៏ចាញ់តេជះ។

ក្នុងលោកឥតទ្វី មានតែមុនី ពេញទីជាព្រះ

ប្រទានសុខស្ងប់ ឱ្យសត្វបានឈ្នះ ឱ្យបានលាកលះ

នូវក្ដីសល់វ៉ល់។

**ឧត្តាន** *គុ.* (សំ. បា.) រាក់; ផ្ងារ; ងាយ :

**ពាក្យកាព្យ**

សព្ទនេះឧត្តាន ពុំចាំបាច់មាន ការពន្យល់ឡើយ

មានន័យរាក់ៗ ងាយយល់ស្រាប់ហើយ ពុំបាច់សួរឆ្លើយ

គេក៏យល់បាន។

**ឧត្រាស** *ន.* (សំ.) សេចក្ដីខ្លាចខ្លាំង, សេចក្ដីតក់ស្លុត (សរសេរជា **ឧត្រាសៈ** ក៏បាន) :

**ពាក្យកាព្យ**

ដើរក្នុងព្រៃជ្រៅ ក្រឡេកមើលទៅ ឃើញសត្វរមាស

ឈរស្ដឹងពីមុខ ក៏កើតឧត្រាស ឃើញក្ដីវិនាស

នៅជិតបង្កើយ។

**ឧត្បាត** *ន.* (សំ.) ភាពអាក្រក់ដែលបណ្ដាលកើតឡើងខុសពីធម្មតា; ផ្ទួលនៃគ្រោះកាច, ភាពនៃហេតុអាក្រក់; អាភេទ; ចង្រៃ :

**ពាក្យកាព្យ**

ពុទ្ធសាសនា មានន័យថែងថា ឧត្បាតចង្រៃ

កើតមានព្រោះកម្ម ដែលពុំប្រពៃ ឥតមានហេតុអ្វី
ក្រៅពីកម្មឡើយ។
កម្មចាស់ឬថ្មី ជាកម្មអប្រិយ ដែលសត្វធ្វើហើយ
កម្មនោះផ្តល់ផល- ឱ្យពុំកន្តើយ កម្មនោះអស់ហើយ
ក៏លែងផ្តល់ផល។

**ឧទានសព្ទ** *ន.* សព្ទជាឧទាន; សូរសំឡេងឧទាន :

**ពាក្យកាព្យ**

ឧទានសព្ទ សម្តីថ្លែងប្រាប់ ឱ្យបានដឹងថា
បន្ទឺឮៗ ជាសព្ទសញ្ញា អ្នកឮយល់ថា
ព្រួយឬត្រេកអរ។
ព្រះពុទ្ធគ្រប់អង្គ បានត្រាស់ភ្លាមទ្រង់ បន្លឺអំណរ
ថាអញបានរួច ផុតការណ៍វឹកវរ ជរានិងមរណ៍
ក៏អស់មានហើយ។
ដ្បិតអញបានឆ្លង រួចផុតរំលង សាគរដល់ត្រើយ
អម្រឹតនិព្វាន ត្រឹមជាតិនេះហើយ ឱសុខស្ងប់អើយ
យូរណាស់ទើបបាន !។

**ឧន្នាម** *គុ.* ដែលអស់ទូន្មានបាន, ដែលបង្វឹកមិនកើត; ដែលឡើងកម្លាំងឡើងចិត្ត, ទ្រើសកម្លាំងទ្រើសចិត្ត, ទ្រើសឃ្នង, ឡើងចាងមិនស្តាប់ឱវាទ

មិនស្តាប់ច្បាប់; ខ្លាំងចំពោះរាជការផែនដី :

**ពាក្យកាព្យ**

កូនប្រុសទម្រើស ទាល់តែឡើងទ្រើស ទៅជាឧទ្ទាម
នាំឱ្យរដ្ឋា- ភិបាលគំរាម វាមិនស្តាប់តាម
ម៉ែឪព្រួយខ្លាំង។
ជួននាំបះបោរ ជួនទៅជាចោរ ឃោរឃៅប្រឆាំង
គួរម៉ែឪស្តាយ កូនប្រុសត្រឡាំង មិនគួរភ័ន្តភាំង
ដល់ម៉្លឹងទៅសោះ។
ឧទ្ទាមឡើងចាង ព្រោះវាមានអាង ព្រៃជួយរំដោះ
ពេលថ្ងៃលាក់ខ្លួន ពេលយប់ផុតគ្រោះ វាចូលភូមិព្រោះ-
អ្នកភូមិខ្លាចវា។

**ឧទ្ទិស** *កិ.* (បា.) សំដៅទៅរក, សំដៅចំពោះ, ឆ្ពោះត្រង់, តម្រង់ទៅរក; បម្រុងត្រង់, បម្រុងចំពោះ, ធ្វើបម្រុងឬដើម្បី :

**ពាក្យកាព្យ**

ពុទ្ធសាសនា ឱ្យបុត្រធីតា ឬញាតិសន្តាន
ឧទ្ទិសភាគផល កុសលបុណ្យទាន ឆ្ពោះអ្នកចែកឋាន
បាត់បង់ទៅហើយ។

**ឧទ្ទោសិតបាល** *ន.* (បា.) អ្នករក្សាឃ្លាំងដាក់របស់, ឆ្មាំឃ្លាំងដាក់អីវ៉ាន់ (បើស្ត្រីជា **ឧទ្ទោសិតបាលី** ឬ **ឧទ្ទោសិតបាលិកា**) :

**ពាក្យកាព្យ**

| | |
|---|---|
| ឧទ្ទោសិតបាល | ពុំត្រអាលប៉ុន្មានទេ ប្រយ័ត្នឥតធ្វេសទ្វេ |
| | ខ្លាចក្រែងគេលួចរបស់។ |
| រាល់ថ្ងៃរែងព្រួយគិត | ខំពិនិត្យទ្រព្យទាំងអស់ ជូនក្រែងមានរលស់ |
| | ឬគង់នៅសព្វគ្រប់ទេ។ |

**ឧទ្ទេហិក** ឬ **ឧទ្ទេហិកះ** *ន.* (បា. **ឧទ្ទេហិក**) ទានដែលធ្វើចំពោះមតកបុគ្គល ត្រង់ថ្ងៃដែលបុគ្គលនោះទទួលមរណភាព :

**ពាក្យកាព្យ**

| | | |
|---|---|---|
| ឧទ្ទេហិក | ជាទានរំលឹក | គុណុត្តមា |
| នៃបុព្វជន | មាតាបិតា | ជីដូនជីតា |
| | ដែលចែកឋានទៅ។ | |
| ជាទក្ខិណា- | ទានដ៏ថ្លៃថ្លា | ឧទ្ទិសសំដៅ |
| បើបានទទួល | ជាភ័ព្វកូនចៅ | អាចបានបុណ្យក្រៅ |
| | ពីនោះទៅទៀត។ | |

**ឧទ្ធរណ៍** *ន.* (សំ. បា. **ឧទ្ធរណ**) ការរើឡើង; ការរើសើ, ការរើធ្វើជាថ្មីទៀត។ ខ្មែរប្រើពាក្យនេះជាឈ្មោះសាលាឬសាលតុលាការទី២សម្រាប់រើ

ជំនុំជម្រះអធិករណ៍ ដែលគូក្ដីម្ខាងពុំសុខចិត្តនឹងសេចក្ដីវិនិច្ឆ័យនៃចៅក្រមសាលាដំបូង ហើយប្ដឹងសុំឱ្យរើជំនុំកាត់សេចក្ដីម្ដងទៀត។ ប្រើជា *កិ.* ក៏មាន «**សើរើ, រើប្ដឹងជាថ្មីទៀត**» :

**ពាក្យកាព្យ**

សាលាដំបូងវិនិច្ឆ័យ កាត់ក្ដីត្រឹមត្រូវដោយយុត្តិធម៌ ប៉ុន្តែអ្នកចាញ់ឡើងឧទ្ធរណ៍
នាំរៀវឱ្យខូចឈ្មោះចៅក្រម។
ឧទ្ធរណ៍ពីសើជម្រះទៅ ឃើញនៅដូចមុនឥតច្រឡំ ប៉ុន្តែអ្នកក្ដីថាពុំសម
ក៏ខំឡើងសាលវិនិច្ឆ័យ។

**ឧន្នាគ៌ា** *ន.* (**សំ. ឧន្មាគ៌**) ផ្លូវខុស, ផ្លូវអាក្រក់, ផ្លូវទុច្ចរិត; ផ្លូវឆ្វេង; មារយាទអាក្រក់ :

**ពាក្យកាព្យ**

រីឧន្នាគ៌ា ចូរអ្នករាល់គ្នា ចៀសវាងកុំដើរ
ព្រោះជាផ្លូវខុស ពុំគាប់ប្រសើរ ប្រសិនបើដើរ
នឹងភ្លាត់ជើងដួល។

**ឧបករណ៍** *ន.* (**សំ. បា. ឧបករណ**) សេចក្ដីទំនុកបម្រុង, ការជួយទប់ទល់គ្នា; គ្រឿងទប់ទល់, គ្រឿងប្រុង, គ្រឿងប្រកបផ្សំគ្នា; គ្រឿងចិញ្ចឹមជីវិត, មុខការរបរ, ផ្លូវធ្វើការរកស៊ី, ...:

**ពាក្យកាព្យ**

មុខការរបរ ត្រូវមានឧបករណ៍ ទុកជាជំហារ

បើខ្វះឧបករណ៍ អំណរសាទរ ក៏ពុំបវរ
ផុតមុខផុតក្រោយ។
មាននេះខ្វះនោះ មុខការលេះលោះ ពុំផ្ដល់អំណោយ
ទោះបីផ្ដល់ខ្លះ ទ្រព្យធនក៏ខ្សោយ គួរជនកុំធ្លោយ
ឱ្យខ្វះឧបករណ៍។

**ឧបការី** *ន.* (**បា.**) អ្នកទំនុកបម្រុង, អ្នកផ្គត់ផ្គង់, អ្នកផ្ទុងផ្ដើម។ បើស្ត្រីជា **ឧបការិនី** :

**ពាក្យកាព្យ**

ឧបការី ឧបការិនី គួរជនកុំធ្លោយ
បំភ្លេចគុណគេ ក្រែងខ្លួននឹងខ្សោយ ត្រូវធ្វើអំណោយ
តបគុណគេវិញ។
អ្នកលុបគុណគេ កន្ដើយធ្វេសទ្វេ ពុំដែលចំណេញ
ច្រើនតែហិនហោច ទ្រព្យធនប្រាសចេញ ទើបនឹកទន្ទេញ
ដោយក្ដីស្ដាយក្រោយ។

**ឧបកិច្ច** *ន.* (**បា. ឧប** «ចូលជិត» + **កិច្ច** «ការដែលត្រូវធ្វើ»; **សំ. ឧប** + **ក្ឫត្យ**) កិច្ចដែលត្រូវធ្វើភ្លាមៗ; កិច្ចផ្ទាល់ខ្លួន។ ខ្មែរប្រើសំដៅសេចក្ដីថា «ការបំប្លែងដំណើរ, បំប្លែងកិច្ច; ការបំបៀតបំបែរកិច្ច; ការនិយាយបញ្ចៀងតម្រូវតាមដំណើរដែលត្រូវការ, ការធ្វើដោយសន្មតិ, សន្មតិតាមត្រូវការ»។ ប្រើជា *កិ.* ក៏មាន :

**ពាក្យកាព្យ**

ឧបកិច្ចនិងពាក្យឧបក្រិត្យ អ្នកប្រើពេញចិត្តប្រើពាក្យណា ទាំងពីរនេះមាននន័យដូចគ្នា
ចង់ប្រើពាក្យណាក៏ប្រើចុះៗ

**ឧបក្រម** *ន.* (សំ.) ការផ្តួងព្យាយាម, ការព្យាយាមធ្វើ :

**ពាក្យកាព្យ**

ពួកខ្មាំងខិតខំ ធ្វើឧបក្រម រុករានភូមិស្រុក
នៅពេលគេដេក កំពុងលន់លក់ វាចូលសម្រុក
ទាល់តែមានគ្រោះ។

**ឧបក្រោស** *ន.* (សំ.) ការពោលទោសគេ, ការតិះដៀលគេ, ដំណៀល; ការជេរប្រទេចគេ :

**ពាក្យកាព្យ**

កុំធ្វើឧបក្រោស ឱ្យកើតជាទោស បង្ខាតប្រយោជន៍
ច្រើនមានកំហុស នាំឱ្យហិនហោច ឈឺចិត្តផ្សាខ្លោច
ព្រោះតែឧបក្រោស។

**ឧបច្ឆេទកកម្ម** *ន.* (បា.) អកុសលកម្មពីព្រេងនាយដែលអន្ទោលជាប់តាមមកចេញមុខឱ្យផលផ្តាច់ជីវិត :

**ពាក្យកាព្យ**

វិឧបច្ឆេទកកម្ម រង់ចាំផ្តល់ផលផ្តាច់ជីវិត គឺទោសបាណាតិបាតពិត
ដែលញាំងជីវិតគេឱ្យខ្លីៗ

| | | |
|---|---|---|
| បាណាតិបាតកម្មកាច | អាចផ្តល់ជីវិតកូនក្មេងខ្ចី | មិនឱ្យរស់យូរតើព្រោះអ្វី? |
| | ព្រោះថ្វីដៃខ្លួនក្នុងបុព្វ។ | |

**ឧបជីវក** *ន.* (**សំ. បា.**) អ្នកដែលចូលនៅអែបអាងចិញ្ចឹមជីវិតដោយសារគេឱ្យទទេៗ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| ឧបជីវិក | រាល់ពេលបាយទឹក | គិតតែពោះខ្លួន |
| មួយឆ្អែតមួយឆ្អែត | ឱ្យតែគ្រប់ធួន | ពុំសូវនឹកសួន |
| | ប្រណីគេឡើយ។ | |

**ឧបជីវី** *ន.* (**បា.**) អ្នកដែលរស់ដោយសារគេចិញ្ចឹម។ បើស្ត្រីជា**ឧបជីវិនី** :

**ពាក្យកាព្យ**

| | | |
|---|---|---|
| ឧបជីវី | ខ្ជិលពុំរកស៊ី | ដោយអាងតែគេ |
| ចិញ្ចឹមរាល់ថ្ងៃ | ឥតបីរិះរេ | ឱ្យបួសថាទេ |
| | ព្រោះខ្ជិលរៀនធម៌។ | |
| អ្នកបួសក៏ដែរ | បើគ្មានចិត្តបែរ | រកសីលបវរ |
| គិតតែពីឆាន់ | ដោយក្តីត្រេកអរ | ឃ្លាតចាកសីលធម៌ |
| | ក៏ពុំប្រពៃ។ | |

**ឧបត្ថម្ភកកម្ម** *ន.* (**បា.**) កុសលកម្មពីព្រេងនាយដែលចេញមុខទំនុកបម្រុងឱ្យបានសេចក្តីសុខចម្រើន :

**ពាក្យកាព្យ**

វិឌ្ឍបត្ថម្ភកកម្ម ជួយគាំទ្រសត្វឱ្យបានសុខ ទំនុកបម្រុងឱ្យរីកមុខ
និរទុក្ខនិរភ័យជានិរន្តរ៍ៗ

កម្មនេះជាតួបុណ្យកុសល រែងផ្តល់ផលល្អមិនអាប់អន់ មានតាពជាកម្មដ៏សោភ័ណ
ផ្តល់សុខគ្រប់គ្រាន់ឱ្យសប្បាយៗ

មិនត្រឹមតែផ្តល់សុខឱ្យកូន អាចជូនក្តីសុខឱ្យដល់ម្តាយ អាពុកនិងញាតិផងទាំងឡាយ
ឱ្យបានសប្បាយដោយសារផងៗ

**ឧបទេស** *ន.* (បា. សំ.) ការពន្យល់, ការណែនាំ, ការឱ្យន័យឱ្យទំនង; ការបញ្ចេះ, ការប្រៀនប្រដៅ :

**ពាក្យកាព្យ**

ឧបទេសបុរាណ ដែលចាស់ព្រេងបាន ពន្យល់ទុកមក
គួរបច្ឆាជន គន់គិតរាវរក កុំបីកាន់យក
សេចក្តីព្រាវៗ។

**មួយបែបទៀតថា**

ធ្វើការធ្វេសៗ គ្មានឧបទេស ពីគ្រូណាសោះ
ច្រើនតែភ្លាំងភ្លាត់ វិបត្តិការនោះ បើពុំដូច្នោះ
ក៏គង់មានឆ្គង។

**ឧបធិក** *ន.* (សំ. បា.) អ្នកឆបោក, អ្នកបោកប្រាស់, អ្នកប្រវញ្ច, អ្នកបំបាត់គេ។ បើស្ត្រីជា **ឧបធិកា** :

### ពាក្យកាព្យ

ឧបធិកនឹកតែពីប្លោកប្រាស់ នោះបីចាស់ហើយក៏មិនចាល ថែមទាំងបានស្រីខូចត្រកាល
ឧបធិកាជាប្រពន្ធ។

រឹតតែត្រូវគ្នាជាធ្លុងមួយ មិនព្រួយរកស៊ីយល់ថាធ្ងន់ ដូចគ្នាទាំងទ្វីប្ដីប្រពន្ធ
ទុជីនទាំងនេះឥតក្រែងច្បាប់។

ជាប់គុកច្រើនដងក៏មិនខ្លាស ច្រឡាសត្រូវតែតម្រួតចាប់ ចាប់ចុះកុំឱ្យតែសម្លាប់
ចាប់ញយប្លោកញយជាប់គុកញយ។

**ឧបនាហៈ** *ន.* (**សំ. បា. ឧបនាហ**) ដំណើរចងកំហឹង, ការផ្ញុំកំហឹងឱ្យធំនៅជានិច្ច; ការចងគំនុំឬចងពៀរ។ **ព. កា.** ប្រើជា **ឧបនាហ៍** ក៏បាន :

### ពាក្យកាព្យ

ឧបនាហ៍ជាធ្នក់ឡើងដ៏ធំ ចេះតែក្ដៅធំនៅជានិច្ច មិនឆាប់ក៏យូរតែងទង្គិច
នាំឱ្យលង់លិចបែកសាមគ្គី។

បើខឹងឆេវឆាវតែមួយភ្លែត មិនកជាហេតុក្ដៅរ៉ុករ៉ី កំហឹងក៏ស្រាលស្រាកឃ្លាតពី-
គំនុំគុំក្ហួនទៅឯងៗ។

**ឧបបីឡកកម្ម** *ន.* (**បា.**) អកុសលកម្មពីព្រេងនាយដែលជាប់តាមមកផ្ដល់បៀតបៀនឱ្យបាននូវសេចក្ដីទុក្ខលំបាកវិនាសទ្រព្យធនជាដើម :

### ពាក្យកាព្យ

រីឧបបីឡកកម្ម គយឃ្លាំបៀតបៀនផ្ដល់ក្តីទុក្ខ តាមហេតុដែលធ្វើស៊ុកគ្រលុក
ញុាំងសុខឱ្យប្រាសចេញពីគេ។

ប្រតពមកពីរហោសា ជាកម្មខ្លាំងក្លាក្នុងបុព្វេ តាមមកផ្ដល់ផលមិនតិចទេ

ធ្វើគេយ៉ាងណាផ្ដល់យ៉ាងនោះៗ

**ឧបភោគ** *ន.* (សំ. បា.) គ្រឿងសម្រាប់ប្រើប្រាស់ជិតខ្លួន (ជាគូគ្នានឹង **បរិភោគ**) :

**ពាក្យកាព្យ**

គ្រឿងឧបភោគនិងបរិភោគ ក្នុងលោកគេតែងតែផ្គត់ផ្គង់ បើគ្មានតណ្ហា:នេះបម្រុង
ផ្ទុងផ្ដើមជានិច្ចនឹងវិនាសៗ

ទោះបីអ្នកបួសរស់ដោយសារ- សីលផ្ទួសធម៌អាចិក៏រទាស រទែងសុំគេដោយឥតខ្មាស
គ្រាន់តែមិនផ្ដាសប៉ុណ្ណោះឯងៗ

គួរសុំទើបសុំបើមិនគួរ ពុំហ៊ានសួរឱ្យគេចំបែង សុំគេតាមទាពជាគម្លែង
ឈ្មោះថាអ្នកស្វែងមួយបែបដែរៗ

**ឧបមា** *ន.* (សំ. បា.) សេចក្ដីប្រៀប, សេចក្ដីប្រៀបធៀប, ការប្រៀបប្រដូច, ការប្រដូច, ការប្រៀបផ្ទឹម, ការទាញយកហេតុជាដើមមកប្រៀប, មកប្រដូចឱ្យងាយយល់។ ខ្មែរប្រើជា *កិ.* ក៏មាន «ប្រៀប, ប្រៀបប្រដូច»។ ប្រើជា *គុ.* ក៏មាន «ដែលប្រៀប, ដែលប្រដូច» :

**ពាក្យកាព្យ**

ឧបមាកុំថាអបូមា ប្រសិនបើថាខូចសេចក្ដី ព្រោះមានប្រភពជាបាលី
គួរស្ដីឱ្យត្រូវតាមអក្សរៗ

**ឧបមាតា** *ន.* (បា. **ឧបមាតុ**) : ស្ត្រីអ្នកចិញ្ចឹមរក្សា (ដូចម្ដាយ), ភីលៀង :

**ពាក្យកាព្យ**

បើនាងទៅណា ឧបមាតា តែងតាមទៅផង

ពុំដែលបោះបង់ ខ្លាចក្រែងមានហ្មង ទើបតែនេះម្តង

នាងបងពុំទៅ។

**ឧបរោធ** *ន.* (សំ. បា.) ការបិទ, ការរាំង, ការខ្ទប់, ការខាំង; ការបិទឬខ្ទប់ផ្លូវមិនឱ្យចេញចូលបាន :

**ពាក្យកាព្យ**

កុំធ្វើឧបរោធ ឱ្យកើតក្តីក្រោធ នាំឱ្យបែកគ្នា

នៅភូមិជាមួយ ត្រូវជួយរក្សា ឱ្យមានសុខា

កើតសាមគ្គី។

សាមគ្គីជាមូល ឱ្យមានសុខស្រួល មិនខ្មាំខ្មែចខ្មី

ចម្រើនធនទ្រព្យ គួរគាប់ពេញទី គួរជនសំភី

ប្រាស្រ័យរកគ្នា។

**ឧបលិង្គសមុដ្ឋាន** *ន.* (បា.) សមុដ្ឋាននៃឧបលិង្គ :

**ពាក្យកាព្យ**

ខ្ញបលិង្គសមុដ្ឋាន ចេញឱ្យឃើញប្រាជថាពុំស្រួល នាំឱ្យរវចិត្តឆ្អិតក្តៅក្តួល

រំជួលជូរមុខជាទុក្ខក្រៃ។

គិតជួយរំដោះគ្រោះឱ្យផង ដើម្បីឱ្យឆ្លងផុតចង្រៃ បើរង់បង្អង់ឱ្យយូរថ្ងៃ

ក្រែងលោចង្រៃរួបរឹតប្រាន។

**ឧបវាទ** *ន.* (**សំ. បា.**) ការពោលតិះដៀល, ការពោលទោស; ពាក្យតិះដៀល, ពាក្យពោលទោស :

**ពាក្យកាព្យ**

ឧបវាទជាពាក្យគួរចៀសវាង បើឮាត់គួរវាងលែងពោលទៀត ព្រោះជាសម្ដីនាំចង្អៀត

បើចេះតែឆ្លៀតនាំព្រួយចិត្ត។

**ឧបវេសន៍** *ន.* (**សំ. បា. ឧបវេសន**) ការអង្គុយសម្រាក; ការឈប់សម្រាក; ការសម្រាកលំហែកម្លាំង :

**ពាក្យកាព្យ**

ធ្វើការងារធ្ងន់ កុំឱ្យជក់លន់ ត្រូវមានឧបវេសន៍
មួយដងមួយកាល សម្រាលកុំធ្វេស ព្រោះធ្វេសប្រហែស
នាំឱ្យមានរោគ។
ជំងឺជិះជាន់ ផឹកថ្នាំមិនគ្រាន់ តែងនាំឱ្យស្មោក
ធ្វើការលែងកើត ដ្បិតឈឺជាំជោក បានជាចាស់លោក
ហៅរោគសង់ផ្ទះ។

**ឧបសគ្គ** *ន.* (**បា.**) ឧបទ្រព, ចង្រៃ; គ្រឿងទើសទាក់, គ្រឿងជំទាស់, គ្រឿងរារាំងដំណើរ :

**ពាក្យកាព្យ**

ឧបសគ្គជាថ្នាក់នាំជំទាស់ រារាំងឱ្យងាស់ស្មោកកិច្ចការ ទោះជនកំពុងកាន់ធមិ៌អាថ៌

អាចារ្យក៏ដោយដូចជាគ្នា។

**ឧបហាស** *ន.* (**សំ. បា.**) ការសើចសប្បាយ, ការសើចក្អាកក្អាយ; ការរីករាយសប្បាយឥតបើគិត :

**ពាក្យកាព្យ**

ពេលគេឈឺចាប់ ឬមានគេស្លាប់ កុំធ្វើឧបហាស
ត្រូវមើលមុខក្រោយ កុំធ្លោយផ្តេសផ្តាស រីឯឧបហាស
សម្រាប់ពេលផ្សេង។

**ឧបហេតុ** *ន.* (**សំ. បា.**) ហេតុជិត, ហេតុដែលប្រាកដនៅមុខ, ទំនងដែលបណ្តាលឱ្យឃើញនៅមុខ :

**ពាក្យកាព្យ**

ឧបហេតុចម្លែកស្តែងពិតៗ ពិនិត្យសង្កេតទៅឃើញច្បាស់ បើតាមធ្លាប់ដឹងថាល្អណាស់
ចាស់ៗតែងទាយថាមានលាភៗ

**ឧបាទវ៍** *ន.* (ពាក្យប្រើក្លាយមកពី **បា. ឧបទ្ទវ**) ឧបទ្រព :

**ពាក្យកាព្យ**

ឧបាទវ៍ក៏គឺឧបទ្រព ងងឹតដូចយប់ពុំប្រាកដ ជាតួចង្រៃកើតពីបទ
ប្រព្រឹត្តទុច្ចរិតឥតមានក្រែងៗ
យើងមើលឧបាទវ៍ពុំឃើញច្បាស់ ព្រោះក្រាស់ដោយក្តីតំនូវង្វេង សុចរិតជាធមីដាច់សង្វេង
ប្រព្រឹត្តជាក់ស្តែងគ្មានឧបាទវ៍ៗ

**ឧបាទាន** *ន.* (**សំ. បា.**) ការប្រកាន់មាំ, ការប្រតោងចិត្តគំនិត, សេចក្តីប្រកាន់ជាប់ស្អិត, សេចក្តីជំពាក់ចិត្ត :

**ពាក្យកាព្យ**

ឧបាទានមានព្រោះតែតណ្ហា ឱ្យទាក់ទងគ្នាទៅរកភព ប្រគោងព្រឃឹតឥតមានឈប់
វិភពទាក់ទងទៅរកជាតិ។
ឯជាតិជរាហើយនិងមរណ៍ ឈរគោងឃឹតគ្នាពុំដែលឃ្លាត ទុក្ខសោកក៏មានតជាអាទិ
បដិច្ចុប្បាទជាប់តគ្នា។
មានអវិជ្ជាជាប្រភព ងងឹតដូចយប់គ្រប់វេលា ឱ្យសត្វកើតស្លាប់បន្តគ្នា
កើតស្លាប់ស្លាប់កើតជាប់មិនដាច់។

**ឧបាធ្យាយ** *ន.* (សំ.) ឧបជ្ឈាយ៍ (**ព. ពុ.**)។ គ្រូបង្រៀនធម៌, គ្រូបង្រៀនច្បាប់ :

**ពាក្យកាព្យ**

វិគ្រូបាធ្យាយ អាចឱ្យពណ្ណរាយ មានរូបរស្មី
អាចឱ្យរុងរឿង អស់បញ្ចិន្ទ្រិយ ស្មើព្រះជននី
ជនកសោតហោង។

**ឧបាយ** *ន.* (សំ. បា.) ល្បិច, ល្បិចល្បួង, កិច្ចកល; ផ្លូវគំនិត; កលមាយា :

**ពាក្យកាព្យ**

ឧបាយកម្មាយប្រាប់ការណ៍ពិត ប៉ុន្តែគំនិតស្រួចស្រាល់ជាង បើមានប្រាជ្ញាភ្លាវ៉ៃរាំង
ច្រើនតែមិនឃ្លាងចាកប្រយោជន៍។

**ឧបាយកោសល្ល** *ន.* (បា.) សេចក្ដីឈ្លាសវៃក្នុងការប្រើឧបាយ :

**ពាក្យកាព្យ**

ឧបាយកោសល្ល រមែងតែផ្ដល់ នូវជ័យជម្នះ

គួរពួកយោធា មានស្រីតេជះ សំភីកុំលះ
ឧបាយកោសល្អ។

**ឧបាយាស** *ន.* (**សំ. បា.**) សេចក្ដីចង្អៀតចិត្ត, សេចក្ដីតឹងចិត្តខ្លាំង, សេចក្ដីតានតឹងចិត្ត :

**ពាក្យកាព្យ**

ឧបាយាសកើតពីជរា- មរណៈដែលជាធម៌រួបរឹត សម្ពុទ្ធសាស្ដាទ្រង់ពិនិត្យ
ឃើញពិតឥតល្អៀងឈ្លៀងឃ្លាតឡើយ។

**ឧបាសក** *ន.* (**សំ. បា.**) អ្នកអង្គុយជិតឱ្យប្រើប្រាស់, អ្នកបម្រើ, សិស្ស សាសនា។

**ព. ពុ.** អ្នកដល់ព្រះរត្នត្រ័យជាទីពឹងឬជាទីរឭក គឺគ្រហស្ថដែលចូលកាន់ពុទ្ធសាសនាស៊ប់ ហើយកាន់សីលធម៌ខ្ជាប់ខ្ជួនតាមច្បាប់សម្រាប់ពុទ្ធសាសនិកជនជាគ្រហស្ថ :

**ពាក្យកាព្យ**

ឧបាសកផ្ទុយគ្នាពីទាយក ដែលគ្រាន់តែដាក់ចិត្តឱ្យទាន ប៉ុន្តែគេអាចហៅរួមបាន
ឬាសកទាយកទាយិកា។
ព្រោះសុទ្ធតែពួកសប្បុរស មានចិត្តស្រស់បស់ឆ្ពោះសាសនា កាន់សីលឱ្យទានរួបរួមគ្នា
សាមគ្គីសមគ្គាបង្កើតសុខ។

**ឧបាហន** ឬ **ឧបាហនា** *ន.* (**បា.**; **សំ. ឧបាហន**) ស្បែកជើងឬស្បែកជើងមួយសម្រាប់ :

## ពាក្យកាព្យ

ឧបាហនាដែលគេធ្វើដោយស្បែក ប្លែកគ្នាពីពាក្យបាទុកា ដែលមានពុទ្ធប្បញ្ញត្តិថា
និក្ខុសាមណេរមិនត្រូវប្រើ។

បាទុកាប្រែថាទ្រនាប់ជើង រដ្ឋយើងសព្វថ្ងៃមិនសូវប្រើ ព្រោះឮខ្លែកខ្លួកពុំជាបើ
ស្រាប់តែលែងប្រើឯងៗទៅ។

**ឧបេក្ខា** *ន.* (បា.) ការតាំងចិត្តជាកណ្ដាល, សេចក្ដីព្រងើយកន្តើយ, ដំណើរមិនលម្អៀងទៅខាងណា :

## ពាក្យកាព្យ

មេត្តា-ករុណា-មុទិតា ឧបេក្ខាទាំងបួននេះសោតា ប្រសិនបើជនទាំងអស់គ្នា
អាចកាន់រក្សាឱ្យជិតដល់។

សមលោកទាំងមូលបានសុខស្ងប់ គ្រលប់ជាឥតជ្រួលច្របល់ ព្រោះធម៌បួននេះបញ្ចេញផល
ផ្ដល់សន្តិសុខឱ្យជានិច្ច។

សូម្បីដាច់តែមេត្តាមួយ ទុក្ខព្រួយតែងតែប៉ះទង្គិច ឈឺចាប់ក្ដៅផ្សាជាងឃុំទិច
លិចលង់ហិនហោចជាអនេក។

**ឧបោសថិក** *គុ.* (បា.) ដែលជាប់ទាក់ទងដោយថ្ងៃឧបោសថឬដែលមានក្នុងថ្ងៃឧបោសថ។ *ន.* អ្នករក្សាឧបោសថសីល (បើស្ត្រីជា**ឧបោសថិកា**) :

## ពាក្យកាព្យ

ឧបោសថិក គេអាចបង្វឹក- ចិត្តឱ្យឃ្លាតឆ្ងាយ
ពីកាមគុណ មិនឱ្យរាយមាយ កិច្ចការសម្ដាយ
គេឈប់មិនធ្វើ។

ថ្ងៃមួយយប់មួយ ឈប់គិតមិនព្រួយ គេតាំងចិត្តស្មើ
នឹកឆ្ពោះតែសីល ហើយនិងអំពើ អ្វីដែលគួរធ្វើ
ទើបធ្វើតាមគួរ។

**ឧប្បត្តិក** *ន.* (បា. ស.; បា. **ឧប្បត្តិ**) ការកើត; ការចាប់ជាតិ។ ខ្មែរប្រើសំដៅសេចក្តីថា «ការកើតឯង; ការចាប់កំណើតឥតមាតាបិតា, ឥតមេបា; ឧបបាតិក»។ ប្រើជា *កិ.* ក៏មាន «កើតឯង; សន្មតឱ្យជា» :

**ពាក្យកាព្យ**

សម្តីឧប្បត្តិកឡើងឯងៗ គួរក្រែងកុំអាលប្រញាប់ថា- តាមឆ្លាមត្រូវតែពិចារណា
បើពិតសឹមថាកុំធ្វេសធ្លោយៗ
ដ្បិតពាក្យឧប្បត្តិកសឹងតែឆ្លាត់ ចេញតែមាត់ជនកម្សោយ មនុស្សល្ងង់ជ្រុលជឿលុះថ្ងៃក្រោយ
នាំឱ្យអ្នកផងគេមើលងាយៗ

**ឧភតោសុជាត** *ន.* (បា.) អ្នកដែលកើតអំពីមាតាបិតាមានពូជពង្សស្មើគ្នា :

**ពាក្យកាព្យ**

រីព្រះមហាសត្វ ព្រះនាមសិទ្ធត្ថ ឧភតោសុជាត
តព្រះរាជវង្ស មហាក្សត្រនរនាថ តាំងពីព្រះបាទ
ឱកាកៈមក។

**ឧភយ** *សំខ្យា.* ឬ *គុ.* (សំ. បា.) ទាំងពីរ, ទាំងគូ :

**ពាក្យកាព្យ**

ខ្ញុំឃើញយាយតា ទាំងឧភយា បណ្តើរគ្នាទៅ

តាដោលឈើច្រត់ យាយទូលផ្ដៅ គាត់ប្រាប់ថាទៅ
ធ្វើបុណ្យឆ្លងថ្នល់។

ខ្ញុំឮថាគាត់ សំដៅទៅវត្ត ឥឡូវបានដល់-
ទៅវត្តស្រេចហើយ កំពុងខ្វាយខ្វល់ ធ្វើបុណ្យឆ្លងថ្នល់
ដូចថាហើយតើ។

**មួយបែបទៀតថា**

រាជបុត្រា ទាំងឧភយា នាំគ្នាចេញទៅ
រករៀនវិជ្ជា នាប្រទេសក្រៅ ព្រះទ័យសំដៅ
វិជ្ជាពាណិជ្ជ។

**ឧយ្យាន** *ន.* (**បា.**) ឧទ្យាន :

**ពាក្យកាព្យ**

បាលីថាឧយ្យាន មានសេចក្ដីថាគេដើរ ដើម្បីមើលឈើបណ្ដើរ
តាមដំណើរគេចូលទៅ។

ខ្មែរប្រើជាឱទ្យាន តាមលំអានពាក្យស្រួលហៅ សេចក្ដីក៏សំដៅ
ថាឧយ្យាននោះដដែល។

**ឧយ្យាមភាព** *ន.* (**បា. ឧយ្យាមភាវ**) ភាវៈនៃព្យាយាម, សេចក្ដីខំប្រឹង, វីរិយភាព:

**ពាក្យកាព្យ**

ឧយ្យាមភាព ញុំាងការទន់ទាប ឱ្យឡើងខ្ពស់បាន

កម្ចាត់ក្តីទុក្ខ មិនឱ្យរុករាន ទោះបីទុក្ខមាន

ក៏មានស្តើងស្តួច។

**ឧរា** *ន.* (**បា. ឧរ**) ទ្រូង។ (**ព. កា.** ប្រើជា **ឱរា** ក៏មាន, តាមស្រួលមាត់) :

**ពាក្យកាព្យ**

ហៃកូនពុំងា ម្តាយតឹងឱរា ស្មើរប្រេះសញ្ញែក

ត្រូវកូនស្តាប់ម្តាយ កុំឱ្យទឹកភ្នែក- ម្តាយហូរច្រើនពេក

ណាកូនមាសម្តាយ។

**មួយបែបទៀតថា**

គេរត់ចោលទៅ ឧរាឯងក្តៅ ឈឺផ្សាឥតស្រាក

នៅតែម្នាក់ឯង កណ្តោងលំបាក អញត្រូវសម្រាក

ឯណាទៅអើយ !

**ឧរ៉េ** ឬ **ឱរ៉េ** *ន.* (**ព. បុ.**) មាសឆ្អិន; មាសទឹកដប់ :

**ពាក្យកាព្យ**

ហៃស្ងួនខ្ញុំអើថ្លៃកម្សត់ គួរអត់ទ្រាំទៅកុំសោកឡើយ ធ្វើម្តេចយើងកើតក្នុងលោកហើយ

កោះត្រើយនៅត្រង់សីលនិងធម៌ៗ

គួរយើងខំស្រាវជ្រាវរាវរក ជ្រើសយកតែគុណដ៏បវរ គង់យើងនឹងបានតួអំណរ

ដែលសីលនិងធម៌ផ្តល់សុខឱ្យៗ

**រថេសភៈ** *ន.* (**បា. រថេសភ**) អ្នកជាប្រមុខនៃរថានីក (មេទ័ពទាហានរថ); ក្សត្រទ្រង់រាជ្យ :

### ពាក្យភាព្យ

មន្ត្រីទេវីនាងទូលថា បពិត្របិតារថៃសត ខ្ញុំម្ចាស់សូមតាមទៅគោរព
ព្រះវង្សន្តរជាស្វាមីៗ
ព្រោះបើមិនទៅនៅឯអាយ ជាស្ត្រីមេម៉ាយពុំគប្បី ខ្ញុំម្ចាស់ត្រូវទៅតាមស្វាមី
បុត្រាបុត្រីត្រូវទៅដែរៗ

**ឧសា** *ន.* (**សំ.**) ពន្លឺបំព្រាងជិតព្រឹក, វេលាភ្លឺស្រាង, ពេលបំព្រាង, ពេលក្រហមឯកើត (ហៅ **ឧសាកាល, ឧសាសម័យ** ឬ **ឧសាប្រភាត** ក៏បាន) :

### ពាក្យភាព្យ

នៅពេលឧសា ដែលព្រះសុរិយា បញ្ចេញរង្សី
អស់ទាំងជនផង ទោះប្រុសទោះស្រី ទោះទាំងបក្សី
ក៏ភ្ញាក់ពីដេក។
ធ្លាប់ធ្វើការអ្វី ជាប្រក្រតី តាមដោយចិត្តត្រេក
ទោះការនោះធ្ងន់ ពេកពន់ស្កុះស្គេក ធម្មតាវែកញែក
ឱ្យខានពុំបាន។

**ឧស្ម័ន** *ន.* (**សំ. ឧស្មន**) ចំហាយ, ចំហាយក្ដៅ, ចំហាយភ្លើង, កម្បួល, អៃ :

### ពាក្យភាព្យ

ខស្ម័នសំខាន់ខាងចំហាយ ឱ្យចេញផ្សព្វផ្សាយតាំពារធាតុ ទោះមនុស្សទោះសត្វកាលបើឃ្លាត
ខស្ម័នហើយប្រាសចាកជីវិតៗ
ព្រះពុទ្ធទ្រង់ត្រាស់ពន្យល់ថា កាលណាខស្ម័នអស់សូន្យពិត អាយុវិញ្ញាណក៏គ្មានឫទ្ធិ

ជីវិតក៏ស្ងួនស្ងក្រាយស្ពុកស្ពឹងៗ

គេបោះបង់ខុសពីកាលមុន ទោះបើមានគុណាគួរគេដឹង ជារូបដេកស្ពុកឥតការប្រឹង

ស្ពុកស្ពឹងដូចកល់អង្កត់ខូសៗ

**ឧស្សាហ៍** *ន.* (**បា. ឧស្សាហ**) សេចក្ដីឧិហាត, សេចក្ដីខ្មីឃ្មាតឬសង្វាត, ការខំប្រឹងមិនខ្ជិល, មិនច្រអូស :

**ពាក្យកាព្យ**

ហៃកូនរាល់គ្នា ត្រូវមានឧស្សាហ៍ កុំខ្ជិលច្រអូស

កម្ជិលទ័លក្រ ដូចដើរដួលស្រួស សុំគេងងូស

ព្រលួសកេរ្តិ៍ឈ្មោះ។

**អុះឱ** ! ពាក្យទួញឬពិលាប :

**ពាក្យកាព្យ**

អុះឱក្ដីទុក្ខ ! ពីនេះទៅមុខ តើបានអ្នកណា

នឹងជួយផ្គត់ផ្គង់ បម្រុងមាតា កាលមានបុត្រភ្វា

ធូរចិត្តធូរថ្លើម។

ពីថ្ងៃនេះទៅ គ្រាន់តែរស់នៅ ដោយដកដង្ហើម

ក្ដីព្រាត់ប្រាសបុត្រ ស្រយុតសម្បើម អុះឱដង្ហើម

ខ្ញុំអស់ថ្ងៃណា !

**អួត** *កិ.* និយាយលើកសរសើរ, ប្រកាសគុណ, ប្រកាសសេចក្ដីល្អឱ្យអ្នកដទៃស្ដាប់ ឬនិយាយលើកបំផ្លើសលើសហេតុឱ្យគេស្ងើច :

## ពាក្យភាព្យ

ការអ្វីមិនទាន់ដល់ កុំខ្វាយខ្វល់ពោលអួតមុន ព្រោះក្រែងអួតទៅស៊ុន
អួតមុនច្រើនតែខូចការ ។

ចួនកាលមានសត្រូវ រារាំងផ្លូវឬខាំងខារ ពុំអាចនឹងការពារ
បែរជាស្មោកខូចការអស់ ។

**ឡូឆ ៩.** នេសាទុបករណ៍មួយប្រភេទ មានក្រឡាដូចសំណាញ់ មានសណ្ឋានវែង មានកម្សួលបណ្តែតសម្រាប់ដាក់វាយក្នុងទឹកជ្រៅឱ្យជាប់ត្រី :

## ពាក្យភាព្យ

ប្រយ័ត្នផុងខ្លួន ក្រែងលោជាប់អួន ពិបាកបង្រះ
ដូចជនអន្ធពាល មានចិត្តស្រាលខ្លះ ជាប់អួនឡេះឡះ
អ្នកណាជួយកើត?

**ឡើពើ កិ.** យកចិត្តទុកដាក់; គោរព, មានអាទរភាព, ប្រុងប្រយ័ត្ន; នឹកនា, នាំពា; ទំនុកបម្រុង :

## ពាក្យភាព្យ

មនុស្សអើពើមិនប្រហែស សហេតុច្បាស់ចែសឱ្យឃើញជាក់ មនុស្សបែបនេះបើច្រើននាក់
មានលក្ខណ៍នាំឱ្យជាតិចម្រើន ។

**ឡៀ ៩.** ឈ្មោះរោគមួយប្រភេទ កើតនាភ្នែក ធ្វើទុក្ខភ្នែកឱ្យមានកន្ទុយថ្លែន និងពពឹក ឱ្យភ្នែកព្រៀកជានិច្ចជាជំងឺរ៉ាំរ៉ៃ ទាំងជារោគងាយឆ្លងពីអ្នកម្នាក់ទៅអ្នកដទៃផងទៀត :

## ពាក្យកាព្យ

រោគអៀស៊ីភ្នែក គ្រូពេទ្យបច្ចេក- ទេសហៅថា
ជំងឺត្រាកូម ងាយឆ្លងពីគ្នា គួរបុត្រធីតា
ប្រយ័ត្នខ្លាចឆ្លង។

ច្រើនតែក្មេងៗ ដែលវារួមលេង ចូលគ្នាម្ដងៗ
ក្មេងម្នាក់មានរោគ- ត្រាកូមចម្លង ដោយការទាក់ទង
គ្នាវានោះឯង។

វាឆ្លងងាយណាស់ ទោះចាស់និងចាស់ ក៏ឆ្លងស្ដែងៗ
លុះតែពេទ្យភ្នែក ទើបអាចថ្លាថ្លែង ប្រាប់ហេតុនេះឯង
ឱ្យអស់សង្ស័យ។

**អេចអូច** ***ភិ. ១.*** ដែលចេញអាការៈបបូរមាត់អូចៗឬទុលហើបៗមិនច្បាស់ការ
ជាថាអ្វី :

## ពាក្យកាព្យ

ខ្សឹបខ្សៀវអេចអូច ជួននាំឱ្យខូច ប្រយោជន៍តូចធំ
ជួនកើតរឿងហេតុ ណាមួយពុំសម ជួនភ័ន្តច្រឡំ
ព្រោះខ្សឹបអេចអូច។

មានរឿងពីព្រេង ថ្លែងពីការលេង- ល្បែងខ្សឹបបង្ខូច
ឱ្យបែកសាមគ្គី ខ្ទេចខ្ទីធំតូច ព្រោះខ្សឹបអេចអូច

ខូចរដ្ឋទាំងមូល។

**អេះអុះ** *កិ. ទ.* ត្រេះត្រុះដោយទាល់គំនិតឬទាល់សម្ដី, ទាល់សេចក្ដីឆ្លើយឬដោយអផ្សុកចង់ក្រោកចេញប៉ុន្តែមិនហ៊ាន ព្រោះខ្លាចឬព្រោះញញើតជាដើម :

**ពាក្យកាព្យ**

កូនខ្មែរទាំងឡាយ ត្រូវហាត់និយាយ កុំធ្វើអេះអុះ
ញញើតញញើម ច្រិមច្រុមត្រេះត្រុះ ត្រូវហាត់ឱ្យលុះ
ជំនុំចំណោម។

**ឯកអគ្គ** *ន.* (បា.) អង្គប្រសើរផុត; អ្នកដែលមានខ្លួនប្រសើរផុត :

**ពាក្យកាព្យ**

ក្សត្រក្សាន្តឯកអគ្គ ស្ដេចយាងតម្រង់ ទៅកាន់ប្រាសាទ
រាជនិវេសន៍ ប្រសើរស្អាងស្អាត ដល់ហើយព្រះបាទ
ទ្រង់ស្ដេចចូលក្នុង។

**ឯកអគ្គារហន្ត** ឬ **ឯកអគ្គារហា** *ន.* (បា. «**ឯក + អគ្គ + អរហន្ត** ឬ **ឯក + អគ្គ + អរហា**») ព្រះអរហន្តប្រសើរឯកឬព្រះអរហន្តប្រសើរផុត :

**ពាក្យកាព្យ**

ព្រះពុទ្ធព្រះបច្ចេក និងឯកអគ្គារហា អគ្គសាវកា
និងមាតាបិតាផង។
គ្រូនិងសាស្ត្រាចារ្យ និងទាយកឥតមោះហ្មង និងអ្នកទេសនា
កុំយង់ឃ្នងឆ្គងប្រមាថ។

បុគ្គលទាំងដប់នេះ គួរប្រាជ្ញវិរះរេសម្អាត ត្រូវកុំបីប្រមាថ
គួរឱហាតរៀនឱ្យចាំ។
ថាមិនត្រូវប្រទូស្ត ឬរឹងរូសធ្វើឱ្យឆ្គាំ- ឆ្គងខុសក្រែងនឹងនាំ-
ឱ្យបានទុក្ខឃើញទាន់ហន់។

**មួយបែបទៀតថា**

ឯកោ-ឯកានិងឯកំ កវីសម្រាំងតែងកាព្យ ដូចកាព្យថាងកោរាជា
ឯកាទេវីរដ្ឋឯកំ។
ទាំងបីពាក្យនេះសុទ្ធតែឯក ឥតមានចម្លែកឱ្យទ័ន្តតាំង ប្រើតាមជើងកាព្យចួនមិនគាំង
ឯកោឯកំឬឯកា។

**មួយបែបទៀតថា**

វីសព្ទថាឯក ផ្សំបានអនេក នឹងសព្ទដទៃ
ស្រេចនឹងអ្នកប្រើ គេចេះប្រើលៃ ឱ្យតែប្រពៃ
កុំឱ្យមានឆ្គង។

**ឯតទគ្គៈ** *ន.* (**បា. ឯតទគ្គ**) អ្នកដែលគេលើកថាប្រសើរជាងគេខាងមុខការ ឬចំណេះវិជ្ជាណាមួយ :

**ពាក្យកាព្យ**

ពួកសាស្ត្រាចារ្យ ដែលនៅធ្វើការ ក្នុងវិទ្យាល័យ
នុះគេសុទ្ធតែ មានវិទ្យាថ្លៃ ទាន់កាលសម័យ
នៃការសិក្សា។

ខ្លះមានចំណេះ ខ្ពស់ដល់ថ្នាក់ចេះ ឯតទគ្គា
គួរបុត្រធីតា កូនចៅរាល់គ្នា ឱ្យមានវិជ្ជា
ឯតទគ្គៈ។

**អែបអប** *កិ.* (ព. ប្រ.) ផ្គាប់ផ្គុនរណេបរណប់ដើម្បីឱ្យជិតស្និទ្ធស្នាល, ឡេបឡប :

**ពាក្យកាព្យ**

រីជនអែបអប ប្រើបែបឡេបឡប ប្រចុបប្រចែង
បញ្ជោរនាយអាយ ដោយប្រើពាក្យក្លែង តាមតែចិត្តឯង
ឱ្យបានប្រយោជន៍។

ពុំស្ងូវអៀនខ្មាស បញ្ជោរផ្ដេសផ្ដាស មានឆៅមានខ្លោច
អ្នកខ្សោយគំនិត ពុំគិតល្អិតល្អោច ជួនកាលដោយហោច
គង់លង់តាមខ្លះ។

**អែមខិជា** *ន.* ខិជារសផ្អែម :

**ពាក្យកាព្យ**

ស្វាយនោះមានអែមខ្ទិជា ជាងស្វាយនានា គួរនាំគ្នាដាំឱ្យច្រើន។
បើដាំនឹងបានចម្រើន ទ្រព្យធនកើតកើន ក្រវើនដាំទៅកុំខ្ជិល។
កុំឱ្យរបររេចរិល ព្រោះតែការខ្ជិល រមិលពុំឃើញទ័លក្រ។

**អែមផ្លែម ឬ អ៊ែមផ្លែម** *ន.* ប្រដាប់បង្កើតភ្លើងមួយប្រភេទ ធ្វើដោយឈើខ្លឹមសាច់ជិតឬដោយភ្លុក, ដោយស្នែងមានរាងស្រដៀងគ្នានឹងត្បាល់បុកស្លា,

មានស្នូលសម្រាប់ដាក់ប៉ុយគឬប៉ុយទន្សែនៅត្រង់ចុងបំផុតខាងក្រោម, ប្រើទះនឹងបាតដៃឱ្យទង្គិចគ្នាកើតជាភ្លើងឆេះប៉ុយ (ហៅ **ឆះឆេះ** ឬ **ចំពង់ឆះឆេះ** ក៏បាន; គួរប្រើពាក្យនេះវិញសមរម្យជាង) :

**ពាក្យកាព្យ**

បំពង់ទះឆេះ នេះជាចំណេះ ខ្មែរក្នុងបុរាណ
ប្រើជួសដែកភ្លើង ដែលយើងធ្វើបាន ចាស់ទុំបុរាណ
ហៅអរណី ។

**អ៊ែសមែស** *កិ. ១.* ឬ *គុ.* ស៊ែសគ្រមែស, ស៊ិសគ្រលស, ដែលមានអាការៈព្រងើយឥតគោរពកោតក្រែងអ្នកណា :

**ពាក្យកាព្យ**

ជនឫកអ៊ែសមែស ច្រើនភ្លេចប្រហែស សុជីវធម៌
ឃើញគេត្រឹមត្រូវ ពុំសូវត្រេកអរ ច្រើនមានអំណរ
ឆ្ពោះក្ដីវាយមាយ ។
កិច្ចការពិបាក ច្រើនតែឈប់ផ្អាក ចង់បានការងាយ
ទម្ងន់ត្រូវរែក ចូលចិត្តតែស្ពាយ បើខាងចាយវាយ
ងាយឥតបើគិត ។

**ឱក័ស** *ន.* (**សំ. ឱកស**) ផ្ទះ, លំនៅ, ទីនៅអាស្រ័យ :

**ពាក្យកាព្យ**

ពីដើមនគ្គពេញមានឱក័ស តិចណាស់មិនច្រើនដូចសព្វថ្ងៃ ឥឡូវជាក្រុងទាន់សម័យ

ឱកាសច្រើនក្រៃអនេកលន់ៗ

**ឱភាគ** *ន.* (បា.) ឈ្មោះរាជវង្សនៃព្រះបាទមនុ (ក្នុងបឋមកប្ប) ដែលជាប្រថមក្សត្របូជាដើមរាជវង្សនៃក្សត្រទាំងឡាយតៗមក :

**ពាក្យភាព្យ**

| | | |
|---|---|---|
| ព្រះបាទសុទ្ធោទន៍ | គោតមគោត្ត | ឱកាកវង្ស |
| មានរាជបុត្រ | វិសុទ្ធគឺអង្គ | ព្រះសម្ពុទ្ធទ្រង់- |

ជាលោកនាថ។

**ឱភាស** *ន.* (បា.) ហេតុ, ការណ៍; ស្ថាន, ទី, ទីទំនេរ, ចន្លោះ; វេលា, វេលាទំនេរ, ពេលស្រួល; ផ្លូវ, ទំនង; សិទ្ធិជោគ; ការនិយម, ការអនុលោម; សេចក្ដីអនុញ្ញាតឱ្យ; ការយល់ព្រមតាម :

**ពាក្យភាព្យ**

| | | |
|---|---|---|
| យើងទៅរកគេកុំចូលផ្ដាស | ត្រូវសុំឱកាសគេជាមុន | កុំស្រាប់តែចូលឱ្យហួសស៊ុន |
| | គេពុំដឹងមុនកុំអាលចូល។ | |
| នេះគឺជាសុជីវធម៌ | បវរដែលលោកតែងអនុកូល | ឬអាចហៅថាច្បាប់ចេញចូល |
| | ដូច្នេះទៅវិញក៏សឹងបាន។ | |

**ឱជ** *ន.* (**បា. ឱជា**) អ្វីៗដែលបង្កើតកម្លាំង, គ្រឿងបង្កើតកម្លាំង, ជំនួយកម្លាំង គឺរសដែលនាំឱ្យមានកម្លាំង, រសឆ្ងាញ់; ជីជាតិ; កម្លាំងកាយឬទឹកកម្លាំងក្នុងខ្លួន :

**ពាក្យកាព្យ**

ចំណីអែមឱជ អ្នកផងបាមោជ្ឈ ចាប់ចិត្តរាល់គ្នា
ដោយសារអ្នកធ្វើ គេបានសិក្សា រៀនក្នុងសាលា
មានគ្រូជំនាញ។

នារីនានា គួររៀនវិជ្ជា មេផ្ទះកុំគ្រាញ
កុំក្រាញខ្ជិលរៀន អៀនប្រៀនទូញទាញ ខ្មៅពេករែងលាញ
គេរឺឈ្មោះមេផ្ទះ។

ទោះបីខ្លួនធំ វ័យពេញក្រមុំ ក៏គួររូតរះ
រៀនធ្វើចំណី ឱ្យចេះជ្រៅជ្រះ នឹងមានតេជះ
ឱ្យកើតទ្រព្យធន។

**ឱតត័ន្ត** *ន.* សម្ដីមានរបៀបបែបបទត្រឹមត្រូវ, សម្ដីមិនឆ្គង :

**ពាក្យកាព្យ**

គាត់ហ្នឹងគាត់ធ្វើឫកត្រុកៗ ប្បានជាអ្នកស្រុកខ្លះមើលងាយ ស្រាប់តែដល់គាត់អើកមួយ
សម្ដីលែបខាយមានឱតត័ន្តៗ

ពេលនោះអ្នកស្រុកឡែកសព្រោង តោងគ្នារយោងស្ញើចគាត់លាន់ ពីព្រោះគាត់មានវោហារគ្រាន់
អ្នកស្ដាប់លួកលាន់ពុំប្បាន។

**ឱត្តប្បៈ** *ន.* (**បា. ឱត្តប្ប**) ការខ្លាចបាប, ដំណើរខ្លាចទុច្ចរិត, ដំណើរខ្លាចមិនហ៊ានធ្វើអំពើអាក្រក់, សេចក្ដីតក់ស្លុត ជ្រញរអាចំពោះបាប :

## ពាក្យភាព្យ

| | | |
|---|---|---|
| ហិរិ-ឱត្តប្បៈ | ជាធម្មៈប្រសើរក្រៃ | ជាធម៌តែងអាស្រ័យ |
| | នាំធម៌ពីរឱ្យកើតបាន។ | |
| ធម៌នោះគឺសតិ- | សម្បជញ្ញៈឱ្យមាន | ស្មារតីដឹងខ្លួនប្រាណ |
| | នឹកឃើញបានមិនភ្លេចភ្លាំង។ | |
| បើធម៌ប្អូនទន់ខ្សោយ | ភ្លេចមុខក្រោយរំផងតែតាំង | គំនិតរឹងក្រទាំង |
| | កម្លាំងចិត្តក៏តែងស្បើយ។ | |

**ឱនក** ***នុ.*** (**ឃ.**) ដែលរស់នៅក្នុងទឹក :

## ពាក្យភាព្យ

| | | |
|---|---|---|
| ដំណាំឱទក | ប្រើធ្វើអន្លក់ | បន្លែក៏បាន |
| មានស្រះត្រពាំង | ខែប្រាំងគង់មាន- | ទឹកដក់នៅបាន- |
| | យូរត្រូវដាំទៅ។ | |
| កុំខ្ជិលច្រអូស | ខ្លះដើររងងូស | សុំគេអ្នកក្រៅ |
| សុំគេញយពេក | អ្នកមានមាត់ឆៅ | គេស្តីប្រដៅ |
| | គួរខ្មាសគេណាស់។ | |
| ដំណាំឱទក | ដាំច្រើនអាចលក់ | ព្រោះកើតរហ័ស |
| ពុំយូរប៉ុន្មាន | បានប្រាក់ច្បាស់ៗ | បានជាចាស់ៗ |
| | ហៅទ្រព្យផ្កាប់ឆ្នាំង។ | |

**ឱ្យ** *កិ.* ធ្វើអំណោយ គឺលះអ្វីៗដល់អ្នកដទៃ :

**ពាក្យកាព្យ**

| | | |
|---|---|---|
| រីពាក្យអញអ្នក | នេះនោះបញ្ជាក់ | ដល់ឱ្យនិងហោង |
| ពោលជាពាក្យកាព្យ | ឱ្យងាយចាំចង | សរសេរម្ដងៗ |
| | កុំភ្លាត់តាមសូរ។ | |
| ប៉ុណ្ណេះជាអាទិ | ប្រើកុំឱ្យឃ្លាត | យកផ្សេងជាថ្នូរ |
| អញ្ញត្រសព្ទ | មិនត្រូវផ្លាស់ប្ដូរ | ទោះបីមានសូរ |
| | ឮផ្សេងក៏ដោយ។ | |

**ឱរស** *ន.* (**បា.**) បុត្របង្កើត (កូនប្រុសបង្កើត) :

**ពាក្យកាព្យ**

| | | |
|---|---|---|
| នាងទេវីទាំងអស់ | ឥតឱរសដូចជាគ្នា | ហេតុនេះព្រះរាជា |
| | ទ្រង់រំពឹងដល់រដ្ឋា។ | |
| ឥតពីព្រះអង្គទៅ | បើឥតបុត្រនិងធីតា | ដូច្នេះតើនរណា |
| | នឹងគ្រប់គ្រងរដ្ឋតទៅ។ | |

**ឱហាត** *កិ.* សង្វាតជានិច្ច, សំភី។ ប្រើជា *គុ.* ក៏មាន ដែលមានសេចក្ដីសង្វាតជានិច្ច, ដែលសំភី :

**ពាក្យកាព្យ**

| | | |
|---|---|---|
| រីមនុស្សឱហាត | សំភីសង្វាត | ព្យាយាមមាំមួន |
| កាន់ការអ្វីៗ | កាន់យ៉ាងខ្ជាប់ខ្ជួន | រមែងញុំាងខ្លួន |

ឱ្យមានទ្រព្យធន។

**មួយបែបទៀតថា**

ហៃកូនធីតា រីឯប្រាជ្ញា ពុំមែនកើតឯង
លុះតែឱហាត រៀនសូត្រជាក់ស្តែង ទើបខ្លួនយើងឯង
ប្រទះប្រាជ្ញា។

ដូងទុំមានប្រេង ដាក់ចោលលេងៗ ឥតស្ងួតឱ្យវា
បញ្ចេញប្រេងឱ្យ បានប្រេងពីណា រីឯប្រាជ្ញា
ក៏ដូច្នោះដែរ។

**ឱឡឹកល្ល** *៩.* (**ឃ.**) ប្រឡាយបង្ហូរទឹកសម្អុយ, រណ្ដៅទឹកសម្អុយ :

**ពាក្យភាព្យ**

ក្រុងធំត្រូវមានឱឡឹកល្អ ទើបគ្មានកង្វល់ដោយស្មោកគ្រោក បើគ្មានច្រើនតែមានមេរោគ
កំចោកពួកជនឱ្យឈឺចាប់ៗ

ទោះបីក្រុងតូចៗក៏ដោយ បើធ្លោយពុំមានត្រូវប្រញាប់ ខ្នះខ្នែងធ្វើឆ្លាមឱ្យបានឆាប់
កុំឱ្យរោគចាប់ឆ្លងរាលដាល។

**អំណាត់** *៩.* សេចក្ដីអត់, ការអត់ទ្រាំ :

**ពាក្យភាព្យ**

អំណាត់ជានាម កុំបាច់តោងទាម ថែមពាក្យ «សេចក្ដី»
ពុំនោះកុំថែម ស៊ែមពាក្យថា «ក្ដី» មកទៀតធ្វើអ្វី
ឱ្យឃ្លាតចាកបែប។

**អំណារ ៩.** សេចក្ដីអរ :

**ពាក្យកាព្យ**

ពាក្យថាអំណរ ជានាមនៃអរ ជាកិរិយាសព្ទ
ចេញមកជានាម ប្រើតាមប្រញប្ដិ វេយ្យាករណ៍ប្រាប់
ឱ្យប្រើស្រេចហើយ។
កុំថែមពាក្យថ្មី ថា «**មានសេចក្ដី-** **អំណរ**» ចេះឡើយ
ព្រោះកាលបើថែម សឹមលើសបែបហើយ នឹងទៅជាល្ហើយ
ខុសពីរបៀប។

**អំនួត ៩.** ការពោលអួត, សម្ដីអួត :

**ពាក្យកាព្យ**

អំនួតជានាមសព្ទ មានបែបប្រាប់ថាកុំប្រើ- «សេចក្ដី» ថែមសឹមលើ
ទាំងកុំប្រើ «ក្ដី» ផ្សំឡើយៗ

**អំពុត និ.** បំណាច់នឹង, បើបានជា :

**ពាក្យកាព្យ**

គិតសិនកុំធ្លោយ អំពុតនឹងឱ្យ ត្រូវដឹងវែងខ្លី
ឱ្យដាច់តែម្ដង ស្រួលជាងឱ្យខ្ចី ព្រោះគ្នាគ្មានអ្វី
នឹងសងវិញទេ។
ការឱ្យមានបី មួយគឺឱ្យខ្ចី មួយឱ្យទទេ
ដោយចិត្តអាណិត មេត្តាឆ្ពោះគេ មួយដោយរិះរេ

ឱ្យព្រោះគ្នាសូម។

**អំពើ** *ន.* ការដែលធ្វើ, អ្វីៗដែលត្រូវធ្វើ (កម្ម) :

**ពាក្យកាព្យ**

ពាក្យថាអំពើ កើតមកពីធ្វើ បាលីហៅកម្ម
ព្រះពុទ្ធប្រាប់ថា ត្រូវសត្វចងចាំ សុខទុក្ខស៊ាំទាំ
កើតពីអំពើ។

**អំពៅ** *ន.* ឈ្មោះដំណាំមួយពួក, ដើមមានថ្នាំងដូចឫស្សី, សាច់ជ្រួតជ្រាប ពេញដោយទឹកមានរសផ្អែម សម្រាប់ប្រើការយកមកទំពាជញ្ជក់យកទឹកផ្អែម, គាបយកទឹកឬរំងាស់ទឹកធ្វើស្ករ :

**ពាក្យកាព្យ**

អំពៅទោះនៅក្នុងការគាប មិនលះសភាពរសជាតិផ្អែម បណ្ឌិតគំនិតស្រួចរលែម
ទោះមានទុក្ខថែមផ្ទួនៗក្ដី។
នៅតែប្រព្រឹត្តធម៌សុចរិត មិនស្និតនឹងកម្មមិនគប្បី ទោះគេគំរាមឱ្យស្រដី
ស៊ូកាន់សច្ចៈមិនឱ្យល្អៀង។

**អំព្រំប្រែក្រោយ** *ន.* ឈ្មោះអាវដៃខ្លីឬឥតដៃមានឡេវខាងខ្នង :

**ពាក្យកាព្យ**

ពួកក្មេងស្រីៗ ពាក់អាវដៃខ្លី អំព្រំប្រែក្រោយ
នាំគ្នាដើរលេង តាមផ្លូវរជយ ធំៗដើរក្រោយ
តូចៗដើរមុខ។

**អំមិញ** ឬ **អំម៉េញ** *និ.* ពាក្យសាមញ្ញសម្រាប់និយាយដោយប្រញាប់ក្លាយមកពីពាក្យ **អម្បាញ់មិញ** :

**ពាក្យកាព្យ**

ឃើញវាមកទិញ　　អីវ៉ាន់អំមិញ　　រួចចេញបាត់ទៅ
វាថាទៅផ្ទះ　　ម្ដាយមីងដែលនៅ　　ជិតផ្ទះក្បែរផ្លូវ
ត្រឡែងកែងបួន។

**អរាំងឡាំង** *កិ.* *វិ.* ឬ *គុ.* ស្រឡាំងកាំង, មិងមាំង; ដែលគាំងផ្លូវគិត :

**ពាក្យកាព្យ**

ភិតភ័យភ័ន្តភាំង　　ទៅជាអាំងឡាំង　　គាំងស្មារតីអស់
បែរនឹកទៅរក　　ដល់ទ្រព្យរបស់　　ឬដល់អម្រស់-
អម្រក៏ភ្លេច។

នេះគឺកម្មកាច　　ដែលគួរតែខ្លាច　　គួររាងគួរគេច
ចុះបើម្ដឹងៗ　　តើប្រឹងដូចម្ដេច　　លែងដឹងសាច់គ្រេច
រាក់ជ្រៅអស់ហើយ។

**អះអាង** *កិ.* ទទួលខ្លួនជាសម្អាង, ទទួលខុសត្រូវលើខ្លួន, ទទួលរ៉ាប់រង :

**ពាក្យកាព្យ**

ខ្ញុំបាទធានា-　　អះអាងជួសវា　　ដ្បិតវាស្លូតត្រង់
បើបែរជាវា　　ធ្វើតាមចំណង់　　ឱ្យខុសពីអង្គ-
ច្បាប់ខ្ញុំទទួល។

## អក្សរខ្មែរ កាព្យរំលឹកអំពីអក្សរ ពាក្យ៧

អក្សរខ្មែររុងរឿងដោយសារខ្មែរ ពុំហ៊ានបំបែរឱ្យឆ្លាត់ខុស
ជនខ្មែរគ្រប់គ្នាទាំងស្រីប្រុស ពុំហ៊ានបង្ខុសឱ្យខូចបង់ៗ
ជនខ្មែរស្រុះគ្នាលើកតម្កើង ដំឡើងពាក្យពេចន៍ដោយផ្ចិតផ្ចង់
ខ្មែរជាគ្រហស្ថខ្មែរជាសង្ឃ ខំប្រឹងតម្រង់អក្សរជាតិៗ
អក្សរវិបត្តិជាតិវិបត្តិ ខ្ចាយខ្ចាត់រាត់រាយក្លាយឃ្លៀងឃ្លាត
ហេតុនេះខ្មែរយើងកុំរវាត ត្រូវរក្សាជាតិឱ្យរឹងប៉ឹងៗ
បើដឹងមិនដល់កុំធ្វើចេះ ចំណេះតិចតួចស្ដួចស្ដើងស្ដឹង
បើចង់ច្បាស់លាស់ត្រូវខំប្រឹង កុំដេកសម្ងឹងឱ្យចេះឯងៗ
ចំណេះកើតមានព្រោះការរៀន កម្និលអៀនប្រៀនកុំសម្ដែង
ធ្វើឱ្យគេស្ញើចគេកោតក្រែង ស្លាក់ស្លែងទេកុំរិះគន់គេៗ
ត្រូវរិះគន់ខ្លួនឯងជាមុន កុំឱ្យស៊ីយស៊ុនខុសទទេ
បើឆ្ងល់ពុំយល់ត្រូវសួរគេ ឥតថោកអ្វីទេថ្លៃទេតើៗ
បុរាណថាថោកអីនឹងដៃ ថ្លៃអីនឹងមាត់ពោលសើអ៊ី
រៀនទៅសួរទៅទើបគ្រាន់បើ អើពើចង់ចេះប្រសើរណាស់ៗ
ចាស់ថាបើល្ងង់កុំធ្វើចេះ បើមានចំណេះឱ្យជាក់ច្បាស់
បើស្ដើងហើយចង់ឱ្យបានក្រាស់ ត្រូវថែមកម្រាស់ផ្សំសាច់គ្នាៗ
អបស្មបប៉ះប៉ុនយកកម្រាស់ កុំចាំងកុំច្រាសហួសមាត្រា
ប៉ះផ្សំផ្គុំផ្ចិតទើបកើតជា ទោលឬបន្ទារម្ជួនជាងមុនៗ
បើចេះអក្សរនិងភាសា នៃជាតិណាៗកុំជ្រុលស៊ុន

ងាប់សព្ទប្រែស្រាយក្លាយជាប់កុន    សុនត្រុនប្រែស្រាយឃ្លាតក្តីពិតៗ
កាលដែលប្រារព្ធនឹងប្រែស្រាយ    ត្រូវគិតនាយអាយដោយពិនិត្យ
ឱ្យឃើញសេចក្តីជាខ្មែរពិត    សឹមប្រែកុំផ្ចិតតាមពាក្យគេៗ
ត្រូវប្រែឱ្យមកជាសេចក្តី    ដែលខ្មែរប្រុសស្រីអាចរិះរេ
ស្តាប់យល់មិនឆ្ងល់ទើបហៅប្រែ    ត្រឹមត្រូវតាមរូបសេចក្តីពិតៗ
អ្នករៀនភាសាជនបរទេស    ទ្វេធ្វេសដោយការឥតបើគិត
កាលខ្លួនកំពុងរៀនប្រឹងប្រិត    ប្រែផ្ចិតឱ្យចំតាមរូបសព្ទៗ
ឆ្លេចនឹកគិតមកភាសាខ្លួន    ឱ្យយល់សំនួនដែលងាយស្តាប់
សម្លឹងសង្កេតតែរូបសព្ទ    ក៏ស្រាប់តែប្រែខុសទាំងស្រុងៗ
អ្នករៀនសំស្ក្រឹតឬបាលី    ប្រែខុសសេចក្តីព្រោះត័ន្តផុង
យល់ខុសទទេទាំងដើមចុង    ចូលក្នុងរឹងស៊ុងខ្មាសអ្នកផងៗ
តិដ្ឋ: បាលី ប្រែថា ឈរ    អ្នករៀនឈ្លក់វត័ន្តម្តងៗ
ត្រង់មានសេចក្តីថាស្ងួនគុរង    ប្រែឆ្គងថាឈរហៅងាប់សព្ទៗ
ប្រាំងពរ៍កតេស្ងួរល៉ៅតែត    ខ្មែរឆ្អែតចិត្តជាប់បែរប្រែប្រាប់
អ្នកដែលមិនចេះឱ្យគ្នាស្តាប់    បង្គាប់ថាឱ្យកាន់លើក្បាលៗ
មិនប្រាប់ឱ្យគ្នាដឹងថាទូល    នេះហៅស្រមូលពុំត្រកាល
ពាក្យខ្មែរថាទូលក៏លើក្បាល    ត្រអាលប្រែខុសពីពាក្យខ្លួនៗ
តែងកាព្យឱ្យត្រូវតាមសម្ផស្ស    តាមកាព្យចាស់ៗដែលមានចួន
កុំចេះតែតែងតាមចិត្តខ្លួន    ឱ្យកាព្យមានចួនខុសមាត្រាៗ
ពាក្យអឺយ និង អើយ សូរផ្សេងគ្នា    ដូចជាប្អូន អើយ ម្តេចឡើយថា

ស្តាប់បងមិនឮឬស្ងួនថ្វា ធ្វើជាមិនឮព្រោះរឹងខ្លួន?ៗ
ព្រះបាទសម្តេចព្រះហរិរក្ស ទ្រង់បានបញ្ជាក់ដោយផ្ទួនៗ
ក្នុងកាព្យព្រះអង្គដែលមានចួន សិន្ធួនសម្ពស្សឥតមានឆ្គងៗ
កិរិគួរតែយកគម្រាប់ ពុំគួរប្រញាប់កាត់រំលង
រំលុបបែបនោះមិនត្រាប់ត្រង ខុសពីបំណងអ្នកប្រាជ្ញចាស់ៗ
មានអ្នកតែងកាព្យខ្លះហ៊ានថា ម្តេចមិនវាចាឱ្យជាក់ច្បាស់
ប្រើជាកិរិយាសព្ទខុសណាស់ គួរផ្លាស់សម្តីនេះចោលចេញៗ

វត្តឧណ្ណាលោម ក្រុងភ្នំពេញ, ថ្ងៃទី២២ ខែមករា

**ព. ស. ២៥១២ / គ. ស. ១៩៦៩**

កាព្យនេះព្រះរាជនិពន្ធដោយ : **សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី១ គណៈមហានិកាយ ប. អ. ស. - អ. ម. រ.**

## ពន្យល់ពាក្យលំបាកខ្លះៗ

## នៅក្នុង ភាព្យរំលឹកអំពីអក្សរ ពាក្យ៧

**រទាត** *កិ.* ឬ *គុ.* លាស, ឃ្លាត, កន្លែកចេញ; រសាយ, ថយកម្លាំង, ថយអំណាច។

**សើទើ** *គុ.* រាយមាយ, ចាប់នេះចាប់នោះមិនឆ្ពោះត្រង់ណា។

**ស្រមូល** *កិ. ១.* ដែលប្រមូលចូលច្របល់គ្នាជំពាក់ឆ្វាក់ជាដុំ, ដែលប្រមូលច្របូកច្របល់គ្នា។

**ស្លាក់ស្លែខ** *គុ.* ដែលទុច្ចរិតបោះបោក, ដែលគំហកកំហែង។

**ស៊យ** *កិ.* ឬ *គុ.* (ចិ. **ស្វួយ**) មិនប្រទះលាភ, ឃ្លាងលាភ; មិនសមបំណង, ឥតបានអ្វី។

**ខងស៊ុខ** *កិ.* វង្វេងវិលវល់ភ័ន្តស្មារតី។

**ហរិរក្ស** *ន.* ព្រះបរមនាមក្សត្រកម្ពុជរដ្ឋមួយព្រះអង្គសោយរាជ្យគង់នៅក្នុងក្រុងឧត្តុង្គមានជ័យ។

**ស្មុនគ្រុន** *កិ. ១.* ឬ *គុ.* គ្រុនៗ, គគ្រុន; គ្រេះគ្រុះ; ប្រុនៗ។

**ពាក្យកាព្យនៅក្នុងវចនានុក្រមខ្មែរ**

**ភាគទី១និងភាគទី២សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត**

**ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី១ គណៈមហានិកាយ**

**ភាគទី១មានចំនួន២០៧ពាក្យកាព្យ**

**ភាគទី២មានចំនួន៤១៨ពាក្យកាព្យ**

**សរុបពាក្យកាព្យទាំងអស់**

**ភាគទីមួយ ២០៧ + ភាគទីពីរ ៤១៨ = ចំនួន៦២៥**

**សូមគោរពប្រគេន ជូនដំណឹងចំពោះ**

ព្រះតេជព្រះគុណ ឯកឧត្តម លោកជំទាវ បញ្ញវន្ត លោកគ្រូ អ្នកគ្រូ និស្សិតទាំងអស់ មេត្តាជួយកែតម្រូវនិងកែលម្អអត្ថន័យខ្លឹមសារក្នុងគំនិតស្ថាបនាជ្រះថ្លាតាមការគួរដោយក្តីអនុគ្រោះ !

ខ្ញុំព្រះករុណា ខ្ញុំបាទសូមគោរពថ្លែងអំណរព្រះគុណ អរគុណ និងកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅបំផុត !

ចំពោះទឹកព្រះទ័យ ទឹកចិត្តប្រកបដោយកុសលចេតនាជ្រះថ្លា !

**ទូរសព្ទលេខ : ០១២ ៦២ ៧០ ៧០**

**: ០៩៧ ៩៦ ៤៤ ៧១៩**

# គន្ថនិទ្ទេស

១- **ជួន-ណាត** វចនានុក្រមខ្មែរ បោះពុម្ពគ្រាទី៥ ព.ស. ២៥១១-២៥១២ គ.ស. ១៩៦៧-១៩៦៨, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

២- **លី-ថៃលី** វចនានុក្រមសុភាសិតអធិប្បាយភាគទី១

៣- **លី-ថៃលី** វចនានុក្រមសុភាសិតអធិប្បាយភាគទី២

៤- **ច័ន្ទ សំណព្វ** (១៩៩៩) វិជ្ជមានន័យ អវិជ្ជមានន័យ និងបរិធាតុរបស់វា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៥- **ច័ន្ទ សំណព្វ** (២០០២) គោលការណ៍នៃការបង្កើតពាក្យនិងកម្ចីពាក្យ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៦- **ច័ន្ទ សំណព្វ** (២០០៣) ធាតុវេយ្យាករប្រើសម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៧- **ច័ន្ទ សំណព្វ** (២០០៦) ការកំណត់ប្រភេទពាក្យក្នុងភាសាខ្មែរ : តួនាទីនៃបុរេបទ **ភារ** និងផ្នត់ជែក [-**អ់ម/ណា**-] / [-**អឹម/ន**-] សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៨- អគ្គទត្តោ **គល់-សុភាព** ភាសាខ្មែរ

៩- **លី-ធាមតេង** កម្ពុជសុរិយា

១០- ឧកញ៉ាសុត្តន្តប្រីជាឥន្ទ គតិលោកភាគទី១

១១- ព្រះគ្រូមុនីសោភ័ណ **សេខ-នាង** សារញ្ញាណោ, បាលីវេយ្យាករណ៍, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៤៤ គ. ស. ២០០០

១២- ព្រះគ្រូសិរីសោភ័ណ **ភិម-ឌូ**, បទានុក្រមធម្មបទភាគទី១, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៣- ព្រះគ្រូសិរីសោភ័ណ **ភិម-ឌូ**, បទានុក្រមធម្មបទភាគទី២, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៤- ព្រះគ្រូសិរីសោភ័ណ **ភិម-ឌូ**, បទានុក្រមធម្មបទភាគទី៣, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព. ស. ២៥៣៨ គ. ស. ១៩៩៤

១៥- **អៀវ-កើស** ភាសាខ្មែរ

១៦- វចនានុក្រមខ្មែរ KHMER DICTIONARY, ការផ្សាយបណ្ណាគារអង្គរធំ ព. ស. ២៥៥៥ គ. ស. ២០១១

១៧- វេយ្យាករណ៍សំស្ក្រឹត

១៨- ធាតុសង្គ្រោះ

១៩- សទ្ទានុក្រមពាក្យច្បាប់និងរដ្ឋបាល (អង់គ្លេស-បារាំង-ខ្មែរ)

២០- វចនានុក្រមអក្ខរាវិរុទ្ធនៃភាសាខ្មែរ, ការផ្សាយរបស់វិទ្យាស្ថានភាសាជាតិ

២១- ប្រស្នាកច្ចាយនូបត្ថម្ភក: កិតកនិទ្ទេស-ឧណាទិនិទ្ទេស, ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

២២- **ហ៊ីខ-ឆីឫទ្ធិ** អត្ថាធិប្បាយវចនានុក្រមច្បាប់

២៣- អៀង សាយ **មេភាញ្ញ** ព.ស. ២៥៤៨, គ.ស. ២០០៥

២៤- ឯកសារនានា